# ព្រះរាជក្រម

នស/រកម/១០០៥/០៣០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃ ទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# ឧបករណ៍អាចជួញដូរបាន

# និង ប្រតិបត្តិការទូទាត់សងប្រាក់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះគ្រប់គ្រងលើឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ រួមបញ្ចូលទាំងគណនីធនាគារ និងប្រតិបត្តិការនៃប្រព័ន្ធទូទាត់សងប្រាក់ ។

១-ឧបករណ៍អាចជួញដូរបានសំដៅដល់បញ្ជា ឬ ការសន្យាជាលាយលក្ខណ៍អក្សរ ដើម្បីទូទាត់សងចំនួនប្រាក់ជាកំណត់មួយ ដែលអាចផ្ទេរបានតាមរយៈការប្រគល់ ហើយកាលបើចាំបាច់ក៏មានបិដ្ឋិលេខផងដែរ ។ ឧបករណ៍អាចជួញដូរបានដែលគ្រប់គ្រងដោយច្បាប់នេះ រួមមានមូលប្បទានប័ត្រ រូបិយាណត្តិ និងប័ណ្ណសងតាមបញ្ជា ។

២-ប្រតិបត្តិការទូទាត់សងប្រាក់ ដែលគ្រប់គ្រងនិងកំណត់ដោយច្បាប់នេះ ជាការផ្ទេរមូលនិធិរវាង ឬ ពីគណនីធនាគារ ។ ប្រតិបត្តិការទូទាត់សងប្រាក់អាចជាការផ្ទេរឥណទាន ឬ ជាការផ្ទេរឥណពន្ធ ។ ប្រតិបត្តិការនេះ ត្រូវបានផ្តួចផ្តើមឡើងតាមរយៈបញ្ជាទូទាត់ ដែលអាចត្រូវបានធ្វើជាលាយលក្ខណ៍អក្សរតាមអេឡិចត្រូនិក និងដោយផ្ទាល់មាត់នៅក្រោមល័ក្ខខ័ណ្ឌខ្លះ ។

៣-ប្រព័ន្ធទូទាត់សងប្រាក់ រួមមានស្ថាប័ន ឬ យន្តការ ដែលសម្រួលដល់ការទូទាត់សងប្រាក់ជារូបិយវត្ថុ និងជាការផ្ទេរតម្លៃជារូបិយវត្ថុតាមរយៈប្រតិបត្តិការទូទាត់សងប្រាក់ ។

មាត្រា ២.-

ពាក្យបច្ចេកទេសដែលប្រើក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ :

១-**ករណីប្រធានស័ក្តិ** សំដៅដល់ព្រឹត្តិការណ៍ ដែលជាឧបសគ្គមិនអាចចៀសផុតបាន មិនអាចគ្រប់គ្រងបាន និងហួសពីលទ្ធភាពត្រួតត្រារបស់បុគ្គល ដែលត្រូវអនុវត្តកាតព្វកិច្ច ។

២-**ការចេញផ្សាយ** សំដៅដល់ការសរសេរ ចុះហត្ថលេខា និងប្រគល់មូលប្បទានប័ត្រ រូបិយាណត្តិ ឬ ប័ណ្ណសងតាមបញ្ជាឱ្យ ទៅអ្នកកាន់ទីមួយ ។

៣-**ការចេញមូលប្បទានប័ត្រ ឬ រូបិយាណត្តិ** សំដៅដល់ការសរសេរ និងចុះហត្ថលេខាលើមូលប្បទានប័ត្រ ឬ រូបិយាណត្តិ ។

៤-**ការទូទាត់** សំដៅដល់ការសងប្រាក់ ដើម្បីជម្រះកាតព្វកិច្ចលើបញ្ជាទូទាត់អន្តរធនាគារ ។

៥-**ការបង្ហាញ** សំដៅដល់ការប្រគល់មូលប្បទានប័ត្រ រូបិយាណត្តិ ឬ ប័ណ្ណសងតាមបញ្ជា ដើម្បីសុំឱ្យធ្វើស្ទីការចំពោះរូបិយាណត្តិ ឬ ទូទាត់សងប្រាក់ពីមហាវិត ឬ អ្នកចេញប័ណ្ណ ។

៦-**ការប្រតិបត្តិ** នៅក្នុងជំពូកទី ៥ នៃច្បាប់នេះ សំដៅដល់ការអនុវត្តបញ្ជាដែលមាននៅក្នុងបញ្ជាទូទាត់ តាមរយៈការចេញបញ្ជាទូទាត់ពាក់ព័ន្ធទៅកាន់ធនាគារទទួល ។

៧-**ការជាត់ទាត់** សំដៅដល់ការប្តូរគ្នា និងដំណើរការជាអន្តរធនាគារលើបញ្ជាទូទាត់ក្នុងគោលដៅគណនាចំនួនប្រាក់សុទ្ធ ជាទ្វេភាគីឬពហុភាគី ដែលធនាគារនីមួយៗជំពាក់គ្នាទៅវិញទៅមកក្នុងការទូទាត់រាល់បញ្ជាទូទាត់ដែលត្រូវបានបញ្ចូលមកក្នុងគ្រាជាត់ទាត់នីមួយៗ ។

៨-**ការផ្ទេរផ្ទៃក្នុង** សំដៅដល់ការផ្ទេរមូលនិធិពីអ្នកសងប្រាក់ឱ្យទៅអ្នកទទួលប្រាក់ នៅក្នុងធនាគារជាមួយគ្នា ដោយមានបញ្ជាទូទាត់តែមួយ ។ អ្នកចូលរួមនៅក្នុងការផ្ទេរផ្ទៃក្នុង រួមមានអ្នកផ្តើមប្រតិបត្តិការ ធនាគារដែលដើរតួជាអ្នកផ្តើមប្រតិបត្តិការផង និងជាធនាគារគោលដៅផង ហើយនិងអ្នកទទួល ។

៩-**ការផ្ទេរអន្តរធនាគារ** សំដៅដល់ការផ្ទេរមូលនិធិពីអ្នកសងប្រាក់ឱ្យទៅអ្នកទទួលប្រាក់នៅធនាគារពីរផ្សេងគ្នា ដោយមានបញ្ជាទូទាត់យ៉ាងតិចចំនួនពីរ ។ នៅក្នុងការផ្ទេរអន្តរធនាគារ :

ក-ធនាគារទទួលនីមួយៗ ដែលពុំមែនជាធនាគារគោលដៅប្រតិបត្តិតាមបញ្ជាទូទាត់នៃអ្នកផ្ញើរបស់ខ្លួន តាមរយៈការចេញបញ្ជាទូទាត់ពាក់ព័ន្ធទៅកាន់ធនាគារទទួល ហើយបញ្ជាទូទាត់ចុងក្រោយត្រូវបានផ្ញើទៅធនាគារគោលដៅ

ខ-អ្នកចូលរួមនៅក្នុងការផ្ទេរអន្តរធនាគារ រួមមានអ្នកផ្តើមប្រតិបត្តិការ ធនាគារផ្តើមប្រតិបត្តិការ ធនាគារគោលដៅ និងអ្នកទទួល ព្រមទាំងអាចមាន

ធនាគារអន្តរការីមួយ ឬ ច្រើនផងដែរ

គ-នៅពេលណាដែលធនាគារផ្តើមប្រតិបត្តិការ ពុំបានទូទាត់ដោយផ្ទាល់ជាមួយធនាគារគោលដៅទេ យ៉ាងហោចណាស់ក៏ចាំបាច់ត្រូវមានធនាគារអន្តរការីមួយ ឬ ច្រើនផងដែរ

ឃ-សម្រាប់បញ្ជាទូទាត់អន្តរធនាគារនីមួយៗ ធនាគារផ្ញើទូទាត់ជាមួយធនាគារទទួល ដូចមានចែងក្នុងមាត្រា ២០២ នៃច្បាប់នេះ ។

១០-**ការផ្ទេរឥណពន្ធ** សំដៅដល់ប្រតិបត្តិការទូទាត់សងប្រាក់ ផ្តើមឡើងដោយអ្នកទទួលប្រាក់បញ្ជាទៅធនាគាររបស់ខ្លួន ដោយផ្អែកលើការអនុញ្ញាតពីអ្នកសងប្រាក់ឱ្យធ្វើការទារប្រាក់ពីគណនីអ្នកសងប្រាក់ ។

១១-**ការផ្ទេរឥណទាន** សំដៅដល់ប្រតិបត្តិការទូទាត់សងប្រាក់ ផ្តើមឡើងដោយអ្នកសងប្រាក់ដែលបានចេញបញ្ជាទូទាត់ឱ្យធនាគារផ្ទេរមូលនិធិចេញពីគណនីរបស់ខ្លួនឱ្យទៅអ្នកទទួលប្រាក់ ឬទៅក្នុងគណនីអ្នកទទួលប្រាក់ ។

១២-**កិច្ចព្រមព្រៀង** ក្នុងផ្នែកទី ៧ ជំពូកទី ៥ នៃច្បាប់នេះសំដៅដល់កិច្ចសន្យារវាងធនាគារ និងអតិថិជន ដែលអនុវត្តចំពោះប្រតិបត្តិការគណនី រួមទាំងបញ្ហានានា ដូចជារយៈពេលនៃប្រតិបត្តិការនោះ ការកែប្រែ និងបញ្ជាទូទាត់ ។

១៣-**គណនី** សំដៅដល់គណនីទាំងឡាយ ដែលបានបើកនៅក្រោមកិច្ចសន្យារវាងអតិថិជន និងធនាគារ ទោះបីជាគណនីចរន្ត គណនីផ្ញើប្រាក់ ឬ គណនីផ្សេងទៀតក្តី និងរួមទាំងគណនីនៅក្រោមទំនាក់ទំនងពិសេស ដែលបង្កើតឡើងក្នុងគោលបំណងអនុវត្តប្រតិបត្តិការទូទាត់សងប្រាក់តែមួយប៉ុណ្ណោះ ។

១៤-**គណនីទូទាត់** សំដៅដល់គណនីដែលធនាគារមួយ បានបើកនៅក្នុងបញ្ជីរបស់ធនាគារជាតិនៃកម្ពុជាសម្រាប់ប្រតិបត្តិការទូទាត់សងប្រាក់ចូលនិងចេញ ។

១៥-**គណនីធ្លាក់បញ្ជីមានសៀវភៅ** សំដៅដល់គណនីដែលត្រូវបានចុះឥណពន្ធ និងឥណទានដោយធនាគារ ដើម្បីកត់ត្រាប្រតិបត្តិការក្នុងសៀវភៅប្រាក់បញ្ញើដែលធនាគារបានចេញឱ្យអតិថិជនតាំងពីដំបូង ហើយត្រូវបានយកមកឱ្យធនាគារកត់ត្រារាល់ប្រតិបត្តិការ ។

១៦-**តាមការប្រគល់សិទ្ធិ** សំដៅដល់ការប្រគល់សិទ្ធិ ដែលមានកម្រិត

-ដើម្បីទារប្រាក់ក្នុងនាមអ្នកផ្ញើរ ។

១៧-តាមអេឡិចត្រូនិក សំដៅដល់មធ្យោបាយទូរគមនាគមន៍ភ្ជាប់ដោយប្រព័ន្ធកុំព្យូទ័រ ឬការបញ្ជូនជារូបវ័ន្ត ពុំមានការភ្ជាប់ប្រព័ន្ធកុំព្យូទ័រ មានខ្សែអាត់ ហ្វូណ្ណក្រាម ឬឧបករណ៍ប្រហាក់ប្រហែលនេះ ។

១៨-តម្លៃសម្រាប់ការទំលាក់ សំដៅដល់តម្លៃដែលត្រូវបានទទួលដោយអ្នកផ្ញើរនៅពេលធ្វើបេឡានិច័យ ឬតម្លៃដែលទារមកវិញដោយអ្នកទទួលការផ្ញើរ នៅលើឧបករណ៍អាចជួញដូរបាន ។

១៩-តម្លៃសម្រាប់ធានា ឬតម្លៃសម្រាប់ដាក់បញ្ចាំ សំដៅដល់ការផ្ញើរដោយមានការធានា ឬ ការផ្ញើរក្នុងគោលបំណងបង្កើតអត្ថប្រយោជន៍នៃការធានា និងដែលមិនមែនជាការផ្ទេរកម្មសិទ្ធិ ។

២០-ថ្ងៃធ្វើការរបស់ធនាគារ សំដៅដល់ពេលវេលាមួយផ្នែកនៃថ្ងៃដែលក្នុងអំឡុងពេលនោះ ធនាគារបានបើកទ្វារដើម្បីទទួលដំណើរការបញ្ជូនបញ្ជាទូទាត់ និងសារផ្សេងៗដែលទាក់ទងទៅនឹងប្រតិបត្តិការទូទាត់សងប្រាក់ ។

២១-ថ្ងៃប្រសិទ្ធភាព សំដៅដល់ថ្ងៃធ្វើការរបស់ធនាគារ ដែលនៅក្នុងថ្ងៃនោះ បញ្ជាទូទាត់ត្រូវបានអនុវត្តតាមបញ្ជារបស់អ្នកផ្ញើ ។

២២-ធនាគារ សំដៅដល់ធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលត្រូវបានផ្តល់អាជ្ញាប័ណ្ណឱ្យធ្វើប្រតិបត្តិការធនាគារក្រោមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងគ្រឹះស្ថាន ឬ អង្គភាពណាមួយដែលច្បាប់អនុញ្ញាតឱ្យទទួលប្រាក់បញ្ញើ ឬ ចូលរួមក្នុងប្រតិបត្តិការទូទាត់សងប្រាក់លើគណនីរបស់អតិថិជន ។

សាខា ឬ ការិយាល័យដោយឡែករបស់ធនាគារ ត្រូវបានចាត់ទុកជាធនាគារដាច់ដោយឡែក សម្រាប់គោលបំណងនៃ (ក) ភារកិច្ចក្នុងការអនុវត្តប្រតិបត្តិការទូទាត់សងប្រាក់ និង (ខ) ការគណនាពេលវេលាដែលក្នុងពេលនោះ ឬ កំណត់កន្លែងដែលនៅទីនោះសកម្មភាព ឬ សេចក្តីជូនដំណឹង ឬ បញ្ជាត្រូវបានធ្វើ ។

២៣-ធនាគារគោលដៅ សំដៅដល់ធនាគារ ដែលត្រូវបានបញ្ជាក់នៅក្នុងបញ្ជាទូទាត់ ដែលក្នុងនេះ ការទូទាត់ឱ្យទៅអ្នកទទួលប្រាក់ក្នុងការផ្ទេរឥណទាន ត្រូវ

៧/១២៩

បានធ្វើឡើង ឬ ដែលមានគណនីរបស់អ្នកសងប្រាក់ក្នុងការផ្ទេរឥណពន្ធ ។ ធនាគារគោលដៅ ជាធនាគារដែលទទួលបញ្ជាទូទាត់ក្រោយគេបង្អស់ នៅក្នុងប្រតិបត្តិការទូទាត់សងប្រាក់ ។ នៅក្នុងការផ្ទេរឥណទាន ធនាគារគោលដៅ ជាធនាគាររបស់អ្នកទទួលប្រាក់ ។ នៅក្នុងការផ្ទេរឥណពន្ធ ធនាគារគោលដៅ ជាធនាគាររបស់អ្នកសងប្រាក់ ។

២៤-**ធនាគារផ្ដើមប្រតិបត្តិការ** សំដៅដល់ធនាគារដែលទទួលបញ្ជាទូទាត់ដែលផ្ដើមឱ្យមានប្រតិបត្តិការទូទាត់សងប្រាក់ ។ នៅក្នុងការផ្ទេរឥណទាន ធនាគារផ្ដើមប្រតិបត្តិការជាធនាគាររបស់អ្នកសងប្រាក់ ។ នៅក្នុងការផ្ទេរឥណពន្ធ ធនាគារផ្ដើមប្រតិបត្តិការជាធនាគាររបស់អ្នកទទួលប្រាក់ ។

២៥-**ធនាគារទទួល** សំដៅដល់ធនាគារ ដែលបញ្ជាទូទាត់របស់អ្នកផ្ញើត្រូវបានបញ្ជូនឱ្យទៅ ។

២៦-**ធនាគារអន្តរការី** សំដៅដល់ធនាគារទទួល ដែលស្ថិតនៅកណ្ដាលធនាគារផ្ដើមប្រតិបត្តិការ និងធនាគារគោលដៅ ។

២៧-**នីតិវិធីសុវត្ថិភាព** សំដៅដល់នីតិវិធីបង្កើតឡើងដោយកិច្ចព្រមព្រៀងរវាងអតិថិជន និងធនាគារទទួល ក្នុងគោលបំណង :

-ផ្ទៀងផ្ទាត់ថា បញ្ជាទូទាត់ ឬ ការបញ្ជាបញ្ឈប់ពិតជាបញ្ជារបស់អតិថិជន ឬ

-រាវរកការភ័ន្តច្រឡំក្នុងការបញ្ជូន ឬ ក្នុងខ្លឹមសារនៃបញ្ជាសងប្រាក់ ឬបញ្ជាបញ្ឈប់ ។

នីតិវិធីសុវត្ថិភាព អាចទាមទារឱ្យមានការប្រើប្រាស់វិធាន លេខកូដ ឬ លេខសម្ងាត់ដែលបញ្ជាក់ពាក្យ ឬ ចំនួនប្រាក់ពាក្យមានន័យសម្ងាត់ នីតិវិធីសួរបញ្ជាក់ទៅវិញ ឬ វិធីប្រហាក់ប្រហែលផ្សេងទៀត ។ ការប្រៀបធៀបហត្ថលេខានៅលើបញ្ជាទូទាត់ ឬ ទំនាក់ទំនងជាមួយអតិថិជន ដែលមានគំរូហត្ថលេខាប្រតិស្រុតពុំមែនជានីតិវិធីសុវត្ថិភាពឡើយ ។

២៨-**បង្វិលទិញដោយគ្មានសោហ៊ុយ** សំដៅដល់ការសន្យា ដែលអនុញ្ញាតឱ្យធ្វើឧបាស្រ័យទល់នឹងភាគីពាក់ព័ន្ធ ដោយមិនតម្រូវឱ្យអ្នកកាន់ធ្វើវិរុទ្ធវាទ ។

២៩-បញ្ជាទូទាត់ សំដៅដល់បញ្ជាទៅធនាគារឱ្យធ្វើការសងប្រាក់ ឬទារប្រាក់មួយចំនួនចេញពីគណនី ដែលបានចង្អុលបង្ហាញឱ្យទៅ ឬ សម្រាប់អ្នកទទួលប្រាក់ ឬ ឱ្យទៅ ឬ សម្រាប់គណនីរបស់អ្នកទទួលប្រាក់ និងរួមទាំងការកែប្រែណាមួយ នៅលើបញ្ជាទូទាត់ផងដែរ ។ បញ្ជានោះអាចមានកំណត់ថ្ងៃប្រសិទ្ធភាព ប៉ុន្តែមិនត្រូវស្ថិតនៅក្រោមលក្ខខណ្ឌណាមួយ ក្រៅពីអ្វីដែលធនាគារផ្តើមប្រតិបត្តិការបានព្រមព្រៀងអនុវត្តឡើយ ។ ភាគីនៃបញ្ជាទូទាត់ រួមមានអ្នកផ្ញើ និងធនាគារទទួល ។ នៅពេលណាដែលអ្នកផ្ញើជាធនាគារ នៅពេលនោះបញ្ជាទូទាត់ គឺជាបញ្ជាទូទាត់អន្តរធនាគារ ។

៣០-បង្គាប់ករ សំដៅដល់បុគ្គលដែលចេញបញ្ជាឱ្យទូទាត់សងមូលប្បទានប័ត្រ ឬរូបិយាណត្តិ ។

៣១-បង្គាប់ការី សំដៅដល់បុគ្គលដែលទទួលបញ្ជាឱ្យទូទាត់សងមូលប្បទានប័ត្រ ឬរូបិយាណត្តិ ។

៣២-ប្រតិបត្តិការទូទាត់សងប្រាក់ សំដៅដល់ការផ្ទេរមូលនិធិពីគណនីអ្នកសងប្រាក់ឱ្យទៅអ្នកទទួលប្រាក់ ឬ ឱ្យទៅគណនីអ្នកទទួលប្រាក់ ។ ប្រតិបត្តិការទូទាត់សងប្រាក់ :

(ក)អាចជាការផ្ទេរឥណទាន ឬ ជាការផ្ទេរឥណពន្ធ

(ខ)ត្រូវបានផ្តួចផ្តើមឡើងដោយបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការទៅកាន់ធនាគារផ្តើមប្រតិបត្តិការ ឱ្យអនុវត្តប្រតិបត្តិការទូទាត់សងប្រាក់នោះ

(គ)ត្រូវបានអនុវត្តដោយធនាគារអ្នកសងប្រាក់ ដោយការកត់ត្រាឥណពន្ធលើគណនីរបស់អ្នកសងប្រាក់ ចំពោះធនាគាររបស់អ្នកទទួលប្រាក់វិញ ធ្វើការកត់ត្រាឥណទានលើគណនីរបស់អ្នកទទួលប្រាក់ ឬ ដាក់មូលនិធិឱ្យស្ថិតនៅក្នុងការគ្រប់គ្រង និងសម្រាប់តម្រូវការប្រើប្រាស់របស់អ្នកទទួលប្រាក់ ដូចដែលបានបញ្ជាដោយអ្នកផ្តើមប្រតិបត្តិការ

(ឃ)អាចជាការផ្ទេរមូលនិធិពីអ្នកសងប្រាក់ទៅអ្នកទទួលប្រាក់ដែលអាចជារូបវ័ន្តបុគ្គល ឬ នីតិបុគ្គលមួយ ឬ ពីរផ្សេងគ្នា និង

(ង)អាចជាការផ្ទេរមូលនិធិ ដែលនៅក្នុងនោះអ្នកសងប្រាក់ត្រូវតែមានគណនី ហើយការទូទាត់ឱ្យទៅអ្នកទទួលប្រាក់អាចនឹងធ្វើឡើងនៅក្នុងធនាគារតែមួយជាមួយគ្នា ឬ ពីរផ្សេងគ្នា ។

៣៣-**បិដ្ឋីលេខ** សំដៅដល់ហត្ថលេខាលើខ្នងនៃឧបករណ៍អាចជួញដូរបានដោយមាន ឬ គ្មានពាក្យបញ្ជាក់ ។ ដើម្បីមានប្រសិទ្ធភាព បិដ្ឋីលេខត្រូវតែបានបំពេញបង្គ្រប់ដោយការប្រគល់ ។

៣៤-**បុគ្គល** សំដៅដល់នីតិបុគ្គល និងរូបវន្តបុគ្គល ។

៣៥-**ភាពគ្រប់គ្រាន់នៃសមតុល្យ** ចំពោះបញ្ជាទូទាត់ សំដៅដល់ការមានមូលនិធិគ្រប់គ្រាន់ពោលគឺ អត្ថិភាពនៃសមតុល្យគណនី ដែលមិនតិចជាងចំនួនប្រាក់នៃបញ្ជាទូទាត់ រួមមានសមតុល្យនៅពេលបិទបញ្ជីនាថ្ងៃធ្វើការរបស់ធនាគារថ្ងៃម្សិលម្ងៃ ខ្ទង់ឥណទាននៃការផ្ទេរប្រាក់ចូលក្នុងគណនីអ្នកសងប្រាក់នាថ្ងៃធ្វើការរបស់ធនាគារថ្ងៃនេះ ប្រាក់បញ្ញើនិងប្រាក់ផ្ទេរចូល ដក ការសងប្រាក់ចេញ ការដកប្រាក់ដែលកើតមានរួចហើយ នាថ្ងៃធ្វើការរបស់ធនាគារថ្ងៃនេះ និង សោហ៊ុយទាំងឡាយរបស់ធនាគារ ដែលអាចមាន ។ មូលនិធិដែលឆ្លុះបញ្ចាំងជាខ្ទង់ឥណទានបណ្តោះអាសន្ន នៅក្នុងគណនីរបស់អ្នកសងប្រាក់មិនត្រូវបានបូកបញ្ចូលជាផ្នែកមួយនៃចំនួនប្រាក់ ដែលតម្រូវសម្រាប់ការទូទាត់នោះទេ ។

៣៦-**មូលនិធិ** សំដៅដល់សាច់ប្រាក់ និងប្រាក់បញ្ញើ ដែលបានដាក់ផ្ញើនៅក្នុងគណនីធនាគារ ។

៣៧-**រូបិយបដិគាត** សំដៅដល់ការធានាទូទាត់សងប្រាក់លើមូលប្បទានប័ត្រ រូបិយាណត្តិ ឬ ប័ណ្ណសងតាមបញ្ជា ។

៣៨-**រូបិយប័ណ្ណ** សំដៅដល់រូបិយវត្ថុណាមួយ ក្រៅពីរូបិយវត្ថុក្នុងស្រុក ។

៣៩-**រូបិយវត្ថុក្នុងស្រុក** សំដៅដល់ប្រាក់រៀល ដែលជារូបិយវត្ថុផ្លូវការរបស់ព្រះរាជាណាចក្រកម្ពុជា ។

៤០-**ទិវង្គតទាន** សំដៅដល់ប្រតិវេទន៍ជាលាយលក្ខណ៍អក្សរ និងជាផ្លូវការនៅក្នុងកាលៈទេសៈទាំងឡាយដូចជា ការខកខាន ឬ ការបដិសេធមិនធ្វើស៊ីការ ការមិនទូទាត់សងប្រាក់ ឬ មិនផ្តល់ទិដ្ឋាការ ដែលផ្តល់សិទ្ធិដល់អ្នកកាន់ឱ្យធ្វើឧបាស្រ័យលើ

ヲ

10/128

ឧបករណ៍អាចជួញដូរបាន ។ វិក្កយបត្រត្រូវតែបានធ្វើដូច និងនៅពេលដែលតម្រូវដោយបទប្បញ្ញត្តិដោយឡែកនៃច្បាប់នេះ ។

៤១-ស្ទីការ សំដៅដល់ការយល់ព្រមរបស់បហារិតនៃវូបិយាណត្តិដើម្បីអនុវត្តតាមបញ្ជារបស់បហារិក ។ ដើម្បីមានប្រសិទ្ធភាព ស្ទីការត្រូវតែបានបំពេញបង្គ្រប់ ដោយការប្រគល់និងការជូនដំណឹង ។

៤២-សម្រាប់បេឡានិច័យ សំដៅដល់បិដ្ឋិលេខមួយដែលបង្ហាញថាបិដ្ឋិ-លេខនោះមិនមែនជាការផ្ទេរកម្មសិទ្ធិ ប៉ុន្តែសម្រាប់គោលបំណងសម្រួលបេឡានិច័យ ឬ ទារមកវិញនូវចំនួនប្រាក់លើឧបករណ៍អាចជួញដូរបាន ដោយអ្នកទទួលការផ្ទេរក្នុងនាមអ្នកផ្ទេរ ។

៤៣-អត្តគាហក នៅក្នុងជំពូកទី ២ ទី ៣ និងទី ៤ នៃច្បាប់នេះ សំដៅដល់បុគ្គលដែលទទួលផលពីការទូទាត់សងមូលប្បទានប័ត្រ វូបិយាណត្តិ ឬ ប័ណ្ណសងតាមបញ្ជា នៅពេលត្រូវបានចេញផ្សាយ ។

៤៤-អតិថិជន សំដៅដល់ឯកត្តជន ទោះបីជាមានប្រកបមុខរបរក្តី ឬ ពុំមានក្តី ឬនីតិបុគ្គលរួមទាំងធនាគារផង ដែលមានគណនីនៅធនាគារមួយ ។

៤៥-អន្តរាគមន៍ដើម្បីទូទាត់សងប្រាក់ សំដៅដល់នីតិវិធីដែលភាគីមិនពាក់ព័ន្ធនឹងឧបករណ៍អាចជួញដូរបានចូលធ្វើអន្តរាគមន៍ ដើម្បីធ្វើស្ទីការ ឬ ទូទាត់សងប្រាក់ជូនភាគីដែលពាក់ព័ន្ធ ។

៤៦-អ្នកចេញប័ណ្ណសងតាមបញ្ជា ឬ អ្នកចេញប័ណ្ណ សំដៅដល់បុគ្គលដែលធ្វើការសន្យាទូទាត់សងប្រាក់ នៅលើប័ណ្ណសងតាមបញ្ជា ។

៤៧-អ្នកផ្ញើ សំដៅដល់បុគ្គល ដែលបញ្ជូនបញ្ជាទូទាត់ទៅធនាគារទទួល ។

៤៨-អ្នកផ្តើមប្រតិបត្តិការ សំដៅដល់អ្នកផ្ញើបញ្ជាទូទាត់ដំបូង ដែលផ្តើមឱ្យមានប្រតិបត្តិការទូទាត់សងប្រាក់ ។ នៅក្នុងការផ្ទេរឥណទាន អ្នកផ្តើមប្រតិបត្តិការជាអ្នកសងប្រាក់ ។ នៅក្នុងការផ្ទេរឥណពន្ធ អ្នកផ្តើមប្រតិបត្តិការ ជាអ្នកទទួលប្រាក់ ។

៤៩-អ្នកទទួល សំដៅដល់អ្នកចូលរួម ដែលធនាគាររបស់ខ្លួន ជាអ្នកទទួលបញ្ជាទូទាត់ចុងក្រោយបង្អស់ នៅក្នុងប្រតិបត្តិការទូទាត់សងប្រាក់ ។ នៅក្នុងការផ្ទេរឥណទាន អ្នកទទួលជាអ្នកទទួលប្រាក់ ។ នៅក្នុងការផ្ទេរឥណពន្ធ អ្នកទទួលជាអ្នក

សងប្រាក់ ។

៥០-អ្នកទទួលប្រាក់ នៅក្នុងជំពូកទី ៥ នៃច្បាប់នេះ សំដៅដល់អ្នកចូលរួម ដែលនឹងត្រូវទទួលប្រាក់នៅក្នុងប្រតិបត្តិការទូទាត់សងប្រាក់ និងនៅក្នុងការផ្ទេរឥណពន្ធ អ្នកទទួលប្រាក់រាប់បញ្ចូលផងដែរ នូវអ្នកដែលត្រូវទទួលប្រាក់ដោយការផ្ទេរដែលមានការប្រគល់សិទ្ធិ បើសិនជាមាន ។ នៅក្នុងការផ្ទេរឥណទាន អ្នកទទួលប្រាក់ជាអ្នកទទួល ។ នៅក្នុងការផ្ទេរឥណពន្ធ អ្នកទទួលប្រាក់ជាអ្នកផ្តើមប្រតិបត្តិការ ។

៥១-អ្នកសងប្រាក់ សំដៅដល់អ្នកចូលរួម ដែលត្រូវសងប្រាក់នៅក្នុងប្រតិបត្តិការទូទាត់សងប្រាក់ ។ នៅក្នុងការផ្ទេរឥណទាន អ្នកសងប្រាក់ជាអ្នកផ្តើមប្រតិបត្តិការ ។ នៅក្នុងការផ្ទេរឥណពន្ធ អ្នកសងប្រាក់ជាអ្នកទទួល ។

៥២-ឥណទានទិញរូបិយវត្ថុ សំដៅដល់ពិតានៃឥណទាន ដែលអនុញ្ញាតឱ្យដកមូលនិធិ ហើយការដក ឬ ការផ្ទេរមូលនិធិនោះត្រូវប្រើមូលប្បទានប័ត្រ ឬ បញ្ជាទូទាត់ ។

៥៣-កាលប្រតិទាន សំដៅដល់កាលបរិច្ឆេទ ដែលរូបិយាណត្តិ ឬ ប័ណ្ណសងតាមបញ្ជា ត្រូវដល់កាលកំណត់សង ។

៥៤-ឧបាស្រ័យ សំដៅដល់សិទ្ធិប្តឹងទារសំណងមកវិញនូវការខូចប្រយោជន៍ពីបុគ្គលដែលពាក់ព័ន្ធ លើឧបករណ៍អាចជួញដូរបាន ។

## ជំពូកទី ២
## មូលប្បទានប័ត្រ

### ផ្នែកទី ១
### ការចេញនិងទម្រង់នៃមូលប្បទានប័ត្រ

មាត្រា ៣.-

មូលប្បទានប័ត្រ ជាបញ្ជាលាយលក្ខណ៍អក្សរដោយឥតល័ក្ខខ័ណ្ឌឱ្យទៅធនាគារ និងចុះហត្ថលេខាដោយបុគ្គលជាអ្នកចេញបញ្ជា តម្រូវឱ្យធនាគារទូទាត់សងចំនួនប្រាក់ជាកំណត់មួយឱ្យទៅ ឬ តាមបញ្ជាបុគ្គលមួយទៀត ឬ អ្នកកាន់ ។ មូលប្បទានប័ត្រ

ត្រូវតែបានទូទាត់សងប្រាក់នៅពេលបង្ហាញ ហើយស្របតាមរាល់កាតព្វកិច្ចដែលមានចែងនៅក្នុងជំពូកនេះ ។

មាត្រា ៤.-

មូលប្បទានប័ត្រ អាចត្រូវបានសរសេរជាអក្សរខ្មែរ ឬ ជាអក្សរបរទេស និងត្រូវតែមាននិទ្ទេសទាំងឡាយដូចខាងក្រោម :

-ពាក្យថា **មូលប្បទានប័ត្រ** ដែលចារឹកជាភាសាណាមួយដែលប្រើក្នុងការចេញឧបករណ៍នេះ

-បញ្ជាដោយឥតល័ក្ខខ័ណ្ឌឱ្យទូទាត់សងចំនួនប្រាក់ជាកំណត់មួយ

-ឈ្មោះរបស់បហារិតដែលជាធនាគារត្រូវទូទាត់សងប្រាក់

-កន្លែងដែលត្រូវធ្វើការទូទាត់សងប្រាក់

-កាលបរិច្ឆេទ និងកន្លែង ដែលមូលប្បទានប័ត្រត្រូវបានចេញ

-ហត្ថលេខារបស់បហារីក ដែលជាបុគ្គលចេញបញ្ជាលើមូលប្បទានប័ត្រ ។

មាត្រា ៥.-

ឧបករណ៍ដែលខ្វះនិទ្ទេសណាមួយ ដូចមានចែងនៅក្នុងមាត្រា ៤ នៃច្បាប់នេះ ពុំមានសុពលភាពជាមូលប្បទានប័ត្រឡើយ លើកលែងតែក្នុងករណីទាំងឡាយដែលបញ្ជាក់នៅក្នុងកថាខណ្ឌខាងក្រោម :

១-បើគ្មានការបញ្ជាក់ជាពិសេសទេ កន្លែងដែលបញ្ជាក់នៅក្បែរឈ្មោះរបស់បហារិតត្រូវបានចាត់ទុកថា ជាកន្លែងត្រូវទូទាត់សងប្រាក់ ។ បើមានកន្លែងច្រើនបញ្ជាក់នៅក្បែរឈ្មោះរបស់បហារិត មូលប្បទានប័ត្រនោះអាចត្រូវទូទាត់សងប្រាក់នៅកន្លែងដែលបញ្ជាក់មុនបង្អស់ ។

២-បើគ្មានសេចក្តីបញ្ជាក់ទាំងនេះ និងសេចក្តីបញ្ជាក់ណាមួយផ្សេងទៀតទេ មូលប្បទានប័ត្រអាចត្រូវទូទាត់សងប្រាក់នៅកន្លែងដែលបហារិតមានទីស្នាក់ការកណ្តាលរបស់ខ្លួន ។

៣-មូលប្បទានប័ត្រដែលមិនបានបញ្ជាក់ច្បាស់លាស់នូវកន្លែងនៃការចេញ ត្រូវបានចាត់ទុកថាចេញនៅកន្លែងដែលបញ្ជាក់នៅក្បែរឈ្មោះរបស់បហារីក ។

មាត្រា ៦.-

មូលប្បទានប័ត្រត្រូវតែបានចេញឱ្យទូទាត់សងប្រាក់ដោយធនាគារ ដែលបានទទួលរក្សាប្រាក់សម្រាប់ទុកសងក្នុងនាមបហារីក និងដោយអនុលោមទៅតាមកិច្ចព្រមព្រៀង ដែលមានចែង ឬ បញ្ជាក់ឱ្យបហារីកមានសិទ្ធិប្រើប្រាស់ប្រាក់នោះ តាមមូលប្បទានប័ត្រ ។ ទោះបីបដិញ្ញាខាងលើនេះ មិនបានប្រតិបត្តិតាមក្តី ក៏ឧបករណ៍នេះនៅតែមានសុពលភាពជាមូលប្បទានប័ត្រដដែល ។

មាត្រា ៧.-

មូលប្បទានប័ត្រ មិនត្រូវបានធ្វើស្វីការទេ ។ សេចក្តីបញ្ជាក់ពីស្វីការនៅលើមូលប្បទានប័ត្រ មិនត្រូវយកជាបានការឡើយ ។

មូលប្បទានប័ត្រ មិនត្រូវប្រើប្រាស់ជាការផ្ទេរមូលនិធិ ក្នុងដៃរបស់បហារិតដែលមានសម្រាប់ទូទាត់សងប្រាក់ ហើយបហារិតនៃមូលប្បទានប័ត្រក៏មិនទទួលខុសត្រូវចំពោះអ្នកកាន់ឡើយ ។

មាត្រា ៨.-

មូលប្បទានប័ត្រអាចត្រូវបានចេញផ្សាយ ដើម្បីទូទាត់សងប្រាក់ឱ្យទៅ :

-បុគ្គលដែលមានការបញ្ជាក់ដោយមាន ឬ ដោយគ្មានពាក្យថា សងតាមបញ្ជា

-បុគ្គលដែលមានការបញ្ជាក់ដោយពាក្យថា មិនសងតាមបញ្ជា ឬ ដោយពាក្យផ្សេងៗទៀតដែលមានន័យដូចគ្នា ឬ

-អ្នកកាន់ ។

មូលប្បទានប័ត្រ ដែលអាចទូទាត់សងប្រាក់ឱ្យទៅបុគ្គល ដែលមានបញ្ជាក់ដោយពាក្យថា ឬ អ្នកកាន់ ឬ ពាក្យទាំងឡាយដែលមានន័យដូចគ្នានេះ ត្រូវបានចាត់ទុកជាមូលប្បទានប័ត្រ ដែលចេញឱ្យទៅអ្នកកាន់ ។

មូលប្បទានប័ត្រ ដែលមិនបានបញ្ជាក់ឈ្មោះរបស់អត្ថគាហក ត្រូវបានចាត់ទុកជាមូលប្បទានប័ត្រចេញឱ្យទៅអ្នកកាន់ ។

14/12.r

មាត្រា ៩.-

មូលប្បទានប័ត្រ អាចត្រូវចេញឱ្យទូទាត់សងប្រាក់តាមបញ្ជារបស់បហារីកខ្លួនឯងផ្ទាល់ ។

មូលប្បទានប័ត្រ អាចត្រូវចេញជាប្រយោជន៍ឱ្យតតិយជន ។

មូលប្បទានប័ត្រ មិនអាចចេញដើម្បីទូទាត់សងប្រាក់ ដោយបហារីកខ្លួនឯងបានឡើយ លើកលែងតែការចេញនេះ ធ្វើឡើងដោយគ្រឹះស្ថានមួយទៅលើគ្រឹះស្ថានមួយទៀត ដែលជាកម្មសិទ្ធិរបស់បហារីកដដែលនេះ ។

មាត្រា ១០.-

បដិញ្ញាណាមួយពាក់ព័ន្ធទៅនឹងការតម្រូវឱ្យសងការប្រាក់ ដែលកំណត់នៅលើមូលប្បទានប័ត្រមិនត្រូវយកជាបានការឡើយ ។

មាត្រា ១១.-

មូលប្បទានប័ត្រ អាចត្រូវបានទូទាត់សងប្រាក់ នៅទីស្នាក់ការរបស់តតិយបុគ្គលនៅកន្លែងដែលបហារិតមានទីស្នាក់ការ ឬ នៅកន្លែងផ្សេងមួយទៀតឱ្យតែជានិច្ចកាលតតិយបុគ្គលនេះជាធនាគារ ។

មាត្រា ១២.-

ក្នុងករណីដែលចំនួនប្រាក់ត្រូវទូទាត់សង ដោយមូលប្បទានប័ត្រ ត្រូវបានសរសេរជាតួអក្សរផង និងជាតួលេខផង ហើយកាលបើមានលំអៀងគ្នា ចំនួនប្រាក់ជាតួអក្សរជាចំនួនដែលត្រូវយកជាបានការ ។

ក្នុងករណីដែលចំនួនប្រាក់ត្រូវទូទាត់សង ដោយមូលប្បទានប័ត្រ ត្រូវបានសរសេរច្រើនដងជាតួអក្សរ ឬ ជាតួលេខ ហើយកាលបើមានចំនួនលំអៀងគ្នា ចំនួនប្រាក់ដែលតូចជាង ជាចំនួនត្រូវយកជាបានការ ។

មាត្រា ១៣.-

រាល់កាតព្វកិច្ចនៃបុគ្គលដទៃៗទៀត ដែលបានចុះហត្ថលេខាលើមូលប្បទានប័ត្រនៅតែមានតម្លៃដដែល ទោះបីមូលប្បទានប័ត្រនោះ មានហត្ថលេខារបស់បុគ្គលអសម-

ក្ខភាព ឬ ហត្ថលេខាក្លែងបន្លំ ឬ ហត្ថលេខារបស់បុគ្គលតាមការប្រឌិត ឬ ហត្ថលេខាដែលតាមហេតុផលផ្សេងទៀត មិនអាចធ្វើឱ្យបុគ្គលដែលបានចុះហត្ថលេខា ឬបានចុះហត្ថលេខាជំនួសមានការទទួលខុសត្រូវ ។

មាត្រា ១៤.-

បុគ្គលណាដែលបានចុះហត្ថលេខានៅលើមូលប្បទានប័ត្រក្នុងនាមបុគ្គលមួយទៀត ដែលខ្លួនគ្មានសិទ្ធិតំណាងឱ្យទាល់តែសោះ ត្រូវមានការពាក់ព័ន្ធផ្ទាល់ជាភាគីមួយលើមូលប្បទានប័ត្រនោះ ហើយបើខ្លួនបានទូទាត់សងប្រាក់ត្រូវមានសិទ្ធិដូចគ្នានឹងបុគ្គលដែលខ្លួនបានទទួលរ៉ាប់រងជួសឱ្យ ។ វិធានដូចគ្នានេះ ក៏អនុវត្តទៅលើអាណាក្តិជនដែលបានអនុវត្តហួសសិទ្ធិរបស់ខ្លួនផងដែរ ។

មាត្រា ១៥.-

បុព្វការីកទទួលខុសត្រូវក្នុងការទូទាត់សងប្រាក់ ។ បដិញ្ញាណាមួយ ដែលធ្វើឱ្យបុព្វការីរួចផុតពីការទទួលខុសត្រូវនេះ មិនត្រូវយកជាបានការឡើយ ។

មាត្រា ១៦.-

បើមូលប្បទានប័ត្រ មានលក្ខណៈមិនពេញលេញនៅពេលចេញផ្សាយ ហើយត្រូវបានធ្វើឱ្យពេញលក្ខណៈតាមបែបផ្សេងខុសពីការព្រមព្រៀងដែលពាក់ព័ន្ធ ការមិនគោរពតាមការព្រមព្រៀងនេះ មិនអាចយកជាមូលហេតុប្តឹងអ្នកកាន់បានឡើយ លើកលែងតែអ្នកកាន់នេះ បានទទួលមូលប្បទានប័ត្រមកដោយទុច្ចរិត ឬ មានកំហុសដោយការធ្វេសប្រហែសធ្ងន់ធ្ងរ ។

## ផ្នែកទី ២

## បិដ្ឋិលេខមូលប្បទានប័ត្រ

មាត្រា ១៧.-

មូលប្បទានប័ត្រ ដែលចេញឱ្យទូទាត់សងប្រាក់ចំពោះបុគ្គលណាមួយច្បាស់លាស់ ដោយមាន ឬ ដោយគ្មានពាក្យថា សងតាមបញ្ជា អាចត្រូវផ្ទេរបាន ដោយបិដ្ឋិលេខ ។

ꟻ

14/125

មូលប្បទានប័ត្រដែលចេញឱ្យទូទាត់សងប្រាក់ ចំពោះបុគ្គលណាមួយច្បាស់លាស់ ដោយមានពាក្យថា **មិនសងតាមបញ្ជា** ឬ ពាក្យដែលមានន័យដូចគ្នាអាចត្រូវបានផ្ទេរស្របតាមទម្រង់ និងមានសុពលភាពជាការផ្ទេរធម្មតាតែប៉ុណ្ណោះ ។

មូលប្បទានប័ត្រ អាចត្រូវបានធ្វើបិដ្ឋិលេខ ទោះបីឱ្យទៅបរហារិកក្តី ឬ ឱ្យទៅភាគីណាមួយផ្សេងទៀតនៃមូលប្បទានប័ត្រនោះក្តី ។ បុគ្គលទាំងនេះ អាចធ្វើបិដ្ឋិលេខមូលប្បទានប័ត្រនោះ បន្តទៀតបាន ។

**មាត្រា ១៨.-**

បិដ្ឋិលេខ ត្រូវតែបានធ្វើឡើងដោយឥតល័ក្ខខ័ណ្ឌ ។ ល័ក្ខខ័ណ្ឌណាមួយ ដែលត្រូវបានដាក់ចេញជាកម្មវត្ថុចំពោះការធ្វើបិដ្ឋិលេខមូលប្បទានប័ត្រ មិនត្រូវយកជាបានការឡើយ ។

បិដ្ឋិលេខលើមួយផ្នែកនៃចំនួនប្រាក់ក្នុងមូលប្បទានប័ត្រ ត្រូវចាត់ទុកជាមោឃៈ ។

បិដ្ឋិលេខដែលធ្វើឡើងដោយបរហារិក ត្រូវចាត់ទុកជាមោឃៈ ។

បិដ្ឋិលេខដែលធ្វើឱ្យ **អ្នកកាន់** មានតម្លៃស្មើនឹងបិដ្ឋិលេខចំហ ។

បិដ្ឋិលេខដែលធ្វើឱ្យបរហារិក មានតម្លៃត្រឹមតែជាបង្កាន់ដៃទទួលប្រាក់ លើកលែងតែក្នុងករណីដែលបរហារិកមានគ្រឹះស្ថានច្រើនកន្លែង ហើយបិដ្ឋិលេខនេះត្រូវបានធ្វើជាប្រយោជន៍ឱ្យគ្រឹះស្ថានមួយទៀត ក្រៅពីគ្រឹះស្ថានដែលមូលប្បទានប័ត្រនោះ ត្រូវបានចេញ ។

**មាត្រា ១៩.-**

បិដ្ឋិលេខត្រូវតែបានធ្វើជាលាយលក្ខណ៍អក្សរនៅលើខ្នងមូលប្បទានប័ត្រ ឬ នៅលើក្រដាសបិទភ្ជាប់បន្ថែមហៅថា **អនុបំត្រ** និងត្រូវតែបានចុះហត្ថលេខាដោយអ្នកធ្វើបិដ្ឋិលេខ ។

បិដ្ឋិលេខអាចមិនបញ្ជាក់ពីអត្ថគាហក ឬ អាចមានតែហត្ថលេខារបស់អ្នកធ្វើបិដ្ឋិលេខប៉ុណ្ណោះហៅថា **បិដ្ឋិលេខចំហ** ។

មាត្រា ២០.-

បិដ្ឋិលេខផ្ទេរសិទ្ធិទាំងអស់ នៃមូលប្បទានប័ត្រឱ្យ ទៅអ្នកកាន់ ។

បើជាបិដ្ឋិលេខចំហ អ្នកកាន់អាច :

-បំពេញកន្លែងចំហ ឬ ដោយឈ្មោះរបស់ខ្លួនផ្ទាល់ ឬ ដោយឈ្មោះរបស់បុគ្គលដទៃទៀត

-ធ្វើបិដ្ឋិលេខបន្តមូលប្បទានប័ត្រជាចំហ ឬ ឱ្យបុគ្គលដទៃទៀត

-ផ្ទេរមូលប្បទានប័ត្រឱ្យ ទៅតតិយបុគ្គល ដោយមិនចាំបាច់បំពេញកន្លែងចំហ និងមិនចាំបាច់ធ្វើបិដ្ឋិលេខ ។

មាត្រា ២១.-

បើគ្មានបដិញ្ញាផ្ទុយទេ អ្នកធ្វើបិដ្ឋិលេខត្រូវទទួលខុសត្រូវលើការទូទាត់សងប្រាក់ ។

អ្នកធ្វើបិដ្ឋិលេខអាចហាមឃាត់ការធ្វើបិដ្ឋិលេខណាមួយបន្តទៀត ហើយក្នុងករណីនេះ បុគ្គលដែលបានហាមឃាត់មិនទទួលខុសត្រូវទូទាត់សងប្រាក់ទៅបុគ្គលទាំងឡាយណាដែលមូលប្បទានប័ត្រត្រូវបានធ្វើបិដ្ឋិលេខបន្តឡើយ ។

មាត្រា ២២.-

ម្ចាស់មូលប្បទានប័ត្រ ដែលអាចធ្វើបិដ្ឋិលេខ បានជាអ្នកកាន់ស្របច្បាប់ បើបុគ្គលនេះបានក្លាយជាម្ចាស់មូលប្បទានប័ត្រតាមរយៈការធ្វើបិដ្ឋិលេខជាបន្តបន្ទាប់ ទោះបីបិដ្ឋិលេខចុងក្រោយជាបិដ្ឋិលេខចំហក៏ដោយ ។ ក្នុងករណីនេះ បិដ្ឋិលេខដែលលុបចោលមិនត្រូវយកជាបានការឡើយ ។ កាលបើបិដ្ឋិលេខចំហត្រូវបានបន្តដោយបិដ្ឋិលេខមួយទៀត បុគ្គលដែលចុះហត្ថលេខាធ្វើបិដ្ឋិលេខចុងក្រោយនេះ ត្រូវចាត់ទុកថាបានទទួលមូលប្បទានប័ត្រ តាមរយៈបិដ្ឋិលេខចំហ ។

មាត្រា ២៣.-

បិដ្ឋិលេខនៅលើមូលប្បទានប័ត្រ ដែលចេញឱ្យ ទៅអ្នកកាន់នាំឱ្យអ្នកធ្វើបិដ្ឋិលេខនោះមានការទទួលខុសត្រូវស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិធ្វើឧបាស្រ័យ ប៉ុន្តែបិដ្ឋិលេខ

នេះ មិនប្រែក្លាយឧបករណ៍នោះទៅជាមូលប្បទានប័ត្រសងតាមបញ្ជា ឡើយ ។

មាត្រា ២៤.-

នៅពេលដែលបុគ្គលណាមួយបានបាត់បង់សិទ្ធិកាន់កាប់មូលប្បទានប័ត្រដោយមូលហេតុណាក៏ដោយ ទោះបីជាមូលប្បទានប័ត្រចេញឱ្យទៅអ្នកកាន់ក្តី ឬ អាចផ្ទេរបិ-ដ្ឋិលេខបានក្តី ដែលអ្នកកាន់មានសិទ្ធិជាម្ចាស់ដូចមានចែងនៅក្នុងមាត្រា ២២ នៃច្បាប់នេះ អ្នកកាន់ដែលទទួលបានមូលប្បទានប័ត្រមកជាកម្មសិទ្ធិមិនត្រូវបានបង្ខំឱ្យបោះបង់ចោលមូលប្បទានប័ត្រឡើយ លើកលែងតែមូលប្បទានប័ត្រនោះបានមកដោយទុច្ច-រិត ឬ ដោយមានកំហុសពីការធ្វេសប្រហែសធ្ងន់ធ្ងរ ។

មាត្រា ២៥.-

បុគ្គលទាំងឡាយដែលប្តឹងអំពីមូលប្បទានប័ត្រ មិនអាចប្តឹងអ្នកកាន់ដោយសំអាងលើទំនាក់ទំនងផ្ទាល់ខ្លួនជាមួយបញ្ជារីក ឬ ជាមួយអ្នកកាន់មុនៗបានឡើយ លើកលែងតែក្នុងការទទួលមូលប្បទានប័ត្រ អ្នកកាន់បានដឹងច្បាស់ថានឹងនាំឱ្យខូចប្រយោជន៍ដល់កូនបំណុល ។

កថាខណ្ឌខាងលើនៃមាត្រានេះមិនអនុវត្តចំពោះមូលប្បទានប័ត្រ ដែលចេញដើម្បីទូទាត់សងប្រាក់ទៅបុគ្គលណាមួយច្បាស់លាស់ ដែលក្នុងនោះមានពាក្យថា មិនសងតាមបញ្ជា ឬ ប្រយោគណាមួយដែលមានន័យដូចគ្នា ។

មាត្រា ២៦.-

កាលបើបិដ្ឋិលេខមានពាក្យថា តម្លៃសម្រាប់ទារបំណុល ឬ សម្រាប់បេឡានិច័យ ឬ តាមការប្រគល់សិទ្ធិ ឬ ប្រយោគណាមួយផ្សេងទៀត ដែលបញ្ជាក់ពីការប្រគល់សិទ្ធិសាមញ្ញ អ្នកកាន់អាចអនុវត្តសិទ្ធិទាំងអស់នៃមូលប្បទានប័ត្រនោះ ប៉ុន្តែអ្នកកាន់នេះអាចធ្វើបិដ្ឋិលេខបន្តក្នុងនាមជាភ្នាក់ងារតែប៉ុណ្ណោះ ។

ក្នុងករណីនេះ ភាគីពាក់ព័ន្ធទាំងឡាយអាចប្តឹងអ្នកកាន់ ហើយអ្នកកាន់នេះក៏អាចប្តឹងអ្នកធ្វើបិដ្ឋិលេខផងដែរ ។

ការប្រគល់សិទ្ធិដែលមាននៅក្នុងបិដ្ឋិលេខ មិនអាចរលត់បានដោយហេតុផលនៃមរណភាពរបស់ភាគី ដែលបានផ្តល់ការប្រគល់សិទ្ធិ ឬ ដោយហេតុផល ដែលបុគ្គលនេះ បានក្លាយជាអសមត្ថភាពនីត្យានុកូលឡើយ ។

មាត្រា ២៧.-

បិដ្ឋិលេខដែលធ្វើឡើងក្រោយពីវិវុទ្ធភាព ឬ ក្រោយពីការធ្វើប្រតិវេទន៍ដែលសមមូលគ្នា ឬ ក្រោយពីផុតរយៈពេលកំណត់បង្ហាញឱ្យទូទាត់សងប្រាក់ អាចនឹង :

-អនុវត្តបានតាមការផ្ទេរធម្មតាតែប៉ុណ្ណោះ

-មិនអនុវត្តក្នុងការផ្តល់សិទ្ធិក្រោមមាត្រា ២២ មាត្រា ២៤ និង មាត្រា ២៥ នៃច្បាប់នេះឡើយ ។

បើគ្មានភស្តុតាងផ្ទុយទេ បិដ្ឋិលេខដែលគ្មានចុះកាលបរិច្ឆេទត្រូវចាត់ទុកថាបានធ្វើនៅលើមូលប្បទានប័ត្រ មុនពេលធ្វើវិវុទ្ធភាព ឬ ប្រតិវេទន៍ដែលសមមូលគ្នា ឬ នៅមុនផុតរយៈពេលកំណត់យោងតាមកថាខណ្ឌខាងលើនៃមាត្រានេះ ។

## ផ្នែកទី ៣
## រូបិយបដិភោគមូលប្បទានប័ត្រ

មាត្រា ២៨.-

ការទូទាត់សងមូលប្បទានប័ត្រអាចត្រូវបានធានាដោយរូបិយបដិភោគនៅលើចំនួនប្រាក់ទាំងអស់ ឬ មួយផ្នែកនៃមូលប្បទានប័ត្រ ។

ការធានានេះអាចត្រូវបានផ្តល់ដោយតតិយបុគ្គលក្រៅពីបហារិត ឬ ដោយបុគ្គលណាមួយដែលបានចុះហត្ថលេខាលើមូលប្បទានប័ត្រ ។

មាត្រា ២៩.-

រូបិយបដិភោគអាចត្រូវបានធ្វើឡើងនៅលើមូលប្បទានប័ត្រផ្ទាល់ ឬ នៅលើអនុប័ត្រ ។

រូបិយបដិភោគត្រូវបានបញ្ជាក់ដោយពាក្យថា **យល់ព្រមធ្វើរូបិយបដិភោគ** ឬ ដោយរូបមន្តណាមួយផ្សេងទៀតដែលមានន័យដូចគ្នា និងត្រូវតែចុះហត្ថលេខាដោយអ្នកផ្តល់

រូបិយបដិភោគហៅថា រូបិយបដិភោគី ។

ហត្ថលេខាធ្វើរូបិយបដិភោគ ត្រូវបានចុះនៅខាងមុខមូលប្បទានប័ត្រ ។

រូបិយបដិភោគ ត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់នូវបុគ្គលណាមួយ ដែលជាអ្នកទទួលផលពីរូបិយបដិភោគនោះ ។ បើគ្មានសេចក្ដីបញ្ជាក់នេះទេ រូបិយបដិភោគត្រូវបានចាត់ទុកថាធ្វើឱ្យបហារីក ។

មាត្រា ៣០.-

រូបិយបដិភោគីមានកាតព្វកិច្ច ដូចបុគ្គលដែលបានទទួលការធានាដែរ ។

ការចុះហត្ថលេខាធានានៅតែមានតម្លៃ ទោះបីកាតព្វកិច្ចដែលបានធានានោះមិនត្រូវបានអនុវត្តតាមដោយសារហេតុផលផ្សេងៗ ក្រៅពីវិការៈខាងទម្រង់ក៏ដោយ ។

នៅពេលបានទូទាត់សងមូលប្បទានប័ត្រ រូបិយបដិភោគីមានសិទ្ធិទាំងឡាយដែលផ្ដើមចេញពីមូលប្បទានប័ត្រនោះ ទល់នឹងបុគ្គលដែលត្រូវបានធានា និង បុគ្គលដែលពាក់ព័ន្ធជាមួយបុគ្គលដែលត្រូវបានធានានេះ នៅលើមូលប្បទានប័ត្រ ។

## ផ្នែកទី ៤
## ការបង្ហាញមូលប្បទានប័ត្រនិងការទូទាត់សងប្រាក់

មាត្រា ៣១.-

មូលប្បទានប័ត្រ ត្រូវបានទូទាត់សងប្រាក់នៅពេលបង្ហាញ ។ បដិញ្ញាណាមួយដែលមានន័យផ្ទុយពីនេះ មិនត្រូវយកជាបានការឡើយ ។

មូលប្បទានប័ត្រ ដែលបានបង្ហាញឱ្យទូទាត់សងប្រាក់នៅមុនកាលបរិច្ឆេទដែលជាថ្ងៃចេញផ្សាយត្រូវតែទូទាត់សងប្រាក់នៅថ្ងៃបង្ហាញ ។

មាត្រា ៣២.-

មូលប្បទានប័ត្រ ត្រូវតែបានបង្ហាញដើម្បីឱ្យទូទាត់សងប្រាក់ក្នុងរយៈពេលប្រាំមួយ(៦)ខែ គិតពីថ្ងៃចេញផ្សាយ ។

មាត្រា ៣៣.-

នៅពេលដែលមូលប្បទានប័ត្រត្រូវបានចេញនៅកន្លែងមួយហើយ នឹងត្រូវទូទាត់សងប្រាក់នៅកន្លែងមួយផ្សេងទៀត ដែលមានប្រតិទិនខុសគ្នាថ្ងៃចេញផ្សាយនឹងត្រូវបានប្រកាន់យកតាមថ្ងៃដែលត្រូវគ្នាក្នុងប្រតិទិនប្រចាំកន្លែងដែលត្រូវទូទាត់សងប្រាក់ ។

មាត្រា ៣៤.-

ការបង្ហាញមូលប្បទានប័ត្រនៅ ឬ តាមរយៈសភាផាត់ទាត់ ឬ តាមរយៈប្រព័ន្ធអេឡិចត្រូនិកដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង ឬ បទបញ្ជា ដែលចេញដោយធនាគារជាតិនៃកម្ពុជា ជាការបង្ហាញឱ្យទូទាត់សងប្រាក់ជាផ្លូវការ ។

មាត្រា ៣៥.-

ការទូទាត់សងមូលប្បទានប័ត្រអាចត្រូវជំទាស់ ដោយមិនធ្វើឱ្យខូចខាតដល់សិទ្ធិអ្នកកាន់ ។

បើការទូទាត់សងមូលប្បទានប័ត្រមិនត្រូវបានជំទាស់ទេ បហារិតនៅតែអាចទូទាត់សងប្រាក់បាន ទោះបីផុតរយៈពេលកំណត់ត្រូវបង្ហាញក៏ដោយ ។

មាត្រា ៣៦.-

មរណភាព ឬ អសមត្ថភាពរបស់បហារីក ដែលកើតឡើងក្រោយការចេញផ្សាយមូលប្បទានប័ត្រ ពុំមានផលប៉ះពាល់ដល់មូលប្បទានប័ត្រឡើយ ។

មាត្រា ៣៧.-

បហារិតដែលទូទាត់សងមូលប្បទានប័ត្រអាចតម្រូវឱ្យប្រគល់មូលប្បទានប័ត្រនោះឱ្យខ្លួន ក្រោយពីមានបញ្ជាក់ការទទួលប្រាក់ពីអ្នកកាន់ ។

បើមិនមានចំនួនប្រាក់គ្រប់គ្រាន់ ក្នុងគណនីរបស់បហារីកទេ អ្នកកាន់អាចមិនបដិសេធការទូទាត់សងចំនួនប្រាក់មួយផ្នែកនៃមូលប្បទានប័ត្រ ។

ក្នុងករណីមានការទូទាត់សងប្រាក់មួយផ្នែកនៃចំនួនប្រាក់ បហារិតអាចទាមទារឱ្យបញ្ជាក់ការសងប្រាក់មួយផ្នែកនោះ នៅលើមូលប្បទានប័ត្រ និង ទាមទារបង្កាន់ដៃទទួលប្រាក់ផងដែរ ។

មាត្រា ៣៨.-

បហារិតដែលទូទាត់សងមូលប្បទានប័ត្រមានបិដ្ឋិលេខ ត្រូវទទួលខុសត្រូវផ្ទៀងផ្ទាត់ប្រក្រតីភាពនៃលំដាប់បិដ្ឋិលេខ ប៉ុន្តែមិនផ្ទៀងផ្ទាត់ហត្ថលេខាអ្នកធ្វើបិដ្ឋិលេខឡើយ ។

មាត្រា ៣៩.-

រូបិយប័ណ្ណដែលត្រូវប្រើប្រាស់ សម្រាប់ទូទាត់សងប្រាក់លើមូលប្បទានប័ត្រត្រូវបានកំណត់ដូចខាងក្រោម :

១-មូលប្បទានប័ត្រ ត្រូវបានចាត់ទុកជាការអនុញ្ញាតឱ្យបហារិតដើម្បីទូទាត់សងជារូបិយប័ណ្ណនៃគណនី ដែលមូលប្បទានប័ត្រត្រូវបានចេញ ។

២-នៅពេលដែលមូលប្បទានប័ត្រ ត្រូវបានចេញជារូបិយប័ណ្ណផ្សេងពីរូបិយប័ណ្ណនៃគណនី ចំនួនប្រាក់អាចត្រូវសងជារូបិយប័ណ្ណនៃគណនីដោយបហារិតតាមតម្លៃនៃរូបិយប័ណ្ណនោះ នៅថ្ងៃទូទាត់សងប្រាក់ ។

៣-បើមូលប្បទានប័ត្រ ត្រូវបានចេញជារូបិយប័ណ្ណផ្សេងពីរូបិយប័ណ្ណនៃកន្លែងត្រូវទូទាត់សងប្រាក់ ហើយមូលប្បទានប័ត្រនេះមិនត្រូវបានទូទាត់សងប្រាក់នៅពេលបង្ហាញ អ្នកកាន់អាចតម្រូវឱ្យភាគីពាក់ព័ន្ធធ្វើការទូទាត់សងចំនួនប្រាក់នៃមូលប្បទានប័ត្រជារូបិយប័ណ្ណនៃកន្លែងទូទាត់សងប្រាក់តាមអត្រាប្តូរប្រាក់ នៅថ្ងៃបង្ហាញ ឬនៅថ្ងៃទូទាត់សងប្រាក់តាមការជ្រើសរើសរបស់ខ្លួន ។

៤-ការប្រើប្រាស់កន្លែងទូទាត់សងប្រាក់ ត្រូវអនុវត្តក្នុងការកំណត់តម្លៃរូបិយប័ណ្ណ ។ ប៉ុន្តែបហារិកអាចកំណត់ថាចំនួនប្រាក់ទូទាត់សង ត្រូវគណនាទៅតាមអត្រាប្តូរប្រាក់ដែលបញ្ជាក់នៅលើមូលប្បទានប័ត្រ ។

៥-ទោះបីមានកថាខណ្ឌទី ៣ នៃមាត្រានេះក៏ដោយ មូលប្បទានប័ត្រចេញឱ្យទូទាត់សងជារូបិយប័ណ្ណ ដែលត្រូវបានប្រើនៅព្រះរាជាណាចក្រកម្ពុជា ឬ បើនៅលើមូលប្បទានប័ត្រ បហារិកបានបញ្ជាក់ថាការទូទាត់សងប្រាក់ត្រូវតែធ្វើជារូបិយប័ណ្ណមួយច្បាស់លាស់ អ្នកកាន់អាចទាមទារពីភាគីពាក់ព័ន្ធណាមួយឱ្យទូទាត់សងជារូបិយប័ណ្ណ ដែលបានបញ្ជាក់នោះ ។

៦-បើចំនួនប្រាក់នៃមូលប្បទានប័ត្រ ត្រូវបានបញ្ជាក់ជារូបិយប័ណ្ណដែល

មាននាមចារឹកដូចគ្នា ប៉ុន្តែមានតម្លៃខុសគ្នារវាងប្រទេសទូទាត់សងប្រាក់និងប្រទេសចេញផ្សាយ ឬ ប្រទេសណាមួយផ្សេងទៀត លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ នៅពេលដែលរូបិយប័ណ្ណ ដែលបានបញ្ជាក់មិនមែនជារូបិយប័ណ្ណនៃគណនីដែលត្រូវទូទាត់សងប្រាក់ ការទូទាត់សងមូលប្បទានប័ត្រត្រូវធ្វើឡើងជារូបិយប័ណ្ណនៃប្រទេសទូទាត់សងប្រាក់ ។ នៅពេលណាដែលរូបិយប័ណ្ណនៃប្រទេសទូទាត់សងប្រាក់ពុំមាននាមចារឹកដូចគ្នា ការទូទាត់សងប្រាក់នៃមូលប្បទានប័ត្រត្រូវបានធ្វើឡើងជារូបិយប័ណ្ណដែលត្រូវបានប្រើយ៉ាងទូលំទូលាយនៅកន្លែងទូទាត់សងប្រាក់ ។

## ផ្នែកទី ៥

## មូលប្បទានប័ត្រឆូតបន្ទាត់និងមូលប្បទានប័ត្រទូទាត់សងចូលក្នុងគណនី

### មាត្រា ៤០.-

បហារីក ឬ អ្នកកាន់អាចឆូតបន្ទាត់លើមូលប្បទានប័ត្រ ។

ការឆូតបន្ទាត់មានរូបភាពជាបន្ទាត់ស្របគ្នាពីរដែលគូសនៅខាងមុខមូលប្បទានប័ត្រ ។ បន្ទាត់ឆូតអាចមានពីរបែប គឺបន្ទាត់ឆូតទូទៅ ឬ បន្ទាត់ឆូតពិសេស ។

បន្ទាត់ឆូតទូទៅមានបន្ទាត់គូសតែពីរ ឬ នៅចន្លោះបន្ទាត់ទាំងពីរមានពាក្យថា ធនាគារ ឬ ពាក្យផ្សេងទៀតដែលមានន័យដូចគ្នា ។ បន្ទាត់ឆូតពិសេសមានឈ្មោះរបស់ធនាគារនៅចន្លោះបន្ទាត់ទាំងពីរ ។

បន្ទាត់ឆូតទូទៅ អាចត្រូវប្តូរបានទៅជាបន្ទាត់ឆូតពិសេស ប៉ុន្តែបន្ទាត់ឆូតពិសេសមិនអាចត្រូវប្តូរមកជាបន្ទាត់ឆូតទូទៅវិញបានឡើយ ។

ការកោសលុបកែបន្ទាត់ឆូត ឬ ឈ្មោះរបស់ធនាគារ មិនអាចធ្វើបានឡើយ ។

### មាត្រា ៤១.-

ចំពោះមូលប្បទានប័ត្រមានបន្ទាត់ឆូតទូទៅ បហារិតអាចទូទាត់សងឱ្យទៅធនា-គារ ឬ ទៅអតិថិជនរបស់ខ្លួនតែប៉ុណ្ណោះ ។

ចំពោះមូលប្បទានប័ត្រមានបន្ទាត់ឆូតពិសេស បហារិតអាចទូទាត់សងឱ្យទៅធនាគារដែលមានឈ្មោះនៅលើមូលប្បទានប័ត្រតែប៉ុណ្ណោះ ឬ បើធនាគារនេះជាបហា-

វិតអាចទូទាត់សងឱ្យទៅអតិថិជនរបស់ខ្លួនតែប៉ុណ្ណោះដែរ ។ ប៉ុន្តែធនាគារដែលមានឈ្មោះលើមូលប្បទានប័ត្រ អាចធ្វើបេឡានិច័យតាមរយៈធនាគារមួយទៀត ។

ធនាគារអាចទទួលយកមូលប្បទានប័ត្រឆូតបន្ទាត់ពីអតិថិជនរបស់ខ្លួន ឬ ពីធនាគារមួយផ្សេងទៀតតែប៉ុណ្ណោះ ។ ធនាគារមិនអាចធ្វើបេឡានិច័យមូលប្បទានប័ត្រឆូតបន្ទាត់ជាប្រយោជន៍ឱ្យបុគ្គលដទៃទៀត ក្រៅពីបុគ្គលដែលបានពោលខាងលើនេះឡើយ ។

ចំពោះមូលប្បទានប័ត្រដែលមានបន្ទាត់ឆូតពិសេសច្រើន បហារិតមិនអាចទូទាត់សងប្រាក់បានឡើយ លើកលែងតែក្នុងករណីដែលមានបន្ទាត់ឆូតតែពីរកន្លែងដែលក្នុងនោះបន្ទាត់ឆូតមួយកន្លែងសម្រាប់ធ្វើបេឡានិច័យតាមរយៈសភាជាត់ទាត់ ។

បហារិត ឬ ធនាគារ ដែលខកខានមិនបានគោរពតាមបទប្បញ្ញត្តិទាំងឡាយនៃមាត្រានេះត្រូវទទួលខុសត្រូវលើការខូចខាត ដែលកើតឡើងរហូតដល់ស្មើនឹងចំនួនប្រាក់នៃមូលប្បទានប័ត្រ ។

មាត្រា ៩២.-

បហារិក ឬ អ្នកកាន់មូលប្បទានប័ត្រអាចហាមឃាត់ការទូទាត់សងជាសាច់ប្រាក់ដោយសរសេរអក្សរកាត់ទទឹងផ្ទៃមុខមូលប្បទានប័ត្រនោះថា សម្រាប់ទូទាត់សងចូលក្នុងគណនី ឬ តាមសំនួនសេចក្តីដែលមានន័យដូចគ្នា ។

ក្នុងករណីនេះ មូលប្បទានប័ត្រអាចត្រូវបានទូទាត់ដោយបហារិតតាមរយៈកិច្ចបញ្ជិកាគណនេយ្យតែប៉ុណ្ណោះ ដោយការចុះឥណទានចូលគណនី ការផ្ទេរប្រាក់ពីគណនីមួយចូលទៅគណនីមួយទៀត ការកាត់កង ឬ ការទូទាត់តាមរយៈសភាជាត់ទាត់ ។ ការទូទាត់តាមកិច្ចបញ្ជិកាគណនេយ្យមានន័យថា ជាការទូទាត់សងប្រាក់ ។

ការកោសលុបកែណាមួយចំពោះពាក្យថា សម្រាប់ទូទាត់សងចូលក្នុងគណនី មិនអាចធ្វើបានឡើយ ។

បហារិតដែលខកខានមិនបានគោរពតាមបទប្បញ្ញត្តិទាំងឡាយនៃមាត្រានេះត្រូវទទួលខុសត្រូវលើការខូចខាតដែលកើតឡើងរហូតដល់ស្មើនឹងចំនួនប្រាក់នៃមូលប្បទានប័ត្រ ។

៦ៃ/

២៥/១២៥

## ផ្នែកទី ៦
## ឧបាស្រ័យចំពោះការមិនទូទាត់សងប្រាក់

### មាត្រា ៤៣.-

អ្នកកាន់អាចអនុវត្តសិទ្ធិធ្វើឧបាស្រ័យទល់នឹងអ្នកធ្វើបិដ្ឋិលេខបហារិក និងភាគីជាប់ពាក់ព័ន្ធដទៃទៀត បើមូលប្បទានប័ត្រដែលត្រូវបានបង្ហាញនៅក្នុងរយៈពេលកំណត់ត្រឹមត្រូវនោះមិនត្រូវបានទូទាត់សងប្រាក់ ហើយបើមានភស្តុតាងយ៉ាងហោចណាស់មួយ ដែលបង្ហាញពីការបដិសេធមិនទូទាត់សងប្រាក់ដូចខាងក្រោម ៖

-វិរុទ្ធវាទ ឬ ឧបករណ៍ផ្លូវការផ្សេងណាមួយ ឬ

-ប្រតិវេទន៍មានចុះកាលបរិច្ឆេទនិងបញ្ជាក់ដោយបហារិកអំពីថ្ងៃបង្ហាញឱ្យទូទាត់សងប្រាក់ ឬ

-ប្រតិវេទន៍មានចុះកាលបរិច្ឆេទធ្វើឡើងដោយសភាជាត់ទាត់ដែលបញ្ជាក់ថាមូលប្បទានប័ត្រ ត្រូវបានប្រគល់នៅក្នុងរយៈពេលកំណត់ និងមិនត្រូវបានទូទាត់សងប្រាក់ ។

### មាត្រា ៤៤.-

វិរុទ្ធវាទត្រូវតែបានចុះហត្ថលេខាបញ្ជាក់យថាភាពនៃឯកសារដោយមន្ត្រីដែលទទួលសិទ្ធិស្របច្បាប់ ។ ដរាបណាពុំទាន់មានមន្ត្រីដែលបានទទួលសិទ្ធិស្របច្បាប់នោះទេ មន្ត្រីនោះត្រូវតែបានតែងតាំងដោយធនាគារជាតិនៃកម្ពុជា ។ វិរុទ្ធវាទត្រូវមានច្បាប់ថតចម្លង ឬ ច្បាប់ដើមនៃមូលប្បទានប័ត្រភ្ជាប់ជាមួយ ហើយត្រូវបញ្ជាក់ច្បាស់លាស់អំពីបុគ្គលដែលធ្វើវិរុទ្ធវាទ កន្លែងនិងកាលបរិច្ឆេទ មូលហេតុនៃវិរុទ្ធវាទ សំណូមពរដែលលើកឡើង និងចម្លើយដែលផ្តល់មកវិញបើមាន ឬ អំពីការដែលរកមិនឃើញបហារិក ។ វិរុទ្ធវាទត្រូវបានធ្វើឡើងនៅកន្លែងនៃការបដិសេធមិនទូទាត់សង ឬ មិនទទួលយក ឬ នៅកន្លែងផ្សេងទៀតក្នុងព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតក្នុងចម្ងាយមិនលើសដប់(១០)គីឡូម៉ែត្រពីកន្លែងនៃការបង្ហាញ និងនៃការបដិសេធមិនទូទាត់សងប្រាក់ ឬ មិនទទួលយក ។

ᯓ

ᯓ/125

វិវាទឬប្រតិវេទន៍ដែលសមមូលគ្នា ត្រូវតែបានធ្វើឡើងនៅមុនពេលផុតកំណត់បង្ហាញឱ្យទូទាត់សងប្រាក់ ។

បើមូលប្បទានប័ត្រត្រូវបានបង្ហាញឱ្យទូទាត់សង នៅថ្ងៃចុងក្រោយនៃរយៈពេលកំណត់វិវាទ ឬ ប្រតិវេទន៍ដែលសមមូលគ្នាអាចត្រូវបានធ្វើឡើងនៅថ្ងៃធ្វើការទីមួយបន្ទាប់ពីរយៈពេលផុតកំណត់ ។

ក្រោយផុតរយៈពេលកំណត់សម្រាប់ធ្វើវិវាទស្តីពីការមិនទូទាត់សងប្រាក់ អ្នកកាន់ត្រូវបាត់បង់សិទ្ធិធ្វើឧបាស្រ័យទល់នឹងភាគីពាក់ព័ន្ធលើមូលប្បទានប័ត្រនោះ ប៉ុន្តែអាចប្តឹងបហារីកក្រោមបទប្បញ្ញត្តិដោយឡែកស្តីពីកិច្ចសន្យា ហើយសំណងដែលបានមកវិញ ត្រូវកាត់សងលើការខូចខាតដែលបង្កឡើងដោយអ្នកកាន់ចំពោះបហារីកដោយសារតែខកខានមិនបានគោរពរយៈពេលកំណត់ ។

មាត្រា -៤៥.-

អ្នកកាន់ ត្រូវជូនដំណឹងពីការមិនទូទាត់សងប្រាក់ទៅអ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន និងទៅបហារីកនៅក្នុងរយៈពេលបួន(០៤)ថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃដែលវិវាទ ឬ ប្រតិ-វេទន៍ដែលសមមូលគ្នាត្រូវបានធ្វើ ឬ នៅថ្ងៃបង្ហាញឱ្យទូទាត់សងប្រាក់ ក្នុងករណីដែលមានបដិញ្ញាថា បង្វិលវិញដោយគ្មានសោហ៊ុយ ឬបង្វិលវិញដោយគ្មានវិវាទ ឬ សេចក្តីផ្សេងណាមួយដែលមានន័យដូចគ្នា ។ នៅក្នុងរយៈពេលពីរ (០២) ថ្ងៃធ្វើការបន្ទាប់ពីថ្ងៃបានទទួលសេចក្តីជូនដំណឹង អ្នកធ្វើបិដ្ឋិលេខនីមួយៗត្រូវជូនដំណឹងដល់អ្នកធ្វើបិដ្ឋិ-លេខរបស់ខ្លួនអំពីសេចក្តីជូនដំណឹងដែលបានទទួលដោយបញ្ជាក់ពីឈ្មោះនិងអាសយ-ដ្ឋានរបស់អ្នកធ្វើបិដ្ឋិលេខ ដែលបានផ្តល់សេចក្តីជូនដំណឹងមុនៗជាលំដាប់លំដោយរហូតដល់បហារីកបានទទួល ។ រយៈពេលកំណត់ដែលបញ្ជាក់ខាងលើ ត្រូវគិតពីថ្ងៃទទួលបានសេចក្តីជូនដំណឹងមុន ។

ដោយអនុលោមតាមកថាខណ្ឌខាងលើនៃមាត្រានេះ នៅពេលដែលសេចក្តីជូនដំណឹងត្រូវបានផ្តល់ទៅបុគ្គលដែលបានចុះហត្ថលេខាលើមូលប្បទានប័ត្រ សេចក្តីជូនដំណឹងដូចគ្នានេះក៏ត្រូវបានផ្តល់ទៅឱ្យបដិភោគីនៅក្នុងរយៈពេលកំណត់ដូចគ្នា ។

កាលបើអ្នកធ្វើបិដ្ឋិលេខមិនបានបញ្ជាក់អំពីអាសយដ្ឋានរបស់ខ្លួន ឬ ក៏បានបញ្ជាក់ដោយមិនច្បាស់ សេចក្តីជូនដំណឹងដែលបានផ្តល់ទៅអ្នកធ្វើបិដ្ឋិលេខមុនបន្ទាប់ គឺជាការគ្រប់គ្រាន់ ។

បុគ្គលដែលត្រូវផ្តល់សេចក្តីជូនដំណឹង អាចធ្វើសេចក្តីជូនដំណឹងតាមរូបភាពណាមួយក៏បាន ទោះបីត្រឹមតែបញ្ជូនមូលប្បទានប័ត្រត្រឡប់វិញក៏ដោយ ។

បុគ្គលដែលត្រូវផ្តល់សេចក្តីជូនដំណឹងត្រូវបង្ហាញភស្តុតាងថា ខ្លួនបានជូនដំណឹងក្នុងរយៈពេលកំណត់ ។ រយៈពេលកំណត់នេះ នឹងត្រូវចាត់ទុកថាបានគោរពតាម បើលិខិតជូនដំណឹងត្រូវបានផ្ញើតាមប្រៃសណីយ៍ក្នុងរយៈពេលកំណត់នោះ ។

បុគ្គលដែលមិនបានផ្តល់សេចក្តីជូនដំណឹងក្នុងរយៈពេលកំណត់ខាងលើនេះ ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលកើតឡើងដោយការធ្វេសប្រហែសរបស់ខ្លួនបើមាន ប៉ុន្តែចំនួនប្រាក់ដែលទទួលខុសត្រូវមិនត្រូវលើសពីចំនួនប្រាក់នៃមូលប្បទានប័ត្រឡើយ ។

មាត្រា ៤៦.-

តាមរយៈបដិញ្ញាថា បង្វិលទិញដោយគ្មានសោហ៊ុយ ឬ បង្វិលទិញដោយគ្មានវិរុទ្ធវាទ ឬ សេចក្តីផ្សេងណាមួយដែលមានន័យដូចគ្នា ហើយដែលបានសរសេរនិងមានចុះហត្ថលេខានៅលើមូលប្បទានប័ត្រ បហារីក អ្នកធ្វើបិដ្ឋិលេខ ឬបិយបដិភោគីអាចឱ្យអ្នកកាន់មិនចាំបាច់ធ្វើវិរុទ្ធវាទឬប្រតិវេទន៍ដែលសមមូលគ្នា ដើម្បីអនុវត្តសិទ្ធិធ្វើឧបាស្រ័យ ។

បដិញ្ញានេះ មិនអាចឱ្យអ្នកកាន់រួចផុតពីការបង្ហាញមូលប្បទានប័ត្រនៅក្នុងរយៈពេលកំណត់ ឬ ពីការតម្រូវឱ្យមានរាល់សេចក្តីជូនដំណឹង បានឡើយ ។ សោហ៊ុយដែលកើតឡើងពីការបង្ហាញភស្តុតាងនៃការមិនគោរពតាមរយៈពេលកំណត់ដោយអ្នកកាន់ជាបន្ទុករបស់បុគ្គលដែលបានប្តឹងទល់នឹងអ្នកកាន់នោះ ។

បើបដិញ្ញាត្រូវបានសរសេរដោយបហារីក បដិញ្ញានេះត្រូវអនុវត្តបានទៅលើបុគ្គលទាំងឡាយដែលបានចុះហត្ថលេខាលើមូលប្បទានប័ត្រ ។ បើបដិញ្ញាត្រូវបានសរសេរដោយអ្នកធ្វើបិដ្ឋិលេខឬបិយបដិភោគី បដិញ្ញានោះត្រូវអនុវត្តបានចំពោះតែ

អ្នកធ្វើបិដ្ឋិលេខ ឬ រូបិយបដិភោគីនោះតែប៉ុណ្ណោះ ។ ទោះបីជាបដិញ្ញាសរសេរដោយបហារីកក្ដី បើអ្នកកាន់ធ្វើវិរុទ្ធវាទឬប្រតិវេទន៍ដែលសមមូលគ្នា អ្នកកាន់នេះត្រូវទទួលរ៉ាប់រងលើសោហ៊ុយទាំងអស់ដែលកើតមាន ។ កាលបើបដិញ្ញាកើតចេញអំពីអ្នកធ្វើបិដ្ឋិលេខ ឬ រូបិយបដិភោគី សោហ៊ុយនៃវិរុទ្ធវាទ ឬ នៃប្រតិវេទន៍ ដែលសមមូលគ្នា បើមាន អាចត្រូវបានទារពីបុគ្គលទាំងឡាយ ដែលបានចុះហត្ថលេខាលើមូលប្បទានប័ត្រ ។

មាត្រា ៤៧.-

រាល់បុគ្គលដែលជាប់ពាក់ព័ន្ធទៅនឹងមូលប្បទានប័ត្រមានកាតព្វកិច្ចទទួលខុសត្រូវរួមគ្នាចំពោះមុខអ្នកកាន់ ។

អ្នកកាន់មានសិទ្ធិប្ដឹងទល់នឹងបុគ្គលដែលជាប់ពាក់ព័ន្ធទៅនឹងមូលប្បទានប័ត្រជាឯកត្តជន ឬ រួមគ្នាដោយមិនគិតដល់លំដាប់លំដោយដែលបុគ្គលទាំងនេះចូលមកជាប់ពាក់ព័ន្ធឡើយ ។

សិទ្ធិដូចគ្នានេះត្រូវមានចំពោះបុគ្គលណា ដែលបានចុះហត្ថលេខាលើមូលប្បទានប័ត្រ ហើយបានទទួលយកមូលប្បទានប័ត្ររក្សាទុក និងបានទូទាត់សងប្រាក់ ។

រាល់ការប្ដឹងទល់នឹងភាគីមួយនៃភាគីពាក់ព័ន្ធទាំងឡាយ មិនរារាំងការប្ដឹងទល់នឹងបុគ្គលដទៃៗទៀតឡើយ ទោះបីបុគ្គលដទៃទាំងនេះទាក់ទិនបន្តបន្ទាប់ពីបុគ្គលដែលបានទទួលរងការប្ដឹងទីមួយនោះក៏ដោយ ។

មាត្រា ៤៨.-

អ្នកកាន់អាចទាមទារពីភាគីដែលខ្លួនបានអនុវត្តសិទ្ធិធ្វើឧបាស្រ័យនូវចំនួនប្រាក់ដែលមិនត្រូវបានទូទាត់សងការប្រាក់ ដែលគណនាតាមអត្រាកំណត់ដោយធនាគារជាតិនៃកម្ពុជា គិតពីថ្ងៃបង្ហាញឱ្យទូទាត់សងប្រាក់ និងសោហ៊ុយទាំងឡាយដែលកើតមាន ។

មាត្រា ៤៩.-

ភាគីដែលទទួលនិងទូទាត់សងមូលប្បទានប័ត្រ អាចទាមទារមកវិញពីភាគីទាំងឡាយដែលពាក់ព័ន្ធជាមួយនូវចំនួនប្រាក់ទាំងស្រុងដែលបានទូទាត់សង ការប្រាក់លើ

ចំនួនប្រាក់ដែលបានទូទាត់សង គណនាតាមអត្រាកំណត់ដោយធនាគារជាតិនៃកម្ពុជា គិតពីថ្ងៃដែលបានទូទាត់សងប្រាក់ និងសោហ៊ុយទាំងឡាយដែលកើតមាន ។

មាត្រា ៥០.-

ភាគីពាក់ព័ន្ធនីមួយៗដែលទទួលរងការអនុវត្តសិទ្ធិធ្វើឧបាស្រ័យអាចទាមទារ ដោយប្តូរនឹងការទូទាត់សងប្រាក់ឱ្យប្រគល់មកខ្លួននូវមូលប្បទានប័ត្ររួមជាមួយវិរុទ្ធ-វាទ ឬ ប្រតិវេទន៍ដែលសមមូលគ្នា និងបង្កាន់ដៃទទួលប្រាក់ ។

អ្នកធ្វើបិដ្ឋិលេខនីមួយៗ ដែលបានទទួលនិងបានទូទាត់សងមូលប្បទានប័ត្រអាចលុបចោលបិដ្ឋិលេខរបស់ខ្លួន និងរបស់អ្នកធ្វើបិដ្ឋិលេខបន្តបន្ទាប់តាមក្រោយបាន ។

មាត្រា ៥១.-

កាលបើការបង្ហាញមូលប្បទានប័ត្រឱ្យទូទាត់សងប្រាក់ ឬ វិរុទ្ធវាទ ឬ ប្រតិវេទន៍ដែលសមមូលគ្នាក្នុងរយៈពេលកំណត់ត្រូវបានរាំងស្ទះដោយឧបសគ្គមិនអាចឆ្លងផុតបាន ដែលជាករណីប្រធានស័ក្តិ រយៈពេលកំណត់នេះត្រូវបានពន្យារ ។

អ្នកកាន់មានកាតព្វកិច្ចផ្តល់សេចក្តីជូនដំណឹងភ្លាមអំពីករណីប្រធានស័ក្តិឱ្យទៅអ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន និងត្រូវធ្វើប្រតិវេទន៍អំពីសេចក្តីជូនដំណឹងនេះ ដោយចុះកាលបរិច្ឆេទ និងហត្ថលេខាលើមូលប្បទានប័ត្រ ឬ លើអនុប័ត្រ ។ ចំពោះប្រការផ្សេងៗទៀតត្រូវអនុវត្តទៅតាមមាត្រា ៤៥ នៃច្បាប់នេះ ។

នៅពេលដែលករណីប្រធានស័ក្តិបានចប់ អ្នកកាន់ត្រូវបង្ហាញមូលប្បទានប័ត្រភ្លាមដើម្បីឱ្យទូទាត់សងប្រាក់ ហើយបើចាំបាច់ត្រូវធ្វើវិរុទ្ធវាទ ឬ ធ្វើប្រតិវេទន៍ដែលសមមូលគ្នា ។

បើករណីប្រធានស័ក្តិនៅតែបន្តកើតមានលើសពីដប់ប្រាំ(១៥)ថ្ងៃ ក្រោយកាលបរិច្ឆេទដែលអ្នកកាន់បានជូនដំណឹងអំពីករណីប្រធានស័ក្តិនោះទៅអ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន ទោះបីនៅមុនផុតរយៈពេលកំណត់សម្រាប់បង្ហាញឱ្យទូទាត់សងប្រាក់ក្តី ឧបា-ស្រ័យអាចត្រូវបានធ្វើឡើង ហើយទាំងការបង្ហាញឱ្យទូទាត់សងប្រាក់ ទាំងការធ្វើវិរុទ្ធវាទ ឬ ប្រតិវេទន៍ដែលសមមូលគ្នាមិនចាំបាច់ធ្វើឡើយ ។

៩០/១២៥

រាល់អំពើដែលមានលក្ខណៈផ្ទាល់ខ្លួនសុទ្ធសាធរបស់អ្នកកាន់ ឬ របស់បុគ្គល ដែលបានទទួលសិទ្ធិក្នុងការបង្ហាញមូលប្បទានប័ត្រ ឬ ធ្វើវិរុទ្ធវាទ ឬ ធ្វើប្រតិវេទន៍ដែល សមមូលគ្នា មិនត្រូវបានចាត់ទុកជាករណីប្រធានស័ក្តិឡើយ ។

ការទទួលខុសត្រូវលើមូលប្បទានប័ត្រដែលត្រូវបានបាត់បង់ ឬ បំផ្លាញ អាច អនុវត្តបាន លុះណាតែមានការធានាពីភាគីអនុវត្តមូលប្បទានប័ត្រដែលសងការខូច ខាតទៅភាគីពាក់ព័ន្ធចំពោះការទាមទាររបស់បុគ្គលផ្សេងទៀតលើមូលប្បទានប័ត្រ តាមសេចក្តីសម្រេចរបស់តុលាការ បើអ្នកកាន់បានទទួលមូលប្បទានប័ត្រមកដោយ សុចរិត ។

## ផ្នែកទី ៧

## បេឡានិច័យមូលប្បទានប័ត្រ

**មាត្រា ៥២.-**

បេឡានិច័យមូលប្បទានប័ត្រ ត្រូវបានប្រព្រឹត្តទៅដូចខាងក្រោមនេះ :

១-កាលបើមូលប្បទានប័ត្រ ត្រូវបានប្រគល់ឱ្យធនាគារដើម្បីចុះឥណទាន គណនីអតិថិជនតាមចំនួនប្រាក់នៃមូលប្បទានប័ត្រ ធនាគារទទួលបានសិទ្ធិនិងអំណាច ទាំងអស់របស់អ្នកកាន់មូលប្បទានប័ត្រ ។

២-លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ ការចុះឥណទានគណនី នេះមានលក្ខណៈបណ្តោះអាសន្ន ហើយធនាគារអាចចុះឥណពន្ធគណនី ឬ ម្យ៉ាងទៀត អាចធ្វើឧបាស្រ័យទាមទារពីអតិថិជនវិញបាន បើមូលប្បទានប័ត្រមិនត្រូវបានទូទាត់ សងប្រាក់ទេនោះ ។ លើកលែងតែបានព្រមព្រៀងផ្សេងពីនេះ ការដកប្រាក់ចេញពី គណនីឥណទានបណ្តោះអាសន្នអាចធ្វើបាន លុះណាតែមានការសម្រេចរបស់ធនាគារ តែប៉ុណ្ណោះ និងជាកម្មវត្ថុនៃការសងវិញ ឬ ការធ្វើឧបាស្រ័យពីអតិថិជន បើមូលប្បទាន ប័ត្រមិនត្រូវបានទូទាត់សងប្រាក់ទេ ។

៣-ដោយមិនគិតដល់ការខ្វះខាត ការខុសឆ្គង ការរឹតត្បិតឬការកម្រិត ឬ ទម្រង់ ឬ ប្រភេទនៃបិដ្ឋិលេខរបស់អតិថិជន សិទ្ធិរបស់ធនាគារក្រោមកថាខណ្ឌទី ១ នៃមាត្រានេះ គឺជាម្ចាស់នៃមូលប្បទានប័ត្រដែលអាចធ្វើបិដ្ឋិលេខបានអនុលោមតាម មាត្រា ២២ ទោះបីមានមាត្រា ២៦ នៃច្បាប់នេះ ដែលអនុវត្តផ្សេងពីនេះក៏ដោយ ។

មាត្រា ៥៣.-

នៅពេលដែលមូលប្បទានប័ត្រ ត្រូវបានបង្ហាញឱ្យធនាគារធ្វើបេឡានិច័យ មូលប្បទានប័ត្រនោះជាបញ្ជាទូទាត់ដែលគ្រប់គ្រងដោយជំពូកទី ៥ ស្ដីពីប្រតិបត្តិការទូទាត់សងប្រាក់នៃច្បាប់នេះ ។ ក្នុងករណីមិនមានសង្គតិភាពអំពីមូលប្បទានប័ត្ររវាងបទប្បញ្ញត្តិនៃជំពូកនេះ និងជំពូកទី ៥ នៃច្បាប់នេះ បទប្បញ្ញត្តិនៃជំពូកនេះត្រូវយកជាបានការ ។

## ផ្នែកទី ៨
## ការកែលើមូលប្បទានប័ត្រ

មាត្រា ៥៤.-

ក្នុងករណីមានការកែលើខ្លឹមសារនៃមូលប្បទានប័ត្រ រាល់ភាគីដែលបានចុះហត្ថលេខាបន្ទាប់ពីការកែនោះ ត្រូវជាប់ពាក់ព័ន្ធទៅតាមខ្លឹមសារដែលបានកែ ។ ភាគីទាំងឡាយដែលបានចុះហត្ថលេខាមុនការកែ ត្រូវជាប់ពាក់ព័ន្ធទៅតាមខ្លឹមសារដើមនៃមូលប្បទានប័ត្រ ។

## ផ្នែកទី ៩
## រយៈពេលកំណត់នៃការធ្វើឧបាស្រ័យ

មាត្រា ៥៥.-

រាល់ការធ្វើឧបាស្រ័យ ដោយអ្នកកាន់ទល់នឹងអ្នកធ្វើបិដ្ឋិលេខទាំងឡាយ បហារីក និងភាគីពាក់ព័ន្ធដទៃៗទៀត មានរយៈពេលប្រាំមួយ(០៦)ខែ បន្ទាប់ពីការផុតកំណត់រយៈពេលបង្ហាញឱ្យទូទាត់សងប្រាក់ ។

រាល់ការធ្វើឧបាស្រ័យដោយភាគីពាក់ព័ន្ធដទៃៗទៀតអំពីការទូទាត់សងមូលប្បទានប័ត្រទល់នឹងភាគីជាប់ពាក់ព័ន្ធផងគ្នា មានរយៈពេលប្រាំមួយ(០៦)ខែ គិតពីថ្ងៃដែលភាគីពាក់ព័ន្ធបានទូទាត់សងមូលប្បទានប័ត្រ ឬ បានទទួលរងការប្ដឹង ។

៥៤/១២៨

មាត្រា ៥៦.-

ការកំណត់រយៈពេលធ្វើឱ្យបាត់ស្រ័យដូចមានចែងក្នុងមាត្រា ៥៥ នៃច្បាប់នេះមានសុពលភាពទៅលើតែបុគ្គលណាមួយ ដែលរយៈពេលនោះត្រូវបានកំណត់ប៉ុណ្ណោះ ។

## ជំពូកទី ១០
## ការគណនារយៈពេលកំណត់

មាត្រា ៥៧.-

ការបង្ហាញមូលប្បទានប័ត្រឱ្យទូទាត់សងប្រាក់ ឬ ការធ្វើវិរុទ្ធវាទអាចប្រព្រឹត្តទៅបាននៅក្នុងថ្ងៃធ្វើការតែប៉ុណ្ណោះ ។

កាលបើថ្ងៃចុងក្រោយនៃរយៈពេលដែលបានកំណត់ ដើម្បីអនុវត្តសកម្មភាពណាមួយទាក់ទងទៅនឹងមូលប្បទានប័ត្រ ជាពិសេសចំពោះការបង្ហាញឱ្យទូទាត់សងប្រាក់ ឬ ការធ្វើវិរុទ្ធវាទ ឬ ប្រតិវេទន៍ដែលសមមូលគ្នាត្រូវចំថ្ងៃឈប់សម្រាកជាផ្លូវការ រយៈពេលកំណត់នេះត្រូវបានពន្យាររហូតដល់ថ្ងៃធ្វើការទីមួយបន្ទាប់ពីផុតរយៈពេលកំណត់ ។ ថ្ងៃឈប់សម្រាកក៏ត្រូវបានរាប់បញ្ចូលទៅក្នុងការគណនារយៈពេលកំណត់ទាំងនោះផងដែរ ។

មាត្រា ៥៨.-

រយៈពេលកំណត់ទាំងឡាយដែលចែងក្នុងជំពូកនេះនឹងមិនរាប់បញ្ចូលផងទេនូវថ្ងៃដែលរយៈពេលនោះចាប់ផ្តើម ។

មាត្រា ៥៩.-

ទោះបីតាមផ្លូវច្បាប់ក្តី ឬ តាមផ្លូវតុលាការក្តី ពុំអនុញ្ញាតឱ្យមានរយៈពេលអនុគ្រោះឡើយ ។

# ជំពូកទី ៣

# រូបិយាណត្តិ

## ផ្នែកទី ១

## ការចេញផ្សាយនិងទម្រង់នៃរូបិយាណត្តិ

មាត្រា ៦០.-

រូបិយាណត្តិជាបញ្ជាលាយលក្ខណ៍អក្សរដោយឥតល័ក្ខខ័ណ្ឌ ចេញដោយបុគ្គលមួយឱ្យទៅបុគ្គលផងទៃ ចុះហត្ថលេខាដោយបុគ្គលជាអ្នកចេញបញ្ជា តម្រូវឱ្យបុគ្គលជាអ្នកទទួលបញ្ជាទូទាត់សងចំនួនប្រាក់ជាកំណត់មួយឱ្យទៅ ឬ តាមបញ្ជាបុគ្គលមួយទៀត ឬ អ្នកកាន់ ។ រូបិយាណត្តិត្រូវតែបានទូទាត់សងប្រាក់នៅពេលដល់ឥណប្រតិទាន ហើយស្របតាមរាល់កាតព្វកិច្ចដែលមានចែងក្នុងជំពូកនេះ ។

មាត្រា ៦១.-

រូបិយាណត្តិជាឧបករណ៍ឥណទាន ។ រូបិយាណត្តិអាចត្រូវបានសរសេរជាអក្សរខ្មែរ ឬអក្សរបរទេស ហើយត្រូវតែមាននិទ្ទេសទាំងឡាយដូចខាងក្រោម :

-ពាក្យថា រូបិយាណត្តិ ដែលចារឹកជាភាសាណាមួយប្រើក្នុងការចេញឧបករណ៍នេះ

-បញ្ជាដោយឥតល័ក្ខខ័ណ្ឌឱ្យទូទាត់សងនូវចំនួនប្រាក់ជាកំណត់មួយ

-ឈ្មោះរបស់បហារិតដែលជាបុគ្គលត្រូវទូទាត់សងប្រាក់

-រយៈពេលកំណត់ត្រូវទូទាត់សងប្រាក់

-កន្លែងដែលត្រូវធ្វើការទូទាត់សងប្រាក់

-ឈ្មោះរបស់បុគ្គលដែលទទួលការទូទាត់សងប្រាក់ ឬ ឈ្មោះរបស់បុគ្គលដែលមានបញ្ជាឱ្យទូទាត់សងប្រាក់ចំពោះខ្លួន

-កាលបរិច្ឆេទ និងកន្លែង ដែលរូបិយាណត្តិត្រូវបានចេញផ្សាយ

-ហត្ថលេខារបស់បហារីកដែលជាបុគ្គលចេញបញ្ជាលើរូបិយាណត្តិ ។

មាត្រា ៦២.-

ឧបករណ៍ដែលខ្វះនិទ្ទេសណាមួយដូចមានចែងនៅក្នុងមាត្រា ៦១ នៃច្បាប់នេះ ពុំមានសុពលភាពជារូបិយាណត្តិឡើយ លើកលែងតែក្នុងករណីទាំងឡាយដែលបញ្ជាក់នៅក្នុងកថាខណ្ឌដូចខាងក្រោម :

១-រូបិយាណត្តិ ដែលមិនបានបញ្ជាក់រយៈពេលកំណត់ទូទាត់សងប្រាក់ ត្រូវបានចាត់ទុកថាត្រូវទូទាត់សងប្រាក់នៅពេលបង្ហាញ ។

២-បើគ្មានការបញ្ជាក់ជាពិសេសទេ កន្លែងដែលបញ្ជាក់នៅក្បែរឈ្មោះរបស់បហារិតត្រូវបានចាត់ទុកថាជាកន្លែងត្រូវទូទាត់សងប្រាក់ និងជាលំនៅរបស់បហារិកផងដែរ ។

៣-រូបិយាណត្តិ ដែលមិនបានបញ្ជាក់ច្បាស់នូវកន្លែងនៃការចេញផ្សាយ ត្រូវបានចាត់ទុកថាចេញ នៅកន្លែងដែលបញ្ជាក់នៅក្បែរឈ្មោះរបស់បហារីក ។

៤-រូបិយាណត្តិអាចត្រូវចេញឱ្យទូទាត់សងប្រាក់ទៅអ្នកកាន់បាន ។ រូបិយាណត្តិដែលគ្មានឈ្មោះបុគ្គលដែលទទួលការទូទាត់សងប្រាក់ ឬ ឈ្មោះបុគ្គលដែលមានបញ្ជាឱ្យទូទាត់សងប្រាក់ចំពោះខ្លួន ត្រូវបានចាត់ទុកថាជារូបិយាណត្តិទូទាត់សងប្រាក់ឱ្យទៅអ្នកកាន់ ។

មាត្រា ៦៣.-

រូបិយាណត្តិ អាចត្រូវបានចេញឱ្យទូទាត់សងប្រាក់តាមបញ្ជារបស់បហារីក ។ រូបិយាណត្តិអាចត្រូវបានចេញទៅលើបហារីកខ្លួនឯងផ្ទាល់ ឬ ជាប្រយោជន៍ដល់តតិយបុគ្គល ។

មាត្រា ៦៤.-

រូបិយាណត្តិ អាចត្រូវបានទូទាត់សងប្រាក់នៅលំនៅរបស់តតិយបុគ្គល នៅលំនៅរបស់បហារិត ឬ នៅកន្លែងផ្សេងទៀត ។

មាត្រា ៦៥.-

ចំពោះប្រភេទរូបិយាណត្តិដែលត្រូវទូទាត់សងប្រាក់នៅពេលបង្ហាញ ឬ ត្រូវទូទាត់សងប្រាក់ នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ បហារីកអាចចែងល័ក្ខ-

ចំណុចថាចំនួនប្រាក់ទូទាត់សងត្រូវមានការប្រាក់ ។ ក្នុងករណីនៃរូបិយាណត្តិផ្សេងពីខាងលើ បដិញ្ញានេះមិនត្រូវចាត់ទុកជាបានការឡើយ ។

អត្រាការប្រាក់ ត្រូវតែបានបញ្ជាក់នៅលើរូបិយាណត្តិ ។ បើគ្មានសេចក្តីបញ្ជាក់នេះទេ បដិញ្ញាខាងលើនេះមិនត្រូវចាត់ទុកជាបានការឡើយ ។

ការប្រាក់ត្រូវបានគណនាចាប់ពីកាលបរិច្ឆេទចេញផ្សាយរូបិយាណត្តិ លើកលែងតែមានការបញ្ជាក់ពីកាលបរិច្ឆេទផ្សេងទៀត ។

មាត្រា ៦៦.-

ក្នុងករណីដែលចំនួនប្រាក់ត្រូវទូទាត់សងដោយរូបិយាណត្តិ ត្រូវបានសរសេរជាតួអក្សរផង និងជាតួលេខផង ហើយកាលបើមានលំអៀងគ្នា ចំនួនប្រាក់ជាតួអក្សរ ជាចំនួនដែលត្រូវយកជាបានការ ។

ក្នុងករណីដែលចំនួនប្រាក់ត្រូវទូទាត់សងដោយរូបិយាណត្តិ ត្រូវបានសរសេរច្រើនដងជាតួអក្សរ ឬ ជាតួលេខ ហើយកាលបើមានចំនួនលំអៀងគ្នាចំនួនប្រាក់ដែលតូចជាងជាចំនួនត្រូវយកជាបានការ ។

មាត្រា ៦៧.-

រាល់កាតព្វកិច្ចនៃបុគ្គលដទៃៗទៀត ដែលបានចុះហត្ថលេខាលើរូបិយាណត្តិនៅតែមានតម្លៃដដែល ទោះបីរូបិយាណត្តិនោះមានហត្ថលេខារបស់បុគ្គលអសមត្ថភាព ឬ ហត្ថលេខាក្លែងបន្លំ ឬ ហត្ថលេខារបស់បុគ្គលតាមការប្រឌិត ឬ ហត្ថលេខាដែលតាមហេតុផលផ្សេងទៀត មិនអាចធ្វើឱ្យបុគ្គលដែលបានចុះហត្ថលេខា ឬ បានចុះហត្ថ-លេខាជំនួសមានការទទួលខុសត្រូវ ។

មាត្រា ៦៨.-

បុគ្គលណា ដែលបានចុះហត្ថលេខានៅលើរូបិយាណត្តិក្នុងនាមបុគ្គលមួយទៀតដែលខ្លួនគ្មានសិទ្ធិតំណាងឱ្យទាល់តែសោះ ត្រូវមានការពាក់ព័ន្ធផ្ទាល់ជាភាគីមួយលើរូបិយាណត្តិនោះ ហើយបើខ្លួនបានទូទាត់សងប្រាក់ត្រូវមានសិទ្ធិដូចគ្នានឹងបុគ្គលដែលខ្លួនបានទទួលភ៉ារប់រងជួសឱ្យ ។ វិធានដូចគ្នានេះក៏អនុវត្តទៅលើអាណត្តិជនដែលបានអនុវត្តហួសសិទ្ធិរបស់ខ្លួនផងដែរ ។

មាត្រា ៦៩.-

បហារីកធានាលើស្វីការនិងការទូទាត់សងប្រាក់ ។

បហារីកអាចរួចផុតពីការទទួលខុសត្រូវលើស្វីការ ប៉ុន្តែមិនអាចរួចផុតពីការទទួលខុសត្រូវលើការទូទាត់សងប្រាក់ឡើយ ។

មាត្រា ៧០.-

បើរូបិយាណត្តិ មានលក្ខណៈមិនពេញលេញនៅពេលចេញផ្សាយ ហើយត្រូវបានធ្វើឱ្យពេញលក្ខណៈតាមបែបផ្សេងខុសពីការព្រមព្រៀងដែលពាក់ព័ន្ធ ការមិនគោរពតាមការព្រមព្រៀងនេះ មិនអាចយកជាមូលហេតុប្តឹងអ្នកកាន់បានឡើយ លើកលែងតែអ្នកកាន់នេះបានទទួលរូបិយាណត្តិមកដោយទុច្ចរិត ឬ មានកំហុសដោយការធ្វេសប្រហែសធ្ងន់ធ្ងរ ។

## ផ្នែកទី ២
## បិដ្ឋិលេខរូបិយាណត្តិ

មាត្រា ៧១.-

រូបិយាណត្តិដែលចេញឱ្យទូទាត់សងប្រាក់ចំពោះបុគ្គលណាមួយច្បាស់លាស់ដោយមាន ឬ គ្មានបញ្ជាក់ពាក្យថា **សងតាមបញ្ជា** អាចត្រូវបានផ្ទេរដោយបិដ្ឋិលេខ ។

នៅពេលដែលបហារីកបានបញ្ចូលក្នុងរូបិយាណត្តិ ដែលចេញឱ្យទូទាត់សងប្រាក់ចំពោះបុគ្គលណាមួយច្បាស់លាស់នូវពាក្យ **មិនសងតាមបញ្ជា** ឬ ពាក្យដែលមានន័យដូចគ្នា រូបិយាណត្តិនោះអាចត្រូវបានផ្ទេរស្របតាមទម្រង់ និងមានសុពលភាពជាការផ្ទេរធម្មតាតែប៉ុណ្ណោះ ។

រូបិយាណត្តិអាចត្រូវបានធ្វើបិដ្ឋិលេខ ទោះបីឱ្យទៅបហារិតក្តី ឬ ឱ្យទៅភាគីណាមួយផ្សេងទៀតនៃរូបិយាណត្តិនោះក្តី ។ បុគ្គលទាំងនេះ អាចធ្វើបិដ្ឋិលេខរូបិយាណត្តិនោះបន្តទៀតបាន ។

មាត្រា ៧២.-

បិដ្ឋិលេខត្រូវតែបានធ្វើឡើងដោយឥតល័ក្ខខ័ណ្ឌ ។ ល័ក្ខខ័ណ្ឌណាមួយដែលត្រូវបានដាក់ចេញជាកម្មវត្ថុចំពោះការធ្វើបិដ្ឋិលេខរូបិយាណត្តិ មិនត្រូវយកជាបានការឡើយ ។

បិដ្ឋិលេខលើមួយផ្នែកនៃចំនួនប្រាក់ក្នុងរូបិយាណត្តិ ត្រូវចាត់ទុកជាមោឃៈ ។

បិដ្ឋិលេខដែលធ្វើឱ្យអ្នកកាន់ មានតម្លៃស្មើនឹងបិដ្ឋិលេខចំហ ។

មាត្រា ៧៣.-

បិដ្ឋិលេខត្រូវតែបានធ្វើជាលាយលក្ខណ៍អក្សរ នៅលើខ្នងរូបិយាណត្តិ ឬ នៅលើក្រដាសបិទភ្ជាប់បន្ថែមហៅថា អនុបំគ្រ ហើយត្រូវតែបានចុះហត្ថលេខាដោយអ្នកធ្វើបិដ្ឋិលេខ ។

បិដ្ឋិលេខអាចមិនបញ្ជាក់ពីអត្ថគាហក ឬ អាចមានតែហត្ថលេខារបស់អ្នកធ្វើបិដ្ឋិ-លេខប៉ុណ្ណោះ ហៅថា **បិដ្ឋិលេខចំហ** ។

មាត្រា ៧៤.-

បិដ្ឋិលេខផ្ទេរសិទ្ធិទាំងអស់នៃរូបិយាណត្តិឱ្យទៅអ្នកកាន់ ។

បើជាបិដ្ឋិលេខចំហ អ្នកកាន់អាច :

-បំពេញកន្លែងចំហ ឬ ដោយឈ្មោះរបស់ខ្លួនផ្ទាល់ ឬ ដោយឈ្មោះរបស់បុគ្គលដទៃទៀត

-ធ្វើបិដ្ឋិលេខបន្តរូបិយាណត្តិជាចំហ ឬ ឱ្យបុគ្គលដទៃទៀត

-ផ្ទេររូបិយាណត្តិឱ្យទៅតតិយបុគ្គល ដោយមិនចាំបាច់បំពេញកន្លែងចំហ និងមិនចាំបាច់ធ្វើបិដ្ឋិលេខ ។

មាត្រា ៧៥.-

បើគ្មានបដិញ្ញាផ្ទុយទេ អ្នកធ្វើបិដ្ឋិលេខត្រូវទទួលខុសត្រូវលើការទូទាត់សងប្រាក់ ។

អ្នកធ្វើបិដ្ឋិលេខ អាចហាមឃាត់ការធ្វើបិដ្ឋិលេខណាមួយបន្តទៀតបាន ហើយក្នុងករណីនេះ បុគ្គលដែលបានហាមឃាត់ មិនទទួលខុសត្រូវចំពោះការទូទាត់សងប្រាក់ទៅបុគ្គលទាំងឡាយណា ដែលរូបិយាណត្តិត្រូវបានធ្វើបិដ្ឋិលេខបន្តឱ្យទៅនោះឡើយ ។

បិដ្ឋិលេខលើរូបិយាណត្តិចំពោះអ្នកកាន់ នាំឱ្យអ្នកធ្វើបិដ្ឋិលេខមានការទទួលខុសត្រូវស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិធ្វើឧបាស្រ័យ ប៉ុន្តែរូបិយាណត្តិនោះមិនអាចប្រែក្លាយទៅជារូបិយាណត្តិសងតាមបញ្ជា បានឡើយ ។

មាត្រា ៧៦.-

ម្ចាស់រូបិយាណត្តិដែលអាចធ្វើបិដ្ឋិលេខបានជាអ្នកកាន់ស្របច្បាប់ បើបុគ្គលនេះបានក្លាយជាម្ចាស់រូបិយាណត្តិតាមរយៈការធ្វើបិដ្ឋិលេខជាបន្តបន្ទាប់ ទោះបីបិដ្ឋិលេខចុងក្រោយជាបិដ្ឋិលេខចំហក៏ដោយ ។ ក្នុងករណីនេះ បិដ្ឋិលេខដែលលុបចោលមិនត្រូវយកជាបានការឡើយ ។ កាលបើបិដ្ឋិលេខចំហត្រូវបានបន្តដោយបិដ្ឋិលេខមួយទៀត បុគ្គលដែលចុះហត្ថលេខាធ្វើបិដ្ឋិលេខចុងក្រោយនេះ ត្រូវបានចាត់ទុកថាបានទទួលរូបិយាណត្តិតាមរយៈបិដ្ឋិលេខចំហ ។

នៅពេលដែលបុគ្គលណាមួយ បានបាត់បង់សិទ្ធិកាន់កាប់រូបិយាណត្តិដោយមូលហេតុណាក៏ដោយ ទោះបីជារូបិយាណត្តិចេញផ្សាយឱ្យទៅអ្នកកាន់ក្តី ឬ អាចធ្វើបិដ្ឋិលេខបានក្តី ដែលអ្នកកាន់មានសិទ្ធិជាម្ចាស់ដូចមានចែងនៅក្នុងកថាខណ្ឌខាងលើនៃមាត្រានេះ អ្នកកាន់ដែលទទួលបានរូបិយាណត្តិមកជាកម្មសិទ្ធិ មិនត្រូវបានបង្ខំឱ្យបោះបង់ចោលរូបិយាណត្តិឡើយ លើកលែងតែរូបិយាណត្តិនោះបានមកដោយទុច្ចរិត ឬ ដោយមានកំហុសពីការធ្វេសប្រហែសធ្ងន់ធ្ងរ ។

មាត្រា ៧៧.-

បុគ្គលទាំងឡាយដែលប្តឹងអំពីរូបិយាណត្តិ មិនអាចប្តឹងអ្នកកាន់ដោយសំអាងលើទំនាក់ទំនងផ្ទាល់ខ្លួនជាមួយបហារីក ឬ ជាមួយអ្នកកាន់មុនៗបានឡើយ លើកលែងតែក្នុងការទទួលរូបិយាណត្តិ អ្នកកាន់បានដឹងច្បាស់ថានឹងនាំឱ្យខូចប្រយោជន៍ដល់កូនបំណុល ។

កថាខណ្ឌខាងលើនៃមាត្រានេះ មិនអនុវត្តចំពោះរូបិយាណត្តិដែលចេញផ្សាយ ដើម្បីទូទាត់សងប្រាក់ទៅបុគ្គលណាមួយច្បាស់លាស់ ដែលក្នុងនោះមានពាក្យថា មិនសងតាមបញ្ជា ឬ ប្រយោគណាមួយ ដែលមានន័យដូចគ្នាបានឡើយ ។

មាត្រា ៧៨.-

កាលបើបិដ្ឋិលេខមានពាក្យថា តម្លៃសម្រាប់ទារបំណុល ឬ សម្រាប់បេឡានិច័យ ឬ តាមការប្រគល់សិទ្ធិ ឬ ប្រយោគណាមួយផ្សេងទៀត ដែលបញ្ជាក់ពីការប្រគល់សិទ្ធិសាមញ្ញ អ្នកកាន់អាចអនុវត្តសិទ្ធិទាំងអស់នៃរូបិយាណត្តិនោះបាន ប៉ុន្តែអ្នកកាន់នេះអាចធ្វើបិដ្ឋិលេខបន្តបានក្នុងនាមជាភ្នាក់ងារតែប៉ុណ្ណោះ ។

ក្នុងករណីនេះ ភាគីពាក់ព័ន្ធទាំងឡាយអាចប្តឹងអ្នកកាន់បាន ហើយអ្នកកាន់នេះក៏អាចប្តឹងអ្នកធ្វើបិដ្ឋិលេខបានដែរ ។

ការប្រគល់សិទ្ធិដែលមាននៅក្នុងបិដ្ឋិលេខ មិនអាចរលត់បានដោយហេតុផលនៃមរណភាពរបស់ភាគីដែលបានផ្តល់ការប្រគល់សិទ្ធិ ឬ ដោយហេតុផលដែលបុគ្គលនេះបានក្លាយជាអសមត្ថភាពនីត្យានុកូលឡើយ ។

នៅពេលដែលរូបិយាណត្តិត្រូវបានបង្ហាញឱ្យធនាគារធ្វើបេឡានិច័យ រូបិយាណត្តិនោះជាបញ្ជាទូទាត់ដែលគ្រប់គ្រងដោយជំពូកទី ៥ ស្តីពីប្រតិបត្តិការទូទាត់សងប្រាក់នៃច្បាប់នេះ ។ ក្នុងករណីមិនមានសង្គតិភាពអំពីរូបិយាណត្តិរវាងបទប្បញ្ញត្តិនៃជំពូកនេះនិងជំពូកទី ៥ នៃច្បាប់នេះ បទប្បញ្ញត្តិនៃជំពូកនេះត្រូវយកជាបានការ ។

មាត្រា ៧៩.-

កាលបើបិដ្ឋិលេខមួយមានសេចក្តីបញ្ជាក់ថា តម្លៃសម្រាប់ធានា ឬ តម្លៃសម្រាប់ដាក់បញ្ចាំ ឬ សេចក្តីបញ្ជាក់ណាផ្សេងទៀត ដែលមានន័យថាសម្រាប់ដាក់បញ្ចាំ អ្នកកាន់អាចអនុវត្តសិទ្ធិទាំងអស់នៃរូបិយាណត្តិនោះបាន ប៉ុន្តែបិដ្ឋិលេខដែលខ្លួនបានធ្វើឡើង មានប្រសិទ្ធភាពត្រឹមតែជាបិដ្ឋិលេខដោយភ្នាក់ងារតែប៉ុណ្ណោះ ។

បណ្តាភាគីដែលពាក់ព័ន្ធមិនអាចប្តឹងអ្នកកាន់ ដោយសំអាងលើទំនាក់ទំនងផ្ទាល់ជាមួយអ្នកធ្វើបិដ្ឋិលេខបានឡើយ លើកលែងតែក្នុងការទទួលរូបិយាណត្តិ អ្នកកាន់បានដឹងច្បាស់ថានឹងនាំឱ្យខូចប្រយោជន៍ដល់កូនបំណុល ។

មាត្រា ៨០.-

បិទ្ធិលេខដែលធ្វើឡើងក្រោយពីវិរុទ្ធវាទ ឬ ក្រោយពីការធ្វើប្រតិវេទន៍ដែលសមមូលគ្នា ឬ ក្រោយពីផុតរយៈពេលកំណត់សម្រាប់បង្ហាញឱ្យទូទាត់សងប្រាក់អាចនឹង :

-អនុវត្តបានតាមការផ្ទេរធម្មតាតែប៉ុណ្ណោះ

-មិនអនុវត្តក្នុងការផ្តល់សិទ្ធិក្រោមមាត្រា ៧៦ និងមាត្រា ៧៧ នៃច្បាប់នេះឡើយ ។

បើគ្មានភស្តុតាងផ្ទុយទេ បិទ្ធិលេខដែលគ្មានចុះកាលបរិច្ឆេទ ត្រូវចាត់ទុកថាបានធ្វើនៅលើរូបិយាណត្តិមុនពេលធ្វើវិរុទ្ធវាទឬប្រតិវេទន៍ដែលសមមូលគ្នា ឬ មុនផុតរយៈពេលកំណត់ដែលបានយោងក្នុងកថាខណ្ឌខាងលើនៃមាត្រានេះ ។

## ផ្នែកទី ៣
## ស្ទីការរូបិយាណត្តិ

មាត្រា ៨១.-

រហូតដល់ពេលឥណប្រតិទាន អ្នកកាន់ ឬ បុគ្គលដែលមានរូបិយាណត្តិ អាចបង្ហាញរូបិយាណត្តិបាននៅលំនៅរបស់បហារិតដើម្បីឱ្យធ្វើស្ទីការ ។

មាត្រា ៨២.-

ចំពោះប្រភេទរូបិយាណត្តិណាក៏ដោយ បហារិកអាចចែងល័ក្ខខ័ណ្ឌថា រូបិយាណត្តិនោះ ត្រូវបានបង្ហាញឱ្យធ្វើស្ទីការដោយមាន ឬ ដោយគ្មានកំណត់ពេល ។

បហារិកអាចហាមឃាត់ការបង្ហាញឱ្យធ្វើស្ទីការបាន លើកលែងតែក្នុងករណីដែលរូបិយាណត្តិត្រូវទូទាត់សងប្រាក់ នៅអាសយដ្ឋានរបស់តតិយភាគី ឬ នៅកន្លែងផ្សេងទៀត ក្រៅពីលំនៅរបស់បហារិត ឬ លើកលែងតែក្នុងករណីដែលរូបិយាណត្តិត្រូវបានចេញឱ្យទូទាត់សងប្រាក់នៅពេលកំណត់មួយក្រោយការបង្ហាញ ។

បហារិកក៏អាចចែងល័ក្ខខ័ណ្ឌថា ការបង្ហាញឱ្យធ្វើស្ទីការនេះមិនប្រព្រឹត្តទៅនៅមុនកាលបរិច្ឆេទដែលបានកំណត់នោះឡើយ ។

ន៍

អ្នកធ្វើបិដ្ឋិលេខនីមួយៗអាចចែងល័ក្ខខ័ណ្ឌថា រូបិយាណត្តិត្រូវបានបង្ហាញឱ្យធ្វើស៊ីការដោយមាន ឬ ដោយគ្មានរយៈពេលកំណត់ លើកលែងតែបហារីកបានហាមឃាត់ការធ្វើស៊ីការនោះរួចហើយ ។

មាត្រា ៨៣.-

រូបិយាណត្តិទាំងឡាយដែលត្រូវទូទាត់សងប្រាក់នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ ត្រូវតែបានបង្ហាញឱ្យធ្វើស៊ីការនៅក្នុងរយៈពេលមួយ(០១)ឆ្នាំ គិតពីកាលបរិច្ឆេទចេញផ្សាយ ។

បហារីកអាចបង្រួញ ឬ ពន្យាររយៈពេលកំណត់នេះ ។

រយៈពេលកំណត់ទាំងនេះ ក៏អាចត្រូវបានបង្រួញដោយអ្នកធ្វើបិដ្ឋិលេខទាំងឡាយផងដែរ ។

មាត្រា ៨៤.-

បហារិតអាចស្នើសុំឱ្យធ្វើការបង្ហាញរូបិយាណត្តិបានជាលើកទីពីរនៅថ្ងៃបន្ទាប់ពីការបង្ហាញលើកទីមួយ ។ ភាគីទាំងឡាយដែលពាក់ព័ន្ធមិនអាចតវ៉ាថា ការស្នើសុំនេះមិនត្រូវអនុវត្តតាមនោះបានឡើយ លើកលែងតែការស្នើសុំនេះត្រូវបានចែងនៅក្នុងវិរុទ្ធវាទ ។

អ្នកកាន់មិនត្រូវប្រគល់ឱ្យទៅបហារិតនូវរូបិយាណត្តិដែលបង្ហាញឱ្យធ្វើស៊ីការឡើយ ។

មាត្រា ៨៥.-

ស៊ីការត្រូវបានសរសេរនៅលើរូបិយាណត្តិដោយប្រើពាក្យថា ធានះធ្វើស៊ីការះ ឬ ពាក្យផ្សេងទៀតដែលមានន័យដូចគ្នា ហើយត្រូវចុះហត្ថលេខាដោយបហារិត ។ ហត្ថលេខាសាមញ្ញរបស់បហារិតនៅខាងមុខនៃរូបិយាណត្តិបង្កើតបានជាស៊ីការ ។

កាលបើរូបិយាណត្តិ ត្រូវទូទាត់សងប្រាក់ក្នុងរយៈពេលណាមួយក្រោយការបង្ហាញ ឬ ត្រូវតែបានបង្ហាញឱ្យធ្វើស៊ីការនៅក្នុងរយៈពេលកំណត់ណាមួយដោយអនុលោមតាមបដិញ្ញាពិសេស ស៊ីការនោះត្រូវតែបានចុះកាលបរិច្ឆេទនៅថ្ងៃដែលបានធ្វើ លើកលែងតែអ្នកកាន់ទាមទារថា ថ្ងៃនោះជាថ្ងៃបង្ហាញឱ្យទូទាត់សងប្រាក់ ។ បើស៊ីការនោះគ្មាន

ចុះកាលបរិច្ឆេទទេ អ្នកកាន់ ដើម្បីរក្សាសិទ្ធិឧបាស្រ័យទល់នឹងអ្នកធ្វើបិដ្ឋិលេខ និងទល់នឹងបហារីកត្រូវធ្វើឱ្យស្របច្បាប់ចំពោះកំហុសភ្លេចភ្លាំងនោះ ដោយវិរុទ្ធវាទដែលធ្វើឡើងនៅក្នុងពេលវេលាសមស្រប ។

មាត្រា ៨៦.-

ស្ទីការពុំមានល័ក្ខខ័ណ្ឌទេ ប៉ុន្តែបហារិតអាចទាមទារការធ្វើស្ទីការទៅលើតែមួយផ្នែកនៃចំនួនប្រាក់ដែលត្រូវទូទាត់សង ។

រាល់ការកែប្រែផ្សេងទៀត ដែលអ្នកធ្វើស្ទីការបានធ្វើលើខ្លឹមសារនៃរូបិយាណត្តិ គឺជាការបដិសេធមិនធ្វើស្ទីការ ។ ប៉ុន្តែអ្នកធ្វើស្ទីការត្រូវទទួលខុសត្រូវស្របតាមខ្លឹមសារនៃស្ទីការដែលខ្លួនបានកែប្រែ ។

មាត្រា ៨៧.-

កាលបើបហារីកនៃរូបិយាណត្តិបានបញ្ជាក់កន្លែងទូទាត់សងប្រាក់ក្រៅពីលំនៅរបស់បហារិត ដោយគ្មានបញ្ជាក់ពីអាសយដ្ឋានរបស់តតិយភាគីដែលជាកន្លែងត្រូវទូទាត់សងប្រាក់ បហារិតអាចបញ្ជាក់ឈ្មោះតតិយភាគីនេះនៅក្នុងពេលធ្វើស្ទីការតែម្តង ។ បើគ្មានសេចក្តីបញ្ជាក់នេះទេ អ្នកធ្វើស្ទីការត្រូវបានចាត់ទុកថាបានយល់ព្រមទូទាត់សងរូបិយាណត្តិនោះដោយខ្លួនឯងនៅកន្លែងទូទាត់សងប្រាក់ ។

បើរូបិយាណត្តិត្រូវបានទូទាត់សងនៅលំនៅរបស់បហារិត អាសយដ្ឋានដែលជាកន្លែងជាមួយគ្នានឹងកន្លែងដែលធ្វើការទូទាត់សងប្រាក់ ត្រូវបានបញ្ជាក់នៅពេលបហារិតធ្វើស្ទីការ ។

មាត្រា ៨៨.-

រូបិយាណត្តិមិនត្រូវប្រើប្រាស់ជាការផ្ទេរមូលនិធិក្នុងដៃរបស់បហារិតដែលមានសម្រាប់ទូទាត់សងប្រាក់ ហើយបហារិតនៃរូបិយាណត្តិដែលមិនព្រមធ្វើស្ទីការមិនទទួលខុសត្រូវលើរូបិយាណត្តិឡើយ ។

តាមរយៈស្ទីការ បហារិតទទួលទូទាត់សងរូបិយាណត្តិនៅពេលដល់ឥណប្រតិទាន ។

ភ

បើពុំមានការទូទាត់សងប្រាក់ទេ អ្នកកាន់ ទោះបីខ្លួនជាបហារិកក្តី មានសិទ្ធិធ្វើឧបាស្រ័យផ្ទាល់អំពីរូបិយាណត្តិទល់នឹងអ្នកធ្វើស្ទីការ ចំពោះអ្វីៗដែលអាចត្រូវបានទាមទារអនុលោមតាមមាត្រា ១០៦ និងមាត្រា ១០៧ នៃច្បាប់នេះ ។

មាត្រា ៨៩.-

កាលបើបហារិកដែលបានធ្វើស្ទីការនៅលើរូបិយាណត្តិបានលុបស្ទីការនោះ នៅមុនពេលមានបដិទានរូបិយាណត្តិមកវិញ ស្ទីការនេះត្រូវបានចាត់ទុកថា បានបដិសេធចោល ។ ក្នុងករណីដែលគ្មានភស្តុតាងផ្ទុយពីនេះ ការលុបចោលត្រូវបានចាត់ទុកថាធ្វើឡើងនៅមុនពេលរូបិយាណត្តិត្រូវបានធ្វើបដិទាន ។

បើបហារិកបានជូនដំណឹងពីស្ទីការរបស់ខ្លួនជាលាយលក្ខណ៍អក្សរឱ្យទៅអ្នកកាន់ ឬ ឱ្យទៅភាគីណាមួយដែលបានចុះហត្ថលេខាលើរូបិយាណត្តិ ទោះបីយ៉ាងណាក៏ដោយ ក៏បហារិកត្រូវទទួលខុសត្រូវចំពោះភាគីទាំងនេះ ស្របតាមខ្លឹមសារនៃស្ទីការរបស់ខ្លួន ។

## ផ្នែកទី ៤
## រូបិយបដិភោគៈបិយាណត្តិ

មាត្រា ៩០.-

ការទូទាត់សងរូបិយាណត្តិ អាចត្រូវបានធានាដោយរូបិយបដិភោគនៅលើចំនួនប្រាក់ទាំងអស់ ឬ មួយផ្នែកនៃរូបិយាណត្តិ ។

ការធានានេះអាចត្រូវបានផ្តល់ដោយតតិយបុគ្គល ឬ ដោយបុគ្គលណាមួយដែលបានចុះហត្ថលេខាលើរូបិយាណត្តិ ។

មាត្រា ៩១.-

រូបិយបដិភោគអាចត្រូវបានធ្វើឡើង នៅលើរូបិយាណត្តិផ្ទាល់ ឬ នៅលើអនុប័ត្រ ។

រូបិយបដិភោគត្រូវបានបញ្ជាក់ដោយពាក្យថា យល់ព្រមធ្វើរូបិយបដិភោគ ឬ ដោយរូបមន្តណាមួយផ្សេងទៀតដែលមានន័យដូចគ្នា និងត្រូវតែចុះហត្ថលេខាដោយអ្នកផ្តល់រូបិយបដិភោគហៅថារូបិយបដិភោគី ។

រាល់ហត្ថលេខា ដែលបានចុះនៅខាងមុខរូបិយាណត្តិក្រៅពីហត្ថលេខារបស់បហារិត ឬ របស់បហារីក ត្រូវបានចាត់ទុកថាជាហត្ថលេខាធ្វើរូបិយបដិភោគ ។

រូបិយបដិភោគ ត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់នូវបុគ្គលណាមួយដែលជាអ្នកទទួលផលពីរូបិយបដិភោគនោះ ។ បើគ្មានសេចក្តីបញ្ជាក់នេះទេ រូបិយបដិភោគត្រូវបានចាត់ទុកថា ធ្វើឱ្យបហារីក ។

មាត្រា ៩២.-

រូបិយបដិភោគីមានកាតព្វកិច្ចដូចបុគ្គល ដែលបានទទួលការធានាដែរ ។

ការចុះហត្ថលេខាធានានៅតែមានតម្លៃ ទោះបីកាតព្វកិច្ចដែលបានធានានោះមិនត្រូវបានអនុវត្តតាមដោយសារហេតុផលផ្សេងៗ ក្រៅពីវិការៈខាងទម្រង់ក៏ដោយ ។

នៅពេលបានទូទាត់សងរូបិយាណត្តិ រូបិយបដិភោគីមានសិទ្ធិទាំងឡាយនៃរូបិយាណត្តិនោះទល់នឹងបុគ្គលដែលត្រូវបានធានា និងបុគ្គលដែលពាក់ព័ន្ធជាមួយបុគ្គលដែលត្រូវបានធានានេះនៅលើរូបិយាណត្តិ ។

## ផ្នែកទី ៥
## កាលប្បវត្តិនៃរូបិយាណត្តិ

មាត្រា ៩៣.-

រូបិយាណត្តិអាចត្រូវបានចេញដើម្បី :

-ទូទាត់សងប្រាក់នៅពេលបង្ហាញ

-ទូទាត់សងប្រាក់នៅក្នុងរយៈពេលកំណត់មួយ ក្រោយការបង្ហាញ

-ទូទាត់សងប្រាក់នៅក្នុងរយៈពេលកំណត់មួយ ក្រោយកាលបរិច្ឆេទចេញផ្សាយ ឬ

-ទូទាត់សងប្រាក់នៅកាលបរិច្ឆេទមួយជាកំណត់ ។

៤៥/៤៦

រូបិយាណត្តិអាចត្រូវបានចេញឱ្យទូទាត់សងប្រាក់ជាច្រើនដំណាក់កាល ដែលដំណាក់កាលនីមួយៗត្រូវធ្វើនៅកាលបរិច្ឆេទមួយជាកំណត់ ដោយមានល័ក្ខខ័ណ្ឌថា ក្នុងករណីខកខានទូទាត់សងប្រាក់នៅដំណាក់កាលណាមួយ ចំនួនប្រាក់ដែលនៅសល់ត្រូវដល់កាលកំណត់សងទាំងស្រុង ។

រូបិយាណត្តិទាំងឡាយដែលមានឥណប្រតិទានផ្សេងពីនេះ ត្រូវបានចាត់ទុកជាមោឃៈ ។

មាត្រា ៩៤.-

រូបិយាណត្តិទូទាត់សងប្រាក់នៅពេលបង្ហាញ ត្រូវតែបានទូទាត់សងប្រាក់នៅពេលបង្ហាញ ។ រូបិយាណត្តិនេះត្រូវតែបានបង្ហាញនៅពេលណាមួយ ក្នុងរយៈពេលមួយ(០១)ឆ្នាំ គិតពីកាលបរិច្ឆេទចេញផ្សាយ ។ បញ្ញើករអាចបង្រួញ ឬ ពន្យាររយៈពេលនេះ ។ រយៈពេលកំណត់នេះ ក៏អាចត្រូវបានបង្រួញដោយអ្នកធ្វើបិដ្ឋិលេខផងដែរ ។

បញ្ញើករអាចបញ្ជាក់ថា រូបិយាណត្តិទូទាត់សងប្រាក់នៅពេលបង្ហាញមិនត្រូវបានបង្ហាញឱ្យទូទាត់សងប្រាក់នៅមុនថ្ងៃកំណត់ឡើយ ។ ក្នុងករណីនេះ រយៈពេលកំណត់សម្រាប់បង្ហាញ ត្រូវចាប់ផ្ដើមពីថ្ងៃកំណត់នោះ ។

មាត្រា ៩៥.-

ឥណប្រតិទាននៃរូបិយាណត្តិទូទាត់សងប្រាក់នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញត្រូវបានកំណត់ដោយកាលបរិច្ឆេទធ្វើស៊ីការ ឬ កាលបរិច្ឆេទធ្វើវិរុទ្ធ-វាទ ។

បើគ្មានវិរុទ្ធវាទទេ ស៊ីការដែលពុំបានចុះកាលបរិច្ឆេទដោយអ្នកធ្វើស៊ីការ ត្រូវបានចាត់ទុកថា បានធ្វើនៅថ្ងៃចុងក្រោយនៃរយៈពេលកំណត់បង្ហាញឱ្យធ្វើស៊ីការ ។

មាត្រា ៩៦.-

នៅពេលដែលរូបិយាណត្តិ ត្រូវបានចេញឱ្យទូទាត់សងប្រាក់ក្នុងរយៈពេលមួយខែ ឬ ច្រើនខែ ក្រោយកាលបរិច្ឆេទនៃការចេញផ្សាយ ឬ ក្រោយការបង្ហាញរូបិយាណត្តិ

មានឥណប្រតិទាននៅកាលបរិច្ឆេទ ដែលត្រូវគ្នានៅក្នុងខែដែលត្រូវទូទាត់សងប្រាក់ ។ បើគ្មានកាលបរិច្ឆេទត្រូវគ្នាទេ រូបិយាណត្តិមានឥណប្រតិទាននៅថ្ងៃចុងក្រោយនៃខែនោះ ។

កាលបើរូបិយាណត្តិ ត្រូវបានចេញឱ្យទូទាត់សងប្រាក់ក្នុងរយៈពេលមួយខែកន្លះ ឬ ច្រើនខែកន្លះ ក្រោយកាលបរិច្ឆេទនៃការចេញផ្សាយ ឬ ក្រោយការបង្ហាញរយៈពេលពេញលេញនៃខែទាំងនោះ ត្រូវតែបានយកមកគិតជាមុន ។

បើឥណប្រតិទានត្រូវបានកំណត់នៅដើមខែ ពាក់កណ្ដាលខែ ឬ នៅដំណាច់ខែ ត្រូវយកថ្ងៃទីមួយ ថ្ងៃទីដប់ប្រាំ ឬ ថ្ងៃដាច់ខែមកគិត ។

ពាក្យថា ប្រាំបីថ្ងៃ ឬ ដប់ប្រាំថ្ងៃ មិនមានន័យថា មួយសប្ដាហ៍ ឬ ពីរសប្ដាហ៍ទេ គឺជារយៈពេលប្រាំបីថ្ងៃ ឬ ដប់ប្រាំថ្ងៃពិតប្រាកដ ។

ពាក្យថា កន្លះខែ មានន័យថាដប់ប្រាំថ្ងៃ ។

**មាត្រា ៩៧.-**

កាលបើរូបិយាណត្តិ ត្រូវទូទាត់សងប្រាក់នៅកាលបរិច្ឆេទមួយជាកំណត់ នៅកន្លែងដែលមានប្រតិទិនខុសពីប្រតិទិននៃកន្លែងចេញផ្សាយ ថ្ងៃឥណប្រតិទានត្រូវបានកំណត់ទៅតាមប្រតិទិននៃកន្លែងទូទាត់សងប្រាក់ ។

កាលបើរូបិយាណត្តិចេញរវាងកន្លែងពីរ ដែលមានប្រតិទិនខុសគ្នាត្រូវទូទាត់សងប្រាក់នៅក្នុងរយៈពេលកំណត់មួយ ក្រោយកាលបរិច្ឆេទចេញផ្សាយ ថ្ងៃចេញផ្សាយត្រូវបានគិតតាមថ្ងៃដែលត្រូវគ្នានឹងប្រតិទិននៃកន្លែងត្រូវទូទាត់សងប្រាក់ ហើយឥណប្រតិទានក៏ត្រូវកំណត់ស្របទៅតាមនោះដែរ ។ រយៈពេលសម្រាប់បង្ហាញរូបិយាណត្តិត្រូវបានគណនាទៅតាមវិធាននេះ ។

វិធានទាំងនេះមិនត្រូវបានអនុវត្តទេ បើមានបដិញ្ញា ឬ ខ្លឹមសារចែងអំពីវិធានផ្សេងពីនេះ ។

## ផ្នែកទី ៦
## ការទូទាត់សងប្រាក់

**មាត្រា ៩៨.-**

អ្នកកាន់រូបិយាណត្តិ ដែលត្រូវទូទាត់សងប្រាក់នៅកាលបរិច្ឆេទមួយជាកំណត់ ឬ នៅក្នុងពេលកំណត់មួយក្រោយកាលបរិច្ឆេទចេញផ្សាយ ឬ ក្រោយការបង្ហាញ ត្រូវបង្ហាញនៅថ្ងៃទូទាត់សងប្រាក់ ឬ នៅថ្ងៃណាមួយរវាងពីរ(០២)ថ្ងៃ ធ្វើការបន្ទាប់ ។

ការបង្ហាញរូបិយាណត្តិតាមរយៈសភាជាត់ទាត់ ឬ តាមរយៈប្រព័ន្ធអេឡិចត្រូនិក ដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង ឬ បទបញ្ញាដែលចេញដោយធនាគារជាតិនៃកម្ពុជា ជាការបង្ហាញឱ្យទូទាត់សងប្រាក់ជាផ្លូវការ ។

**មាត្រា ៩៩.-**

បរហារិតដែលទូទាត់សងរូបិយាណត្តិ អាចតម្រូវឱ្យប្រគល់រូបិយាណត្តិនោះឱ្យខ្លួនក្រោយពីមានបញ្ជាក់ការទទួលប្រាក់ពីអ្នកកាន់ ។

អ្នកកាន់អាចមិនបដិសេធការទូទាត់សងប្រាក់មួយផ្នែកនៃចំនួនប្រាក់រូបិយាណត្តិ ។

ក្នុងករណីមានការទូទាត់សងប្រាក់មួយផ្នែកនៃចំនួនប្រាក់ បរហារិតអាចទាមទារឱ្យបញ្ជាក់ការសងប្រាក់មួយផ្នែកនោះ នៅលើរូបិយាណត្តិ និងទាមទារបង្កាន់ដៃទទួលប្រាក់ផងដែរ ។

**មាត្រា ១០០.-**

នៅពេលដែលរូបិយាណត្តិមិនត្រូវបានបង្ហាញឱ្យទូទាត់សងប្រាក់នៅក្នុងរយៈពេលដែលកំណត់ដោយមាត្រា ៩៨ នៃច្បាប់នេះ កូនបំណុលត្រូវបានអនុញ្ញាតឱ្យតម្កល់ចំនួនប្រាក់នោះនៅអាជ្ញាធរមានសមត្ថកិច្ច តាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា ក្រោមការទទួលខុសត្រូវ និងហានិភ័យរបស់អ្នកកាន់ ។

**មាត្រា ១០១.-**

អ្នកកាន់រូបិយាណត្តិ មិនអាចត្រូវបានបង្ខំឱ្យទទួលយកការទូទាត់សងប្រាក់នៅមុនពេលដល់កាលប្រតិទានឡើយ ។

៤៦/៧

បហារិកដែលទូទាត់សងប្រាក់មុនពេលដល់ឥណប្រតិទាន ត្រូវទទួលរងហានិភ័យ ដោយខ្លួនឯងផ្ទាល់ ។

បហារិកដែលទូទាត់សងប្រាក់នៅពេលដល់ឥណប្រតិទាន ត្រូវបានរួចផុតយ៉ាងត្រឹមត្រូវពីកាតព្វកិច្ចរបស់ខ្លួន លើកលែងតែមានកំហុសនៃការក្លែងបន្លំ ឬ នៃការធ្វេសប្រហែសធ្ងន់ធ្ងរ ។ បហារិក ត្រូវទទួលខុសត្រូវផ្ទៀងផ្ទាត់ប្រក្រតីភាពនៃលំដាប់បិដ្ឋិលេខ ប៉ុន្តែមិនផ្ទៀងផ្ទាត់ហត្ថលេខាអ្នកធ្វើបិដ្ឋិលេខឡើយ ។

មាត្រា ១០២.-

នៅពេលដែលរូបិយាណត្តិ ត្រូវបានចេញជារូបិយប័ណ្ណដែលមិនមែនជារបស់កន្លែងត្រូវទូទាត់សងប្រាក់ ចំនួនប្រាក់អាចត្រូវទូទាត់សងជារូបិយប័ណ្ណនៃប្រទេសជាកន្លែងទូទាត់សងប្រាក់ ទៅតាមអត្រាប្តូរប្រាក់នៅថ្ងៃឥណប្រតិទាន ។ បើការទូទាត់សងប្រាក់មិនត្រូវបានធ្វើនៅពេលបង្ហាញ អ្នកកាន់អាចស្នើសុំឱ្យការទូទាត់សងចំនួនប្រាក់នៅលើរូបិយាណត្តិនោះធ្វើឡើងជារូបិយប័ណ្ណរបស់ប្រទេសជាកន្លែងទូទាត់សងប្រាក់ទៅតាមអត្រាប្តូរប្រាក់នៅថ្ងៃឥណប្រតិទាន ឬ នៅថ្ងៃទូទាត់សងប្រាក់តាមការជ្រើសរើសរបស់ខ្លួន ។

រាល់ការប្រើប្រាស់កន្លែងទូទាត់សងប្រាក់នឹងត្រូវបានអនុវត្តសម្រាប់កំណត់តម្លៃរូបិយប័ណ្ណ ។ ប៉ុន្តែបហារិកអាចចែងល័ក្ខខ័ណ្ឌថា ចំនួនប្រាក់ដែលទូទាត់សងនឹងត្រូវគណនាទៅតាមអត្រាប្តូរប្រាក់ ដែលបញ្ជាក់នៅលើរូបិយាណត្តិ ។

វិធានទាំងឡាយខាងលើនេះមិនត្រូវបានអនុវត្តចំពោះរូបិយាណត្តិ :

-ដែលចេញជារូបិយប័ណ្ណដែលមានការទទួលយក នៅព្រះរាជាណាចក្រកម្ពុជា

-ដែលក្នុងនោះ បហារិកបានបញ្ជាក់ថាការទូទាត់សងប្រាក់ត្រូវតែធ្វើឡើងជារូបិយប័ណ្ណណាមួយច្បាស់លាស់ ។ ក្នុងករណីខាងលើនេះ រូបិយាណត្តិនឹងត្រូវទូទាត់សងជារូបិយប័ណ្ណ ដែលបានបញ្ជាក់ ។

បើចំនួនប្រាក់នៃរូបិយាណត្តិ ត្រូវបានបញ្ជាក់ជារូបិយប័ណ្ណដែលមាននាមចារឹកដូចគ្នា ប៉ុន្តែមានតម្លៃខុសគ្នារវាងប្រទេសទូទាត់សងប្រាក់ និងប្រទេសចេញផ្សាយ ឬ ប្រទេសណាមួយផ្សេងទៀត លើកលែងតែមានការកំណត់ផ្សេងពីនេះ ចំនួនប្រាក់ក្នុង

រូបិយាណត្តិត្រូវចាត់ទុកថាបានទូទាត់សងជារូបិយប័ណ្ណនៃប្រទេសទូទាត់សងប្រាក់ ។ នៅពេលណាដែលរូបិយប័ណ្ណនៃប្រទេសទូទាត់សងប្រាក់ មិនមាននាមចារឹកដូចគ្នា ការទូទាត់សងប្រាក់ត្រូវបានធ្វើឡើងជារូបិយប័ណ្ណ ដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅកន្លែងទូទាត់សងប្រាក់ ។

នៅពេលដែលរូបិយាណត្តិត្រូវបានទូទាត់សងនៅធនាគារ ការចង្អុលបង្ហាញគណនីដែលត្រូវចុះឥណពន្ធតាមចំនួនប្រាក់ត្រូវទូទាត់សង ត្រូវបានចាត់ទុកជាការអនុញ្ញាតឱ្យទូទាត់សងជារូបិយប័ណ្ណនៃគណនី ។

## ផ្នែកទី ៧
## ឧបាស្រ័យចំពោះការមិនធ្វើស្ថីការឬការមិនទូទាត់សងប្រាក់

មាត្រា ១០៣.-

អ្នកកាន់រូបិយាណត្តិ អាចអនុវត្តសិទ្ធិធ្វើឧបាស្រ័យរបស់ខ្លួនទល់នឹងអ្នកធ្វើបិដ្ឋិលេខទាំងឡាយ បហារក និងភាគីពាក់ព័ន្ធដទៃៗទៀត :

១-នៅពេលដល់ឥណប្រតិទាន បើការទូទាត់សងប្រាក់មិនត្រូវបានធ្វើ ឬ

២-ទោះបីនៅមុនពេលដល់ឥណប្រតិទានក្តី :

-បើមានករណីមិនព្រមធ្វើស្ថីការចំពោះចំនួនប្រាក់ទាំងស្រុង ឬមួយផ្នែកនៃរូបិយាណត្តិ

-ក្នុងករណីធនក្ស័យរបស់បហារិត ទោះបីជាមាន ឬ គ្មានធ្វើស្ថីការក្តី ឬ ក្នុងករណីបញ្ឈប់បហារិតមិនឱ្យទូទាត់សងប្រាក់ដោយគ្មានសេចក្តីសម្រេចពីតុលាការ ឬ នៅពេលណាដែលការអនុវត្តរឹបអូសទ្រព្យសម្បត្តិរបស់បហារិតពុំបានសម្រេច

-ក្នុងករណីធនក្ស័យរបស់បហារកនៃរូបិយាណត្តិ ដែលមិនធ្វើស្ថីការ ។

មាត្រា ១០៤.-

វិរុទ្ធវាទអាចត្រូវបានធ្វើឡើងក្រោមល័ក្ខខ័ណ្ឌដូចតទៅ :

១-ការខកខានមិនបានធ្វើស្ថីការ ឬ មិនបានទូទាត់សងប្រាក់ត្រូវតែបានបង្ហាញភស្តុតាងដោយវិរុទ្ធវាទតាមច្បាប់ ។

ភ្ញ

50/kr

២-វិរុទ្ធភាពចំពោះការមិនធ្វើសួំការ ត្រូវតែបានធ្វើនៅក្នុងរយៈពេលកំណត់បង្ហាញឱ្យធ្វើសួំការ ។ ដូចមានចែងនៅក្នុងមាត្រា ៨៤ នៃច្បាប់នេះ បើការបង្ហាញលើកទីមួយ ត្រូវបានធ្វើនៅថ្ងៃចុងក្រោយនៃរយៈពេលកំណត់នោះ វិរុទ្ធភាពអាចធ្វើឡើងនៅថ្ងៃបន្ទាប់ ។

៣-វិរុទ្ធភាពចំពោះការមិនទូទាត់សងរូបិយាណត្តិ ដែលត្រូវទូទាត់សងប្រាក់ នៅកាលបរិច្ឆេទមួយជាកំណត់ ឬ នៅក្នុងរយៈពេលកំណត់មួយក្រោយកាលបរិច្ឆេទនៃការចេញផ្សាយ ឬ ក្រោយការបង្ហាញត្រូវតែបានធ្វើនៅថ្ងៃណាមួយក្នុងរវាងពីរ(០២)ថ្ងៃធ្វើការបន្ទាប់ពីថ្ងៃដែលរូបិយាណត្តិនោះត្រូវទូទាត់សងប្រាក់ ។ នៅក្នុងករណីនៃរូបិយាណត្តិ ដែលត្រូវទូទាត់សងប្រាក់នៅពេលបង្ហាញវិរុទ្ធភាពត្រូវតែបានធ្វើក្រោមល័ក្ខខ័ណ្ឌទាំងឡាយ ដែលមានចែងនៅក្នុងកថាខណ្ឌទី ២ ខាងលើស្តីពីវិរុទ្ធភាពចំពោះការមិនធ្វើសួំការ ។

៤-វិរុទ្ធភាពចំពោះការមិនធ្វើសួំការ អាចធ្វើបានដោយមិនចាំបាច់បង្ហាញរូបិយាណត្តិឱ្យទូទាត់សងប្រាក់ និងបង្ហាញវិរុទ្ធភាពចំពោះការមិនទូទាត់សងប្រាក់ ។

៥-បើបហារិតត្រូវបានបញ្ឈប់មិនឱ្យទូទាត់សងប្រាក់ ទោះបីមាន ឬ គ្មានសួំការក្តី ឬ បើការអនុវត្តរឹបអូសទ្រព្យសម្បត្តិមិនបានសម្រេច អ្នកកាន់អាចអនុវត្តសិទ្ធិធ្វើឧបាស្រ័យបាន តែនៅក្រោយការបង្ហាញរូបិយាណត្តិឱ្យទៅបហារិតធ្វើការទូទាត់សងប្រាក់ និងនៅក្រោយពេលដែលវិរុទ្ធភាពត្រូវបានធ្វើ ។

៦-បើបហារិតត្រូវបានប្រកាសថាធនក្ស័យ ទោះបីបាន ឬ មិនបានធ្វើសួំ-ការក្តី ឬ បើបហារិកនៃរូបិយាណត្តិ ដែលមិនធ្វើសួំការត្រូវបានប្រកាសថាធនក្ស័យ ការបង្ហាញសាលក្រម ឬ សាលដីការបស់តុលាការដែលប្រកាសពីធនក្ស័យនោះ មានតម្លៃគ្រប់គ្រាន់ឱ្យអ្នកកាន់អាចអនុវត្តសិទ្ធិធ្វើឧបាស្រ័យបាន ។

៧-វិរុទ្ធភាពត្រូវតែបានចុះហត្ថលេខាបញ្ជាក់យថាភាពនៃឯកសារដោយមន្ត្រីដែលទទួលសិទ្ធិស្របច្បាប់ ។ ដរាបណាពុំទាន់មានមន្ត្រី ដែលបានទទួលសិទ្ធិស្របច្បាប់នោះទេ មន្ត្រីនោះត្រូវតែបានតែងតាំងដោយធនាគារជាតិនៃកម្ពុជា ។ វិរុទ្ធភាពត្រូវមានច្បាប់ថតចម្លង ឬ ច្បាប់ដើមនៃរូបិយាណត្តិភ្ជាប់ជាមួយ និងត្រូវបញ្ជាក់ច្បាស់លាស់អំពីបុគ្គលដែលធ្វើវិរុទ្ធភាពនោះ កន្លែងនិងកាលបរិច្ឆេទ មូលហេតុនៃវិរុទ្ធភាព

សំណួមពរដែលលើកឡើង និងចម្លើយដែលផ្តល់មកវិញបើមាន ឬ អំពីការដែលរកមិនឃើញបហារិត ឬ អ្នកធ្វើស៊ីការ ។ វិរុទ្ធវាទត្រូវបានធ្វើឡើងនៅកន្លែងនៃការបដិសេធមិនទូទាត់សងប្រាក់ ឬ មិនធ្វើស៊ីការ ឬ នៅកន្លែងផ្សេងទៀតក្នុងព្រះរាជាណាចក្រកម្ពុជាដែលស្ថិតក្នុងចម្ងាយមិនលើសដប់(១០)គីឡូម៉ែត្រពីកន្លែងនៃការបង្ហាញ និងនៃការបដិសេធមិនទូទាត់សងប្រាក់ ឬ មិនធ្វើស៊ីការ ។

៨-វិរុទ្ធវាទអាចត្រូវបានធ្វើឡើងដោយប្រតិវេទន៍ជាលាយលក្ខណ៍អក្សរ និងមានចុះហត្ថលេខារបស់បហារិតបញ្ជាក់ច្បាស់អំពីព័ត៌មានទាំងឡាយដូចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៧ នៃមាត្រានេះ ។

មាត្រា ១០៥.-

អ្នកកាន់ត្រូវជូនដំណឹងពីការមិនធ្វើស៊ីការ ឬ មិនទូទាត់សងប្រាក់ទៅអ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន បហារិក និងរូបិយបដិភោគីណាមួយនៃអ្នកធ្វើស៊ីការនៅក្នុងរយៈពេលបួន(០៤)ថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃធ្វើវិរុទ្ធវាទ ឬ នៅថ្ងៃបង្ហាញឱ្យទូទាត់សងប្រាក់ ក្នុងករណីដែលមានបដិញ្ញាថា បង្វិលទិញដោយគ្មានសោហ៊ុយ ឬ បង្វិលទិញដោយគ្មានវិរុទ្ធវាទ ឬ សេចក្តីផ្សេងណាមួយដែលមានន័យដូចគ្នា ។ នៅក្នុងរយៈពេលពីរ(០២)ថ្ងៃធ្វើការបន្ទាប់ពីថ្ងៃបានទទួលសេចក្តីជូនដំណឹង អ្នកធ្វើបិដ្ឋិលេខនីមួយៗត្រូវជូនដំណឹងដល់អ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន អំពីសេចក្តីជូនដំណឹងដែលបានទទួល ដោយបញ្ជាក់ពីឈ្មោះ និងអាសយដ្ឋានរបស់អ្នកធ្វើបិដ្ឋិលេខ ដែលបានផ្តល់សេចក្តីជូនដំណឹងមុនៗជាលំដាប់លំដោយរហូតដល់បហារិកបានទទួល ។ រយៈពេលកំណត់ដែលបញ្ជាក់ខាងលើ ត្រូវគិតពីថ្ងៃទទួលបានសេចក្តីជូនដំណឹងមុន ។

ដោយអនុលោមតាមកថាខណ្ឌខាងលើនៃមាត្រានេះ នៅពេលដែលសេចក្តីជូនដំណឹង ត្រូវបានផ្តល់ទៅបុគ្គលដែលបានចុះហត្ថលេខាលើរូបិយាណត្តិ សេចក្តីជូនដំណឹងដូចគ្នានេះ ក៏ត្រូវបានផ្តល់ទៅរូបិយបដិភោគីនៅក្នុងពេលកំណត់ដូចគ្នា ។

កាលបើអ្នកធ្វើបិដ្ឋិលេខ មិនបានបញ្ជាក់ច្បាស់នូវអាសយដ្ឋានរបស់ខ្លួន ឬ ក៏បានបញ្ជាក់ដោយមិនច្បាស់ សេចក្តីជូនដំណឹងដែលបានផ្តល់ទៅអ្នកធ្វើបិដ្ឋិលេខមុនបន្ទាប់ គឺជាការគ្រប់គ្រាន់ ។

បុគ្គលដែលត្រូវផ្ដល់សេចក្ដីជូនដំណឹងអាចធ្វើសេចក្ដីជូនដំណឹងតាមរូបភាពណាមួយក៏បាន ទោះបីត្រឹមតែបញ្ជូនរូបិយាណត្តិត្រឡប់វិញក៏ដោយ ។

បុគ្គលដែលត្រូវផ្ដល់សេចក្ដីជូនដំណឹង ត្រូវបង្ហាញភស្តុតាងថាខ្លួនបានជូនដំណឹងក្នុងរយៈពេលកំណត់ ។ រយៈពេលកំណត់នេះនឹងត្រូវចាត់ទុកថាបានគោរពតាម បើលិខិតជូនដំណឹងត្រូវបានផ្ញើតាមប្រៃសណីយ៍ក្នុងរយៈពេលកំណត់នោះ ។

បុគ្គលដែលមិនបានផ្ដល់សេចក្ដីជូនដំណឹងក្នុងរយៈពេលកំណត់ខាងលើ ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលកើតឡើងដោយការធ្វេសប្រហែសរបស់ខ្លួន បើមាន ប៉ុន្តែចំនួនប្រាក់ដែលទទួលខុសត្រូវមិនត្រូវលើសពីចំនួនប្រាក់នៃរូបិយាណត្តិឡើយ ។

មាត្រា ១០៦.-

តាមរយៈបដិញ្ញាថា បង្វិលទិញដោយគ្មានសោហ៊ុយ ឬ បង្វិលទិញដោយគ្មានវិវាទ ឬ សេចក្ដីផ្សេងណាមួយដែលមានន័យដូចគ្នា ហើយដែលបានសរសេរ និងមានចុះហត្ថលេខានៅលើរូបិយាណត្តិ បហារីក អ្នកធ្វើបិដ្ឋិលេខ ឬ រូបិយបដិភោគី អាចឱ្យអ្នកកាន់មិនចាំបាច់ធ្វើវិវាទ ដើម្បីអនុវត្តសិទ្ធិធ្វើឧបាស្រ័យ ។

បដិញ្ញានេះមិនអាចឱ្យអ្នកកាន់រួចផុតពីការបង្ហាញរូបិយាណត្តិ នៅក្នុងរយៈពេលកំណត់ ឬ ពីការតម្រូវឱ្យមានរាល់សេចក្ដីជូនដំណឹងឡើយ ។ សោហ៊ុយដែលកើតឡើងពីការបង្ហាញភស្តុតាងនៃការមិនគោរពតាមរយៈពេលកំណត់ដោយអ្នកកាន់ ជាបន្ទុករបស់បុគ្គលដែលបានប្ដឹងទល់នឹងអ្នកកាន់ ។

បើបដិញ្ញាត្រូវបានសរសេរដោយបហារីក បដិញ្ញានេះត្រូវអនុវត្តបានទៅលើបុគ្គលទាំងឡាយដែលបានចុះហត្ថលេខាលើរូបិយាណត្តិ ។ បើបដិញ្ញាត្រូវបានសរសេរដោយអ្នកធ្វើបិដ្ឋិលេខ ឬ រូបិយបដិភោគី បដិញ្ញានោះត្រូវអនុវត្តបានចំពោះតែអ្នកធ្វើបិដ្ឋិលេខ ឬ រូបិយបដិភោគីប៉ុណ្ណោះ ។ ទោះបីបដិញ្ញាសរសេរដោយបហារីកក៏ដោយ បើអ្នកកាន់ធ្វើវិវាទ អ្នកកាន់នេះត្រូវទទួលរ៉ាប់រងលើសោហ៊ុយទាំងអស់ដែលកើតមាន ។ កាលបើបដិញ្ញាកើតចេញអំពីអ្នកធ្វើបិដ្ឋិលេខ ឬ រូបិយបដិភោគី សោហ៊ុយនៃ

វិវទ្ធភាព បើមាន អាចត្រូវបានទារពីបុគ្គលទាំងឡាយ ដែលបានចុះហត្ថលេខាលើរូបិយាណត្តិ ។

មាត្រា ១០៧.–

រាល់បរហារិក អ្នកធ្វើស្ទីការ អ្នកធ្វើបិដ្ឋិលេខ ឬ បុគ្គលធានាដោយការធ្វើរូបិយបដិភោគនៃរូបិយាណត្តិ មានកាតព្វកិច្ចទទួលខុសត្រូវរួមគ្នាចំពោះអ្នកកាន់ ។

អ្នកកាន់មានសិទ្ធិប្ដឹងទល់នឹងបុគ្គលជាប់ពាក់ព័ន្ធទៅនឹងរូបិយាណត្តិជាឯកត្តជន ឬ រួមគ្នា ដោយមិនគិតដល់លំដាប់លំដោយដែលបុគ្គលទាំងនេះ ចូលមកជាប់ពាក់ព័ន្ធឡើយ ។

សិទ្ធិដូចគ្នានេះ ត្រូវមានចំពោះបុគ្គលណាដែលបានចុះហត្ថលេខាលើរូបិយាណត្តិ ហើយបានទទួលយករូបិយាណត្តិរក្សាទុក និងបានទូទាត់សងប្រាក់ ។

រាល់ការប្ដឹងទល់នឹងភាគីមួយនៃភាគីពាក់ព័ន្ធទាំងឡាយ មិនរារាំងការប្ដឹងទល់នឹងបុគ្គលដទៃៗទៀតឡើយ ទោះបីបុគ្គលដទៃទាំងនេះទាក់ទិនបន្តបន្ទាប់ ពីបុគ្គលដែលបានទទួលរងការប្ដឹងទីមួយនោះក៏ដោយ ។

មាត្រា ១០៨.–

អ្នកកាន់អាចទាមទារពីបុគ្គលដែលខ្លួនអនុវត្តសិទ្ធិឧបាស្រ័យនូវចំនួនប្រាក់នៃរូបិយាណត្តិដែលមិនបានធ្វើស្ទីការ ឬ មិនបានទូទាត់សងដោយមានការប្រាក់ បើការប្រាក់នោះមានចែងលើរូបិយាណត្តិ ការប្រាក់ដែលគណនាតាមអត្រាកំណត់ដោយធនាគារជាតិនៃកម្ពុជា គិតពីថ្ងៃឥណប្រតិទាន និងសោហ៊ុយទាំងឡាយដែលកើតមាន ។

បើសិទ្ធិធ្វើឧបាស្រ័យត្រូវបានអនុវត្តមុនពេលដល់ឥណប្រតិទាន ចំនួនប្រាក់នៃរូបិយាណត្តិត្រូវជាកម្មវត្ថុនៃការធ្វើអប្បហារ ។ អប្បហារនេះត្រូវបានគណនាទៅតាមអត្រាអប្បហារជាផ្លូវការរបស់ធនាគារ នៅថ្ងៃធ្វើឧបាស្រ័យ នៅកន្លែងស្នាក់នៅរបស់អ្នកកាន់ ។

មាត្រា ១០៩.–

ភាគីដែលបានទទួលយក និងទូទាត់សងរូបិយាណត្តិ អាចទាមទារមកវិញពីភាគីទាំងឡាយដែលពាក់ព័ន្ធជាមួយនូវចំនួនប្រាក់ទាំងស្រុងដែលបានទូទាត់សងការប្រាក់

54/125

លើចំនួនប្រាក់ដែលបានទូទាត់សង គណនាតាមអត្រាកំណត់ដោយធនាគារជាតិនៃកម្ពុជា គិតពីថ្ងៃបានទូទាត់សងប្រាក់ និងសោហ៊ុយទាំងឡាយដែលកើតមាន ។

មាត្រា ១១០.-

ភាគីពាក់ព័ន្ធនីមួយៗ ដែលទទួលរងការអនុវត្តសិទ្ធិធ្វើឧបាស្រ័យអាចទាមទារដោយប្តូរនឹងការទូទាត់សងប្រាក់ឱ្យប្រគល់មកខ្លួន នូវរូបិយាណត្តិរួមជាមួយនឹងវិរុទ្ធភាព និងបង្កាន់ដៃទទួលប្រាក់ ។

អ្នកធ្វើបិដ្ឋិលេខនីមួយៗ ដែលបានទទួលយក និងបានទូទាត់សងរូបិយាណត្តិ អាចលុបចោលបិដ្ឋិលេខរបស់ខ្លួន និងរបស់អ្នកធ្វើបិដ្ឋិលេខបន្តបន្ទាប់តាមក្រោយ ។

មាត្រា ១១១.-

នៅក្នុងករណីដែលការអនុវត្តសិទ្ធិធ្វើឧបាស្រ័យ បន្ទាប់ពីការធ្វើស៊ីការតែលើមួយផ្នែកនៃចំនួនប្រាក់ ភាគីដែលទូទាត់សងចំនួនប្រាក់លើរូបិយាណត្តិដែលមិនត្រូវបានធ្វើស៊ីការនោះ អាចទាមទារឱ្យបញ្ជាក់ការទូទាត់សងប្រាក់មួយផ្នែកនេះនៅលើរូបិយាណត្តិ និងទាមទារយកបង្កាន់ដៃក្នុងការទូទាត់សងប្រាក់នេះផង ។ អ្នកកាន់ក៏ត្រូវតែប្រគល់ឱ្យអ្នកទូទាត់សងប្រាក់នេះ នូវច្បាប់ចម្លងមានវិញ្ញាបនកម្មនៃរូបិយាណត្តិរួមជាមួយនឹងវិរុទ្ធភាព ដើម្បីអាចអនុវត្តសិទ្ធិឧបាស្រ័យជាបន្តទៀត ។

មាត្រា ១១២.-

ក្នុងករណីដែលគ្មានកិច្ចព្រមព្រៀងផ្ទុយពីនេះទេ រាល់បុគ្គលដែលមានសិទ្ធិធ្វើឧបាស្រ័យអាចទូទាត់សងប្រាក់ដោយខ្លួនឯង តាមមធ្យោបាយនៃរូបិយាណត្តិថ្មីមួយទៀតដែលចេញឱ្យទូទាត់សងប្រាក់នៅពេលបង្ហាញឱ្យទៅភាគីណាមួយដែលជំពាក់ខ្លួន និងដែលត្រូវទូទាត់សងនៅលំនៅនៃភាគីនោះ ។

ជាបន្ថែមលើចំនួនប្រាក់នានា ដែលចែងនៅក្នុងមាត្រា ១០៨ និង មាត្រា ១០៩ នៃច្បាប់នេះ រូបិយាណត្តិថ្មីមានបញ្ចូលនូវកម្រៃជើងសា និងថ្លៃតែមប្រិ៍ផងដែរ ។

បើរូបិយាណត្តិថ្មីត្រូវបានចេញដោយអ្នកកាន់ ចំនួនប្រាក់ទូទាត់សង ត្រូវបានកំណត់ទៅតាមអត្រាការប្រាក់សម្រាប់រូបិយាណត្តិទូទាត់សងប្រាក់នៅពេលបង្ហាញ នៅកន្លែងដែលរូបិយាណត្តិដំបូង ត្រូវបានទូទាត់សងប្រាក់នៅលំនៅរបស់ភាគីពាក់

៥៤

ព័ន្ធ ។ បើរូបិយាណត្តិថ្មីត្រូវបានចេញដោយអ្នកធ្វើបិដ្ឋិលេខ ចំនួនប្រាក់ទូទាត់សងត្រូវបានកំណត់ទៅតាមអត្រាការប្រាក់ សម្រាប់រូបិយាណត្តិទូទាត់សងនៅពេលបង្ហាញ នៅកន្លែងដែលបហារិកនៃរូបិយាណត្តិថ្មីនោះ មានលំនៅនៅកន្លែងជាមួយភាគីមួយដែលពាក់ព័ន្ធ ។

មាត្រា ១១៣.-

អ្នកកាន់បាត់បង់សិទ្ធិធ្វើឱបាស្រ័យរបស់ខ្លួនទល់នឹងអ្នកធ្វើបិដ្ឋិលេខទាំងឡាយ បហារិក និងភាគីពាក់ព័ន្ធដទៃទៀត លើកលែងតែសិទ្ធិធ្វើឱបាស្រ័យទល់នឹងអ្នកធ្វើស្វ័-ការ ក្រោយផុតរយៈពេលកំណត់ :

-សម្រាប់ការបង្ហាញរូបិយាណត្តិ ដែលចេញឱ្យទូទាត់សងប្រាក់នៅពេលបង្ហាញ ឬ នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ

-សម្រាប់ការធ្វើវិវាទ្ធភាទ ចំពោះការមិនធ្វើស្វីការ ឬ ការមិនទូទាត់សងប្រាក់

-សម្រាប់ការបង្ហាញឱ្យទូទាត់សងប្រាក់ ក្នុងករណីដែលមានបដិញ្ញាថា បង្វិលវិញដោយគ្មានសោហ៊ុយ ឬ បង្វិលវិញដោយគ្មានវិវាទ្ធទាន ឬ សេចក្ដីផ្សេងណាមួយដែលមានន័យដូចគ្នា ។

បើគ្មានការបង្ហាញឱ្យធ្វើស្វីការក្នុងរយៈពេលដែលកំណត់ដោយបហារិកទេ អ្នកកាន់បាត់បង់សិទ្ធិធ្វើឱបាស្រ័យរបស់ខ្លួនចំពោះការមិនទូទាត់សងប្រាក់ក៏ដូចជាការមិនធ្វើស្វីការ លើកលែងតែខ្លឹមសារនៃបដិញ្ញាបានបង្ហាញថា បហារិកមានចេតនាធ្វើឱ្យខ្លួនរួចផុតពីការធានាលើស្វីការតែប៉ុណ្ណោះ ។

បើបដិញ្ញាស្ដីពីរយៈពេលកំណត់ឱ្យបង្ហាញ មានចុះនៅក្នុងបិដ្ឋិលេខ រយៈពេលកំណត់នេះមានប្រសិទ្ធភាពចំពោះអ្នកធ្វើបិដ្ឋិលេខនោះតែប៉ុណ្ណោះ ។

អ្នកកាន់ដែលបាត់បង់សិទ្ធិធ្វើឱបាស្រ័យក្រោមមាត្រានេះ អាចប្ដឹងបហារិកក្រោមបទប្បញ្ញត្តិដោយឡែកស្ដីពីកិច្ចសន្យា ។ សំណងបានមកវិញដូចមានចែងក្នុងកថាខណ្ឌនេះ ត្រូវបានកាត់សងលើការខូចខាតដែលបង្កឡើងដោយអ្នកកាន់ចំពោះបហារិក ដោយសារតែខកខានមិនបានគោរពរយៈពេលកំណត់ ។

មាត្រា ១១៥.-

កាលបើការបង្ហាញរូបិយាណត្តិឱ្យទូទាត់សងប្រាក់ ឬ ការធ្វើវិរុទ្ធវាទក្នុងរយៈពេលកំណត់ត្រូវបានរាំងស្ទះដោយឧបសគ្គមិនអាចឆ្លងផុតបានដែលជាករណីប្រធានស័ក្តិ រយៈពេលកំណត់នេះត្រូវបានពន្យារ ។

អ្នកកាន់មានកាតព្វកិច្ចផ្តល់សេចក្តីជូនដំណឹងភ្លាមអំពីករណីប្រធានស័ក្តិឱ្យទៅអ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន និងត្រូវបញ្ជាក់អំពីសេចក្តីជូនដំណឹងនេះ ដោយចុះកាលបរិច្ឆេទ និងហត្ថលេខាលើរូបិយាណត្តិ ឬ លើអនុប័ត្រ ។ ចំពោះប្រការផ្សេងៗទៀតត្រូវអនុវត្តទៅតាមមាត្រា ១០៥ នៃច្បាប់នេះ ។

នៅពេលដែលករណីប្រធានស័ក្តិបានចប់ អ្នកកាន់ត្រូវបង្ហាញរូបិយាណត្តិភ្លាមដើម្បីឱ្យធ្វើស្វីការ ឬ ឱ្យទូទាត់សងប្រាក់ ហើយបើចាំបាច់ត្រូវធ្វើវិរុទ្ធវាទ ។

បើករណីប្រធានស័ក្តិ នៅបន្តកើតមានលើសពីសាមសិប (៣០) ថ្ងៃ ក្រោយពេលដល់ឥណប្រតិទាន ឧបាស្រ័យអាចត្រូវបានធ្វើឡើង ហើយទាំងការបង្ហាញឱ្យទូទាត់សងប្រាក់ ទាំងការធ្វើវិរុទ្ធវាទមិនចាំបាច់ធ្វើឡើយ ។

ចំពោះរូបិយាណត្តិ ដែលចេញឱ្យទូទាត់សងប្រាក់នៅពេលបង្ហាញ ឬ នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ រយៈពេលកំណត់សាមសិប (៣០) ថ្ងៃនោះ ត្រូវចាប់ផ្តើមពីកាលបរិច្ឆេទដែលអ្នកកាន់បានជូនដំណឹងពីករណីប្រធានស័ក្តិទៅអ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន ទោះបីនៅមុនផុតរយៈពេលកំណត់ត្រូវបង្ហាញឱ្យទូទាត់សងប្រាក់ក៏ដោយ ។ ចំពោះរូបិយាណត្តិដែលចេញឱ្យទូទាត់សងប្រាក់ នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ រយៈពេលកំណត់សាមសិប (៣០) ថ្ងៃខាងលើនេះ ត្រូវតែបូកបន្ថែមជាមួយរយៈពេលក្រោយការបង្ហាញដែលមានបញ្ជាក់ច្បាស់នៅលើរូបិយាណត្តិ ។

រាល់អំពើដែលមានលក្ខណៈផ្ទាល់ខ្លួនសុទ្ធសាធរបស់អ្នកកាន់ ឬ របស់បុគ្គលដែលបានទទួលសិទ្ធិក្នុងការបង្ហាញរូបិយាណត្តិឱ្យទូទាត់សងប្រាក់ ឬ ក្នុងការធ្វើវិរុទ្ធវាទ មិនត្រូវបានចាត់ទុកជាករណីប្រធានស័ក្តិឡើយ ។

ការទទួលខុសត្រូវលើរូបិយាណត្តិដែលត្រូវបានបាត់បង់ ឬ ត្រូវបំផ្លាញអាចអនុវត្តបាន លុះណាតែមានការធានាពីភាគីអនុវត្តរូបិយាណត្តិដែលសងការខូចខាតទៅភាគីពាក់ព័ន្ធ ចំពោះការទាមទាររបស់បុគ្គលផ្សេងទៀតលើរូបិយាណត្តិតាមសេចក្តី

សម្រេចរបស់តុលាការ បើអ្នកកាន់បានទទួលរូបិយាណត្តិមកដោយសុចរិត ឬ ដោយគ្មានការធ្វេសប្រហែសធ្ងន់ធ្ងរ ។

## ផ្នែកទី ៨
## ការធ្វើអន្តរាគមន៍ដើម្បីទូទាត់សងប្រាក់

**មាត្រា ១១៥.-**

បហារីក អ្នកធ្វើបិដ្ឋិលេខ ឬ រូបិយបដិភោគីអាចបញ្ជាក់ឈ្មោះបុគ្គលដែលត្រូវធ្វើស្វីការ ឬ ទូទាត់សងប្រាក់បានក្នុងករណីចាំបាច់ ។

រូបិយាណត្តិអាចត្រូវបានធ្វើស្វីការ ឬ ទូទាត់សងដោយបុគ្គលដែលធ្វើអន្តរាគមន៍ដើម្បីទូទាត់សងប្រាក់ជួសកូនបំណុលណាមួយ ដែលទទួលរងសិទ្ធិធ្វើឧបាស្រ័យ ។

បុគ្គលដែលបានធ្វើអន្តរាគមន៍អាចជាតតិយភាគីបហារិត ឬ ភាគីដែលបានពាក់ព័ន្ធលើរូបិយាណត្តិរួចហើយ លើកលែងតែអ្នកធ្វើស្វីការ ។

នៅក្នុងរយៈពេលពីរ(០២)ថ្ងៃធ្វើការ បុគ្គលដែលបានធ្វើអន្តរាគមន៍ត្រូវតែជូនដំណឹងទៅភាគី ដែលខ្លួនបានធ្វើអន្តរាគមន៍ដើម្បីទូទាត់សងប្រាក់ ។ បើមិនគោរពតាមរយៈពេលកំណត់នេះទេ អ្នកធ្វើអន្តរាគមន៍ត្រូវទទួលខុសត្រូវចំពោះរាល់ការខូចខាតបើកើតមាន ដែលបណ្តាលមកពីការធ្វេសប្រហែសរបស់ខ្លួន ប៉ុន្តែសំណងលើការខូចខាតមិនត្រូវលើសពីចំនួនប្រាក់នៃរូបិយាណត្តិឡើយ ។

**មាត្រា ១១៦.-**

ស្វីការដោយអន្តរាគមន៍អាចកើតមាននៅក្នុងគ្រប់ករណីដែលអ្នកកាន់មានសិទ្ធិធ្វើឧបាស្រ័យ នៅមុនពេលដល់កាលប្រតិទានលើរូបិយាណត្តិដែលមិនទាន់ត្រូវបានធ្វើស្វីការ ។

កាលបើរូបិយាណត្តិមានបញ្ជាក់ឈ្មោះបុគ្គល ដែលត្រូវបានចាត់តាំងឱ្យធ្វើស្វី-ការ ឬ ឱ្យទូទាត់សងប្រាក់ ក្នុងករណីចាំបាច់នៅកន្លែងដែលទូទាត់សងប្រាក់ អ្នកកាន់មិនអាចអនុវត្តសិទ្ធិធ្វើឧបាស្រ័យរបស់ខ្លួន នៅមុនពេលដល់កាលប្រតិទានទល់នឹងបុគ្គលដែលត្រូវបានចាត់តាំង និងហត្ថលេខីបន្តបន្ទាប់ឡើយ លើកលែងតែអ្នកកាន់បានបង្ហាញ

រូបិយាណត្តិឱ្យទៅបុគ្គលនោះ និងមានសំអាងដោយវិរុទ្ធវាទអំពីការបដិសេធមិនព្រមធ្វើស្ទីការរបស់បុគ្គលដដែលនេះ ។

ក្នុងករណីអន្តរាគមន៍ផ្សេងៗទៀត អ្នកកាន់អាចបដិសេធការធ្វើស្ទីការដោយអន្តរាគមន៍ ។ ផ្ទុយទៅវិញ បើព្រមទទួលយកស្ទីការបែបនេះ អ្នកកាន់បាត់បង់សិទ្ធិធ្វើឧបាស្រ័យ នៅមុនពេលដល់ឥណប្រតិទានទល់នឹងបុគ្គលដែលបានធ្វើស្ទីការនេះនិងហត្ថលេខីបន្តបន្ទាប់ ។

មាត្រា ១១៧.-

ស្ទីការដោយអន្តរាគមន៍ត្រូវធ្វើនៅលើរូបិយាណត្តិ និងចុះហត្ថលេខាដោយបុគ្គលដែលធ្វើអន្តរាគមន៍ ។ ស្ទីការនេះបញ្ជាក់ឈ្មោះបុគ្គល ដែលត្រូវទទួលការទូទាត់សងប្រាក់ ហើយក្នុងករណីគ្មានការបញ្ជាក់នេះទេ ស្ទីការត្រូវបានចាត់ទុកថាបានធ្វើឱ្យបហារិក ។

មាត្រា ១១៨.-

អ្នកធ្វើស្ទីការដោយអន្តរាគមន៍ មានការទទួលខុសត្រូវដូចគ្នានឹងភាគីទទួលអន្តរាគមន៍ចំពោះអ្នកកាន់ និងអ្នកធ្វើបិដ្ឋិលេខទាំងឡាយ បន្ទាប់ក្រោយភាគីដែលបានទទួលអន្តរាគមន៍នោះ ។

ថ្វីបើមានការធ្វើស្ទីការដោយអន្តរាគមន៍ក្តី ក៏ភាគីទទួលអន្តរាគមន៍ និងភាគីទាំងឡាយដែលពាក់ព័ន្ធអាចទាមទារឱ្យអ្នកកាន់ប្រគល់រូបិយាណត្តិវិរុទ្ធវាទ និង ទាមទារបង្កាន់ដៃទទួលប្រាក់បានបើមាន ដើម្បីប្តូរនឹងការទូទាត់សងចំនួនប្រាក់ដូចមានចែងក្នុងមាត្រា ១០៨ នៃច្បាប់នេះ ។

មាត្រា ១១៩.-

ការទូទាត់សងប្រាក់ដោយអន្តរាគមន៍ អាចធ្វើបាននៅក្នុងរាល់ករណីដែលអ្នកកាន់មានសិទ្ធិធ្វើឧបាស្រ័យចំពោះរូបិយាណត្តិ នៅពេលដល់ឥណប្រតិទាន ឬ នៅមុនពេលដល់ឥណប្រតិទាន ។

ការទូទាត់សងប្រាក់ ត្រូវរាប់បញ្ចូលនូវចំនួនប្រាក់ទាំងអស់ដែលត្រូវទូទាត់សងដោយភាគីទទួលអន្តរាគមន៍ ។

ការទូទាត់សងប្រាក់ត្រូវតែបានធ្វើឡើងយ៉ាងយឺតបំផុត នៅថ្ងៃបន្ទាប់ពីថ្ងៃចុងក្រោយដែលអនុញ្ញាតឱ្យធ្វើវិវាទចំពោះការមិនទូទាត់សងប្រាក់ ។

មាត្រា ១២០.-

បើរូបិយាណត្តិត្រូវបានធ្វើស្ទីការដោយអន្តរាគមន៍ពីបុគ្គលដែលមានលំនៅនៅកន្លែងត្រូវទូទាត់សងប្រាក់ ឬ បើបុគ្គលទាំងឡាយដែលមានលំនៅនៅទីនោះដែរត្រូវបានចាត់តាំងជាអ្នកទំនាក់ទំនង ក្នុងករណីចាំបាច់ អ្នកកាន់ត្រូវបង្ហាញរូបិយាណត្តិឱ្យទៅបុគ្គលទាំងនេះ និងបើចាំបាច់ ត្រូវធ្វើវិវាទចំពោះការមិនទូទាត់សងប្រាក់យ៉ាងយឺតបំផុត នៅថ្ងៃបន្ទាប់ពីថ្ងៃចុងក្រោយដែលអនុញ្ញាតឱ្យធ្វើវិវាទ ។

បើគ្មានវិវាទនៅក្នុងរយៈពេលកំណត់នេះទេ ភាគីដែលបានចាត់តាំងអ្នកទំនាក់ទំនងក្នុងករណីចាំបាច់ខាងលើ ឬ ភាគីដែលរូបិយាណត្តិត្រូវបានធ្វើស្ទីការជាប្រយោជន៍ឱ្យ និងអ្នកធ្វើបិដ្ឋិលេខបន្តបន្ទាប់ត្រូវបានរួចផុតពីការទទួលខុសត្រូវ ។

មាត្រា ១២១.-

អ្នកកាន់ដែលបដិសេធការទូទាត់សងប្រាក់ដោយអន្តរាគមន៍បាត់បង់សិទ្ធិធ្វើឧបាស្រ័យរបស់ខ្លួនទល់នឹងបុគ្គលទាំងឡាយ ដែលត្រូវបានរួចផុតពីការទទួលខុសត្រូវដោយអន្តរាគមន៍ ។

មាត្រា ១២២.-

ការទូទាត់សងប្រាក់ដោយអន្តរាគមន៍ ត្រូវតែបានបញ្ជាក់យថាភាព អំពីការទទួលប្រាក់នៅលើរូបិយាណត្តិដោយមានឈ្មោះបុគ្គលដែលទទួលការទូទាត់សងប្រាក់ជូន ។ ក្នុងករណីគ្មានសេចក្តីបញ្ជាក់នេះទេ ការទូទាត់សងប្រាក់ត្រូវបានចាត់ទុកថាបានធ្វើឱ្យបុព្វការី ។

រូបិយាណត្តិ និងវិវាទ បើមាន ត្រូវតែបានប្រគល់ឱ្យទៅបុគ្គលដែលបានទូទាត់សងប្រាក់ដោយអន្តរាគមន៍ ។

មាត្រា ១២៣.-

បុគ្គលដែលបានទូទាត់សងប្រាក់ដោយអន្តរាគមន៍ ទទួលបានសិទ្ធិទាំងអស់នៃរូបិយាណត្តិទល់នឹងភាគីដែលខ្លួនបានធ្វើការទូទាត់សងប្រាក់ជូស និងបុគ្គលទាំងឡាយដែលមានការពាក់ព័ន្ធជាមួយភាគីចុងក្រោយនេះទៅលើរូបិយាណត្តិ ។ ប៉ុន្តែបុគ្គលដែលបានធ្វើអន្តរាគមន៍នេះ មិនអាចធ្វើបិដ្ឋិលេខរូបិយាណត្តិបន្តទៀតឡើយ ។

អ្នកធ្វើបិដ្ឋិលេខបន្ទាប់ពីភាគី ដែលទទួលការទូទាត់សងប្រាក់ជូសត្រូវរួចផុតពីការទទួលខុសត្រូវដោយអន្តរាគមន៍ ។

ក្នុងករណីមានការប្រជែងគ្នា ដើម្បីទូទាត់សងប្រាក់ដោយអន្តរាគមន៍ ការទូ-ទាត់សងដែលមានចំនួនប្រាក់ច្រើនជាងគេ ត្រូវមានអាទិភាព ។ បុគ្គលណាមួយដែលធ្វើអន្តរាគមន៍នៅក្នុងលក្ខណៈផ្ទុយពីវិធាននេះ ដោយយល់ដឹងពីហេតុការណ៍ច្បាស់លាស់ ត្រូវបាត់បង់សិទ្ធិធ្វើឧបាស្រ័យទល់នឹងបុគ្គលដែលត្រូវបានធ្វើឱ្យរួចផុតពីការទទួលខុសត្រូវដោយអន្តរាគមន៍ ។

## ផ្នែកទី ៩

## ផ្នែកទាំងឡាយនៃរូបិយាណត្តិមួយច្បាប់និងច្បាប់ចម្លង

មាត្រា ១២៤.-

នៅពេលដែលរូបិយាណត្តិ ត្រូវបានចេញមួយច្បាប់មានពីរ ឬ ច្រើនផ្នែកដូចគ្នា ផ្នែកនីមួយៗត្រូវចុះលេខ និងមានសេចក្តីយោងទៅផ្នែកផ្សេងទៀត ផ្នែកទាំងអស់បង្កើតបានជារូបិយាណត្តិមួយច្បាប់ ។

ស្ទីការ និងបិដ្ឋិលេខនីមួយៗ នៅលើរូបិយាណត្តិដែលបានចេញក្នុងមួយច្បាប់ អាចត្រូវបានសរសេរនៅលើផ្នែកណាមួយ ប៉ុន្តែត្រូវបានពាក់ព័ន្ធទៅលើរូបិយាណត្តិទាំងមូល ហើយមិនមែនទៅលើតែផ្នែកណាមួយដាច់គ្នានោះទេ ។ ស្ទីការ ឬ បិដ្ឋិលេខនីមួយៗទាំងនោះ ត្រូវបានសរសេរនៅលើតែផ្នែកមួយប៉ុណ្ណោះ ។

បហារីកដែលចុះហត្ថលេខាលើផ្នែកនីមួយៗ មានការទទួលខុសត្រូវនៅលើរូបិ-យាណត្តិទាំងមូល ហើយមិនមែនលើផ្នែកនីមួយៗនោះទេ ។

ភាគីដែលបានធ្វើផ្នែកមួយដើម្បីធ្វើស៊ីការ ត្រូវតែចង្អុលបង្ហាញនៅលើផ្នែកផ្សេងទៀត នូវឈ្មោះរបស់បុគ្គលដែលមានផ្នែកនោះនៅក្នុងដៃ ។ បុគ្គលនោះត្រូវតែប្រគល់ផ្នែកនោះឱ្យទៅអ្នកកាន់ស្របច្បាប់នៃផ្នែកមួយទៀត ។ បើបុគ្គលនោះបដិសេធ អ្នកកាន់អាចអនុវត្តសិទ្ធិឧបាស្រ័យបាន លុះត្រាតែខ្លួនបានធ្វើវិរុទ្ធវាទដោយបញ្ជាក់អំពី ៖

-ផ្នែកដែលបានធ្វើដើម្បីធ្វើស៊ីការ មិនត្រូវបានប្រគល់ឱ្យខ្លួនតាមការស្នើសុំ

-ស៊ីការ ឬការទូទាត់សងប្រាក់មិនត្រូវបានធ្វើនៅលើផ្នែកផ្សេងទៀត ។

## មាត្រា ១២៥.-

នៅពេលដែលអ្នកកាន់រូបិយាណត្តិមួយច្បាប់ធ្វើបិដ្ឋិលេខលើផ្នែកពីរ ឬ ច្រើនឱ្យទៅបុគ្គលផ្សេងគ្នា ៖

-អ្នកកាន់ត្រូវទទួលខុសត្រូវ នៅលើរាល់ផ្នែកទាំងនោះ ហើយអ្នកធ្វើបិដ្ឋិលេខនីមួយៗបន្ទាប់ពីអ្នកកាន់ ត្រូវទទួលខុសត្រូវលើផ្នែកដែលខ្លួនបានធ្វើបិដ្ឋិលេខដូចជារូបិយាណត្តិដាច់ដោយឡែកពីគ្នា

-អ្នកកាន់ស្របច្បាប់នៃផ្នែកដែលមានកម្មសិទ្ធិទីមួយ មានសិទ្ធិទាមទារប្រាក់ដែលបហារីកបានសងឱ្យទៅបុគ្គលណាមួយ ឬ បហារិត ដែលមិនបានធ្វើស៊ីការលើរូបិយាណត្តិ ។

នៅពេលដែលបហារិតធ្វើស៊ីការច្រើនជាងមួយផ្នែក ហើយផ្នែកដែលបានធ្វើស៊ីការនោះធ្លាក់ទៅក្នុងដៃរបស់អ្នកកាន់ស្របច្បាប់ផ្សេងគ្នា បហារិតត្រូវទទួលខុសត្រូវលើរាល់ផ្នែកទាំងនោះ ដូចជារូបិយាណត្តិដាច់ដោយឡែកពីគ្នា ។

## មាត្រា ១២៦.-

នៅពេលដែលអ្នកធ្វើស៊ីការលើរូបិយាណត្តិ ដែលបានចេញមួយច្បាប់ ធ្វើការទូទាត់សងប្រាក់ ដោយពុំបានទាមទារឱ្យប្រគល់មកវិញនូវផ្នែកដែលមានស៊ីការរបស់ខ្លួន ហើយផ្នែកនោះនៅក្នុងដៃរបស់អ្នកកាន់ស្របច្បាប់ នៅពេលដល់កាលប្រតិទាន អ្នកធ្វើស៊ីការនោះ ត្រូវទទួលខុសត្រូវចំពោះអ្នកកាន់នេះ ។

បហារីកនៃរូបិយាណត្តិមួយច្បាប់ ត្រូវរួចផុតពីការទទួលខុសត្រូវ នៅពេលដែលខ្លួនបានសងប្រាក់ នៅលើផ្នែកណាមួយដែលបានយកមកបង្ហាញ ។

ក្រោមបទប្បញ្ញត្តិដែលមានចែងក្នុងមាត្រា ១២៥ និងមាត្រា ១២៦ នៃច្បាប់នេះ នៅពេលដែលផ្នែកណាមួយនៃរូបិយាណត្តិ ត្រូវបានរួចបំណុលដោយការទូទាត់សងប្រាក់ ឬ តាមរបៀបផ្សេងទៀត រូបិយាណត្តិទាំងមូលត្រូវបានរួចបំណុល ។

មាត្រា ១២៧.-

អ្នកកាន់មានសិទ្ធិធ្វើច្បាប់ចម្លងរូបិយាណត្តិ ។

ច្បាប់ចម្លងត្រូវតែធ្វើឱ្យបានត្រឹមត្រូវតាមច្បាប់ដើមជាមួយនិងបិដ្ឋិលេខ និងសេចក្តីបញ្ជាក់ផ្សេងៗទៀតដែលមាននៅក្នុងនោះ ។ ច្បាប់ចម្លងនេះត្រូវបញ្ជាក់ច្បាស់លាស់នូវចំនួនដែលបានធ្វើ ។

ច្បាប់ចម្លងអាចត្រូវបានធ្វើបិដ្ឋិលេខ និងធ្វើរូបិយបដិភោគនៅក្នុងលក្ខណៈដូចគ្នា ហើយមានសុពលភាពដូចគ្នានឹងច្បាប់ដើមដែរ ។

មាត្រា ១២៨.-

ច្បាប់ចម្លងត្រូវតែបញ្ជាក់បុគ្គលដែលកាន់កាប់ច្បាប់ដើម ។ អ្នកកាន់ច្បាប់ដើមត្រូវទទួលខុសត្រូវក្នុងការប្រគល់ច្បាប់ដើមដែលមានចែងខាងលើ ឱ្យទៅអ្នកកាន់ស្របច្បាប់នៃច្បាប់ចម្លងនោះ ។

បើអ្នកកាន់ច្បាប់ដើមបដិសេធ អ្នកកាន់ច្បាប់ចម្លងអាចអនុវត្តសិទ្ធិធ្វើឧបាស្រ័យទល់នឹងបុគ្គលទាំងឡាយដែលបានធ្វើបិដ្ឋិលេខ ឬ ធ្វើរូបិយបដិភោគច្បាប់ចម្លង លុះត្រាតែបានបញ្ជាក់នៅលើវិរុទ្ធវាទថា ច្បាប់ដើមមិនទាន់ត្រូវប្រគល់មកវិញតាមសំណើរបស់ខ្លួននៅឡើយ ។

ក្រោយពីបិដ្ឋិលេខចុងក្រោយដែលធ្វើឡើងមុនពេលធ្វើច្បាប់ចម្លង កាលបើច្បាប់ដើមមានបដិញ្ញាថា **ចាប់ផ្តើមពីពេលនេះ បិដ្ឋិលេខមានសុពលភាពនៅពេលណាដែលបិដ្ឋិលេខធ្វើឡើងលើច្បាប់ចម្លងតែប៉ុណ្ណោះ** ឬ តាមរូបមន្តដែលមានន័យដូចគ្នា បិដ្ឋិលេខបន្ទាប់មកទៀតនៅលើច្បាប់ដើម ត្រូវចាត់ទុកជាមោឃៈ ។

## ផ្នែកទី ១០
## ការកែលើរូបិយាណត្តិ

មាត្រា ១២៩.-

ក្នុងករណីមានការកែលើខ្លឹមសារនៃរូបិយាណត្តិ រាល់ភាគីដែលបានចុះហត្ថលេខាបន្ទាប់ពីការកែ ត្រូវជាប់ពាក់ព័ន្ធទៅតាមខ្លឹមសារដែលបានកែ ។ ភាគីទាំងឡាយដែលបានចុះហត្ថលេខាមុនការកែ ត្រូវជាប់ពាក់ព័ន្ធទៅតាមខ្លឹមសារដើមនៃរូបិយាណត្តិ ។

## ផ្នែកទី ១១
## រយៈពេលកំណត់នៃការធ្វើឧបាស្រ័យ

មាត្រា ១៣០.-

រាល់ឧបាស្រ័យដែលកើតឡើងពីរូបិយាណត្តិ ទល់នឹងអ្នកធ្វើស៊ីការ មានរយៈពេលបី(០៣)ឆ្នាំ គិតពីថ្ងៃឥណប្រតិទាន ។

រាល់ឧបាស្រ័យដែលធ្វើឡើងដោយអ្នកកាន់ ទល់នឹងអ្នកធ្វើបិដ្ឋិលេខទាំងឡាយ និងបហារីក មានរយៈពេលមួយឆ្នាំ គិតពីថ្ងៃធ្វើវិរុទ្ធវាទត្រឹមត្រូវតាមរយៈពេលកំណត់ ឬ គិតពីថ្ងៃឥណប្រតិទាន កាលបើមានបដិញ្ញាថា បង្វិលទិញដោយគ្មានសោហ៊ុយ ឬ បង្វិលទិញដោយគ្មានវិរុទ្ធវាទ ឬ សេចក្តីផ្សេងណាមួយដែលមានន័យដូចគ្នា ។

រាល់ឧបាស្រ័យរបស់អ្នកធ្វើបិដ្ឋិលេខ ទល់នឹងអ្នកធ្វើបិដ្ឋិលេខផងគ្នា និងបហារីក មានរយៈពេលប្រាំមួយ(០៦)ខែ គិតពីថ្ងៃដែលអ្នកធ្វើបិដ្ឋិលេខបានទទួលយក និងបានទូទាត់សងរូបិយាណត្តិ ឬ គិតពីថ្ងៃដែលបានទទួលរងការប្តឹង ។

មាត្រា ១៣១.-

ការកំណត់រយៈពេលធ្វើឧបាស្រ័យដូចមានចែងក្នុងមាត្រា ១៣០ នៃច្បាប់នេះមានសុពលភាពទៅលើតែបុគ្គលណាមួយ ដែលរយៈពេលនោះត្រូវបានកំណត់ប៉ុណ្ណោះ ។

## ផ្នែកទី ១២
## ការគណនារយៈពេលកំណត់

**មាត្រា ១៣២.-**

រូបិយាណត្តិដែលដល់រយៈពេលកំណត់ទូទាត់សងប្រាក់ នៅថ្ងៃឈប់សម្រាកផ្លូវការ នឹងត្រូវទូទាត់សងនៅថ្ងៃធ្វើការបន្ទាប់ ។ រាល់សកម្មភាពដែលទាក់ទងទៅនឹងរូបិយាណត្តិ ជាពិសេសការបង្ហាញឱ្យធ្វើស៊ីការ និងវិវឌ្ឍវាទអាចត្រូវធ្វើឡើងបានតែក្នុងថ្ងៃធ្វើការប៉ុណ្ណោះ ។

កាលបើសកម្មភាពទាំងនេះ ត្រូវតែបានធ្វើនៅក្នុងរយៈពេលកំណត់មួយ ដែលថ្ងៃចុងក្រោយជាថ្ងៃឈប់សម្រាកផ្លូវការ រយៈពេលកំណត់នោះត្រូវបានពន្យាររហូតដល់ថ្ងៃធ្វើការទីមួយបន្ទាប់ ។ ថ្ងៃឈប់សម្រាកត្រូវបានរាប់បញ្ចូលក្នុងការគណនារយៈពេលកំណត់ទាំងនោះដែរ ។

**មាត្រា ១៣៣.-**

រយៈពេលកំណត់ទាំងឡាយដែលចែងក្នុងជំពូកនេះ នឹងមិនរាប់បញ្ចូលជាមួយផងទេនូវថ្ងៃដែលរយៈពេលនោះចាប់ផ្តើម ។

**មាត្រា ១៣៤.-**

ទោះបីតាមផ្លូវច្បាប់ក្តីឬតាមផ្លូវតុលាការក្តី ពុំអនុញ្ញាតឱ្យមានរយៈពេលអនុគ្រោះឡើយ ។

## ជំពូកទី ៤
## ប័ណ្ណសងតាមបញ្ជា

## ផ្នែកទី ១
## ការចេញផ្សាយនិងទម្រង់នៃប័ណ្ណសងតាមបញ្ជា

**មាត្រា ១៣៥.-**

ប័ណ្ណសងតាមបញ្ជា ជាការសន្យាលាយលក្ខណ៍អក្សរដោយឥតល័ក្ខខ័ណ្ឌដែលធ្វើឡើងនិងចុះហត្ថលេខាដោយបុគ្គលជាអ្នកចេញប័ណ្ណដែលសន្យាសងចំនួនប្រាក់

ជាកំណត់មួយ ឱ្យទៅ ឬ តាមបញ្ជាបុគ្គលមួយទៀត ឬ អ្នកកាន់ ។ ប័ណ្ណសងតាមបញ្ជាត្រូវតែបានទូទាត់សងប្រាក់នៅពេលដល់ឥណប្រតិទាន ហើយស្របតាមរាល់កាតព្វកិច្ចដែលមានចែងនៅក្នុងជំពូកនេះ ។

មាត្រា ១៣៦.-

ប័ណ្ណសងតាមបញ្ជាជាឧបករណ៍ឥណទាន ។ ប័ណ្ណសងតាមបញ្ជាអាចត្រូវបានសរសេរជាអក្សរខ្មែរ ឬ អក្សរបរទេស ហើយត្រូវតែមាននិទ្ទេសទាំងឡាយដូចខាងក្រោម :

-ពាក្យថា ប័ណ្ណសងតាមបញ្ជា ដែលចារឹកជាភាសាណាមួយប្រើក្នុងការចេញប័ណ្ណ

-ការសន្យាទូទាត់សងដោយឥតល័ក្ខខ័ណ្ឌនូវចំនួនប្រាក់ជាកំណត់មួយ

-រយៈពេលកំណត់ត្រូវទូទាត់សងប្រាក់

-កន្លែងដែលត្រូវធ្វើការទូទាត់សងប្រាក់

-ឈ្មោះរបស់បុគ្គល ដែលទទួលការទូទាត់សងប្រាក់ ឬ ឈ្មោះរបស់បុគ្គលដែលមានបញ្ជាឱ្យទូទាត់សងប្រាក់

-កាលបរិច្ឆេទ និងកន្លែងដែលប័ណ្ណសងតាមបញ្ជានោះត្រូវបានចេញផ្សាយ

-ហត្ថលេខារបស់អ្នកចេញប័ណ្ណ ដែលជាបុគ្គលធ្វើការសន្យាលើប័ណ្ណសងតាមបញ្ជា ។

មាត្រា ១៣៧.-

ឧបករណ៍ដែលខ្វះនិទ្ទេសណាមួយ ដូចមានចែងនៅក្នុងមាត្រា ១៣៦ នៃច្បាប់នេះពុំមានសុពលភាពជាប័ណ្ណសងតាមបញ្ជាឡើយ លើកលែងតែក្នុងករណីទាំងឡាយដែលបញ្ជាក់នៅក្នុងកថាខណ្ឌដូចខាងក្រោម :

១-ប័ណ្ណសងតាមបញ្ជា ដែលមិនបានបញ្ជាក់រយៈពេលកំណត់ទូទាត់សងប្រាក់ ត្រូវបានចាត់ទុកថាត្រូវទូទាត់សងប្រាក់នៅពេលបង្ហាញ ។

២-បើគ្មានការបញ្ជាក់ជាពិសេសទេ កន្លែងដែលបញ្ជាក់នៅក្បែរឈ្មោះរបស់អ្នកចេញប័ណ្ណ ត្រូវបានចាត់ទុកថាជាកន្លែងត្រូវទូទាត់សងប្រាក់ និងជាលំនៅរបស់អ្នកចេញប័ណ្ណផងដែរ ។

៣-ប័ណ្ណសងតាមបញ្ជា ដែលមិនបានបញ្ជាក់កន្លែងនៃការចេញផ្សាយ ត្រូវបានចាត់ទុកថា ចេញនៅកន្លែងដែលបញ្ជាក់នៅក្បែរឈ្មោះរបស់អ្នកចេញប័ណ្ណ ។

៤-ប័ណ្ណសងតាមបញ្ជា អាចត្រូវចេញដើម្បីទូទាត់សងប្រាក់ទៅអ្នកកាន់ ។ ប័ណ្ណសងតាមបញ្ជាដែលគ្មានឈ្មោះបុគ្គល ដែលទទួលការទូទាត់សងប្រាក់ ឬ ឈ្មោះបុគ្គលដែលមានបញ្ជាឱ្យទូទាត់សងប្រាក់ ត្រូវបានចាត់ទុកថាជាប័ណ្ណសងតាមបញ្ជាទូទាត់សងប្រាក់ឱ្យទៅអ្នកកាន់ ។

**មាត្រា ១៣៨.-**

ប័ណ្ណសងតាមបញ្ជាអាចត្រូវបានទូទាត់សងប្រាក់ នៅកន្លែងក្រៅពីលំនៅរបស់អ្នកចេញប័ណ្ណ រួមទាំងនៅលំនៅរបស់តតិយបុគ្គល នៅលំនៅរបស់អ្នកចេញប័ណ្ណ ឬ នៅកន្លែងផ្សេងទៀត ។

**មាត្រា ១៣៩.-**

ចំពោះប្រភេទប័ណ្ណសងតាមបញ្ជា ដែលត្រូវទូទាត់សងប្រាក់នៅពេលបង្ហាញ ឬ ត្រូវទូទាត់សងប្រាក់ នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ អ្នកចេញប័ណ្ណអាចចែងល័ក្ខខ័ណ្ឌថា ចំនួនប្រាក់ទូទាត់សងត្រូវមានការប្រាក់ ។ ក្នុងករណីនៃប័ណ្ណសងតាមបញ្ជាផ្សេងពីខាងលើ បដិញ្ញានេះ មិនត្រូវចាត់ទុកជាបានការឡើយ ។

អត្រាការប្រាក់ត្រូវតែបានបញ្ជាក់នៅលើប័ណ្ណសងតាមបញ្ជា ។ បើគ្មានសេចក្តីបញ្ជាក់នេះទេ បដិញ្ញាខាងលើនេះមិនត្រូវចាត់ទុកជាបានការឡើយ ។

ការប្រាក់ ត្រូវបានគណនាចាប់ពីកាលបរិច្ឆេទចេញប័ណ្ណសងតាមបញ្ជា លើកលែងតែមានការបញ្ជាក់ពីកាលបរិច្ឆេទផ្សេងទៀត ។

**មាត្រា ១៤០.-**

ក្នុងករណីដែលចំនួនប្រាក់ត្រូវទូទាត់សងដោយប័ណ្ណសងតាមបញ្ជា ត្រូវបានសរសេរជាតួអក្សរផង និងជាតួលេខផង ហើយកាលបើមានលំអៀងគ្នា ចំនួនប្រាក់ជា

តួអក្សរជាចំនួនដែលត្រូវយកជាបានការ ។

ក្នុងករណីដែលចំនួនប្រាក់ត្រូវទូទាត់សងដោយប័ណ្ណសងតាមបញ្ជា ត្រូវបានសរសេរច្រើនដងជាតួអក្សរ ឬ ជាតួលេខ និងកាលបើមានចំនួនលំអៀងគ្នា ចំនួនប្រាក់ដែលតូចជាងជាចំនួនត្រូវយកជាបានការ ។

មាត្រា ១៤១.-

រាល់កាតព្វកិច្ចនៃបុគ្គលដទៃទៀត ដែលបានចុះហត្ថលេខាលើប័ណ្ណសងតាមបញ្ជា នៅតែមានតម្លៃដដែល ទោះបីប័ណ្ណសងតាមបញ្ជានោះមានហត្ថលេខារបស់បុគ្គលអសមត្ថភាព ឬ ហត្ថលេខាក្លែងបន្លំ ឬ ហត្ថលេខារបស់បុគ្គលតាមការប្រឌិត ឬ ហត្ថលេខាដែលតាមហេតុផលផ្សេងទៀត មិនអាចធ្វើឱ្យបុគ្គលដែលបានចុះហត្ថលេខា ឬ បានចុះហត្ថលេខាជំនួសមានការទទួលខុសត្រូវ ។

មាត្រា ១៤២.-

បុគ្គលណាដែលបានចុះហត្ថលេខានៅលើប័ណ្ណសងតាមបញ្ជា ក្នុងនាមបុគ្គលមួយទៀតដែលខ្លួនគ្មានសិទ្ធិតំណាងឱ្យទាល់តែសោះ ត្រូវមានការពាក់ព័ន្ធផ្ទាល់ជាភាគីមួយលើប័ណ្ណសងតាមបញ្ជានោះ ហើយបើខ្លួនបានទូទាត់សងប្រាក់ ត្រូវមានសិទ្ធិដូចគ្នានឹងបុគ្គលដែលខ្លួនបានទទួលភ័ប់រងជួសឱ្យ ។ វិធានដូចគ្នានេះក៏អនុវត្តទៅលើអាណត្តិជន ដែលបានអនុវត្តហួសសិទ្ធិរបស់ខ្លួនផងដែរ ។

មាត្រា ១៤៣.-

បើប័ណ្ណសងតាមបញ្ជាមានលក្ខណៈមិនពេញលេញនៅពេលចេញផ្សាយ ហើយត្រូវបានធ្វើឱ្យពេញលក្ខណៈតាមបែបផ្សេងខុសពីការព្រមព្រៀងដែលពាក់ព័ន្ធ ការមិនគោរពតាមការព្រមព្រៀងនេះ មិនអាចយកជាមូលហេតុប្តឹងអ្នកកាន់បានឡើយ លើកលែងតែអ្នកកាន់នេះបានទទួលប័ណ្ណសងតាមបញ្ជាមកដោយទុច្ចរិត ឬ មានកំហុសដោយការធ្វេសប្រហែសធ្ងន់ធ្ងរ ។

67/125

## ផ្នែកទី ២
## បិដ្ឋិលេខប័ណ្ណសងតាមបញ្ជា

**មាត្រា ១៥៤.-**

ប័ណ្ណសងតាមបញ្ជា ដែលចេញឱ្យទូទាត់សងចំពោះបុគ្គលណាមួយច្បាស់លាស់ ដោយមាន ឬ គ្មានបញ្ជាក់ពាក្យថា សងតាមបញ្ជា អាចត្រូវបានផ្ទេរដោយបិដ្ឋិលេខ ។

នៅពេលដែលអ្នកចេញប័ណ្ណ បានបញ្ចូលក្នុងប័ណ្ណសងតាមបញ្ជា ដែលចេញ ដើម្បីទូទាត់សងប្រាក់ចំពោះបុគ្គលណាមួយច្បាស់លាស់នូវពាក្យ មិនសងតាមបញ្ជា ឬ ពាក្យដែលមានន័យដូចគ្នា ប័ណ្ណសងតាមបញ្ជានោះអាចត្រូវបានផ្ទេរស្របតាមទម្រង់ និងមានសុពលភាព ជាការផ្ទេរជាធម្មតាតែប៉ុណ្ណោះ ។

ប័ណ្ណសងតាមបញ្ជាអាចត្រូវបានធ្វើបិដ្ឋិលេខ ទោះបីឱ្យទៅអ្នកចេញប័ណ្ណក្តី ឬ ឱ្យទៅភាគីណាមួយផ្សេងទៀតនៃប័ណ្ណសងតាមបញ្ជានោះក្តី ។ បុគ្គលទាំងនេះអាចធ្វើ បិដ្ឋិលេខប័ណ្ណសងតាមបញ្ជានោះបន្តទៀតបាន ។

ឧបករណ៍ដែលមានទម្រង់ជាប័ណ្ណសងតាមបញ្ជា ដែលអាចទូទាត់សងបានតាម បញ្ជាអ្នកចេញប័ណ្ណ មិនមែនជាប័ណ្ណសងតាមបញ្ជាក្រោមជំពូកនេះឡើយ លើកលែង តែប័ណ្ណនេះត្រូវបានធ្វើបិដ្ឋិលេខដោយអ្នកចេញប័ណ្ណ។

**មាត្រា ១៥៥.-**

បិដ្ឋិលេខត្រូវតែបានធ្វើឡើងដោយឥតល័ក្ខខ័ណ្ឌ ។ ល័ក្ខខ័ណ្ឌណាមួយដែលត្រូវ បានដាក់ចេញជាកម្មវត្ថុចំពោះការធ្វើបិដ្ឋិលេខប័ណ្ណសងតាមបញ្ជា មិនត្រូវយកជាបាន ការឡើយ ។

បិដ្ឋិលេខលើមួយផ្នែកនៃចំនួនប្រាក់ក្នុងប័ណ្ណសងតាមបញ្ជា ត្រូវចាត់ទុកជា មោឃៈ ។

បិដ្ឋិលេខដែលធ្វើឱ្យ អ្នកកាន់ មានតម្លៃស្មើនឹងបិដ្ឋិលេខចំហ ។

ស្មេះ·

**មាត្រា ១៤៦.-**

បិដ្ឋិលេខត្រូវតែបានធ្វើជាលាយលក្ខណ៍អក្សរ នៅលើខ្នងប័ណ្ណសងតាមបញ្ជា ឬ នៅលើក្រដាសបិទភ្ជាប់បន្ថែមហៅថា **អនុបត្រ** ហើយត្រូវតែបានចុះហត្ថលេខាដោយអ្នកធ្វើបិដ្ឋិលេខ ។

បិដ្ឋិលេខ អាចមិនបញ្ជាក់ពីអត្ថគាហក ឬ អាចមានតែហត្ថលេខារបស់អ្នកធ្វើបិដ្ឋិលេខប៉ុណ្ណោះហៅថា **បិដ្ឋិលេខចំហ** ។

**មាត្រា ១៤៧.-**

បិដ្ឋិលេខ ផ្ទេរសិទ្ធិទាំងអស់នៃប័ណ្ណសងតាមបញ្ជាឱ្យទៅអ្នកកាន់ ។

បើជាបិដ្ឋិលេខចំហ អ្នកកាន់អាច :

-បំពេញកន្លែងចំហ ឬ ដោយឈ្មោះរបស់ខ្លួនផ្ទាល់ ឬ ដោយឈ្មោះរបស់បុគ្គលដទៃទៀត

-ធ្វើបិដ្ឋិលេខបន្តប័ណ្ណសងតាមបញ្ជាជាចំហ ឬ ឱ្យបុគ្គលដទៃទៀត

-ផ្ទេរប័ណ្ណសងតាមបញ្ជាឱ្យទៅតតិយបុគ្គល ដោយមិនចាំបាច់បំពេញកន្លែងចំហ និងមិនចាំបាច់ធ្វើបិដ្ឋិលេខ ។

**មាត្រា ១៤៨.-**

បើគ្មានបដិញ្ញាផ្ទុយទេ អ្នកធ្វើបិដ្ឋិលេខត្រូវទទួលខុសត្រូវលើការទូទាត់សងប្រាក់ ។

អ្នកធ្វើបិដ្ឋិលេខអាចហាមឃាត់ការធ្វើបិដ្ឋិលេខណាមួយបន្តទៀត ហើយក្នុងករណីនេះ បុគ្គលដែលបានហាមឃាត់ មិនទទួលខុសត្រូវទូទាត់សងប្រាក់ទៅបុគ្គលទាំងឡាយណា ដែលប័ណ្ណសងតាមបញ្ជាត្រូវបានធ្វើបិដ្ឋិលេខបន្តឱ្យទៅនោះឡើយ ។

បិដ្ឋិលេខលើប័ណ្ណសងតាមបញ្ជាចំពោះអ្នកកាន់ នាំឱ្យអ្នកធ្វើបិដ្ឋិលេខមានការទទួលខុសត្រូវស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិធ្វើឧបាស្រ័យ ប៉ុន្តែប័ណ្ណសងតាមបញ្ជានោះមិនអាចប្រែក្លាយទៅជាប័ណ្ណសងតាមបញ្ជា **ដើម្បីសងតាមបញ្ជា**ឡើយ ។

**មាត្រា ១៤៩.-**

ម្ចាស់ប័ណ្ណសងតាមបញ្ជាដែលអាចធ្វើបិដ្ឋិលេខបាន ជាអ្នកកាន់ស្របច្បាប់

71/45

បើបុគ្គលនេះបានក្លាយជាម្ចាស់ប័ណ្ណសងតាមបញ្ជា តាមរយៈការធ្វើបិដ្ឋិលេខជាបន្តបន្ទាប់ ទោះបីបិដ្ឋិលេខចុងក្រោយជាបិដ្ឋិលេខចំហក៏ដោយ ។ ក្នុងករណីនេះ បិដ្ឋិលេខដែលលុបចោលមិនត្រូវយកជាបានការឡើយ ។ កាលបើបិដ្ឋិលេខចំហត្រូវបានបន្តដោយបិដ្ឋិលេខមួយទៀត បុគ្គលដែលចុះហត្ថលេខាធ្វើបិដ្ឋិលេខចុងក្រោយនេះ ត្រូវបានចាត់ទុកថាបានទទួលប័ណ្ណសងតាមបញ្ជា តាមរយៈបិដ្ឋិលេខចំហ ។

នៅពេលដែលបុគ្គលណាមួយបានបាត់បង់សិទ្ធិកាន់កាប់ប័ណ្ណសងតាមបញ្ជា ដោយមូលហេតុណាក៏ដោយ ទោះបីជាប័ណ្ណសងតាមបញ្ជាចេញឱ្យទៅអ្នកកាន់ក្តី ឬ អាចធ្វើបិដ្ឋិលេខបានក្តី ដែលអ្នកកាន់មានសិទ្ធិជាម្ចាស់ដូចមានចែងនៅក្នុងកថាខណ្ឌខាងលើនៃមាត្រានេះ អ្នកកាន់ដែលទទួលបានប័ណ្ណសងតាមបញ្ជាមកជាកម្មសិទ្ធិ មិនត្រូវបានបង្ខំឱ្យបោះបង់ចោលប័ណ្ណសងតាមបញ្ជាឡើយ លើកលែងតែប័ណ្ណសងតាមបញ្ជានោះបានមកដោយទុច្ចរិត ឬ ដោយមានកំហុសពីការធ្វេសប្រហែសធ្ងន់ធ្ងរ ។

## មាត្រា ១៥០.-

បុគ្គលទាំងឡាយដែលប្តឹងអំពីប័ណ្ណសងតាមបញ្ជា មិនអាចប្តឹងអ្នកកាន់ដោយសំអាងលើទំនាក់ទំនងផ្ទាល់ខ្លួនជាមួយអ្នកចេញប័ណ្ណ ឬ ជាមួយអ្នកកាន់មុនៗបានឡើយ លើកលែងតែក្នុងការទទួលប័ណ្ណសងតាមបញ្ជា អ្នកកាន់បានដឹងច្បាស់ថានឹងនាំឱ្យខូចប្រយោជន៍ដល់កូនបំណុល ។

កថាខណ្ឌខាងលើនៃមាត្រានេះ មិនអនុវត្តចំពោះប័ណ្ណសងតាមបញ្ជាដែលចេញដើម្បីទូទាត់សងទៅបុគ្គលណាមួយច្បាស់លាស់ ដែលក្នុងនោះមានពាក្យថា មិនសងតាមបញ្ជា ឬ ប្រយោគណាមួយដែលមានន័យដូចគ្នា ។

## មាត្រា ១៥១.-

កាលបើបិដ្ឋិលេខមានពាក្យថា តម្លៃសម្រាប់ការបំណុល ឬ សម្រាប់បេឡានិច្ច័យ ឬ តាមការប្រគល់សិទ្ធិ ឬ ប្រយោគណាមួយផ្សេងទៀតដែលបញ្ជាក់ពីការប្រគល់សិទ្ធិសាមញ្ញ អ្នកកាន់អាចអនុវត្តសិទ្ធិទាំងអស់នៃប័ណ្ណសងតាមបញ្ជា ប៉ុន្តែអ្នកកាន់នេះអាចធ្វើបិដ្ឋិលេខបន្តក្នុងនាមជាភ្នាក់ងារតែប៉ុណ្ណោះ ។

ក្នុងករណីនេះ ភាគីពាក់ព័ន្ធទាំងឡាយអាចប្ដឹងអ្នកកាន់បាន ហើយអ្នកកាន់នេះក៏អាចប្ដឹងអ្នកធ្វើបិដ្ឋិលេខបានផងដែរ ។

ការប្រគល់សិទ្ធិដែលមាននៅក្នុងបិដ្ឋិលេខ មិនអាចរលត់បានដោយហេតុផលនៃមរណភាពរបស់ភាគីដែលបានផ្ដល់ការប្រគល់សិទ្ធិ ឬ ដោយហេតុផលដែលបុគ្គលនេះបានក្លាយជាអសមត្ថភាពនីត្យានុកូលឡើយ ។

នៅពេលដែលប័ណ្ណសងតាមបញ្ជា ត្រូវបានបង្ហាញឱ្យធនាគារធ្វើបេឡានិច័យ ប័ណ្ណសងតាមបញ្ជានោះជាបញ្ជាទូទាត់ដែលគ្រប់គ្រងដោយជំពូកទី ៥ ស្ដីពីប្រតិបត្តិការទូទាត់សងប្រាក់នៃច្បាប់នេះ ។ ក្នុងករណីមិនមានសង្គតិភាពអំពីប័ណ្ណសងតាមបញ្ជារវាងបទប្បញ្ញត្តិនៃជំពូកនេះ និងជំពូកទី ៥ នៃច្បាប់នេះ បទប្បញ្ញត្តិនៃជំពូកនេះត្រូវយកជាបានការ ។

មាត្រា ១៥២.–

កាលបើបិដ្ឋិលេខមួយមានសេចក្ដីបញ្ជាក់ថា តម្លៃសម្រាប់ធានា ឬ តម្លៃសម្រាប់ដាក់បញ្ចាំ ឬ សេចក្ដីបញ្ជាក់ណាផ្សេងទៀតដែលមានន័យថាសម្រាប់ដាក់បញ្ចាំ អ្នកកាន់អាចអនុវត្តសិទ្ធិទាំងអស់នៃប័ណ្ណសងតាមបញ្ជានោះ ប៉ុន្តែបិដ្ឋិលេខដែលខ្លួនបានធ្វើឡើង មានប្រសិទ្ធភាពត្រឹមតែជាបិដ្ឋិលេខដោយភ្នាក់ងារតែប៉ុណ្ណោះ ។

បណ្ដាភាគីដែលពាក់ព័ន្ធមិនអាចប្ដឹងអ្នកកាន់បាន ដោយសំអាងលើទំនាក់ទំនងផ្ទាល់របស់ខ្លួនជាមួយអ្នកធ្វើបិដ្ឋិលេខឡើយ លើកលែងតែក្នុងការទទួលប័ណ្ណសងតាមបញ្ជា អ្នកកាន់បានដឹងច្បាស់ថានឹងនាំឱ្យខូចប្រយោជន៍ដល់កូនបំណុល ។

មាត្រា ១៥៣.–

បិដ្ឋិលេខដែលធ្វើឡើងក្រោយពីការធ្វើវិរុទ្ធវាទ ឬ ក្រោយពីការធ្វើប្រតិវេទន៍ដែលសមមូលគ្នា ឬ ក្រោយពីផុតរយៈពេលកំណត់សម្រាប់បង្ហាញឱ្យទូទាត់សងប្រាក់អាចនឹង :

-អនុវត្តបានតាមការផ្ទេរធម្មតាតែប៉ុណ្ណោះ

-មិនអនុវត្តក្នុងការផ្ដល់សិទ្ធិក្រោមមាត្រា ១៤៩ និងមាត្រា ១៥០ នៃច្បាប់នេះ ។

ð

ð

បើគ្មានកស្តុតាងផ្ទុយទេ បិដ្ឋិលេខដែលគ្មានចុះកាលបរិច្ឆេទ ត្រូវចាត់ទុកថាបាន ធ្វើនៅលើប័ណ្ណសងតាមបញ្ជាមុនធ្វើវិរុទ្ធវាទ ឬ ប្រតិវេទន៍ដែលសមមូលគ្នា ឬ មុនផុត រយៈពេលកំណត់ ដែលបានយោងក្នុងកថាខណ្ឌទី ១ នៃមាត្រា ១៥៣ នេះ ។

## ផ្នែកទី ៣
## ការទទួលខុសត្រូវរបស់អ្នកចេញប័ណ្ណសងតាមបញ្ជា

**មាត្រា ១៥៤.-**

ក្នុងការចេញប័ណ្ណសងតាមបញ្ជា អ្នកចេញប័ណ្ណសន្យាទូទាត់សងប្រាក់នៅពេល ដល់ឥណប្រតិទាន ។

បើមិនបានទូទាត់សងប្រាក់ អ្នកកាន់អាចធ្វើឧបាស្រ័យដោយផ្ទាល់លើប័ណ្ណសង តាមបញ្ជាទល់នឹងអ្នកចេញប័ណ្ណ ដើម្បីទាមទារនូវអ្វីដែលអាចធ្វើបានស្របតាមមាត្រា ១៧៥ និងមាត្រា ១៧៦ នៃច្បាប់នេះ ។

**មាត្រា ១៥៥.-**

ប័ណ្ណសងតាមបញ្ជាដែលត្រូវទូទាត់សងប្រាក់នៅក្នុងរយៈពេលកំណត់មួយ ក្រោយការបង្ហាញ ត្រូវតែបានបង្ហាញឱ្យធ្វើទិដ្ឋាការនៅក្នុងរយៈពេលមួយឆ្នាំ គិតពីកាល បរិច្ឆេទចេញប័ណ្ណ ។

អ្នកចេញប័ណ្ណអាចបង្រួញ ឬ ពន្យាររយៈពេលកំណត់នេះបាន ។

រយៈពេលកំណត់ទាំងនេះ ក៏អាចត្រូវបានបង្រួញដោយអ្នកធ្វើបិដ្ឋិលេខទាំងឡាយ ផងដែរ ។

**មាត្រា ១៥៦.-**

ទិដ្ឋាការត្រូវបានសរសេរនៅលើប័ណ្ណសងតាមបញ្ជា ដោយប្រើពាក្យថា **បានធ្វើ ទិដ្ឋាការ** ឬ ពាក្យផ្សេងទៀតដែលមានន័យដូចគ្នា ហើយត្រូវចុះហត្ថលេខាដោយអ្នក ចេញប័ណ្ណ ។

ទិដ្ឋាការត្រូវតែបានចុះកាលបរិច្ឆេទនៅថ្ងៃដែលបានធ្វើ លើកលែងតែអ្នកកាន់ទាមទារថា ថ្ងៃនោះជាថ្ងៃដែលបង្ហាញឱ្យទូទាត់សងប្រាក់ ។ បើទិដ្ឋាការនោះគ្មានចុះកាលបរិច្ឆេទទេ អ្នកកាន់ដើម្បីរក្សាសិទ្ធិឧបាស្រ័យរបស់ខ្លួនទល់នឹងអ្នកធ្វើបិដ្ឋិលេខ និងអ្នកចេញប័ណ្ណ ត្រូវធ្វើឱ្យស្របច្បាប់ចំពោះកំហុសភ្លេចភ្លាំងនោះ ដោយវិរុទ្ធវាទដែលធ្វើឡើងនៅក្នុងពេលវេលាសមស្រប ។

រយៈពេលកំណត់ក្រោយការបង្ហាញដែលប័ណ្ណសងតាមបញ្ជាត្រូវទូទាត់សងប្រាក់ ត្រូវគិតពីថ្ងៃធ្វើទិដ្ឋាការដែលបានចុះហត្ថលេខាដោយអ្នកចេញប័ណ្ណ នៅលើប័ណ្ណសងតាមបញ្ជា ។ ការបដិសេធរបស់អ្នកចេញប័ណ្ណក្នុងការផ្តល់ទិដ្ឋាការដោយមានចុះកាលបរិច្ឆេទ ត្រូវតែបញ្ជាក់ដោយការធ្វើវិរុទ្ធវាទ ដែលជាកាលបរិច្ឆេទកំណត់ថ្ងៃចាប់ផ្តើមនៃរយៈពេលកំណត់ បន្ទាប់ពីថ្ងៃបង្ហាញឱ្យទូទាត់សងប្រាក់ ។

## ផ្នែកទី ៤
## រូបិយបដិភោគប័ណ្ណសងតាមបញ្ជា

### មាត្រា ១៥៧.-

ការទូទាត់សងប័ណ្ណសងតាមបញ្ជាអាចត្រូវបានធានាដោយរូបិយបដិភោគនៅលើចំនួនប្រាក់ទាំងអស់ ឬ មួយផ្នែកនៃប័ណ្ណសងតាមបញ្ជា ។

ការធានានេះអាចត្រូវបានផ្តល់ដោយតតិយបុគ្គល ឬ ដោយបុគ្គលណាមួយដែលបានចុះហត្ថលេខាលើប័ណ្ណសងតាមបញ្ជា ។

### មាត្រា ១៥៨.-

រូបិយបដិភោគអាចត្រូវបានធ្វើឡើងនៅលើប័ណ្ណសងតាមបញ្ជាផ្ទាល់ ឬ នៅលើអនុប័ត្រ ។

រូបិយបដិភោគត្រូវបានបញ្ជាក់ដោយពាក្យថា យល់ព្រមធ្វើរូបិយបដិភោគ ឬ ដោយរូបមន្តណាមួយផ្សេងទៀត ដែលមានន័យដូចគ្នា និងត្រូវតែចុះហត្ថលេខាដោយអ្នកផ្តល់រូបិយបដិភោគហៅថារូបិយបដិភោគី ។

រាល់ហត្ថលេខាដែលបានចុះនៅខាងមុខប័ណ្ណសងតាមបញ្ជា ក្រៅពីហត្ថលេខារបស់អ្នកចេញប័ណ្ណ ត្រូវបានចាត់ទុកថាជាហត្ថលេខាធ្វើវូបិយបនិភោគ ។

វូបិយបនិភោគត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់ នូវបុគ្គលណាមួយដែលជាបុគ្គលទទួលផលពីវូបិយបនិភោគនោះ ។ បើគ្មានសេចក្តីបញ្ជាក់នេះទេ វូបិយបនិភោគត្រូវបានចាត់ទុកថាធ្វើឱ្យអ្នកចេញប័ណ្ណ ។

មាត្រា ១៥៩.-

វូបិយបនិភោគីមានកាតព្វកិច្ចដូចបុគ្គលដែលបានទទួលការធានាដែរ ។

ការចុះហត្ថលេខាធានានៅតែមានតម្លៃ ទោះបីកាតព្វកិច្ចដែលបានធានានោះមិនត្រូវបានអនុវត្តតាមដោយសារហេតុផលផ្សេងៗ ក្រៅពីវិការៈខាងទម្រង់ក៏ដោយ ។

នៅពេលបានទូទាត់សងប័ណ្ណសងតាមបញ្ជា វូបិយបនិភោគីមានសិទ្ធិទាំងឡាយនៃប័ណ្ណសងតាមបញ្ជានេះ ទល់នឹងបុគ្គលដែលត្រូវបានធានា និងបុគ្គលដែលពាក់ព័ន្ធជាមួយបុគ្គលដែលត្រូវបានធានានោះ នៅលើប័ណ្ណសងតាមបញ្ជា ។

## ផ្នែកទី ៥
## កាលប្រតិទានប័ណ្ណសងតាមបញ្ជា

មាត្រា ១៦០.-

ប័ណ្ណសងតាមបញ្ជា អាចត្រូវបានចេញដើម្បី :

-ទូទាត់សងប្រាក់នៅពេលបង្ហាញ

-ទូទាត់សងប្រាក់នៅក្នុងរយៈពេលកំណត់មួយ ក្រោយការបង្ហាញ

-ទូទាត់សងប្រាក់នៅក្នុងរយៈពេលកំណត់មួយ ក្រោយកាលបរិច្ឆេទចេញប័ណ្ណ

-ទូទាត់សងប្រាក់នៅកាលបរិច្ឆេទមួយជាកំណត់ ។

ប័ណ្ណសងតាមបញ្ជាអាចត្រូវបានចេញដើម្បីឱ្យទូទាត់សងប្រាក់ជាច្រើនដំណាក់កាល ដែលដំណាក់កាលនីមួយៗត្រូវធ្វើនៅកាលបរិច្ឆេទមួយជាកំណត់ ដោយមាន

ល្បីស

ល័ក្ខខ័ណ្ឌថា ក្នុងករណីខកខានទូទាត់សងប្រាក់នៅដំណាក់កាលណាមួយ ចំនួនប្រាក់ដែលនៅសល់ត្រូវដល់កាលកំណត់សងទាំងស្រុង ។

ប័ណ្ណសងតាមបញ្ជាទាំងឡាយ ដែលមានឥណប្រតិទានផ្សេងពីនេះត្រូវបានចាត់ទុកជាមោឃៈ ។

**មាត្រា ១៦១.–**

ប័ណ្ណសងតាមបញ្ជាទូទាត់សងប្រាក់នៅពេលបង្ហាញ ត្រូវតែបានទូទាត់សងប្រាក់នៅពេលបង្ហាញ ហើយត្រូវតែបានបង្ហាញនៅពេលណាមួយក្នុងរយៈពេលមួយ(០១) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញផ្សាយ ។ អ្នកចេញប័ណ្ណអាចបង្រួញ ឬ ពន្យាររយៈពេលនេះបាន ។ រយៈពេលកំណត់នេះក៏អាចត្រូវបានបង្រួញ ដោយអ្នកធ្វើបិដ្ឋិលេខផងដែរ ។

អ្នកចេញប័ណ្ណអាចបញ្ជាក់ថា ប័ណ្ណសងតាមបញ្ជាដែលអាចទូទាត់សងប្រាក់នៅពេលបង្ហាញ មិនត្រូវបានបង្ហាញឱ្យទូទាត់សងប្រាក់នៅមុនថ្ងៃកំណត់ឡើយ ។ ក្នុងករណីនេះ រយៈពេលកំណត់សម្រាប់បង្ហាញត្រូវចាប់ផ្តើមពីថ្ងៃកំណត់នោះ ។

**មាត្រា ១៦២.–**

ឥណប្រតិទាននៃប័ណ្ណសងតាមបញ្ជាទូទាត់សងប្រាក់ នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ ត្រូវបានកំណត់ដោយកាលបរិច្ឆេទធ្វើទិដ្ឋាការ ឬ កាលបរិច្ឆេទធ្វើវិរុទ្ធវាទ ។

បើគ្មានវិរុទ្ធវាទទេ ទិដ្ឋាការដែលពុំបានចុះកាលបរិច្ឆេទដោយអ្នកចេញប័ណ្ណ ត្រូវបានចាត់ទុកថាបានធ្វើនៅថ្ងៃចុងក្រោយនៃរយៈពេលកំណត់បង្ហាញឱ្យធ្វើទិដ្ឋាការ ។

**មាត្រា ១៦៣.–**

នៅពេលដែលប័ណ្ណសងតាមបញ្ជាត្រូវបានចេញ ដើម្បីឱ្យទូទាត់សងប្រាក់ក្នុងរយៈពេលមួយខែ ឬ ច្រើនខែក្រោយកាលបរិច្ឆេទនៃការចេញប័ណ្ណ ឬ ក្រោយការបង្ហាញ ប័ណ្ណសងតាមបញ្ជាមានឥណប្រតិទាន នៅកាលបរិច្ឆេទដែលត្រូវគ្នានៅក្នុងខែដែលត្រូវទូទាត់សងប្រាក់ ។ បើគ្មានកាលបរិច្ឆេទត្រូវគ្នាទេ ប័ណ្ណសងតាមបញ្ជាមានឥណប្រតិទាននៅថ្ងៃចុងក្រោយនៃខែនោះ ។

៧៥/១២៧

កាលបើប័ណ្ណសងតាមបញ្ជាត្រូវបានចេញដើម្បីឱ្យទូទាត់សងប្រាក់ ក្នុងរយៈពេលមួយខែកន្លះ ឬ ច្រើនខែកន្លះ ក្រោយកាលបរិច្ឆេទនៃការចេញប័ណ្ណ ឬ ក្រោយការបង្ហាញ រយៈពេលពេញលេញនៃខែទាំងនោះ ត្រូវតែបានយកមកគិតជាមុន ។

បើឥណប្រតិទានត្រូវបានកំណត់នៅដើមខែ ពាក់កណ្តាលខែ ឬ នៅដំណាច់ខែ ត្រូវយកថ្ងៃទីមួយ ថ្ងៃទីដប់ប្រាំ ឬ ថ្ងៃដាច់ខែមកគិត ។

ពាក្យថា ប្រាំបីថ្ងៃ ឬដប់ប្រាំថ្ងៃ មិនមានន័យថាមួយសប្តាហ៍ ឬ ពីរសប្តាហ៍ទេ គឺជារយៈពេលប្រាំបីថ្ងៃ ឬ ដប់ប្រាំថ្ងៃពិតប្រាកដ ។

ពាក្យថាកន្លះខែ មានន័យថាដប់ប្រាំថ្ងៃ ។

**មាត្រា ១៦៤.-**

កាលបើប័ណ្ណសងតាមបញ្ជាត្រូវទូទាត់សងប្រាក់នៅថ្ងៃកំណត់មួយ ឬ នៅរយៈពេលកំណត់មួយ បន្ទាប់ពីថ្ងៃកំណត់ នៅកន្លែងដែលមានប្រតិទិនខុសពីប្រតិទិននៃកន្លែងចេញផ្សាយ លើកលែងតែមានបដិញ្ញានៅក្នុងប័ណ្ណសងតាមបញ្ជា ឬ មានល័ក្ខខ័ណ្ឌសាមញ្ញ ដែលប័ណ្ណសងតាមបញ្ជាចង្អុលបង្ហាញអំពីបំណងក្នុងការជ្រើសរើសយកវិធានផ្សេងពីនេះ ថ្ងៃឥណប្រតិទានត្រូវបានកំណត់ទៅតាមប្រតិទិននៃកន្លែងទូទាត់សងប្រាក់ ។

## ផ្នែកទី ៦
## ការទូទាត់សងប្រាក់

**មាត្រា ១៦៥.-**

អ្នកកាន់ប័ណ្ណសងតាមបញ្ជាដែលត្រូវទូទាត់សងប្រាក់នៅកាលបរិច្ឆេទមួយជាកំណត់ ឬ នៅក្នុងពេលកំណត់មួយក្រោយកាលបរិច្ឆេទចេញប័ណ្ណ ឬ ក្រោយការបង្ហាញ ត្រូវបង្ហាញនៅថ្ងៃទូទាត់សងប្រាក់ ឬ នៅថ្ងៃណាមួយរវាងពីរ(០២) ថ្ងៃធ្វើការបន្ទាប់ ។

ការបង្ហាញប័ណ្ណសងតាមបញ្ជាតាមរយៈសភាផាត់ទាត់ ឬ តាមរយៈប្រព័ន្ធអេឡិចត្រូនិកដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង ឬ បទបញ្ញាដែលចេញដោយធនាគារជាតិនៃកម្ពុជា គឺជាការបង្ហាញឱ្យទូទាត់សងប្រាក់ជាផ្លូវការ ។

មាត្រា ១៦៦.-

អ្នកចេញប័ណ្ណដែលទូទាត់សងប័ណ្ណសងតាមបញ្ជា អាចតម្រូវឱ្យប្រគល់ប័ណ្ណសងតាមបញ្ជានោះឱ្យខ្លួន ក្រោយពីមានបញ្ជាក់ការទទួលប្រាក់ពីអ្នកកាន់ ។

អ្នកកាន់អាចមិនបដិសេធការទូទាត់ប្រាក់មួយផ្នែកនៃចំនួនប្រាក់ប័ណ្ណសងតាមបញ្ជា ។

ក្នុងករណីមានការទូទាត់សងប្រាក់មួយផ្នែកនៃចំនួនប្រាក់ អ្នកចេញប័ណ្ណអាចទាមទារឱ្យបញ្ជាក់ការសងប្រាក់មួយផ្នែកនោះនៅលើប័ណ្ណសងតាមបញ្ជា និង ទាមទារបង្កាន់ដៃទទួលប្រាក់ផងដែរ ។

មាត្រា ១៦៧.-

នៅពេលដែលប័ណ្ណសងតាមបញ្ជាមិនត្រូវបានបង្ហាញឱ្យទូទាត់សងប្រាក់ នៅក្នុងរយៈពេលដែលកំណត់ដោយមាត្រា ១៦៥ នៃច្បាប់នេះ កូនបំណុលត្រូវបានអនុញ្ញាតឱ្យតម្កល់ចំនួនប្រាក់នោះនៅអាជ្ញាធរមានសមត្ថកិច្ច តាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា ក្រោមការទទួលខុសត្រូវ និងហានិភ័យរបស់អ្នកកាន់ ។

មាត្រា ១៦៨.-

អ្នកកាន់ប័ណ្ណសងតាមបញ្ជាមិនអាចត្រូវបានបង្ខំឱ្យទទួលយកការទូទាត់សងប្រាក់ នៅមុនពេលដល់ឥណប្រតិទានឡើយ ។

អ្នកចេញប័ណ្ណដែលទូទាត់សងប្រាក់ នៅមុនពេលដល់ឥណប្រតិទាន ត្រូវទទួលរងហានិភ័យដោយខ្លួនឯងផ្ទាល់ ។

អ្នកចេញប័ណ្ណដែលទូទាត់សងប្រាក់ នៅពេលដល់ឥណប្រតិទាន ត្រូវបានរួចផុតយ៉ាងត្រឹមត្រូវពីកាតព្វកិច្ចរបស់ខ្លួន លើកលែងតែមានកំហុសនៃការក្លែងបន្លំ ឬ នៃការធ្វេសប្រហែសធ្ងន់ធ្ងរ ។ អ្នកចេញប័ណ្ណត្រូវទទួលខុសត្រូវផ្ទៀងផ្ទាត់ប្រក្រតីភាពនៃលំដាប់បិដ្ឋិលេខ ប៉ុន្តែមិនផ្ទៀងផ្ទាត់ហត្ថលេខាអ្នកធ្វើបិដ្ឋិលេខឡើយ ។

មាត្រា ១៦៩.-

នៅពេលដែលប័ណ្ណសងតាមបញ្ជាត្រូវបានធ្វើជារូបិយប័ណ្ណ ដែលមិនមែនជារបស់កន្លែងត្រូវទូទាត់សងប្រាក់ ចំនួនប្រាក់អាចត្រូវទូទាត់សងជារូបិយប័ណ្ណនៃប្រទេស

ជាកន្លែងទូទាត់សងប្រាក់ ទៅតាមអត្រាប្តូរប្រាក់នៅថ្ងៃឥណប្រតិទាន ។ បើការទូទាត់សងប្រាក់មិនត្រូវបានធ្វើនៅពេលបង្ហាញ អ្នកកាន់អាចស្នើសុំឱ្យការទូទាត់សងចំនួនប្រាក់នៅលើប័ណ្ណសងតាមបញ្ជានោះ ធ្វើឡើងជារូបិយប័ណ្ណរបស់ប្រទេសជាកន្លែងទូទាត់សងប្រាក់ ទៅតាមអត្រាប្តូរប្រាក់នៅថ្ងៃឥណប្រតិទាន ឬ នៅថ្ងៃដែលទូទាត់សងប្រាក់ តាមការជ្រើសរើសរបស់ខ្លួន ។

រាល់ការប្រើប្រាស់កន្លែងទូទាត់សងប្រាក់នឹងត្រូវបានអនុវត្តសម្រាប់កំណត់តម្លៃរូបិយប័ណ្ណ ។ ប៉ុន្តែអ្នកចេញប័ណ្ណអាចចែងល័ក្ខខ័ណ្ឌថា ចំនួនប្រាក់ដែលទូទាត់សងនឹងត្រូវគណនាទៅតាមអត្រាប្តូរប្រាក់ ដែលបញ្ជាក់នៅលើប័ណ្ណសងតាមបញ្ជា ។

វិធានទាំងឡាយខាងលើនេះ មិនត្រូវបានអនុវត្តចំពោះប័ណ្ណសងតាមបញ្ជា :

-ដែលធ្វើជារូបិយប័ណ្ណដែលមានការទទួលយកនៅព្រះរាជាណាចក្រកម្ពុជា

-ដែលក្នុងនោះ អ្នកចេញប័ណ្ណបានបញ្ជាក់ថាការទូទាត់សងប្រាក់ត្រូវតែធ្វើឡើងជារូបិយប័ណ្ណណាមួយច្បាស់លាស់ ។ ក្នុងករណីខាងលើនេះ ប័ណ្ណសងតាមបញ្ជានឹងត្រូវទូទាត់សងជារូបិយប័ណ្ណដែលបានបញ្ជាក់ ។

បើចំនួនប្រាក់នៃប័ណ្ណសងតាមបញ្ជាត្រូវបានបញ្ជាក់ជារូបិយប័ណ្ណ ដែលមាននាមចារឹកដូចគ្នា ប៉ុន្តែមានតម្លៃខុសគ្នារវាងប្រទេសទូទាត់សងប្រាក់ និង ប្រទេសចេញផ្សាយ ឬ ប្រទេសណាមួយផ្សេងទៀត លើកលែងតែមានការកំណត់ផ្សេងពីនេះ ចំនួនប្រាក់ក្នុងប័ណ្ណសងតាមបញ្ជា ត្រូវចាត់ទុកថាបានទូទាត់សងជារូបិយប័ណ្ណនៃប្រទេសទូទាត់សងប្រាក់ ។ នៅពេលណាដែលរូបិយប័ណ្ណនៃប្រទេសទូទាត់សងប្រាក់មិនមាននាមចារឹកដូចគ្នា ការទូទាត់សងប្រាក់ត្រូវបានធ្វើឡើងជារូបិយប័ណ្ណ ដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅកន្លែងទូទាត់សងប្រាក់ ។

នៅពេលដែលប័ណ្ណសងតាមបញ្ជាត្រូវបានទូទាត់សងប្រាក់នៅធនាគារ ការចង្អុលបង្ហាញគណនីដែលត្រូវចុះឥណពន្ធតាមចំនួនប្រាក់ត្រូវទូទាត់សង ត្រូវបានចាត់ទុកជាការអនុញ្ញាតឱ្យទូទាត់សងជារូបិយប័ណ្ណនៃគណនី ។

## ផ្នែកទី៧
## ឧបាស្រ័យចំពោះការមិនទូទាត់សងប្រាក់

**មាត្រា ១៧០.-**

អ្នកកាន់ប័ណ្ណសងតាមបញ្ជា អាចអនុវត្តសិទ្ធិធ្វើឧបាស្រ័យរបស់ខ្លួនទល់នឹងអ្នកធ្វើបិដ្ឋិលេខទាំងឡាយ អ្នកចេញប័ណ្ណ និងភាគីពាក់ព័ន្ធដទៃៗទៀត :

-នៅពេលដល់ឥណប្រតិទាន បើការទូទាត់សងប្រាក់មិនត្រូវបានធ្វើ

-នៅមុនពេលដល់ឥណប្រតិទាន ក្នុងករណីធនក្ស័យរបស់អ្នកចេញប័ណ្ណ ឬ ក្នុងករណីអ្នកចេញប័ណ្ណបញ្ឈប់មិនឱ្យទូទាត់សងប្រាក់ ទោះបីគ្មានសេចក្តីសម្រេចពីតុលាការក្តី ឬ នៅពេលណាដែលការអនុវត្តរឹបអូសទ្រព្យសម្បត្តិរបស់អ្នកចេញប័ណ្ណពុំបានសម្រេចក្តី ។

**មាត្រា ១៧១.-**

ការខកខានមិនបានទូទាត់សងប្រាក់ ត្រូវតែបានបង្ហាញភស្តុតាងដោយវិរុទ្ធវាទតាមច្បាប់ ។

វិរុទ្ធវាទចំពោះការមិនទូទាត់សងប័ណ្ណសងតាមបញ្ជា ដែលត្រូវទូទាត់សងប្រាក់នៅកាលបរិច្ឆេទមួយជាកំណត់ ឬ នៅក្នុងរយៈពេលកំណត់មួយក្រោយកាលបរិច្ឆេទនៃការចេញប័ណ្ណឬក្រោយការបង្ហាញ ត្រូវតែបានធ្វើនៅថ្ងៃណាមួយក្នុងរវាងពីរ(០២)ថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃដែលប័ណ្ណសងតាមបញ្ជានោះត្រូវទូទាត់សងប្រាក់ ។ នៅក្នុងករណីនៃប័ណ្ណសងតាមបញ្ជាដែលត្រូវទូទាត់សងប្រាក់នៅពេលបង្ហាញ វិរុទ្ធវាទត្រូវតែបានធ្វើនៅក្នុងរយៈពេលកំណត់សម្រាប់បង្ហាញឱ្យទូទាត់សងប្រាក់ ។ វិរុទ្ធវាទចំពោះការបដិសេធមិនផ្តល់ទិដ្ឋាការ អាចធ្វើបានដោយមិនចាំបាច់បង្ហាញឱ្យទូទាត់សងប្រាក់ ហើយត្រូវតែធ្វើនៅក្នុងរយៈពេលកំណត់សម្រាប់បង្ហាញឱ្យទូទាត់សងប្រាក់ ។

បើអ្នកចេញប័ណ្ណ បញ្ឈប់មិនឱ្យទូទាត់សងប្រាក់ ឬ បើការអនុវត្តរឹបអូសទ្រព្យសម្បត្តិមិនបានសម្រេច អ្នកកាន់អាចអនុវត្តសិទ្ធិធ្វើឧបាស្រ័យបាន តែនៅក្រោយការ

បង្ហាញប័ណ្ណសងតាមបញ្ជា ឱ្យទៅអ្នកចេញប័ណ្ណធ្វើការទូទាត់សងប្រាក់ និងនៅក្រោយពេលដែលវិរុទ្ធវាទត្រូវបានធ្វើ ។

បើអ្នកចេញប័ណ្ណត្រូវបានប្រកាសថាធនក្ស័យ ការបង្ហាញសាលក្រម ឬ សាលដីការបស់តុលាការដែលប្រកាសពីធនក្ស័យនោះ មានតម្លៃគ្រប់គ្រាន់ឱ្យអ្នកកាន់អាចអនុវត្តសិទ្ធិធ្វើឧបាស្រ័យបាន ។

វិរុទ្ធវាទត្រូវតែបានចុះហត្ថលេខាដោយមន្ត្រីដែលទទួលសិទ្ធិស្របច្បាប់ឱ្យបញ្ជាក់យថាភាពនៃឯកសារ ។ ដរាបណាពុំទាន់មានមន្ត្រីដែលបានទទួលសិទ្ធិស្របច្បាប់នោះទេ មន្ត្រីនោះត្រូវតែបានតែងតាំងដោយធនាគារជាតិនៃកម្ពុជា ។ វិរុទ្ធវាទត្រូវមានច្បាប់ថតចម្លង ឬ ច្បាប់ដើមនៃប័ណ្ណសងតាមបញ្ជាភ្ជាប់ជាមួយ និងត្រូវបញ្ជាក់ច្បាស់លាស់ឈ្មោះបុគ្គលដែលធ្វើវិរុទ្ធវាទ កន្លែងនិងកាលបរិច្ឆេទ មូលហេតុនៃវិរុទ្ធវាទ សំណួរដែលលើកឡើង និងចម្លើយដែលផ្តល់មកវិញបើមាន ឬ អំពីការដែលរកមិនឃើញអ្នកចេញប័ណ្ណ ។ វិរុទ្ធវាទត្រូវបានធ្វើឡើងនៅកន្លែងនៃការបដិសេធមិនទូទាត់សង ឬ នៅកន្លែងផ្សេងទៀតក្នុងព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតក្នុងចម្ងាយមិនលើសពីដប់ (១០) គីឡូម៉ែត្រពីកន្លែងនៃការបង្ហាញ និងនៃការបដិសេធមិនទូទាត់សងប្រាក់ ។

វិរុទ្ធវាទអាចត្រូវបានធ្វើឡើងដោយប្រតិវេទន៍ជាលាយលក្ខណ៍អក្សរ និងមានចុះហត្ថលេខារបស់អ្នកចេញប័ណ្ណ បញ្ជាក់ច្បាស់អំពីព័ត៌មានទាំងឡាយដូចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៥ នៃមាត្រានេះ ។

**មាត្រា ១៧២.-**

អ្នកកាន់ត្រូវជូនដំណឹងពីការមិនទូទាត់សងប្រាក់ទៅអ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន និងរូបិយបដិភោគីណាមួយនៃអ្នកចេញប័ណ្ណ នៅក្នុងរយៈពេលបួន (០៤) ថ្ងៃធ្វើការបន្ទាប់ពីថ្ងៃធ្វើវិរុទ្ធវាទ ឬ នៅថ្ងៃបង្ហាញឱ្យទូទាត់សងប្រាក់ ក្នុងករណីដែលមានបដិញ្ញាថា **បង្វិលទិញវិញដោយគ្មានសោហ៊ុយ** ឬ **បង្វិលទិញវិញដោយគ្មានវិរុទ្ធវាទ** ឬ សេចក្តីផ្សេងណាមួយដែលមានន័យដូចគ្នា ។ នៅក្នុងរយៈពេលពីរ (០២) ថ្ងៃធ្វើការបន្ទាប់ពីថ្ងៃបានទទួលសេចក្តីជូនដំណឹង អ្នកធ្វើបិដ្ឋិលេខនីមួយៗត្រូវជូនដំណឹងដល់អ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន អំពីសេចក្តីជូនដំណឹងដែលបានទទួលដោយបញ្ជាក់ពីឈ្មោះ និងអាសយដ្ឋាន

របស់អ្នកធ្វើបិដ្ឋិលេខ ដែលបានផ្ដល់សេចក្ដីជូនដំណឹងមុនៗជាលំដាប់លំដោយរហូតដល់អ្នកចេញប័ណ្ណបានទទួល ។ រយៈពេលកំណត់ដែលបញ្ជាក់ខាងលើ ត្រូវគិតពីថ្ងៃទទួលបានសេចក្ដីជូនដំណឹងមុន ។

ដោយអនុលោមតាមកថាខណ្ឌខាងលើនៃមាត្រានេះ នៅពេលដែលសេចក្ដីជូនដំណឹងត្រូវបានផ្ដល់ទៅបុគ្គលដែលបានចុះហត្ថលេខាលើប័ណ្ណសងតាមបញ្ជា សេចក្ដីជូនដំណឹងដូចគ្នានេះក៏ត្រូវបានផ្ដល់ទៅរូបិយបដិភោគី នៅក្នុងពេលកំណត់ដូចគ្នា ។

កាលបើអ្នកធ្វើបិដ្ឋិលេខមិនបានបញ្ជាក់ច្បាស់នូវអាសយដ្ឋានរបស់ខ្លួន ឬ ក៏បានបញ្ជាក់ដោយមិនច្បាស់ សេចក្ដីជូនដំណឹងដែលបានផ្ដល់ទៅអ្នកធ្វើបិដ្ឋិលេខមុនបន្ទាប់ គឺជាការគ្រប់គ្រាន់ ។

បុគ្គលដែលត្រូវផ្ដល់សេចក្ដីជូនដំណឹង អាចធ្វើសេចក្ដីជូនដំណឹងតាមរូបភាពណាមួយក៏បាន ទោះបីត្រឹមតែបញ្ជូនប័ណ្ណសងតាមបញ្ជាត្រឡប់វិញក៏ដោយ ។

បុគ្គលដែលត្រូវផ្ដល់សេចក្ដីជូនដំណឹង ត្រូវបង្ហាញភស្តុតាងថាខ្លួនបានជូនដំណឹងក្នុងរយៈពេលកំណត់ ។ រយៈពេលកំណត់នេះនឹងត្រូវបានចាត់ទុកថា បានគោរពតាម បើលិខិតជូនដំណឹងត្រូវបានធ្វើតាមប្រៃសណីយ៍ក្នុងរយៈពេលកំណត់នោះ ។

បុគ្គលដែលមិនបានផ្ដល់សេចក្ដីជូនដំណឹងក្នុងរយៈពេលកំណត់ខាងលើនេះ ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលកើតឡើង ដោយការធ្វេសប្រហែសរបស់ខ្លួន បើមាន ប៉ុន្តែចំនួនប្រាក់ដែលទទួលខុសត្រូវមិនត្រូវលើសពីចំនួនប្រាក់នៃប័ណ្ណសងតាមបញ្ជាឡើយ ។

មាត្រា ១៧៣.-

តាមរយៈបដិញ្ញាថា បង្វិលទិញដោយគ្មានសោហ៊ុយ ឬ បង្វិលទិញដោយគ្មានវិរុទ្ធវាទ ឬ សេចក្ដីផ្សេងណាមួយដែលមានន័យដូចគ្នា ហើយដែលបានសរសេរនិងមានចុះហត្ថលេខានៅលើប័ណ្ណសងតាមបញ្ជា អ្នកធ្វើបិដ្ឋិលេខ ឬរូបិយបដិភោគីអាចឱ្យអ្នកកាន់មិនចាំបាច់ធ្វើវិរុទ្ធវាទ ដើម្បីអនុវត្តសិទ្ធិធ្វើឧបាស្រ័យ ។

បដិញ្ញានេះមិនអាចឱ្យអ្នកកាន់រួចផុតពីការបង្ហាញប័ណ្ណសងតាមបញ្ជានៅក្នុងរយៈពេលកំណត់ ឬ ពីការតម្រូវឱ្យមានរាល់សេចក្ដីជូនដំណឹងឡើយ ។ សោហ៊ុយ

ដែលកើតឡើងពីការបង្ហាញភស្តុតាងនៃការមិនគោរពតាមរយៈពេលកំណត់ដោយអ្នកកាន់ ត្រូវធ្លាក់ទៅលើបុគ្គលដែលបានប្ដឹងទល់នឹងអ្នកកាន់ ។

បដិញ្ញាដែលត្រូវបានសរសេរដោយអ្នកធ្វើបិដ្ឋិលេខ ឬ រូបិយបដិភោគីត្រូវអនុវត្តបានចំពោះអ្នកធ្វើបិដ្ឋិលេខ ឬរូបិយបដិភោគីតែប៉ុណ្ណោះ ។ ទោះបីជាមាន ឬ គ្មានបដិញ្ញាក្ដី បើអ្នកកាន់ធ្វើវិវុទ្ធវាទ សោហ៊ុយនៃការធ្វើវិវុទ្ធវាទអាចត្រូវបានទារពីបុគ្គលទាំងឡាយដែលបានចុះហត្ថលេខាលើប័ណ្ណសងតាមបញ្ជា ។

មាត្រា ១៧៤.-

អ្នកចេញប័ណ្ណ អ្នកធ្វើបិដ្ឋិលេខ ឬ បុគ្គលធានា ដោយការធ្វើរូបិយបដិភោគនៃប័ណ្ណសងតាមបញ្ជា មានកាតព្វកិច្ចទទួលខុសត្រូវរួមគ្នាចំពោះអ្នកកាន់ ។

អ្នកកាន់ មានសិទ្ធិប្ដឹងទល់នឹងបុគ្គលដែលជាប់ពាក់ព័ន្ធទៅនឹងប័ណ្ណសងតាមបញ្ជាជាឯកត្តជន ឬ រួមគ្នា ដោយមិនគិតដល់លំដាប់លំដោយដែលបុគ្គលទាំងនេះចូលមកជាប់ពាក់ព័ន្ធឡើយ ។

សិទ្ធិដូចគ្នានេះត្រូវមានចំពោះបុគ្គលណា ដែលបានចុះហត្ថលេខាលើប័ណ្ណសងតាមបញ្ជា ហើយបានទទួលយកប័ណ្ណសងតាមបញ្ជារក្សាទុក និងបានទូទាត់សងប្រាក់ ។

រាល់ការប្ដឹងទល់នឹងភាគីមួយនៃភាគីពាក់ព័ន្ធទាំងឡាយ មិនរារាំងការប្ដឹងទល់នឹងបុគ្គលដទៃៗទៀតឡើយ ទោះបីបុគ្គលដទៃទាំងនេះទាក់ទិនបន្តបន្ទាប់ពីបុគ្គលដែលបានទទួលរងការប្ដឹងទីមួយនោះក៏ដោយ ។

មាត្រា ១៧៥.-

អ្នកកាន់អាចទាមទារពីបុគ្គលដែលខ្លួនអនុវត្តសិទ្ធិធ្វើឧបាស្រ័យ នូវចំនួនប្រាក់នៃប័ណ្ណសងតាមបញ្ជា ដែលមិនបានទូទាត់សងដោយមានការប្រាក់ បើការប្រាក់នោះមានចែងលើប័ណ្ណសងតាមបញ្ជា ការប្រាក់ដែលគណនាតាមអត្រាកំណត់ដោយធនាគារជាតិនៃកម្ពុជា គិតពីថ្ងៃឥណប្រតិទាន និងសោហ៊ុយទាំងឡាយដែលកើតមាន ។

បើសិទ្ធិធ្វើឧបាស្រ័យត្រូវបានអនុវត្តមុនពេលដល់ឥណប្រតិទាន ចំនួនប្រាក់នៃប័ណ្ណសងតាមបញ្ជាត្រូវជាកម្មវត្ថុនៃការធ្វើអបហារ ។ អបហារនេះត្រូវបានគណនា

ទៅតាមអត្រាអប្បហារជាផ្លូវការរបស់ធនាគារ នៅថ្ងៃធ្វើឧបស្រ័យនៅកន្លែងស្នាក់នៅរបស់អ្នកកាន់ ។

មាត្រា ១៧៦.-

ភាគីដែលបានទទួលយកនិងទូទាត់សងប័ណ្ណសងតាមបញ្ជា អាចទាមទារមកវិញពីភាគីទាំងឡាយដែលមានការពាក់ព័ន្ធជាមួយនូវចំនួនប្រាក់ទាំងស្រុងដែលបានទូទាត់សង ការប្រាក់លើចំនួនប្រាក់ដែលបានទូទាត់សង គណនាតាមអត្រាកំណត់ ដោយធនាគារជាតិនៃកម្ពុជាគិតពីថ្ងៃបានទូទាត់សងប្រាក់ និងសោហ៊ុយទាំងឡាយដែលកើតមាន ។

មាត្រា ១៧៧.-

ភាគីពាក់ព័ន្ធនីមួយៗ ដែលទទួលរងការអនុវត្តសិទ្ធិធ្វើឧបស្រ័យអាចទាមទារដោយប្តូរនឹងការទូទាត់សងប្រាក់ ឱ្យប្រគល់មកខ្លួននូវប័ណ្ណសងតាមបញ្ជារួមជាមួយនឹងវិក្កយបត្រ និងបង្កាន់ដៃទទួលប្រាក់ ។

អ្នកធ្វើបិដ្ឋិលេខនីមួយៗ ដែលបានទទួលយកនិងបានទូទាត់សងប័ណ្ណសងតាមបញ្ជា អាចលុបចោលបិដ្ឋិលេខរបស់ខ្លួនផ្ទាល់ និងរបស់អ្នកធ្វើបិដ្ឋិលេខបន្តបន្ទាប់បានតាមក្រោយ ។

មាត្រា ១៧៨.-

ក្នុងករណីដែលគ្មានកិច្ចព្រមព្រៀងផ្ទុយពីនេះទេ រាល់បុគ្គលដែលមានសិទ្ធិធ្វើឧបស្រ័យអាចទូទាត់សងខ្លួនឯង តាមមធ្យោបាយនៃការចេញរូបិយាណត្តិដែលត្រូវទូទាត់សងប្រាក់នៅពេលបង្ហាញទៅលើភាគីណាមួយដែលជំពាក់ខ្លួន និងដែលត្រូវទូទាត់សងបាននៅលំនៅនៃភាគីនោះ ។

ជាបន្ថែមលើចំនួនប្រាក់នានាដែលចែងនៅក្នុងមាត្រា ១៧៥ និងមាត្រា ១៧៦ នៃច្បាប់នេះ រូបិយាណត្តិមានបញ្ចូលនូវកម្រៃជើងសានិងថ្លៃតែមប្រិ៍ផងដែរ ។

បើរូបិយាណត្តិត្រូវបានចេញដោយអ្នកកាន់ ចំនួនប្រាក់ទូទាត់សងត្រូវបានកំណត់ទៅតាមអត្រាការប្រាក់សម្រាប់រូបិយាណត្តិ ដែលត្រូវទូទាត់សងប្រាក់នៅពេលបង្ហាញនៅពេលដែលប័ណ្ណសងតាមបញ្ជាដំបូងត្រូវបានទូទាត់សងនៅលំនៅរបស់ភាគីពាក់ព័ន្ធ ។ បើរូបិយាណត្តិត្រូវបានចេញដោយអ្នកធ្វើបិដ្ឋិលេខ ចំនួនប្រាក់ទូទាត់សងត្រូវ

៧៤/៤៩

បានកំណត់ទៅតាមអត្រាការប្រាក់ សម្រាប់រូបិយាណត្តិដែលត្រូវទូទាត់សងប្រាក់នៅពេលបង្ហាញ នៅពេលដែលអ្នកចេញរូបិយាណត្តិនោះ មានលំនៅនៅកន្លែងជាមួយភាគីដែលពាក់ព័ន្ធ ។

មាត្រា ១៧៩.-

អ្នកកាន់បាត់បង់សិទ្ធិធ្វើឧបាស្រ័យរបស់ខ្លួនទល់នឹងអ្នកធ្វើបិដ្ឋិលេខទាំងឡាយ និងភាគីពាក់ព័ន្ធដទៃៗទៀត លើកលែងតែអ្នកចេញប័ណ្ណក្រោយផុតរយៈពេលកំណត់ :

-សម្រាប់ការបង្ហាញប័ណ្ណសងតាមបញ្ជា ដែលចេញដើម្បីឱ្យទូទាត់សងប្រាក់ នៅពេលបង្ហាញ ឬ នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ

-សម្រាប់ធ្វើវិរុទ្ធវាទចំពោះការមិនទូទាត់សងប្រាក់

-សម្រាប់ការបង្ហាញឱ្យទូទាត់សងប្រាក់ ក្នុងករណីដែលមានបដិញ្ញាថា បង្វិលទិញដោយគ្មានសោហ៊ុយ ឬ បង្វិលទិញដោយគ្មានវិរុទ្ធវាទ ឬ សេចក្តីផ្សេងណាមួយ ដែលមានន័យដូចគ្នា ។

បើបដិញ្ញាស្តីពីរយៈពេលកំណត់ឱ្យបង្ហាញមានចុះនៅក្នុងបិដ្ឋិលេខ រយៈពេលកំណត់នេះមានប្រសិទ្ធភាពចំពោះអ្នកធ្វើបិដ្ឋិលេខតែប៉ុណ្ណោះ ។

មាត្រា ១៨០.-

កាលបើការបង្ហាញប័ណ្ណសងតាមបញ្ជាឱ្យទូទាត់សងប្រាក់ ឬ ការធ្វើវិរុទ្ធវាទក្នុងរយៈពេលកំណត់ ត្រូវបានរាំងស្ទះដោយឧបសគ្គមិនអាចឆ្លងផុតបាន ដែលជាករណីប្រធានស័ក្តិ រយៈពេលកំណត់នឹងត្រូវបានពន្យារ ។

អ្នកកាន់មានកាតព្វកិច្ចផ្តល់សេចក្តីជូនដំណឹងភ្លាមអំពីករណីប្រធានស័ក្តិឱ្យទៅអ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន និងត្រូវបញ្ជាក់អំពីសេចក្តីជូនដំណឹងនេះ ដោយចុះកាលបរិច្ឆេទ និងហត្ថលេខាលើប័ណ្ណសងតាមបញ្ជា ឬ លើអនុប័ត្រ ។ ចំពោះប្រការផ្សេងៗទៀតត្រូវអនុវត្តទៅតាមមាត្រា ១៧២ នៃច្បាប់នេះ ។

នៅពេលដែលករណីប្រធានស័ក្តិបានចប់ អ្នកកាន់ត្រូវបង្ហាញប័ណ្ណសងតាមបញ្ជាភ្លាម ដើម្បីឱ្យធ្វើការទូទាត់សងប្រាក់ ហើយបើចាំបាច់ត្រូវធ្វើវិរុទ្ធវាទ ។

បើករណីប្រធានស័ក្តិនៅបន្តកើតមានលើសពីសាមសិប (៣០) ថ្ងៃ ក្រោយពេលផុតកំណត់ប្រតិទាន ឧបាស្រ័យអាចត្រូវបានធ្វើឡើង ហើយទាំងការបង្ហាញឱ្យទូទាត់សងប្រាក់ ទាំងការធ្វើវិរុទ្ធវាទ មិនចាំបាច់ធ្វើឡើយ ។

ចំពោះប័ណ្ណសងតាមបញ្ជាដែលចេញឱ្យទូទាត់សងប្រាក់ នៅពេលបង្ហាញ ឬ នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ រយៈពេលកំណត់សាមសិប (៣០) ថ្ងៃនោះត្រូវចាប់ផ្តើមពីកាលបរិច្ឆេទដែលអ្នកកាន់បានជូនដំណឹងពីករណីប្រធានស័ក្តិទៅអ្នកធ្វើបិដ្ឋិលេខរបស់ខ្លួន នោះបើនៅមុនផុតរយៈពេលកំណត់ត្រូវបង្ហាញឱ្យទូទាត់សងប្រាក់ក៏ដោយ ។ ចំពោះប័ណ្ណសងតាមបញ្ជាដែលចេញឱ្យទូទាត់សងប្រាក់ នៅក្នុងរយៈពេលកំណត់មួយក្រោយការបង្ហាញ រយៈពេលកំណត់សាមសិប (៣០) ថ្ងៃខាងលើនេះ ត្រូវតែបូកបន្ថែមជាមួយរយៈពេលក្រោយការបង្ហាញ ដែលមានបញ្ជាក់ច្បាស់នៅលើប័ណ្ណសងតាមបញ្ជា ។

រាល់អំពើដែលមានលក្ខណៈផ្ទាល់ខ្លួនសុទ្ធសាធរបស់អ្នកកាន់ ឬរបស់បុគ្គលដែលបានទទួលសិទ្ធិក្នុងការបង្ហាញប័ណ្ណសងតាមបញ្ជាឱ្យទូទាត់សងប្រាក់ ឬ ក្នុងការធ្វើវិរុទ្ធវាទ មិនត្រូវបានចាត់ទុកជាករណីប្រធានស័ក្តិឡើយ ។

ការទទួលខុសត្រូវលើប័ណ្ណសងតាមបញ្ជាដែលត្រូវបានបាត់បង់ ឬ ត្រូវបំផ្លាញអាចអនុវត្តបាន លុះណាតែមានការធានាពីភាគីអនុវត្តប័ណ្ណសងតាមបញ្ជាដែលសងការខូចខាតទៅភាគីពាក់ព័ន្ធ ចំពោះការទាមទាររបស់បុគ្គលផ្សេងទៀតលើប័ណ្ណសងតាមបញ្ជាតាមសេចក្តីសម្រេចរបស់តុលាការ បើអ្នកកាន់បានទទួលប័ណ្ណសងតាមបញ្ជាមកដោយសុចរិត ឬ ដោយគ្មានការធ្វេសប្រហែសធ្ងន់ធ្ងរ ។

## ផ្នែកទី ៨
## ការធ្វើអន្តរាគមន៍ដើម្បីទូទាត់សងប្រាក់

**មាត្រា ១៨១.-**

អ្នកចេញប័ណ្ណ អ្នកធ្វើបិដ្ឋិលេខ ឬ វូបិយបដិភោគីអាចបញ្ជាក់ឈ្មោះបុគ្គលដែលត្រូវទូទាត់សងប្រាក់ ក្នុងករណីចាំបាច់ ។

៩៤/១២៤

ប័ណ្ណសងតាមបញ្ជាអាចត្រូវបានទូទាត់សងប្រាក់ ដោយបុគ្គលដែលធ្វើអន្តរាគមន៍ដើម្បីទូទាត់សងប្រាក់ជូនកូនបំណុលណាមួយដែលទទួលរងសិទ្ធិធ្វើឧបាស្រ័យ ។

បុគ្គលដែលបានធ្វើអន្តរាគមន៍អាចជាតតិយភាគីដែលបានពាក់ព័ន្ធលើប័ណ្ណសងតាមបញ្ជា ។

នៅក្នុងរយៈពេលពីរ (០២) ថ្ងៃធ្វើការ បុគ្គលដែលបានធ្វើអន្តរាគមន៍ត្រូវតែជូនដំណឹងទៅភាគីដែលខ្លួនបានធ្វើអន្តរាគមន៍ដើម្បីទូទាត់សងប្រាក់ ។ បើមិនគោរពតាមរយៈពេលកំណត់នេះទេ អ្នកធ្វើអន្តរាគមន៍ត្រូវទទួលខុសត្រូវចំពោះរាល់ការខូចខាតបើកើតមាន ដែលបណ្តាលមកពីការធ្វេសប្រហែសរបស់ខ្លួន ប៉ុន្តែសំណងលើការខូចខាតមិនត្រូវលើសពីចំនួនប្រាក់នៃប័ណ្ណសងតាមបញ្ជាឡើយ ។

មាត្រា ១៨២.-

ការទូទាត់សងប្រាក់ដោយអន្តរាគមន៍អាចធ្វើបាន នៅក្នុងរាល់ករណីដែលអ្នកកាន់មានសិទ្ធិធ្វើឧបាស្រ័យចំពោះប័ណ្ណសងតាមបញ្ជានៅពេលដល់ឥណប្រតិទាន ឬនៅមុនពេលដល់ឥណប្រតិទាន ។

ការទូទាត់សងប្រាក់ត្រូវរាប់បញ្ចូលនូវចំនួនប្រាក់ទាំងអស់ ដែលត្រូវទូទាត់សងដោយភាគីទទួលអន្តរាគមន៍ ។

ការទូទាត់សងប្រាក់ត្រូវតែបានធ្វើឡើងយ៉ាងយឺតបំផុត នៅថ្ងៃបន្ទាប់ពីថ្ងៃចុងក្រោយដែលអនុញ្ញាតឱ្យធ្វើវិរុទ្ធវាទចំពោះការមិនទូទាត់សងប្រាក់ ។

មាត្រា ១៨៣.-

បើបុគ្គលទាំងឡាយដែលមានលំនៅនៅកន្លែងទូទាត់សងប្រាក់ ត្រូវបានចាត់តាំងជាអ្នកទំនាក់ទំនង ក្នុងករណីចាំបាច់ អ្នកកាន់ត្រូវបង្ហាញប័ណ្ណសងតាមបញ្ជាឱ្យទៅបុគ្គលទាំងនេះ និងបើចាំបាច់ត្រូវធ្វើវិរុទ្ធវាទចំពោះការមិនទូទាត់សងប្រាក់ យ៉ាងយឺតបំផុតនៅថ្ងៃបន្ទាប់ពីថ្ងៃចុងក្រោយដែលអនុញ្ញាតឱ្យធ្វើវិរុទ្ធវាទ ។

បើគ្មានវិរុទ្ធវាទនៅក្នុងរយៈពេលកំណត់នេះទេ ភាគីដែលបានចាត់តាំងអ្នកទំនាក់ទំនងក្នុងករណីចាំបាច់ខាងលើ និងអ្នកធ្វើបិដ្ឋិលេខបន្តបន្ទាប់ត្រូវបានរួចផុតពីការទទួលខុសត្រូវ ។

ភ

មាត្រា ១៨៤.-

អ្នកកាន់ដែលបដិសេធការទូទាត់សងប្រាក់ដោយអន្តរាគមន៍បាត់បង់សិទ្ធិធ្វើឧបាស្រ័យរបស់ខ្លួនទល់នឹងបុគ្គលទាំងឡាយ ដែលត្រូវបានរួចផុតពីការទទួលខុសត្រូវដោយអន្តរាគមន៍ ។

មាត្រា ១៨៥.-

ការទូទាត់សងប្រាក់ដោយអន្តរាគមន៍ ត្រូវតែបានបញ្ជាក់យថាភាពអំពីការទទួលប្រាក់នៅលើប័ណ្ណសងតាមបញ្ជា ដោយមានឈ្មោះបុគ្គលដែលទទួលការទូទាត់សងប្រាក់ជួស ។ ក្នុងករណីគ្មានសេចក្ដីបញ្ជាក់នេះទេ ការទូទាត់សងប្រាក់ត្រូវបានចាត់ទុកថាបានធ្វើឱ្យអ្នកចេញប័ណ្ណ ។

ប័ណ្ណសងតាមបញ្ជា និងវិរុទ្ធភាព បើមាន ត្រូវតែបានប្រគល់ឱ្យទៅបុគ្គលដែលបានទូទាត់សងប្រាក់ដោយអន្តរាគមន៍ ។

មាត្រា ១៨៦.-

បុគ្គលដែលបានទូទាត់សងប្រាក់ដោយអន្តរាគមន៍ ទទួលបានសិទ្ធិទាំងអស់នៃប័ណ្ណសងតាមបញ្ជាទល់នឹងភាគីដែលខ្លួនបានធ្វើការទូទាត់សងប្រាក់ជួស និងបុគ្គលទាំងឡាយដែលមានការពាក់ព័ន្ធជាមួយភាគីចុងក្រោយនេះទៅលើប័ណ្ណសងតាមបញ្ជា ។ ប៉ុន្តែបុគ្គលដែលបានធ្វើអន្តរាគមន៍នេះ មិនអាចធ្វើបិដ្ឋិលេខប័ណ្ណសងតាមបញ្ជាបន្តទៀតឡើយ ។

អ្នកធ្វើបិដ្ឋិលេខបន្ទាប់ពីភាគីដែលទទួលការទូទាត់សងប្រាក់ជួស ត្រូវរួចផុតពីការទទួលខុសត្រូវដោយអន្តរាគមន៍ ។

ក្នុងករណីមានការប្រជែងគ្នា ដើម្បីទូទាត់សងប្រាក់ដោយអន្តរាគមន៍ការទូទាត់សងដែលមានចំនួនប្រាក់ច្រើនជាងគេត្រូវមានអាទិភាព ។ បុគ្គលណាមួយដែលធ្វើអន្តរាគមន៍ទៅក្នុងលក្ខណៈផ្ទុយពីវិធាននេះ ដោយយល់ដឹងពីហេតុការណ៍ច្បាស់លាស់ត្រូវបាត់បង់សិទ្ធិធ្វើឧបាស្រ័យទល់នឹងបុគ្គលដែលត្រូវបានធ្វើឱ្យរួចផុតពីការទទួលខុសត្រូវដោយអន្តរាគមន៍ ។

## ផ្នែកទី ៩
## ច្បាប់ចម្លង

**មាត្រា ១៨៧.-**

អ្នកកាន់មានសិទ្ធិធ្វើច្បាប់ចម្លងប័ណ្ណសងតាមបញ្ជា ។

ច្បាប់ចម្លងត្រូវតែធ្វើឱ្យបានត្រឹមត្រូវតាមច្បាប់ដើមជាមួយនឹងបិដ្ឋិលេខ និងសេចក្ដីបញ្ជាក់ផ្សេងៗទៀតដែលមាននៅក្នុងនោះ ។ ច្បាប់ចម្លងនេះត្រូវបញ្ជាក់ច្បាស់លាស់នូវចំនួនដែលបានធ្វើ ។

ច្បាប់ចម្លងអាចត្រូវបានធ្វើបិដ្ឋិលេខនិងធ្វើរូបិយបដិភោគ នៅក្នុងលក្ខណៈដូចគ្នា និងមានសុពលភាពដូចគ្នានឹងច្បាប់ដើមដែរ ។

**មាត្រា ១៨៨.-**

ច្បាប់ចម្លងត្រូវតែបញ្ជាក់បុគ្គលដែលកាន់កាប់ច្បាប់ដើម ។ អ្នកកាន់ច្បាប់ដើមត្រូវទទួលខុសត្រូវក្នុងការប្រគល់ច្បាប់ដើម ដែលមានចែងខាងលើឱ្យទៅអ្នកកាន់ស្របច្បាប់នៃច្បាប់ចម្លងនោះ ។

បើអ្នកកាន់ច្បាប់ដើមបដិសេធ អ្នកកាន់ច្បាប់ចម្លងអាចអនុវត្តសិទ្ធិធ្វើឱ្យបានស្រ័យទល់នឹងបុគ្គលទាំងឡាយដែលបានធ្វើបិដ្ឋិលេខ ឬ ធ្វើរូបិយបដិភោគច្បាប់ចម្លង លុះត្រាតែបានបញ្ជាក់នៅលើវិវទ្ធវាទថា ច្បាប់ដើមមិនទាន់ត្រូវបានប្រគល់មកវិញតាមសំណើរបស់ខ្លួននៅឡើយ ។

ក្រោយពីបិដ្ឋិលេខចុងក្រោយដែលធ្វើឡើងមុនពេលធ្វើច្បាប់ចម្លង កាលបើច្បាប់ដើមមានបដិញ្ញាថា ចាប់ផ្ដើមពីពេលនេះ បិដ្ឋិលេខមានសុពលភាពនៅពេលណាដែលបិដ្ឋិលេខធ្វើឡើងលើច្បាប់ចម្លងតែប៉ុណ្ណោះ ឬ តាមរូបមន្តដែលមានន័យដូចគ្នា បិដ្ឋិលេខបន្ទាប់មកទៀតនៅលើច្បាប់ដើម ត្រូវចាត់ទុកជាមោឃៈ ។

## ផ្នែកទី ១០
## ការកែលើប័ណ្ណសងតាមបញ្ជា

**មាត្រា ១៨៩.-**

ក្នុងករណីមានការកែលើខ្លឹមសារនៃប័ណ្ណសងតាមបញ្ជា រាល់ភាគីដែលបានចុះហត្ថលេខាបន្ទាប់ពីការកែ ត្រូវជាប់ពាក់ព័ន្ធទៅតាមខ្លឹមសារដែលបានកែ ។ ភាគីទាំងឡាយដែលបានចុះហត្ថលេខាមុនការកែ ត្រូវជាប់ពាក់ព័ន្ធទៅតាមខ្លឹមសារដើមនៃប័ណ្ណសងតាមបញ្ជា ។

## ផ្នែកទី ១១
## រយៈពេលកំណត់នៃការធ្វើឧបាស្រ័យ

**មាត្រា ១៩០.-**

រាល់ឧបាស្រ័យដែលកើតឡើងពីប័ណ្ណសងតាមបញ្ជាទល់នឹងអ្នកចេញប័ណ្ណមានរយៈពេលបី (០៣) ឆ្នាំ គិតពីថ្ងៃឥណប្រតិទាន ។

រាល់ឧបាស្រ័យដែលធ្វើឡើងដោយអ្នកកាន់ទល់នឹងអ្នកធ្វើបិដ្ឋិលេខទាំងឡាយមានរយៈពេលមួយ (០១) ឆ្នាំ គិតពីថ្ងៃធ្វើវិរុទ្ធវាទត្រឹមត្រូវតាមរយៈពេលកំណត់ ឬ គិតពីថ្ងៃឥណប្រតិទានកាលបើមានបដិញ្ញាថា **បង្វិលទិញដោយគ្មានសោហ៊ុយ** ឬ **បង្វិលទិញដោយគ្មានវិរុទ្ធវាទ** ឬ សេចក្ដីផ្សេងណាមួយដែលមានន័យដូចគ្នា ។

រាល់ឧបាស្រ័យរបស់អ្នកធ្វើបិដ្ឋិលេខទល់នឹងអ្នកធ្វើបិដ្ឋិលេខផងគ្នាមានរយៈពេលប្រាំមួយ (០៦) ខែ គិតពីថ្ងៃដែលអ្នកធ្វើបិដ្ឋិលេខបានទទួលយក និងបានទូទាត់សងប័ណ្ណសងតាមបញ្ជា ឬ គិតពីថ្ងៃដែលបានទទួលរងការប្ដឹង ។

**មាត្រា ១៩១.-**

ការកំណត់រយៈពេលធ្វើឧបាស្រ័យដូចមានចែងក្នុងមាត្រា ១៩០ នៃច្បាប់នេះមានសុពលភាពទៅលើតែបុគ្គលណាមួយ ដែលរយៈពេលនោះត្រូវបានកំណត់ប៉ុណ្ណោះ ។

## ផ្នែកទី ១២

## ការគណនារយៈពេលកំណត់

**មាត្រា ១៩២.-**

ប័ណ្ណសងតាមបញ្ជាដែលដល់រយៈពេលកំណត់ទូទាត់សងប្រាក់នៅថ្ងៃឈប់សម្រាកផ្លូវការនឹងត្រូវទូទាត់សងប្រាក់នៅថ្ងៃធ្វើការបន្ទាប់ ។ រាល់សកម្មភាពដែលទាក់ទងទៅនឹងប័ណ្ណសងតាមបញ្ជា ជាពិសេសការបង្ហាញឱ្យទូទាត់សងប្រាក់ និងវិរុទ្ធវាទអាចត្រូវធ្វើឡើងតែក្នុងថ្ងៃធ្វើការប៉ុណ្ណោះ ។

កាលបើសកម្មភាពទាំងនេះ ត្រូវតែបានធ្វើនៅក្នុងរយៈពេលកំណត់មួយដែលថ្ងៃចុងក្រោយជាថ្ងៃឈប់សម្រាកផ្លូវការ រយៈពេលកំណត់នោះត្រូវបានពន្យាររហូតដល់ថ្ងៃធ្វើការទីមួយបន្ទាប់ ។ ថ្ងៃឈប់សម្រាកត្រូវបានរាប់បញ្ចូលក្នុងការគណនារយៈពេលកំណត់ទាំងនោះដែរ ។

**មាត្រា ១៩៣.-**

រយៈពេលកំណត់ទាំងឡាយដែលចែងក្នុងជំពូកនេះនឹងមិនរាប់បញ្ចូលជាមួយផងទេ នូវថ្ងៃដែលរយៈពេលនោះចាប់ផ្តើម ។

**មាត្រា ១៩៤.-**

ទោះបីតាមផ្លូវច្បាប់ក្តី ឬ តាមផ្លូវតុលាការក្តីពុំអនុញ្ញាតឱ្យមានរយៈពេលអនុគ្រោះឡើយ ។

## ជំពូកទី ៥

## ប្រតិបត្តិការទូទាត់សងប្រាក់

## ផ្នែកទី ១

## កម្មវត្ថុនៃការអនុវត្ត

**មាត្រា ១៩៥.-**

ជំពូកនេះអនុវត្តចំពោះប្រតិបត្តិការទូទាត់សងប្រាក់ជារូបិយវត្ថុក្នុងស្រុក ឬ រូបិយប័ណ្ណណាមួយ ។ ជំពូកនេះកំណត់សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកចូលរួមនិងអនុវត្ត

ចំពោះការរៀបចំប្រតិបត្តិការ ការត្រួតពិនិត្យ និងការគ្រប់គ្រងប្រព័ន្ធទូទាត់សងប្រាក់ក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ១៩៦.-

រូបវ័ន្តបុគ្គល ឬ នីតិបុគ្គល អាចបើកគណនីជារូបិយវត្ថុក្នុងស្រុក និងជារូបិយ-ប័ណ្ណ និងអាចធ្វើប្រតិបត្តិការទូទាត់សងប្រាក់តាមរយៈគណនីទាំងនេះ នៅក្រោមល័ក្ខខ័ណ្ឌដែលបានព្រមព្រៀងទៅតាមបទប្បញ្ញត្តិទាំងឡាយក្នុងផ្នែកទី ៧ នៃជំពូកនេះ ។ រូបវ័ន្តបុគ្គលឬនីតិបុគ្គលអាចមានគណនីមួយ ឬ ច្រើនក្នុងធនាគារមួយ ឬ ច្រើនបាន ។

កថាខណ្ឌខាងលើនៃមាត្រានេះពុំបានបដិសេធចោល និងត្រូវអនុលោមតាមកាតព្វកិច្ចណាមួយដែលតម្រូវដោយច្បាប់ទាក់ទងទៅនឹងការប្រើប្រាស់រូបិយវត្ថុក្នុងស្រុកដូចជាការរឹតត្បិត ឬ ការដាក់កំហិតដោយច្បាប់ដែលពាក់ព័ន្ធទៅនឹងប្រភេទ ឬ ផ្លាក់ជាក់លាក់របស់គណនី ឬរូបិយប័ណ្ណ ។

មាត្រា ១៩៧.-

បញ្ជាទូទាត់អាចត្រូវផ្ញើដោយអតិថិជនណាមួយពីក្នុង ឬ ពីក្រៅព្រះរាជាណា-ចក្រកម្ពុជា និងទទួលដោយធនាគារណាមួយដែលមានទីតាំងនៅក្នុង ឬ ក្រៅព្រះរាជា-ណាចក្រកម្ពុជា ។

បញ្ជាទូទាត់ដែលទទួលដោយសាខា ឬ ការិយាល័យដោយឡែកនៃធនាគារមួយដែលមានទីតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃជំពូកនេះ ហើយបទប្បញ្ញត្តិណាដែលពុំមានចែងទេ ត្រូវស្ថិតនៅក្រោមច្បាប់ដទៃទៀតដែលអនុវត្តនៅព្រះរាជាណាចក្រកម្ពុជា ។ កថាខណ្ឌនេះត្រូវអនុវត្តចំពោះការផ្ញើពីក្នុង ឬ ពីក្រៅព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានកិច្ចព្រមព្រៀងផ្ទុយពីនេះរវាងអ្នកផ្ញើ និងធនាគារទទួល ។

បញ្ជាទូទាត់ដែលទទួលដោយសាខា ឬ ការិយាល័យដោយឡែកនៃធនាគារដែលមានទីតាំងនៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវស្ថិតនៅក្រោមច្បាប់ដែលអនុវត្តនៅកន្លែងដែលសាខា ឬ ការិយាល័យដោយឡែកនោះបានបោះទីតាំង លើកលែងតែមាន

91/128

កិច្ចព្រមព្រៀងផ្ទុយពីនេះរវាងអ្នកផ្ញើ និងធនាគារទទួល ។

សិទ្ធិនិងកាតព្វកិច្ចរវាងធនាគារនិងអតិថិជនរបស់ខ្លួន ដែលទាក់ទងនឹងគណនី និងបញ្ជាទូទាត់ចូល ឬ ចេញ ត្រូវស្ថិតនៅក្រោមច្បាប់ដែលអនុវត្តនៅកន្លែងដែលជាទីតាំងនៃសាខា ឬ ការិយាល័យដោយឡែកដែលបានរក្សាគណនីទាំងនោះ លើកលែងតែមានកិច្ចព្រមព្រៀងផ្ទុយពីនេះរវាងធនាគារនិងអតិថិជនរបស់ខ្លួន ។

បញ្ហាពេលវេលានៃការទូទាត់សងប្រាក់ធ្វើឡើងដោយអ្នកសងប្រាក់ឱ្យទៅអ្នកទទួលប្រាក់ នៅក្នុងប្រតិបត្តិការទូទាត់សងប្រាក់មួយ ត្រូវស្ថិតនៅក្រោមច្បាប់ដែលអនុវត្តនៅកន្លែងជាទីតាំងនៃសាខា ឬ ការិយាល័យដោយឡែករបស់ធនាគារគោលដៅ ។

បញ្ជាទូទាត់អាចត្រូវបញ្ជូនទៅធនាគារជាតិនៃកម្ពុជាឱ្យអនុវត្តការសងប្រាក់ចេញពី ឬ ចូលទៅក្នុងគណនីដែលបានបើកនៅទីនោះ ។ ក្នុងករណីនេះ ជំពូកនេះនឹងត្រូវអនុវត្តចំពោះធនាគារជាតិនៃកម្ពុជាក្នុងនាមជាធនាគារមួយដែរ ។

នៅពេលណាដែលធនាគារទទួលយល់ព្រមអនុវត្តបញ្ជាដែលពុំមែនជាបញ្ជាទូទាត់ ដោយហេតុថាបញ្ជានោះជាកម្មវត្ថុនៃល័ក្ខខ័ណ្ឌណាមួយ បញ្ជាបែបនេះក៏ត្រូវបានចាត់ទុកថាជាបញ្ជាទូទាត់ដែរ ។ ជំពូកនេះអនុវត្តចំពោះប្រតិបត្តិការទូទាត់សងប្រាក់ ប៉ុន្តែមិនត្រូវអនុវត្តចំពោះភារកិច្ច :

-របស់ធនាគារទទួលក្នុងការបញ្ជូនបន្តនូវល័ក្ខខ័ណ្ឌណាមួយទៅកាន់ធនាគារគោលដៅ និង

-របស់ធនាគារគោលដៅ ដើម្បីអនុវត្តល័ក្ខខ័ណ្ឌនោះឡើយ ។

**មាត្រា ១៩៨.-**

សិទ្ធិអំណាចរបស់អ្នកទទួលក្នុងការផ្ទេរឥណពន្ធ មានដូចខាងក្រោម :

១-នៅក្នុងការផ្ទេរឥណពន្ធ អ្នកទទួលអាចដកហូតសិទ្ធិអំណាចដែលបានប្រគល់ឱ្យអ្នកផ្តើមប្រតិបត្តិការដោយធ្វើសេចក្តីជូនដំណឹងដល់ធនាគារគោលដៅអំពីការដកហូតសិទ្ធិអំណាចនោះជាលាយលក្ខណ៍អក្សរ តាមអេឡិចត្រូនិក ឬ ដោយផ្ទាល់មាត់ក៏បាន បើមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមុនឱ្យធ្វើបែបនេះ ។ សេចក្តីជូនដំណឹងត្រូវតែធ្វើឡើងមុនពេលដែលប្រតិបត្តិការទូទាត់សងប្រាក់ត្រូវបានបញ្ចប់ និងក្នុងរយៈពេលនិងតាមវិធីគ្រប់គ្រាន់ ដែលអាចឱ្យធនាគារគោលដៅមានឱកាស

៩៦/៥១

សមស្របក្នុងការអនុវត្តតាម ។ ធនាគារគោលដៅត្រូវបដិសេធបញ្ជាទូទាត់ទាំងឡាយណារបស់អ្នកផ្ញើ ដែលមានសេចក្តីជូនដំណឹងឱ្យដកហូតសិទ្ធិអំណាច ។

២-នៅក្នុងការផ្ទេរឥណពន្ធ សេចក្តីជូនដំណឹងបញ្ជាក់ពីមរណភាព ឬ សេចក្តីសម្រេចរបស់តុលាការអំពីអសមត្ថភាពនីត្យានុកូលនៃអ្នកទទួលដែលធនាគារគោលដៅទទួលបាន មានប្រសិទ្ធភាពដូចគ្នានឹងសេចក្តីជូនដំណឹងរបស់អ្នកទទួលអំពីការដកហូតសិទ្ធិអំណាច ដែលមានចែងនៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះដែរ ។

៣-អតិថិជនដែល :

-គណនីត្រូវបានកត់ត្រាឥណពន្ធតាមចំនួនប្រាក់ក្នុងបញ្ជាទូទាត់នៃការផ្ទេរឥណពន្ធ

-គរ៉ាពីសិទ្ធិអំណាចរបស់អ្នកផ្តើមប្រតិបត្តិការ និង

-ជំទាស់ជាលាយលក្ខណ៍អក្សរនឹងការចុះឥណពន្ធក្នុងរយៈពេលបួន (០៤) ថ្ងៃបន្ទាប់ពីបានដឹងដំណឹងអំពីការចុះឥណពន្ធនេះ នៅក្នុងគណនីរបស់ខ្លួន អាចមានសិទ្ធិចុះបញ្ច្រាសការចុះឥណពន្ធនោះវិញ លើកលែងតែធនាគារគោលដៅបានផ្តល់ភស្តុតាងអំពីសិទ្ធិអំណាចដែលផ្តល់ដោយអតិថិជនទៅកាន់អ្នកផ្តើមប្រតិបត្តិ-ការនោះ ។

៤-តាមរយៈការអនុញ្ញាតឱ្យធ្វើការផ្ទេរឥណពន្ធ អ្នកទទួលបានធានាការទូទាត់សងប្រាក់ទៅអ្នកផ្តើមប្រតិបត្តិការ ។

៥-មាត្រានេះមិនអនុវត្តចំពោះសិទ្ធិអំណាចដែលអ្នកទទួលបានប្រគល់ឱ្យអ្នកផ្តើមប្រតិបត្តិការ តាមការចេញផ្សាយមូលប្បទានប័ត្រនោះទេ ។

## ផ្នែកទី ២

## បញ្ជាទូទាត់

**មាត្រា ១៩៩.-**

បញ្ជាទូទាត់ជាបញ្ជារបស់អ្នកផ្ញើទៅធនាគារទទួល និងមិនប្រើជាការផ្ទេរមូលនិធិឱ្យអ្នកចូលរួមណាមួយ ក្នុងប្រតិបត្តិការទូទាត់សងប្រាក់ឡើយ ។

បញ្ជាទូទាត់អាចធ្វើឡើងជាលាយលក្ខណ៍អក្សរតាមអេឡិចត្រូនិក ឬ អាចធ្វើ

96/128

ឡើងដោយផ្ទាល់មាត់ បើមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមុនរវាងភាគីនៃបញ្ជាទូទាត់ ។ បើមានការព្រមព្រៀងដូច្នេះពីមុន និងជាកម្មវត្ថុនៃល័ក្ខខ័ណ្ឌក្នុងកិច្ចព្រមព្រៀង ទំនាក់ទំនងជាបន្តបន្ទាប់មកទៀតរួមទាំងបញ្ជាបញ្ឈប់ផង ក៏អាចត្រូវធ្វើឡើងដោយផ្ទាល់មាត់បានដែរ ។

បញ្ជាទូទាត់ត្រូវកំណត់អត្តសញ្ញាណ អ្នកទទួលនិងធនាគារគោលដៅឱ្យបានត្រឹមត្រូវ ។ នៅពេលណាដែលបញ្ជាទូទាត់កំណត់អត្តសញ្ញាណអ្នកចូលរួមណាមួយនៅក្នុងប្រតិបត្តិការទូទាត់សងប្រាក់តាមប្រព័ន្ធស្វ័យប្រវត្តិដោយបញ្ជាក់ឈ្មោះ និង លេខកូដ ធនាគារទទួលពុំចាំបាច់បញ្ជាក់នូវសង្គតិភាពរវាងឈ្មោះ និង លេខកូដនោះឡើយ ហើយអាចសងប្រាក់ដោយផ្អែកតែលើលេខកូដប៉ុណ្ណោះ ។ នៅពេលណាដែលនិយោជិតណាម្នាក់ជាអ្នកអនុវត្តបញ្ជាទូទាត់កត់សម្គាល់ឃើញថាឈ្មោះ និងលេខកូដពុំមានសង្គតិភាព ធនាគារទទួលត្រូវបដិសេធបញ្ជាទូទាត់នោះ ។

ធនាគារជាតិនៃកម្ពុជាអាចចេញបទបញ្ជាចែងអំពីល័ក្ខខ័ណ្ឌនានា ដែលនៅក្នុងនោះបញ្ជាទូទាត់ និងទំនាក់ទំនងផ្សេងៗទៀតរួមទាំងបញ្ជាបញ្ឈប់ផងដែរ អាចត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ ។

មាត្រា ២០០.–

នៅក្នុងការផ្ទេរឥណទាន លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ ធនាគារទទួលមានកាតព្វកិច្ចអនុវត្តបញ្ជាទូទាត់របស់អ្នកធ្វើ តែក្នុងករណីដែលគណនីអ្នកធ្វើមានសមតុល្យគ្រប់គ្រាន់ប៉ុណ្ណោះ ។

នៅក្នុងការផ្ទេរឥណពន្ធ ធនាគារផ្ដើមប្រតិបត្តិការត្រូវអនុវត្តបញ្ជាទូទាត់របស់អ្នកផ្ដើមប្រតិបត្តិការ បន្ទាប់ពីមានភស្តុតាងសមស្របអំពីសិទ្ធិអំណាចដែលអ្នកទទួលប្រគល់ឱ្យ និងមានការធានាសងការខូចខាតវិញពីអ្នកផ្ដើមប្រតិបត្តិការ ។ លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ ធនាគារផ្ដើមប្រតិបត្តិការពុំមានកាតព្វកិច្ចផ្ដល់មូលនិធិដល់អ្នកផ្ដើមប្រតិបត្តិការ ឬ សុំឱ្យធ្វើការចុះឥណទានបណ្ដោះអាសន្នត្រី នៅមុនពេលបញ្ចប់ការផ្ទេរឥណពន្ធ ។ បើគណនីរបស់អ្នកផ្ដើមប្រតិបត្តិការត្រូវបានចុះឥណទានដោយធនាគារផ្ដើមប្រតិបត្តិការ មុនពេលមានការបញ្ចប់ការផ្ទេរឥណពន្ធ ការចុះ

ឥណទាននោះត្រូវមានលក្ខណៈបណ្ដោះអាសន្ន ហើយគណនីអ្នកផ្ដើមប្រតិបត្តិការអាចនឹងត្រូវចុះឥណពន្ធវិញក្នុងចំនួនប្រាក់ស្មើនឹងការចុះឥណទាន បើការផ្ទេរឥណពន្ធពុំត្រូវបានបញ្ចប់ដូចដែលបានចែងក្នុងមាត្រា ២១០ នៃច្បាប់នេះទេ ។

ធនាគារទទួល ត្រូវអនុវត្តតែបញ្ជាទូទាត់ណាដែល :

- បានបំពេញសេចក្ដីត្រឹមត្រូវ និងបានការអនុញ្ញាត ឬ មានយថាភាព
- បានកំណត់អត្តសញ្ញាណធនាគារគោលដៅត្រឹមត្រូវ
- បានពណ៌នាអំពីអ្នកទទួលដោយប្រាកដប្រជា ។

ធនាគារទទួលដែលមិនអនុវត្តបញ្ជាទូទាត់របស់អ្នកផ្ញើត្រូវជូនដំណឹងដល់អ្នកផ្ញើជាបន្ទាន់អំពីការបដិសេធ ឬ ការមិនទទួលរបស់ខ្លួន ។

លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ និងមិនគិតដល់ការយកសោហ៊ុយដូចដែលបានព្រមព្រៀង ឬ ដែលជាទម្លាប់ក្ដី ធនាគារទទួលត្រូវអនុវត្តបញ្ជាទូទាត់តាមចំនួនប្រាក់ដែលបានបញ្ជាដោយអ្នកផ្ញើ ។

ធនាគារទទួលត្រូវអនុវត្តបញ្ជាទាំងឡាយ ដែលមាននៅក្នុងបញ្ជាទូទាត់នៅថ្ងៃធ្វើការដែលធនាគារទទួលបានបញ្ជានោះ ឬ នៅថ្ងៃប្រសិទ្ធភាពរបស់បញ្ជាទូទាត់នោះ បើមាន ដែលជាទូទៅគឺនៅពេលក្រោយមកទៀត ។ ធនាគារទទួលអាចកំណត់ពេលម៉ោងកំណត់សម្រាប់អនុវត្តបញ្ជាទូទាត់ ។ រាល់បញ្ជាទូទាត់ណាដែលបានទទួលក្រោយពេលកំណត់នេះ ត្រូវបានចាត់ទុកថាបានទទួលនៅថ្ងៃធ្វើការបន្ទាប់របស់ធនាគារ ។

ធនាគារផ្ដើមប្រតិបត្តិការនៅក្នុងការផ្ទេរឥណទាន និងធនាគារគោលដៅ នៅក្នុងការផ្ទេរឥណពន្ធដែលបានទទួលបញ្ជាទូទាត់លើសពីមួយក្នុងអំឡុងថ្ងៃធ្វើការរបស់ធនាគារ ឬ បញ្ជាស្របច្បាប់ផ្សេងទៀត ដើម្បីដកមូលនិធិចេញពីគណនី អាចនឹងអនុវត្តបញ្ជាទាំងនោះតាមលំដាប់លំដោយណាក៏បាន លើកលែងតែមានការចែងផ្សេងពីនេះ នៅក្នុងច្បាប់ផ្សេងទៀត ។

ធនាគារទទួលត្រូវមានការប្រុងប្រយ័ត្នជានិច្ចក្នុងការអនុវត្តបញ្ជាទូទាត់ ។ ធនាគារទទួលត្រូវប្រុងប្រយ័ត្នក្នុងការបកស្រាយបញ្ជាទូទាត់ដែលមិនច្បាស់លាស់ ហើយធ្វើសកម្មភាពដោយស្មោះត្រង់ និងត្រូវអនុវត្តបញ្ជាទូទាត់ទៅតាមអត្ថន័យសមស្របដោយមិនបាច់ស្វែងយល់ថាការបកស្រាយនោះជាការផ្ទុយពីបំណងរបស់អ្នកផ្ញើឡើយ ។

*

៩៥/១២៧

ក្នុងការទទួលបញ្ជាទូទាត់ និងធ្វើសកម្មភាពនៅក្នុងប្រតិបត្តិការទូទាត់សងប្រាក់ និងទោះបីជាមានកិច្ចព្រមព្រៀងផ្ទុយពីនេះក៏ដោយ ធនាគារទទួលត្រូវតែគោរពតាមច្បាប់នេះ ព្រមទាំងបទបញ្ជា ឬ សេចក្ដីណែនាំទាំងឡាយដែលពាក់ព័ន្ធក៏ដូចជាច្បាប់ដទៃទៀតដែរ ។ ធនាគារត្រូវធ្វើសកម្មភាពដោយយកចិត្តទុកដាក់ និងសុចរិតស្រប តាមស្តង់ដារួមរបស់ធនាគារ និងត្រូវជួយដល់អ្នកចូលរួមនានាក្នុងការបញ្ចប់ប្រតិបត្តិការទូទាត់សងប្រាក់ដោយត្រឹមត្រូវ ។ នៅក្នុងក្របខ័ណ្ឌដែលមានចែងនៅក្នុងច្បាប់នេះ ឬ ច្បាប់ផ្សេងទៀត ធនាគារត្រូវរក្សាការសម្ងាត់ និងធ្វើសកម្មភាពជាប្រយោជន៍ខ្ពស់បំផុតរបស់អ្នកផ្ញើ ។

ជាកម្មវត្ថុនៃកាតព្វកិច្ចរក្សាការសម្ងាត់ នៅក្រោមច្បាប់នានាដែលកំពុងអនុវត្ត ធនាគារទទួល ដែលបានបញ្ជាឱ្យបញ្ជូនប្រតិបត្តិការទូទាត់សងប្រាក់តាមរយៈធនាគារអន្តរការី ឬ ទៅកាន់ធនាគារគោលដៅដែលខ្លួនវិនិច្ឆ័យថាពុំអាចទុកចិត្តបានក្នុងកាលៈទេសៈនោះ ត្រូវជូនដំណឹងជាបន្ទាន់ដល់អ្នកផ្ញើអំពីការបារម្ភរបស់ខ្លួន ។ ប៉ុន្តែនៅពេលណាដែលធនាគារទទួលនៅតែបានទទួលបញ្ជាឱ្យបញ្ជូនប្រតិបត្តិការផ្ទុយពីការជូនដំណឹងរបស់ខ្លួន ធនាគារទទួលអាចបដិសេធមិនទទួលបញ្ជាទូទាត់នោះ ឬ ដោយមិនគិតដល់បទប្បញ្ញត្តិផ្សេងទៀតនៅក្នុងច្បាប់នេះ អាចប្រតិបត្តិបញ្ជានោះដោយអ្នកផ្ញើត្រូវទទួលរ៉ាប់រងហានិភ័យ ។

មាត្រា ២០១.-

លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ រវាងអ្នកផ្ញើ និង ធនាគារទទួល បញ្ជាទូទាត់អាចត្រូវបដិសេធឬបញ្ឈប់បាន ។ បញ្ជាទូទាត់នឹងត្រូវបានបញ្ឈប់ដោយអ្នកផ្ញើ នៅពេលណាដែលបញ្ជាបញ្ឈប់មានការអនុញ្ញាត ឬ មានការបញ្ជាក់ត្រឹមត្រូវដោយអ្នកផ្ញើឬក្នុងនាមអ្នកផ្ញើ ត្រូវបានទទួលដោយធនាគារទទួលនៅក្នុងពេល និងតាមវិធីដែលធនាគារអាចធ្វើការបញ្ឈប់បញ្ជាទូទាត់នៅមុនពេលអនុវត្ត ។

ទោះបីជាបន្ទាប់ពីបានប្រតិបត្តិបញ្ជាទូទាត់របស់អ្នកផ្ញើរួចហើយក្តី តាមការស្នើសុំរបស់អ្នកផ្ញើ ធនាគារដែលបានទទួលនិងប្រតិបត្តិបញ្ជានេះអាចចេញបញ្ជាបញ្ឈប់ឱ្យទៅធនាគារទទួលរបស់ខ្លួន ដូចមានចែងក្នុងកថាខណ្ឌខាងលើនៃមាត្រានេះ ។ បញ្ជា

បញ្ឈប់ដែលចេញដោយអ្នកផ្ញើទៅកាន់ធនាគារគោលដៅនៅក្នុងប្រតិបត្តិការទូទាត់សងប្រាក់នឹងមានប្រសិទ្ធភាពតែនៅពេលណាដែលបញ្ជាបញ្ឈប់នោះបានទៅដល់ធនាគារគោលដៅ នៅមុនពេលដែលប្រតិបត្តិការទូទាត់សងប្រាក់ត្រូវបានបញ្ចប់ប៉ុណ្ណោះ ។

បញ្ជាបញ្ឈប់ត្រូវតែកត់សម្គាល់បញ្ជាទូទាត់ ដែលត្រូវបញ្ឈប់នោះឱ្យបានច្បាស់លាស់ និងត្រូវបានបញ្ជូនទៅធនាគារទទួលជាលាយលក្ខណ៍អក្សរតាមអេឡិចត្រូនិក ឬ ដោយផ្ទាល់មាត់បើមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីមុនរវាងភាគីនៃបញ្ជាទូទាត់ ។

បញ្ជាទូទាត់ដែលពុំទាន់បានអនុវត្តដោយធនាគារទទួលត្រូវបានដកមកវិញនៅក្នុងករណីដូចតទៅ :

-នៅពេលបញ្ចប់ថ្ងៃធ្វើការទីប្រាំរបស់ធនាគារទទួល ឬ ក្នុងរយៈពេលខ្លីជាងនេះតាមការព្រមព្រៀងគ្នា បន្ទាប់ពីបានទទួលបញ្ជាទូទាត់ ឬ នៅថ្ងៃប្រសិទ្ធភាពនៃបញ្ជាទូទាត់ ដែលជាទូទៅនៅពេលក្រោយមកទៀត

-នៅពេលណាដែលធនាគារទទួលបានដឹងអំពីមរណភាព ឬ សេចក្តីសម្រេចរបស់តុលាការអំពីអសមត្ថភាពនីត្យានុកូលនៃអ្នកផ្ញើ ឬ

-នៅពេលណាដែលធនាគារទទួលត្រូវបានបិទដោយអាជ្ញាធរត្រួតពិនិត្យ ។

ការបញ្ឈប់ឬការដកមកវិញនូវបញ្ជាទូទាត់នឹងមិនមានប្រសិទ្ធភាពទេ បន្ទាប់ពីប្រតិបត្តិការទូទាត់សងប្រាក់នោះ ត្រូវបានបញ្ចប់ជាស្ថាពរ ។

មាត្រា ២០២.-

ការទូទាត់បញ្ជាទូទាត់អន្តរធនាគារ និងពេលវេលាសម្រាប់ការទូទាត់ត្រូវបានកំណត់ដូចតទៅ :

១-ការទូទាត់ចំពោះបញ្ជាទូទាត់អន្តរធនាគារ អាចធ្វើឡើង :

ក-នៅលើគណនីទូទាត់របស់បណ្តាធនាគារនៅធនាគារជាតិនៃកម្ពុជា ដែលនៅក្នុងករណីនេះ ត្រូវស្ថិតក្រោមបទបញ្ជាទាក់ទងនឹងសភាផាត់ទាត់ដែល

ចេញដោយធនាគារជាតិនៃកម្ពុជា

ខ-តាមរយៈការកត់ត្រាឥណពន្ធ ឬ ឥណទានទៅក្នុងគណនីផ្សេង ពីគណនីទូទាត់ ដែលធនាគារមួយមាននៅធនាគារមួយទៀត ឬ នៅធនាគារទីបី ។ ការចុះឥណពន្ធ ឬ ឥណទានបែបនេះអាចធ្វើឡើងសម្រាប់បញ្ជាទូទាត់នីមួយៗដោយឡែកពីគ្នា ឬ សម្រាប់បញ្ជាទូទាត់ជាសំណុំ ដែលក្នុងករណីណាក៏ដោយ ក៏ត្រូវធ្វើឡើងនៅចុងគ្រានៃការជាត់ទាត់ដែរ

គ-តាមមធ្យោបាយផ្សេងទៀត ដែលអាចសម្រេចកាតព្វកិច្ចបាន ។

២-ពេលវេលាសម្រាប់ការទូទាត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះមានដូចតទៅ :

ក-នៅក្រោមកថាខណ្ឌទី ១-ក នៅពេលណាដែលការទូទាត់ត្រូវបានបញ្ចប់ក្រោមបទបញ្ជាទាក់ទងនឹងសភាជាត់ទាត់ដែលចេញដោយធនាគារជាតិនៃកម្ពុជា

ខ-នៅក្រោមកថាខណ្ឌទី ១-ខ តាមរយៈការចុះឥណពន្ធគណនីមួយ នៅពេលណាដែលខ្ទង់ឥណពន្ធត្រូវបានកត់ត្រាទៅក្នុងគណនី

គ-នៅក្រោមកថាខណ្ឌទី ១-ខ តាមរយៈការចុះឥណទានគណនីមួយ នៅពេលណាខ្ទង់ឥណទានដែលបានកត់ត្រាក្នុងគណនីត្រូវបានប្រើប្រាស់ ឬ បើមិនបានប្រើប្រាស់ គឺនៅពេលចាប់ផ្តើមថ្ងៃធ្វើការបន្ទាប់ដែលមានខ្ទង់ឥណទានសម្រាប់ប្រើប្រាស់ ហើយធនាគារបានដឹងអំពីការចុះឥណទានក្នុងគណនីរបស់ខ្លួន

ឃ-នៅក្នុងកថាខណ្ឌទី ១-គ អនុលោមតាមច្បាប់ដែលបានកំណត់អំពីពេលសម្រេចកាតព្វកិច្ច ។

៣-កថាខណ្ឌនេះត្រូវអនុវត្តកាលបើការទូទាត់នៅក្រោមកថាខណ្ឌទី ១-ខ នៃមាត្រានេះកើតមានឡើងដោយអនុលោមតាមកិច្ចព្រមព្រៀង ឬ វិធានដែលអនុវត្តចំពោះការបញ្ចប់ការទូទាត់អន្តរធនាគារក្រៅធនាគារជាតិនៃកម្ពុជា និង សម្រាប់បញ្ជាទូទាត់សងប្រាក់តាមចំនួនសុទ្ធជាទ្វេ ឬ ពហុភាគី ។ ទោះបីជាមានកថាខណ្ឌទី ២-ខ នៃមាត្រានេះក៏ដោយ ការទូទាត់បែបនេះកើតមានឡើងនៅពេលដែលការទូទាត់សងនេះ ត្រូវបានបញ្ចប់តាមកិច្ចព្រមព្រៀង ឬ វិធាន ។

៤-បទបញ្ជាដែលចេញដោយធនាគារជាតិនៃកម្ពុជាអាចរឹតត្បិត ឬ គ្រប់គ្រងលើកាលៈទេសៈ ដែលក្នុងនេះការទូទាត់នៅក្រោមកថាខណ្ឌទី ១-ខ ឬ គ នៃមាត្រានេះអាចកើតមានឡើង ក៏ដូចជាអាចកែប្រែពេលវេលាសម្រាប់ការទូទាត់ ។

៥-ដោយមិនគិតដល់អ្វីដែលមានចែងនៅក្នុងច្បាប់ណាមួយ ដែលទោះជាទាក់ទងឬមិនទាក់ទងដល់បណ្តឹងអំពីអសាធនភាពទល់នឹងធនាគារ មិនត្រូវ :

-មានឥទ្ធិពលប្រតិសកម្មលើសិទ្ធិ និងកាតព្វកិច្ចដែលកើតឡើងពី ឬ ដែលពាក់ព័ន្ធជាមួយការផាត់ទាត់ និងការទូទាត់បញ្ជាទូទាត់ឡើយ ក្រៅពីនៅពេលវេលាដែលបណ្តឹងអំពីអសាធនភាពនោះ ត្រូវបានធ្វើ ឬ

-មានផលប៉ះពាល់ទៅលើប្រសិទ្ធភាព និងការអនុវត្តបាននៃបញ្ជាទូទាត់ដែលទទួលបានដោយធនាគារទទួល នៅមុនពេលមានបណ្តឹងអំពីអសាធនភាពនេះ និងមុនពេលការទូទាត់សងប្រាក់តាមចំនួនសុទ្ធជាទ្វេ ឬ ពហុភាគីព្រមទាំងមុនពេលមានការផ្តល់ការធានាណាមួយ ។

៦-ដើម្បីគោលបំណងនៃកថាខណ្ឌទី ៥ នៃមាត្រានេះ និងកថាខណ្ឌទី ២ នៃមាត្រាទី ២២៧ នៃច្បាប់នេះ **បណ្តឹងអំពីអសាធនភាព** គឺជាវិធានការរួមដែលកំណត់ដោយច្បាប់ដើម្បីជំរះបញ្ជី បញ្ឈប់សកម្មភាព ឬ ដើម្បីរៀបចំធនាគារឡើងវិញ ទោះដោយស្ម័គ្រចិត្ត ឬ មិនស្ម័គ្រចិត្តក្តី ហើយពេលវេលានៃការបើកបណ្តឹងអំពីអសាធនភាព ជាពេលវេលាដែលអាជ្ញាធរតុលាការ ឬ រដ្ឋបាលពាក់ព័ន្ធប្រកាសអំពីសេចក្តីសម្រេចរបស់ខ្លួន ។

## ផ្នែកទី ៣
## អ្នកដំណើរការតតិយភាគី

**មាត្រា ២០៣.–**

ក្នុងការអនុវត្តផ្នែកណាមួយនៃប្រតិបត្តិការទូទាត់សងប្រាក់ ធនាគារអាចប្រើប្រាស់អ្នកដំណើរការតតិយភាគី ។ ដូចដែលបានអនុញ្ញាតដោយធនាគារ អ្នកដំណើរការតតិយភាគីអាចធ្វើការក្នុងនាមធនាគារដែលបានផ្តល់សិទ្ធិជា :

-អ្នកទំនាក់ទំនង

-អ្នកជាត់ទាត់អន្តរធនាគារ ដែលអាចបញ្ជូនជាបន្តនូវព័ត៌មានអំពីការទូទាត់អន្តរធនាគារទៅកាន់ធនាគារនានា រួមទាំងធនាគារជាកន្លែងដែលការទូទាត់ត្រូវបានបញ្ចប់ផងដែរ

-ភ្នាក់ងារគ្រប់គ្រងនិងប្រតិបត្តិការ សម្រាប់ធនាគារដែលមានគណនីអតិថិជន និង/ឬ

-កន្លែងធ្វើនិងទទួលបញ្ជាទូទាត់ដែលត្រូវបានធ្វើឬទទួលដោយធនាគារ ហើយដែលអតិថិជនរបស់ធនាគារអាចចូលទាក់ទងដោយផ្ទាល់សម្រាប់ការធ្វើ និងទទួលបញ្ជាទូទាត់ ។

មាត្រា ២០៤.-

អ្នកដំណើរការតតិយភាគីត្រូវគោរពតាមរាល់កាតព្វកិច្ច ល័ក្ខខ័ណ្ឌ និងការរឹត-ត្បិតទាំងឡាយដែលកំណត់ដោយបទបញ្ជារបស់ធនាគារជាតិនៃកម្ពុជា ។ បទបញ្ជាទាំងនោះអាចចែងអំពីការផ្តល់អាជ្ញាប័ណ្ណ បញ្ញត្តិកម្ម ការត្រួតពិនិត្យ និងអាចអនុវត្តចំពោះអ្នកដំណើរការតតិយភាគីគ្រប់ប្រភេទទាំងអស់ ។ ប្រភេទផ្សេងគ្នានៃអ្នកដំណើរការតតិយភាគី តាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា អាចស្ថិតក្រោមកាតព្វកិច្ចខុសៗគ្នា ។

ធនាគារមួយអាចធ្វើជាអ្នកដំណើរការតតិយភាគីក្នុងនាមធនាគារមួយទៀត ។

មាត្រា ២០៥.-

ក្រៅពីការទទួលខុសត្រូវរវាងធនាគារនិងអ្នកដំណើរការតតិយភាគី ធនាគារដែលបានប្រគល់សិទ្ធិឱ្យអ្នកដំណើរការតតិយភាគីធ្វើសកម្មភាពជួសមុខឱ្យ ត្រូវទទួលខុសត្រូវទាំងស្រុងលើសកម្មភាព ឬ កំហុសរបស់អ្នកដំណើរការតតិយភាគីនោះ ។

ដើម្បីធានាការគោរពតាមច្បាប់នេះនិងកាតព្វកិច្ចស្របច្បាប់ផ្សេងទៀត ធនា-គារត្រូវធានាថា អ្នកដំណើរការតតិយភាគីត្រូវធ្វើប្រតិបត្តិការនៅក្រោមការគ្រប់គ្រងនិងការត្រួតពិនិត្យទាំងស្រុងរបស់ខ្លួន ចំពោះហេតុការណ៍ទាំងឡាយដែលបុគ្គលនេះបានធ្វើសកម្មភាពជួសមុខឱ្យ ហើយធនាគារមិនអាចបដិសេធការគ្រប់គ្រង និងការ

ត្រួតពិនិត្យនេះទេ ។

មាត្រា ២០៦.-

អ្នកដំណើរការតតិយភាគីត្រូវបដិសេធបញ្ជាទូទាត់ដែលអតិថិជនរបស់ធនាគារផ្ញើមកខ្លួនដោយផ្ទាល់ លើកលែងតែ :

ក-បញ្ជូទូទាត់នោះត្រូវបានផ្ញើមក ដោយការប្រគល់សិទ្ធិរបស់ធនាគារ

ខ-នៅក្នុងករណីនៃការផ្ទេរឥណទាន

-អ្នកដំណើរការតតិយភាគីធ្វើសកម្មភាពក្នុងនាមធនាគារ ជាភ្នាក់ងារគ្រប់គ្រង ឬ ប្រតិបត្តិការលើគណនីអតិថិជន ហើយគណនីអតិថិជននោះមានសមតុល្យគ្រប់គ្រាន់

-អ្នកដំណើរការតតិយភាគី បានទទួលការអនុញ្ញាតពីធនាគារ ។

បញ្ជាទូទាត់របស់អតិថិជនដែលអនុវត្តដោយអ្នកដំណើរការតតិយភាគី ត្រូវបានចាត់ទុកថា ជាបញ្ជាពីអតិថិជនទៅកាន់ធនាគាររបស់ខ្លួន អនុវត្តតាមបញ្ជាទូទាត់នេះ ធនាគារធ្វើបញ្ជាទូទាត់ផ្ញើទៅអ្នកដំណើរការតតិយភាគី ដើម្បីបញ្ជូនបន្តទៅកាន់ធនាគារទទួល ។

នៅពេលណាដែលធនាគារមួយផ្តល់សិទ្ធិដល់អ្នកដំណើរការតតិយភាគីឱ្យធ្វើជាកន្លែងទទួលបញ្ជាទូទាត់ទាំងឡាយដែលផ្ញើមកធនាគារ បញ្ជាទូទាត់ដែលបានទទួលដោយអ្នកដំណើរការតតិយភាគី ត្រូវបានចាត់ទុកថាបានទទួលដោយធនាគារទទួល ។

## ផ្នែកទី ៤

## ការបញ្ចប់ការផ្ទេរឥណទាននិងការសងបំណុល

មាត្រា ២០៧.-

ការផ្ទេរឥណទានត្រូវបានបញ្ចប់ក្នុងករណីដូចខាងក្រោម :

១-ការផ្ទេរឥណទាននឹងត្រូវបានបញ្ចប់នៅពេលណាដែលធនាគារគោលដៅបានទទួលប្រាក់ ។ ចំពោះការផ្ទេរផ្ទៃក្នុង ធនាគារបានទទួលការសងប្រាក់នៅពេលណាដែលខ្លួនបានកត់ត្រាឥណពន្ធក្នុងគណនីរបស់អ្នកផ្តើមប្រតិបត្តិការនូវចំនួនប្រាក់

114/125

នៃបញ្ជាទូទាត់ ។ ចំពោះការផ្ទេរឥណទានអន្តរធនាគារ ធនាគារគោលដៅបានទទួលប្រាក់នៅពេលណាដែលការទូទាត់អន្តរធនាគាររួមទាំងបញ្ជាទូទាត់របស់ធនាគារផ្ញើផងនោះ ត្រូវបានបញ្ចប់ ។

២-ការផ្ទេរឥណទានត្រូវបានបញ្ចប់ នៅពេលចាប់ផ្តើមថ្ងៃធ្វើការរបស់ធនាគារ បន្ទាប់ពីថ្ងៃដែលធនាគារគោលដៅបានទទួលបញ្ជាទូទាត់ ឬ បន្ទាប់ពីថ្ងៃប្រសិទ្ធភាពដែលជាថ្ងៃក្រោយមកទៀត បើនៅពេលនោះ អ្នកផ្ញើមានចំនួនប្រាក់គ្រប់គ្រាន់សម្រាប់ចុះឥណទាននៅធនាគារគោលដៅ និងលើកលែងតែធនាគារគោលដៅបដិសេធបញ្ជាទូទាត់មិនយឺតជាងមួយម៉ោងក្រោយមក ។

៣-នៅពេលណាដែលអ្នកទទួលពុំមានគណនីជាមួយនិងធនាគារគោលដៅពីមុនមកទេ ឬ នៅពេលណាដែលគណនីនោះ ត្រូវបិទ ឬ រាំងខ្ទប់ចំពោះការសងប្រាក់ចូល ការផ្ទេរឥណទានត្រូវបានបញ្ចប់នៅពេលណាដែលធនាគារគោលដៅសងប្រាក់ឱ្យទៅអ្នកទទួល ។

មាត្រា ២០៨.-

នៅពេលបញ្ចប់ការផ្ទេរឥណទាន ធនាគារគោលដៅនឹងក្លាយទៅជាអ្នកជំពាក់បំណុលចំពោះអ្នកទទួលតាម ចំនួនប្រាក់នៃបញ្ជាទូទាត់ដែលខ្លួនបានទទួល ហើយក្រោយពីការដកចេញកម្រៃសេវាសមស្រប ធនាគារនោះត្រូវសងប្រាក់ឱ្យទៅអ្នកទទួលភ្លាម ។

ការសងប្រាក់ឱ្យទៅអ្នកទទួលដោយធនាគារគោលដៅ ត្រូវធ្វើឡើងតាមរយៈការចុះឥណទានគណនីអ្នកទទួលមិនឱ្យហួសពីថ្ងៃធ្វើការរបស់ធនាគារ បន្ទាប់ពីការផ្ទេរឥណទានត្រូវបានបញ្ចប់ ។ នៅពេលណាដែលពុំមានគណនីរបស់អ្នកទទួលប្រាក់ ឬ ពុំអាចសម្គាល់គណនីឱ្យបានច្បាស់លាស់គ្រប់គ្រាន់ទេ ឬ នៅពេលណាដែលមានការបញ្ជាបែបនេះ ធនាគារគោលដៅត្រូវផ្តល់ដំណឹងភ្លាមដល់អ្នកទទួលអំពីការដែលខ្លួនមានមូលនិធិនៅក្នុងដៃ និងត្រូវសងឱ្យទៅអ្នកទទួល ។

នៅពេលណាដែលអ្នកទទួល ឬ គណនីអ្នកទទួលពុំត្រូវបានបញ្ជាក់ច្បាស់លាស់នៅក្នុងបញ្ជាទូទាត់ដែលធនាគារគោលដៅបានទទួល ជាហេតុនាំឱ្យមានការសង្ស័យ

អំពីអត្តសញ្ញាណអ្នកទទួល ធនាគារគោលដៅមិនត្រូវទទួលបញ្ជាទូទាត់នោះឡើយ ហើយត្រូវផ្តល់ដំណឹងដល់អ្នកផ្ញើពីការមិនទទួលនេះ ។

នៅពេលណាដែលធនាគារគោលដៅបានសងប្រាក់ឱ្យទៅអ្នកទទួល ឬ បានសន្យាថាសងប្រាក់ឱ្យទៅអ្នកទទួលជាមុន ការសងប្រាក់ ឬ ការសន្យានេះត្រូវមានលក្ខណៈស្ថាពរនិងមិនអាចកែប្រែបាន ហើយការផ្ទេរឥណទានត្រូវចាត់ទុកថាបានបញ្ចប់ ប៉ុន្តែអ្នកផ្ញើអាចនៅជំពាក់ធនាគារទទួលរបស់ខ្លួន ។ ការសន្យាសងប្រាក់របស់ធនាគារគោលដៅអាចត្រូវធ្វើដោយផ្ទាល់ជាមួយអ្នកទទួល ឬ តាមកិច្ចព្រមព្រៀងអន្តរធនាគារ ។

មាត្រា ២០៩.-

នៅពេលណាដែលការផ្ទេរឥណទានត្រូវបានធ្វើឡើងដើម្បីសងបំណុល ដែលអ្នកផ្តើមប្រតិបត្តិការបានជំពាក់អ្នកទទួល លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះរវាងភាគីទាំងពីរ បំណុលនឹងត្រូវបានសងរួចនៅពេលណាដែលប្រតិបត្តិការទូទាត់សងប្រាក់ត្រូវបានបញ្ចប់ ។ ការទូទាត់សងមានកម្រិតត្រឹមចំនួនប្រាក់ដែលបានសងនៅក្នុងប្រតិបត្តិការទូទាត់សងប្រាក់តែប៉ុណ្ណោះ ។

ការសងបំណុលត្រូវធ្វើឡើងមុនពេលបញ្ចប់ប្រតិបត្តិការទូទាត់សងប្រាក់ បន្ទាប់ពីអ្នកទទួលយល់ព្រមធ្វើការធានាលើការទូទាត់សងប្រាក់ ឬ ការធានាលើការទូទាត់សងប្រាក់នោះ ត្រូវបានបញ្ជាក់ដោយធនាគារគោលដៅទៅអ្នកទទួល លើកលែងតែក្នុងកាលៈទេសៈដូចមានចែងក្នុងកថាខណ្ឌទី ៣ មាត្រា ២០៧ នៃច្បាប់នេះ ។

អ្នកធានាឬធនាគារគោលដៅដែលបានធានាឬបញ្ជាក់អំពីការទូទាត់សងប្រាក់ក្រោមកថាខណ្ឌខាងលើត្រូវទទួលរ៉ាប់រងទូទាត់សងប្រាក់ និងក្លាយជាអ្នកជំពាក់ចំពោះអ្នកទទួលនូវចំនួនប្រាក់ដែលបានធានាឬបញ្ជាក់នោះ ។

## ផ្នែកទី ៥
## ការបញ្ចប់ការផ្ទេរឥណពន្ធនិងការសងបំណុល

**មាត្រា ២១០.-**

ការផ្ទេរឥណពន្ធត្រូវបានបញ្ចប់ក្នុងករណីដូចខាងក្រោម :

104/128

១-ការផ្ទេរឥណពន្ធនឹងត្រូវបានបញ្ចប់ នៅពេលណាដែលធនាគារគោលដៅកត់ត្រាឥណពន្ធគណនីរបស់អ្នកទទួល ដូចដែលបានបញ្ជានៅក្នុងបញ្ជាទូទាត់ដែលខ្លួនបានទទួលហើយពុំបានចុះបញ្ជ្រាសឥណពន្ធ និងពុំបានបដិសេធបញ្ជាទូទាត់រហូតដល់ចុងថ្ងៃធ្វើការរបស់ធនាគារ បន្ទាប់ពីបានទទួលបញ្ជាទូទាត់ ។ នៅពេលណាដែលបញ្ជាទូទាត់បញ្ជាទៅធនាគារគោលដៅ ឱ្យចុះឥណពន្ធលើគណនីណាមួយដែលបើកនៅធនាគារនោះ ការផ្ទេរឥណពន្ធនឹងត្រូវបញ្ចប់នៅពេលចប់ថ្ងៃធ្វើការរបស់ធនាគារបន្ទាប់ពីបានទទួលបញ្ជាទូទាត់ ទោះបីជាមុនការកត់ត្រាឥណពន្ធលើគណនីអ្នកទទួលក៏ដោយ និងបើរហូតមកទល់ពេលនោះពុំមានការបដិសេធសមស្របចំពោះបញ្ជាទូទាត់នោះទេ ។

២-រហូតដល់ពេលបញ្ចប់ថ្ងៃធ្វើការរបស់ធនាគារ បន្ទាប់ពីបានទទួលបញ្ជាទូទាត់ ធនាគារគោលដៅអាចបដិសេធបញ្ជាទូទាត់នោះបាន ។ ធនាគារគោលដៅមានសិទ្ធិដែលទទួលបានពីអ្នកផ្ញើរបស់ខ្លួន ដើម្បីទូទាត់ចំនួនប្រាក់ឱ្យទៅអ្នកផ្ញើនោះវិញដោយជូនដំណឹងអំពីការបដិសេធរបស់ខ្លួនដល់អ្នកផ្ញើ និងធនាគារផ្ដើមប្រតិបត្តិ-ការ បើអ្នកទាំងពីរនេះជាធនាគារពីរផ្សេងគ្នា ។ ការបដិសេធ និង ការទទួលសិទ្ធិពីអ្នកផ្ញើមានលក្ខណៈស្វ័យប្រវត្តិតាមច្បាប់ នៅពេលណាដែលធនាគារទទួលត្រូវបានបិទទ្វារដោយអាជ្ញាធរត្រួតពិនិត្យមុនពេលបញ្ចប់ថ្ងៃធ្វើការរបស់ធនាគារ បន្ទាប់ពីបានទទួលបញ្ជាទូទាត់ ។

៣-នៅពេលបានទទួលសេចក្ដីជូនដំណឹងពីការបដិសេធ ធនាគារផ្ញើនីមួយៗដែលពុំមែនជាធនាគារផ្ដើមប្រតិបត្តិការត្រូវជូនដំណឹងដល់អ្នកផ្ញើរបស់ខ្លួន និងមានសិទ្ធិដូចគ្នានេះ ក្នុងការទទួលការទូទាត់សងប្រាក់ពីអ្នកផ្ញើនោះ ។ ធនាគារផ្ញើនីមួយៗដែលពុំមែនជាធនាគារផ្ដើមប្រតិបត្តិការ ត្រូវជូនដំណឹងដល់អ្នកផ្ញើរបស់ខ្លួនអំពីការបដិសេធនោះមិនឱ្យហួសពីថ្ងៃធ្វើការរបស់ធនាគារ បន្ទាប់ពីថ្ងៃបានទទួលការជូនដំណឹងអំពីការបដិសេធ ។

៤-នៅពេលបានទទួលដំណឹងពីការបដិសេធ ធនាគារផ្ដើមប្រតិបត្តិការត្រូវផ្ដល់ដំណឹងភ្លាមដល់អ្នកផ្ដើមប្រតិបត្តិការអំពីការបដិសេធនោះ ដោយមិនឱ្យហួសពីមួយថ្ងៃធ្វើការបន្ទាប់របស់ធនាគារ និងអាចចុះបញ្ជ្រាសឥណទានដែលបានកត់ត្រា

ជាបណ្ដោះអាសន្ននៅគ្រាមុនទៅក្នុងគណនីអ្នកផ្ដើមប្រតិបត្តិការ ឬ ម៉្យាងទៀតអាច ប្រមូលពីអ្នកផ្ដើមប្រតិបត្តិការមកវិញនូវការទូទាត់សងប្រាក់ដែលបានធ្វើនៅពេល មុន ចំពោះបញ្ជាទូទាត់នោះ ។

៥-ថ្វីបើមានកថាខណ្ឌទី២នៃមាត្រានេះក្ដី ធនាគារគោលដៅត្រូវទទួល ខុសត្រូវចំពោះមុខអ្នកទទួល ក្នុងការមិនទូទាត់សងប្រាក់ដោយខុសឆ្គង នៅពេលណា ដែលខ្លួនបានបដិសេធបញ្ជាទូទាត់នោះ ដោយមិនត្រឹមត្រូវតាមច្បាប់ ឬ ដោយគ្មាន មូលហេតុស្របច្បាប់ :

-ទោះបីជាមានការយល់ដឹងអំពីសិទ្ធិរបស់អ្នកទទួលចំពោះការ ផ្ទេរឥណពន្ធក្ដី

-ទោះបីជាមានអត្តសញ្ញាណច្បាស់លាស់នៅក្នុងបញ្ជាទូទាត់ទទួល ដោយធនាគារ ដែលមានគណនីអ្នកទទួលហើយក្ដី និង

-ទោះបីមានសមតុល្យគ្រប់គ្រាន់ក្នុងគណនីក្ដី ។

៦-រយៈពេលដែលបានកំណត់តាមមាត្រា ២១០ និងមាត្រា ២១១ នៃ ច្បាប់នេះអាចត្រូវបានបង្រួញដោយកិច្ចព្រមព្រៀង ឬ បទបញ្ជា ។

មាត្រា ២១១.-

នៅពេលបញ្ចប់ការផ្ទេរឥណពន្ធ ធនាគារគោលដៅ និង ធនាគារទទួលនីមួយៗ ដែលបានទទួលការសងប្រាក់ពីធនាគារទទួលរបស់ខ្លួន ត្រូវទទួលខុសត្រូវចំពោះអ្នក ផ្ញើរបស់ខ្លួននូវចំនួនប្រាក់ដែលខ្លួនបានទទួលនោះ ។ ការសងប្រាក់ដោយធនាគារ គោលដៅឱ្យទៅអ្នកផ្ញើរបស់ខ្លួនត្រូវមានចំនួនស្មើនឹងខ្ទង់ឥណពន្ធដែលបានចុះនៅលើ គណនីអ្នកទទួល និងត្រូវធ្វើឡើងមិនហួសពីថ្ងៃធ្វើការរបស់ធនាគារ បន្ទាប់ពីបានបញ្ចប់ ការផ្ទេរឥណពន្ធនោះ ។ ការសងប្រាក់ដោយធនាគារទទួលដទៃទៀតត្រូវធ្វើឡើងមិន ហួសពីថ្ងៃធ្វើការរបស់ធនាគារ បន្ទាប់ពីបានទទួលការទូទាត់សងរបស់ខ្លួន ។

នៅពេលបានទទួលប្រាក់រួច និងជាកម្មវត្ថុនៃការចុះបញ្ជោសនៅក្នុងកថាខណ្ឌ ទី ៣ មាត្រា ១៩៨ នៃច្បាប់នេះ ធនាគារផ្ដើមប្រតិបត្តិការត្រូវជំពាក់អ្នកផ្ដើមប្រតិ- បត្តិការនូវចំនួនប្រាក់ដែលខ្លួនបានទទួល ។ ក្នុងករណីនេះ ខ្ទង់ឥណទានបណ្ដោះអា-

105/127

សន្ទទាំងឡាយ ដែលបានផ្តល់ឱ្យទៅអ្នកផ្តើមប្រតិបត្តិការត្រូវចូលជាស្ថាពរ ។ មុនពេលដែលឥណទានចូលជាស្ថាពរ ពុំត្រូវមានការទាមទារឱ្យធនាគារផ្តើមប្រតិបត្តិការផ្តល់មូលនិធិឱ្យទៅអ្នកផ្តើមប្រតិបត្តិការទេ លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ ការផ្តល់មូលនិធិណាមួយ មុនពេលមានការបញ្ចប់ការផ្ទេរឥណពន្ធ ត្រូវមានលក្ខណៈបណ្តោះអាសន្នរហូតដល់ពេលបញ្ចប់តែម្តង ។

មាត្រា ២១២.-

នៅពេលណាដែលការផ្ទេរឥណពន្ធតាមការប្រគល់សិទ្ធិត្រូវបានធ្វើឡើង ដើម្បីសងបំណុលដែលអ្នកទទួលបានជំពាក់អ្នកផ្តើមប្រតិបត្តិការ លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះរវាងភាគីទាំងពីរ បំណុលនឹងត្រូវបានសងរួចនៅពេលណាដែលប្រតិបត្តិការទូទាត់សងប្រាក់ត្រូវបានបញ្ចប់ ។ ការរួចផុតពីបំណុលមានកម្រិតត្រឹមចំនួនប្រាក់ដែលបានទូទាត់សងនៅពេលបញ្ចប់ប្រតិបត្តិការ ។

ការសងបំណុលត្រូវធ្វើឡើងមុនពេលបញ្ចប់ប្រតិបត្តិការទូទាត់សងប្រាក់ ប្រសិនបើ និងនៅពេលណាដែលការធានាលើការទូទាត់សងប្រាក់ត្រូវបានយល់ព្រមដោយអ្នកផ្តើមប្រតិបត្តិការ ឬ ត្រូវបានបញ្ជាក់ដោយធនាគារផ្តើមប្រតិបត្តិការទៅអ្នកផ្តើមប្រតិបត្តិការ ។

អ្នកធានា ឬ ធនាគារផ្តើមប្រតិបត្តិការដែលបានធានាឬបញ្ជាក់អំពីការទូទាត់សងប្រាក់ក្រោមកថាខណ្ឌខាងលើ ត្រូវទទួលរ៉ាប់រងទូទាត់សងប្រាក់ និងក្លាយជាអ្នកជំពាក់ចំពោះអ្នកផ្តើមប្រតិបត្តិការនូវចំនួនប្រាក់ដែលបានធានា ឬ បញ្ជាក់នោះ ។

## ផ្នែកទី ៦

## ការទទួលខុសត្រូវ ការខូចខាត និងសំណង

មាត្រា ២១៣.-

ការទទួលខុសត្រូវរបស់អ្នកផ្ញើ ត្រូវបានកំណត់ដូចខាងក្រោម :

១-បុគ្គលជាអ្នកផ្ញើត្រូវទទួលខុសត្រូវលើបញ្ជាសងប្រាក់ ឬ លើបញ្ជាបញ្ឈប់ដែលយល់ព្រមដោយធនាគារទទួល នៅពេលណាដែលបញ្ជាសងប្រាក់ ឬបញ្ជា

បញ្ឈប់នោះត្រូវបាន :

ក-ចេញដោយបុគ្គលនោះឱ្យទៅធនាគារទទួល

ខ-ចេញដោយអ្នកទទួលសិទ្ធិពីបុគ្គលនោះ ឱ្យទៅធនាគារទទួល

គ-យល់ព្រមដោយធនាគារទទួល អនុលោមតាមនីតិវិធីសុវត្ថិភាពសមស្របដែលមានលក្ខណៈពាណិជ្ជកម្ម ដែលបានព្រមព្រៀងរវាងធនាគារនិងបុគ្គលនោះ ដើម្បីពិនិត្យបញ្ជាក់ពីយថាភាពនៃបញ្ជាទូទាត់ដែលបញ្ជាដោយបុគ្គលនោះទៅកាន់ធនាគារ ឬ

ឃ-បញ្ជាក់យល់ព្រមដោយបុគ្គលនោះ ។

២-កថាខណ្ឌទី ១-គ នៃមាត្រានេះពុំត្រូវបានអនុវត្តទេ ហើយបុគ្គលជាអ្នកផ្ញើបញ្ជាទូទាត់ក៏ពុំត្រូវទទួលខុសត្រូវដែរ នៅពេលណាដែលបុគ្គលនោះបង្ហាញភស្តុតាងថាខ្លួនមិនបានទទួលផលប្រយោជន៍ពីបញ្ជាសងប្រាក់ ឬ ពីបញ្ជាបញ្ឈប់ ហើយការចេញបញ្ជាសងប្រាក់ឬបញ្ជាបញ្ឈប់ដោយគ្មានការអនុញ្ញាតនោះ ពុំត្រូវបានបង្កឡើងដោយ :

-បុគ្គលជាអ្នកផ្ញើ ឬ ជនដទៃទៀតជាអ្នកទទួលសេចក្តីទុកចិត្តគ្រប់ពេលវេលាឱ្យធ្វើការងារសម្រាប់បុគ្គលនេះ ពាក់ព័ន្ធទៅនឹងប្រតិបត្តិការទូទាត់សងប្រាក់ ឬ នីតិវិធីសុវត្ថិភាព ឬ

-ជនណាដែលបានទទួលពីបុគ្គលជាអ្នកផ្ញើ ឬ ពីប្រភពនៅក្រោមការគ្រប់គ្រងរបស់បុគ្គលនេះនូវលទ្ធភាពប្រើប្រាស់មធ្យោបាយបញ្ជូនសារ ឬព័ត៌មានព្រមទាំងមធ្យោបាយប្រើប្រាស់កម្មវិធី សូហ្វវែរ កុំព្យូទ័រ ឬ មធ្យោបាយដូចគ្នានេះ ដែលងាយស្រួលក្នុងការល្មើសនឹងនីតិវិធីសុវត្ថិភាព ។

៣-សម្រាប់គោលបំណងនៃកថាខណ្ឌទី ១-គ នៃមាត្រានេះ នីតិវិធីសុវត្ថិភាពនឹងត្រូវបានចាត់ទុកថាសមស្របតាមលក្ខណៈពាណិជ្ជកម្ម បើនីតិវិធីនេះត្រូវបានជ្រើសរើសដោយអតិថិជនផ្ទុយពីការណែនាំរបស់ធនាគារដែលបានស្នើឡើងនូវនីតិវិធីសមស្រប ហើយត្រូវបានអតិថិជនបដិសេធ ។

169/08

មាត្រា ២១៤...

នៅពេលណាដែលការផ្ទេរឥណទានត្រូវបានបញ្ចប់ អ្នកផ្ញើមិនត្រូវធ្វើឱ្យមានការខូចប្រយោជន៍ដល់ធនាគារទទួលទេ និងត្រូវសងទៅធនាគារនោះវិញចំពោះការខាតបង់ផ្សេងៗ រហូតដល់ចំនួនប្រាក់នៃបញ្ជាទូទាត់ចំណាយសមស្របតាមលក្ខណៈពាណិជ្ជកម្ម សោហ៊ុយព្រមទាំងការប្រាក់ ។

នៅក្នុងការផ្ទេរឥណទាន ទោះបីជាធនាគារទទួលបានអនុវត្ត និងមានការបញ្ចប់ប្រតិបត្តិការទូទាត់សងប្រាក់រួចហើយក្ដី អ្នកផ្ញើពុំមានការទទួលខុសត្រូវឡើយ ចំពោះធនាគារទទួលលើបញ្ជាទូទាត់ដែលត្រូវបានបញ្ជូនទៅកាន់ធនាគារទទួល ដោយអនុលោមតាមនីតិវិធីសុវត្ថិភាពសម្រាប់រាវរកនូវការខុសឆ្គង ហើយផ្អែកលើកម្រិតអនុញ្ញាតដោយច្បាប់រដ្ឋប្បវេណី ធនាគារទទួលត្រូវមានសិទ្ធិទារពីអ្នកទទួលមកវិញនូវចំនួនប្រាក់ដែលអ្នកផ្ញើសងដោយភ័ន្តច្រឡំ ក្នុងករណី :

-អ្នកផ្ញើគ្មានបំណងផ្ញើបញ្ជាទូទាត់ អ្នកផ្ញើមានបំណងបញ្ជាឱ្យសងប្រាក់ទៅអ្នកទទួលផ្សេងក្រៅពីអ្នកដែលមាននៅក្នុងបញ្ជាទូទាត់ ឬ បញ្ជាទូទាត់មានចំនួនប្រាក់ធំជាងចំនួនដែលអ្នកផ្ញើមានបំណងសង និង

-អ្នកផ្ញើបង្ហាញភស្តុតាងថាខ្លួនបានគោរពតាមនីតិវិធីសុវត្ថិភាព ហើយការភ័ន្តច្រឡំអាចនឹងត្រូវបានរាវរកឃើញ បើធនាគារទទួលបានគោរពតាមនីតិវិធីសុវត្ថិភាពផងដែរ ។

នៅក្នុងការផ្ទេរឥណពន្ធ អ្នកផ្ញើនីមួយៗធានាចំពោះធនាគារទទួលថាបញ្ជាទូទាត់របស់ខ្លួនមានការអនុញ្ញាតត្រឹមត្រូវ និងស្របតាមការប្រគល់សិទ្ធិដែលមានប្រសិទ្ធភាព និងសុពលភាពរបស់អ្នកផ្ដើមប្រតិបត្តិការនិងអ្នកទទួល ។

អ្នកផ្ញើបញ្ជាទូទាត់ និង អ្នកទទួលដែលអនុញ្ញាតឱ្យអ្នកផ្ដើមប្រតិបត្តិការធ្វើការផ្ទេរឥណពន្ធរួមទាំងការចេញផ្សាយមូលប្បទានប័ត្រ ត្រូវមានការប្រុងប្រយ័ត្នជានិច្ចដើម្បីទប់ស្កាត់ការក្លែងបន្លំ និងការចេញផ្សាយ ឬ ការកែប្រែបញ្ជាទូទាត់ ដោយគ្មានការអនុញ្ញាតឬដោយគ្មានសិទ្ធិចេញផ្សាយ និងដើម្បីធានាថាបញ្ជាទូទាត់នោះមានលក្ខណៈច្បាស់លាស់និងមានអត្ថន័យប្រាកដប្រជា ។

ខ

០៤/២៥

មាត្រា ២១៥.-

នៅពេលណាដែលការផ្ទេរឥណទានមិនត្រូវបានបញ្ចប់ទេ ដោយមិនគិតដល់កំហុសដែលបណ្ដាលមកពីផ្នែកណាមួយនៃអ្នកចូលរួមក្នុងប្រតិបត្តិការទូទាត់សងប្រាក់ :

១-អ្នកផ្ដើមប្រតិបត្តិការពុំមានការទទួលខុសត្រូវចំពោះមុខធនាគារផ្ដើមប្រតិបត្តិការទេ និងមានសិទ្ធិឱ្យ ចុះឥណទានឡើងវិញលើគណនីរបស់ខ្លួនតាមចំនួនប្រាក់ដែលបានចុះឥណពន្ធ ដើម្បីសងចំនួនប្រាក់ក្នុងបញ្ជាទូទាត់ ។ លើសពីនេះទៀត អ្នកផ្ដើមប្រតិបត្តិការត្រូវមានសិទ្ធិទាមទារពីធនាគារផ្ដើមប្រតិបត្តិការនូវចំណាយដែលសមស្របតាមលក្ខណៈពាណិជ្ជកម្ម សោហ៊ុយព្រមទាំងការប្រាក់លើចំនួនប្រាក់ដែលបានចុះឥណទានឡើងវិញនោះ ។

២-ធនាគារផ្ដើមប្រតិបត្តិការនិងធនាគារអន្តរការីណាមួយ ដែលអនុវត្តបញ្ជាពីអ្នកផ្ញើរបស់ខ្លួន ត្រូវបានរួចផុតដូចគ្នានេះដែរពីការទទួលខុសត្រូវចំពោះមុខធនាគារទទួលរបស់ខ្លួន និងមានសិទ្ធិទទួលសំណងរៀងៗខ្លួនពីធនាគារនោះ លើកលែងតែចំណាយ និងសោហ៊ុយផ្សេងៗ ។

មាត្រា ២១៦.-

ធនាគារទទួល ត្រូវទទួលខុសត្រូវចំពោះចំណាយសមស្របតាមលក្ខណៈពាណិ-ជ្ជកម្ម សោហ៊ុយ ការប្រាក់ ការខូចប្រយោជន៍នានារួមទាំងការខាតបង់ពីអត្រាប្ដូរប្រាក់ផងដែរបើមាន ដែលបណ្ដាលមកពីការយឺតយ៉ាវ ឬ កំហុសរបស់ខ្លួន ក្នុងការអនុវត្តបញ្ជាទូទាត់ ។ អ្នកផ្ដើមប្រតិបត្តិការអាចទាមទារការខាតបង់នេះ ឬ មួយពីធនាគារផ្ដើមប្រតិបត្តិការ ឬ ពីធនាគារទទួល ដែលបានធ្វើឱ្យយឺតយ៉ាវ ឬ ដែលមានកំហុស ។ អ្នកទទួលប្រាក់អាចទាមទារការខាតបង់ ឬ មួយពីធនាគារគោលដៅ ឬ ពីធនាគារទទួលដែលបានធ្វើឱ្យយឺតយ៉ាវ ឬ ដែលមានកំហុស ។ ធនាគារទទួលដែលបានធ្វើឱ្យយឺតយ៉ាវ ឬ ដែលមានកំហុស ត្រូវទទួលខុសត្រូវសងឱ្យធនាគារផ្ដើមប្រតិ-បត្តិការ ឬ ធនាគារគោលដៅ នូវចំនួនប្រាក់ដែលពួកគេសងការខូចខាត ។

លើសពីនេះទៀត ធនាគារទទួលដែល :

-ពុំបានផ្ដល់ដំណឹងភ្លាមដល់អ្នកផ្ញើ អំពីការបដិសេធរបស់ខ្លួនចំពោះបញ្ជាទូទាត់ ឬ

110/126

-មានការធ្វេសប្រហែសធ្ងន់ធ្ងរក្នុងការអនុវត្ត ឬ ពុំបានអនុវត្តនូវបញ្ជាទូទាត់

ត្រូវទទួលខុសត្រូវចំពោះអ្នកផ្តើមប្រតិបត្តិការលើការខូចខាតជាក់ស្តែងដែលអាចដឹងមុន ដែលពុំលើសពីចំនួនប្រាក់នៃបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ ទោះបីអ្នកផ្តើមប្រតិបត្តិការជាអ្នកផ្ញើ ឬ មិនមែនអ្នកផ្ញើរបស់ខ្លួនក្តី ប៉ុន្តែអាស្រ័យដោយអ្នកផ្តើមប្រតិបត្តិការពុំមានការធ្វេសប្រហែសដែរ ។ នៅពេលដែលអាចអនុវត្តបាន អ្នកផ្ញើក៏អាចមានសិទ្ធិទទួលចំនួនប្រាក់នៃបញ្ជាទូទាត់ដែលបានសងមកវិញ អនុលោមតាមមាត្រា ២១៥ នៃច្បាប់នេះ ។

អ្នកផ្តើមប្រតិបត្តិការមានសិទ្ធិទទួលមកវិញ នៅក្រោមកថាខណ្ឌទី ១ នៃមាត្រានេះ នូវចំនួនប្រាក់ទាំងស្រុងពីធនាគារផ្តើមប្រតិបត្តិការ ឬ ពីធនាគារដែលមានការធ្វេសប្រហែសធ្ងន់ធ្ងរ ។ អាស្រ័យដោយកិច្ចព្រមព្រៀងអន្តរធនាគារ ធនាគារដែលទទួលខុសត្រូវនៅក្រោមមាត្រានេះ មានសិទ្ធិទាមទារការចូលរួមចំណែកទទួលខុសត្រូវពីភាគីផ្សេងទៀត យោងតាមកម្រិតនៃការបង្កឱ្យមានការខូចខាតរបស់ភាគីទាំងនោះ ។

នៅក្នុងការផ្ទេរឥណពន្ធ ការទទួលខុសត្រូវនៅក្រោមមាត្រានេះ និងកំរិតកំណត់ណាមួយដែលពាក់ព័ន្ធ មិនគិតដល់ការទទួលខុសត្រូវរបស់ធនាគារគោលដៅលើការខុសឆ្គងក្នុងការមិនព្រមទូទាត់សងប្រាក់នៅក្រោមមាត្រា ២១០(៥) ទេ ។

**មាត្រា ២១៧.-**

នៅពេលណាដែលការផ្ទេរឥណទានត្រូវបានបញ្ចប់ ដោយមានការភ័ន្តច្រឡំរបស់ធនាគារទទួល ដែលជាធនាគារមានកំហុស ដូចជាការសងប្រាក់ទៅអ្នកទទួលពុំបានធ្វើឡើង ដូចដែលបានបញ្ជានៅក្នុងបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ ជាបន្ថែមទៅលើសំណងមកវិញនៅក្រោមមាត្រា ២១៦ នៃច្បាប់នេះ បើអនុវត្តបាន ត្រូវអនុវត្តវិធានដូចតទៅ :

១-នៅពេលណាដែលចំនួនប្រាក់សងឱ្យទៅអ្នកទទួលច្រើនហួស ឬ តិចជាងចំនួនប្រាក់នៃបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ ការផ្ទេរឥណទានត្រូវបាត់

111/115.

ទុកថាបានបញ្ចប់ក្នុងចំនួនប្រាក់ដែលបានសងឱ្យទៅអ្នកទទួល ។ នៅលើបញ្ជាទូទាត់នីមួយៗ អ្នកផ្ញើនីមួយៗត្រូវទទួលខុសត្រូវចំពោះមុខធនាគារទទួលក្នុងចំនួនប្រាក់នៃបញ្ជាទូទាត់របស់ខ្លួន ដែលនាំឱ្យ :

ក-នៅពេលណាដែលចំនួនប្រាក់សងឱ្យទៅអ្នកទទួលច្រើនលើសពីចំនួនប្រាក់នៃបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ ធនាគារមានកំហុសមានសិទ្ធិទទួលបានមកវិញពីអ្នកទទួលនូវចំនួនប្រាក់ដែលសងលើសនោះ តាមការប្តឹងដែលស្ថិតក្រោមច្បាប់នៅកន្លែងជាទីតាំងរបស់ធនាគារគោលដៅ និង

ខ-នៅពេលណាដែលចំនួនប្រាក់សងឱ្យទៅអ្នកទទួលតិចជាងចំនួនប្រាក់នៃបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ ធនាគារមានកំហុសត្រូវសងប្រាក់ដែលខ្វះឱ្យទៅអ្នកទទួល និងមានសិទ្ធិរក្សាទុក ឬ ទទួលការទូទាត់សងប្រាក់ពីអ្នកផ្ញើរបស់ខ្លួននូវចំនួនប្រាក់នៃបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ ។

២-នៅពេលណាដែលការសងប្រាក់ត្រូវបានធ្វើឱ្យទៅអ្នកទទួល ដែលពុំមែនជាអ្នកមានឈ្មោះនៅក្នុងបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ ហើយធនាគារមានកំហុសពុំមែនជាធនាគារគោលដៅនៃបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការទេនោះ អ្នកផ្តើមប្រតិបត្តិការនិងអ្នកផ្ញើឯទៀតមុនធនាគារមានកំហុស និងអ្នកទទួលបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ អាចចាត់ទុកថាការផ្ទេរឥណទានពុំទាន់បានបញ្ចប់ទេ ។ ធនាគារមានកំហុសមានសិទ្ធិប្រមូលមកវិញពីអ្នកទទួលនូវចំនួនប្រាក់ដែលបានទូទាត់សង តាមការប្តឹងដែលស្ថិតក្រោមច្បាប់នៃកន្លែងជាទីតាំងរបស់ធនាគារគោលដៅ ។

៣-ធនាគារមានកំហុសត្រូវទទួលខុសត្រូវ ចំពោះអ្នកចូលរួមលើប្រាក់ដើម ការប្រាក់ព្រមទាំងចំណាយសមស្របតាមលក្ខណៈពាណិជ្ជកម្មដូចជាសោហ៊ុយចំណាយធនាគារ ឬ ចំណាយទាក់ទងព័ត៌មាន ដែលកើតឡើងអំពីការភ័ន្តច្រឡំនោះ ។

៤-សម្រាប់ការអនុវត្តមាត្រានេះ ការភ័ន្តច្រឡំអាចកើតឡើង ឬ បង្កឡើងដោយអចេតនា ដោយការធ្វេសប្រហែស ឬ ដោយការក្លែងបន្លំ ។

114/118

មាត្រា ២១៨.-

នៅពេលដែលការផ្ទេរឥណពន្ធត្រូវបានបញ្ចប់ ដោយពុំស្របតាមការបញ្ជានៅក្នុងបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ ដោយសារតែការភ័ន្តច្រឡំរបស់ធនាគារទទួល ដែលជាធនាគារមានកំហុស ជាបន្ថែមទៅលើសំណងមកវិញ នៅក្រោមកថាខណ្ឌទី ៥ នៃមាត្រា ២១០ និងមាត្រា ២១៦ នៃច្បាប់នេះ បើអនុវត្តបាន ត្រូវអនុវត្តវិធាន ដូចតទៅ :

១-នៅពេលណាដែលការចុះឥណពន្ធលើគណនីអ្នកទទួលនៃបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការមានចំនួនប្រាក់តិចជាងចំនួនក្នុងបញ្ជាទូទាត់នេះ ធនាគារមានកំហុសត្រូវទាមទារចំនួនប្រាក់ដែលខ្វះពីអ្នកទទួល ហើយប្រគល់ឱ្យទៅអ្នកផ្តើមប្រតិបត្តិការ ។

២-នៅពេលណាដែលការចុះឥណពន្ធលើគណនីអ្នកទទួលនៃបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការមានចំនួនប្រាក់ច្រើនជាងចំនួនក្នុងបញ្ជាទូទាត់នេះ ធនាគារគោលដៅត្រូវចុះឥណទានភ្លាមលើគណនីអ្នកទទួលនូវចំនួនប្រាក់ដែលលើសនោះ ។ ធនាគារមានកំហុសត្រូវសងចំនួនប្រាក់ដែលលើស ឱ្យទៅធនាគារគោលដៅ និងទារចំនួនប្រាក់លើសពីអ្នកផ្តើមប្រតិបត្តិការ ឬ អ្នកចូលរួមផងទៀត ទៅតាមចំនួនប្រាក់លើសដែលបានរក្សាទុក ។

៣-នៅពេលណាមានការកត់ត្រាឥណពន្ធ នៅលើគណនីអ្នកទទួលមួយផ្សេង ក្រៅពីអ្នកដែលមានឈ្មោះនៅក្នុងបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ ធនាគារគោលដៅត្រូវចុះឥណទានភ្លាមលើគណនីអ្នកទទួលនេះនូវចំនួនប្រាក់ដែលបានចុះឥណពន្ធ និងត្រូវចុះឥណពន្ធគណនីអ្នកទទួលដែលមានឈ្មោះនៅក្នុងបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការតាមចំនួនប្រាក់នៃបញ្ជាទូទាត់ ។

៤-នៅពេលណាដែលមានការកត់ត្រាឥណពន្ធ គណនីអ្នកទទួលនៅក្នុងធនាគារគោលដៅមួយផ្សេង ក្រៅពីធនាគារនៅក្នុងបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការ ធនាគារគោលដៅនោះត្រូវចុះឥណទានគណនីអ្នកទទួលនោះវិញតាមចំនួនប្រាក់ដដែល និងទារប្រាក់នេះពីធនាគារមានកំហុស ។ ធនាគារមានកំហុសត្រូវទារចំនួនប្រាក់ក្នុងបញ្ជាទូទាត់របស់អ្នកផ្តើមប្រតិបត្តិការពីអ្នកទទួលបញ្ជាទូទាត់របស់អ្នក

ផ្ដើមប្រតិបត្តិការ ។

៥-នៅក្រោមមាត្រានេះ ការទារប្រាក់ត្រូវធ្វើតាមរយៈការផ្ទេរឥណពន្ធ ហើយការសងប្រាក់តាមរយៈការផ្ទេរឥណទាន ។

៦-ធនាគារមានកំហុសត្រូវទទួលខុសត្រូវចំពោះអ្នកចូលរួមណាមួយលើប្រាក់ដើម ការប្រាក់ ព្រមទាំងចំណាយសមស្របតាមលក្ខណៈពាណិជ្ជកម្មដូចជាសោហ៊ុយចំណាយធនាគារ ឬ ចំណាយទាក់ទងព័ត៌មានដែលកើតឡើងពីការភ័ន្តច្រឡំនោះ ។

៧-សម្រាប់ការអនុវត្តមាត្រានេះ ការភ័ន្តច្រឡំអាចកើតឡើង ឬ បង្កឡើងដោយអចេតនា ដោយការធ្វេសប្រហែស ឬ ដោយការក្លែងបន្លំ ។

## ផ្នែកទី ៧
## គណនីធនាគារ

**មាត្រា ២១៩.-**

យោងតាមល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀង និងលើកលែងតែក្នុងកាលៈទេសៈដែលមានចែងនៅក្នុងកថាខណ្ឌទី ២ នៃមាត្រានេះ សមតុល្យឥណទាយីដែលមានគ្រប់គ្រាន់អាចនឹងត្រូវអតិថិជនដកប្រាក់ចេញ ឬ ធនាគារធ្វើការសងប្រាក់តាមបញ្ជាទូទាត់ ។ ធនាគារពុំត្រូវបានបង្ខំឱ្យយល់ព្រម លើការដកប្រាក់ចេញពីគណនីប្រាក់បញ្ញើលើសកម្រិតសមតុល្យឥណទាយីឱ្យអតិថិជនឡើយ ។

កថាខណ្ឌខាងលើនៃមាត្រានេះ នឹងពុំត្រូវអនុវត្តឡើយ នៅពេលណាដែល :

-សមតុល្យឥណទាយីនៅក្នុងគណនី គឺជាកម្មវត្ថុនៃបណ្ដឹងតវ៉ា ការរឹបអូស ឬ នីតិវិធីប្រហាក់ប្រហែលនេះរបស់ឥណទាយក

-គណនីត្រូវបានបិទ ព្យួរទុក រាំងខ្ទប់ ឬ បង្កក និង

-ក្នុងការអនុវត្តបញ្ជាទូទាត់ ឬ បញ្ជាឱ្យដកប្រាក់នោះ ធនាគារត្រូវល្មើសនឹងច្បាប់ណាមួយ ។

អតិថិជននិងធនាគារអាចព្រមព្រៀងថា មូលនិធិដែលបានបញ្ចូនមក និងបានទទួលជាប្រាក់បញ្ញើ នៅធនាគារសម្រាប់អតិថិជន ត្រូវតែបានបែងចែកតាមការបញ្ជារបស់អតិថិជន ទៅកាន់គណនីមួយឬច្រើនរបស់អតិថិជននោះ ។ គណនីនីមួយៗត្រូវ

ﬖ

//6/1.

ជាកម្មវត្ថុនៃការចុះបញ្ជីគណនេយ្យដោយឡែកពីគ្នា ពាក់ព័ន្ធទៅនឹងចលនានៃមូលនិធិ ដែលបានទទួលនិងបានសងដោយធនាគារ សម្រាប់អតិថិជន ។

មាត្រា ២២០.–

ការបើកចំហព័ត៌មាននៅក្រោមមាត្រានេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬ តាមអេឡិកត្រូនិក អាស្រ័យលើការព្រមព្រៀងគ្នា ។

ធនាគារត្រូវបើកចំហព័ត៌មានចំពោះអតិថិជនបច្ចុប្បន្ន និងអនាគត តាមទម្រង់រៀបចំជាស្រេចដែលងាយយល់អំពីបែបបទ និង ល័ក្ខខ័ណ្ឌសម្រាប់អនុវត្តប្រតិបត្តិការទូទាត់សងប្រាក់ រួមទាំងសោហ៊ុយរបស់ធនាគារ និងបើមាន អំពីពេលវេលាចាំបាច់សម្រាប់បញ្ចប់ប្រតិបត្តិការទូទាត់សងប្រាក់នោះ ។

ចំពោះប្រតិបត្តិការទូទាត់សងប្រាក់ណាមួយ ឬ ខ្ទង់ឥណពន្ធ ឬ ឥណទានផ្សេងទៀត ដែលបានកត់ត្រាចូលគណនី ធនាគារត្រូវផ្តល់ដល់អតិថិជននូវព័ត៌មានច្បាស់លាស់ ដែលអាចឱ្យអតិថិជនសម្គាល់បានការដកប្រាក់ ការដាក់ផ្ញើប្រាក់ ឬ ប្រតិបត្តិការទូទាត់សងប្រាក់ រួមទាំងលេខយោង កាលបរិច្ឆេទ សោហ៊ុយ និង អត្រាប្តូរប្រាក់ផងដែរ បើមាន ។

លើកលែងតែចំពោះគណនីដែលមានសៀវភៅប្រាក់បញ្ញើ ធនាគារត្រូវផ្តល់ឱ្យអតិថិជនជាប្រចាំ ក្នុងរយៈពេលមិនលើសពីមួយខែ នូវរបាយការណ៍គណនីដែលបង្ហាញពីការកត់ត្រាចូលខ្ទង់ឥណទាន និងឥណពន្ធ ចាប់ពីកាលបរិច្ឆេទធ្វើរបាយការណ៍ចុងក្រោយ និងដែលផ្តល់សមតុល្យចុងគ្រាផងដែរ ។

ចំពោះគណនីដែលមានសៀវភៅប្រាក់បញ្ញើ ធនាគារត្រូវសម្រួលឱ្យមានការកត់ត្រានូវចលនាថ្មីៗ ទៅក្នុងគណនីជាបន្តបន្ទាប់ក្នុងសៀវភៅប្រាក់បញ្ញើនេះ ។ ការកត់ត្រានេះត្រូវបង្ហាញពីខ្ទង់ឥណទាន ឬ ឥណពន្ធនីមួយៗ ដែលបានធ្វើទៅលើគណនីចាប់តាំងពីពេលកត់ត្រាគ្រាមុន និងបង្ហាញពីសមតុល្យចុងគ្រាផងដែរ ។ អតិថិជនត្រូវយកសៀវភៅប្រាក់បញ្ញើមកឱ្យធនាគារកត់ត្រាដោយទៀងទាត់ ។

អតិថិជនត្រូវមានការប្រុងប្រយ័ត្នជាទូទៅ និងការរួសរាន់ក្នុងការពិនិត្យលើរបាយការណ៍ប្រចាំគ្រាទាំងនោះ ព្រមទាំងលើការកត់ត្រាចលនាថ្មីៗលើសៀវភៅប្រាក់បញ្ញើ ហើយផ្តល់ព័ត៌មានដល់ធនាគារអំពីភាពមិនប្រក្រតីឬមានការតវ៉ាលើការកត់

ក្រោមឥណពន្ធ ឬ ឥណទាន ។ ធនាគារត្រូវជួយដល់អតិថិជនក្នុងការតាមដានអង្កេតលើភាពមិនប្រក្រតី ឬ លើខ្ទង់ឥណពន្ធ ឬ ឥណទានដែលមានការតវ៉ានោះ ដោយផ្តល់ព័ត៌មានពាក់ព័ន្ធទាំងអស់ដែលមាន និងបើអាចធ្វើទៅបាន ធ្វើការកែសម្រួល និងកែតម្រូវចាំបាច់លើគណនីនោះ ។

មាត្រា ២២១.-

ការបើកចំហព័ត៌មានត្រូវបានកំណត់តាមវិធីដូចខាងក្រោមនេះ :

១-ធនាគារត្រូវរក្សាការសម្ងាត់ និងពុំត្រូវបើកចំហព័ត៌មានណាមួយអំពីគណនីឱ្យទៅជនណាមួយ ក្រៅពីអតិថិជនជាម្ចាស់គណនី លើកលែងតែ :

ក-នៅពេលដែលការបើកចំហ ត្រូវបានតម្រូវដោយច្បាប់

ខ-នៅពេលដែលផលប្រយោជន៍របស់ធនាគារ តម្រូវឱ្យមានការបើកចំហ

គ-នៅពេលដែលការបើកចំហ ត្រូវបានធ្វើឡើងដោយមានការយល់ព្រមពីអតិថិជន

ឃ-នៅពេលដែលការបើកចំហ ត្រូវបានធ្វើឡើងតាមការស្នើសុំជាពិសេសពីធនាគារផ្សេងទៀត ក្រោមការផ្តល់មតិលើអតិថិជនក្នុងដំណើរអាជីវកម្មធម្មតា ឬ

ង-នៅពេលដែលអតិថិជន មិនបានគោរពតាមកាតព្វកិច្ចរបស់ខ្លួនចំពោះធនាគារ ។

២-ការបើកចំហក្រោមកថាខណ្ឌទី ១-ខ នៃមាត្រានេះនឹងត្រូវបានធ្វើឡើងតែ :

-នៅពេលណាដែលមានការប្តឹងផ្តល់តាមផ្លូវតុលាការ ដែលក្នុងនេះធនាគារជាភាគីមួយ

-រវាងធនាគារដែលមានទំនាក់ទំនងគ្នាទៅវិញទៅមកតាមរយៈរចនាសម្ព័ន្ធនៃកម្មសិទ្ធិរួម ប៉ុន្តែនៅត្រឹមតែកម្រិតការចាំបាច់សមស្រប ដើម្បីការពារធនាគារ និងសម្ព័ន្ធញាតិរបស់ខ្លួនទល់នឹងការខាតបង់តែប៉ុណ្ណោះ ក្នុងការផ្តល់នូវសេវាធនាគារ ឬ

-ផ្សារភ្ជាប់ជាមួយនេះ និងក្នុងការចាំបាច់ ការស្នើលក់ធនាគារខ្លួនឯង ឬ មួយផ្នែកធំនៃទ្រព្យសម្បត្តិរបស់ខ្លួន ។

៣-មិនមានការបើកចំហណាមួយ ត្រូវបានធ្វើឡើងក្រោមកថាខណ្ឌទី ១-ឃ នៃមាត្រានេះឡើយ បើអតិថិជនបញ្ឈប់ការយល់ព្រមឱ្យបើកចំហនេះ និងលើកលែងតែធនាគារបានពន្យល់ឱ្យអតិថិជនយល់អំពីសិទ្ធិរបស់ខ្លួន ក្នុងការបញ្ឈប់នូវការយល់ព្រមនោះ ។ ការពន្យល់នេះ អាចត្រូវបានផ្តល់ឱ្យអតិថិជនក្នុងពេលបើកគណនីជាមួយធនាគារ ។

៤-ការបើកចំហក្រោមកថាខណ្ឌទី ១-ង នៃមាត្រានេះ ត្រូវកម្រិតចំពោះការផ្តល់ព័ត៌មានដល់ធនាគារ ឬ ភ្នាក់ងារឥណទានណាមួយ ដោយមានការយល់ព្រមពីធនាគារជាតិនៃកម្ពុជា នៅពេលមានកំហុស និងនៅពេលខកខានរបស់អតិថិជនដើម្បីទូទាត់សង ផ្តល់សុវត្ថិភាពគ្រប់គ្រាន់ ឬ ម្យ៉ាងទៀត បំពេញសំណូមពររបស់ធនាគារក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ដោយសំណើជាលាយលក្ខណ៍អក្សរឱ្យទូទាត់សងកាតព្វកិច្ចដែលនៅជាប់ជំពាក់ ។

៥-សំណងការខូចខាតដែលកើតមានដល់អតិថិជន ចំពោះការប្រព្រឹត្តល្មើសនឹងកាតព្វកិច្ចក្រោមមាត្រានេះ មិនត្រូវបានកម្រិតត្រឹមតែការខាតបង់ចំនួនប្រាក់នោះទេ និងអាចរួមបញ្ចូលសំណងលើការខូចប្រយោជន៍ ការរំខាន ឬ ការប៉ះពាល់ដែលត្រូវបានបង្កឡើង ។

**មាត្រា ២២២.-**

ធនាគារមិនត្រូវកែប្រែជាឯកតោភាគី នូវល័ក្ខខ័ណ្ឌនៃការព្រមព្រៀងទេ លើកលែងតែបានជូនដំណឹងដល់អតិថិជនយ៉ាងតិចសាមសិប (៣០) ថ្ងៃ មុនពេលដែលការកែប្រែនោះមានសុពលភាព ។ ការកែប្រែដែលផ្ទុយនឹងបទប្បញ្ញត្តិនេះ ពុំមានសុពលភាពឡើយ ។

**មាត្រា ២២៤.-**

ដើម្បីជាចំណងនីត្យានុកូលទៅលើអតិថិជន កិច្ចព្រមព្រៀងត្រូវតែមានលក្ខណៈត្រឹមត្រូវព្រមទាំងមានចែងពីសិទ្ធិ និងការទទួលខុសត្រូវច្បាស់លាស់ និងជាភាសា

សាមញ្ញ ដោយប្រើប្រាស់ភាសាច្បាប់និងបច្ចេកទេសតែនៅពេលណាដែលចាំបាច់ប៉ុណ្ណោះ ។

ធនាគារត្រូវមានការប្រុងប្រយ័ត្នជាប្រចាំក្នុងការអនុវត្តបញ្ជាទូទាត់ និងរាល់បញ្ជាផ្សេងៗទៀតរបស់អតិថិជន ។

អតិថិជនត្រូវមានការប្រុងប្រយ័ត្ន ដើម្បីការពារការក្លែងបន្លំ និងការចេញផ្សាយ ឬ ការកែប្រែគ្មានអនុញ្ញាតលើបញ្ជាទូទាត់ និងលើបញ្ជាផ្សេងៗទៀតទៅធនាគារ និងដើម្បីធានាថា បញ្ជាទាំងនោះមានខ្លឹមសារច្បាស់លាស់និងប្រាកដប្រជា ។

ធនាគារ និងអតិថិជន ត្រូវប្រតិបត្តិភារកិច្ចដែលនៅក្រោមច្បាប់នេះ រួមទាំងបទប្បញ្ញត្តិនានា និងកិច្ចព្រមព្រៀងរបស់ខ្លួនដោយសុចរិត ។

ជាកម្មវត្ថុនៃកម្រិតកំណត់ ឬ ការកំហិតពិសេសណាមួយដែលកំណត់ដោយច្បាប់នេះ ឬ ច្បាប់ផ្សេងទៀត ធនាគារត្រូវទទួលខុសត្រូវចំពោះអតិថិជន ហើយអតិថិ-ជនត្រូវទទួលខុសត្រូវចំពោះធនាគារ សម្រាប់ការខាតបង់ ឬ ការខូចខាតណាមួយដែលបង្កឡើងពីការប្រព្រឹត្តល្មើសនឹងភារកិច្ចក្រោមច្បាប់នេះ ។

មាត្រា ២២៤.-

ធនាគារអាចដកកម្រៃពីមូលនិធិឬមូលប័ត្រដែលបានដាក់ផ្ញើ ក្នុងការផ្តល់សេវាចំពោះអតិថិជន ដូចជាការរក្សាសុវត្ថិភាព ការបញ្ជូននិងការផ្ទេរមូលនិធិជាប្រាក់បញ្ញើនៅធនាគារជាដើម ។

ធនាគារអាចប្រមូលផ្តុំគណនីនានារបស់អតិថិជនតែមួយ និងដកប្រាក់ដែលមានសមតុល្យឥណទាយី នៅក្នុងគណនីមួយដើម្បី :

-សងតាមបញ្ជាទូទាត់របស់អតិថិជន បើគណនីដែលត្រូវដកប្រាក់សម្រាប់បញ្ជាទូទាត់នោះ ពុំមានសមតុល្យគ្រប់គ្រាន់

-សងបំណុលដែលអតិថិជនជំពាក់ និងត្រូវសងឱ្យទៅធនាគារនេះ

បើក្នុងករណីនីមួយៗខាងលើ ធនាគារពុំបានដឹងថាមូលនិធិនៅក្នុងសមតុល្យឥណទាយីដែលបានដកនោះ ត្រូវបានរក្សាទុកសម្រាប់បុគ្គលផ្សេងទៀតនោះទេ ។

លុះត្រាតែមានការព្រមព្រៀងផ្សេងពីនេះ ធនាគារអាចប្រើប្រាស់មូលនិធិ មូល-ប័ត្រ ឬ សមតុល្យឥណទាយីក្រោមមាត្រានេះ តែនៅពេលណាដែលមូលនិធិ មូលប័ត្រ ឬសមតុល្យឥណទាយីនោះ មានទំនេរសម្រាប់ឱ្យអតិថិជនដកយកភ្លាមៗប៉ុណ្ណោះ ។

## ផ្នែកទី ៨
## ប្រតិបត្តិការនៃប្រព័ន្ធទូទាត់សងប្រាក់

### មាត្រា ២២៥.-

ធនាគារជាតិនៃកម្ពុជា មានសិទ្ធិបើកគណនីឱ្យអតិថិជននៅក្នុងបញ្ជីរបស់ខ្លួន រួមទាំងគណនីទូទាត់ និងទទួលប្រាក់បញ្ញើ ពីធនាគារជារូបិយវត្ថុក្នុងស្រុក និងរូបិយប័ណ្ណ ទៅតាមបែបបទនិងល័ក្ខខ័ណ្ឌ ដូចដែលមានចែងដោយបទបញ្ញា ឬ ដូចដែលបានព្រមព្រៀងគ្នា ។

### មាត្រា ២២៦.-

ធនាគារជាតិនៃកម្ពុជាត្រូវកំណត់ រៀបចំ សម្រេច ផ្សព្វផ្សាយជាសាធារណៈ និងត្រួតពិនិត្យការអនុវត្តគោលនយោបាយប្រព័ន្ធទូទាត់សងប្រាក់ សំដៅបម្រើផលប្រយោជន៍សាធារណជនជាអតិបរមា ។ គោលនយោបាយប្រព័ន្ធទូទាត់សងប្រាក់ត្រូវមានសង្គតិភាពជាមួយនឹងស្តង់ដារអន្តរជាតិ ។ គោលនយោបាយនេះត្រូវលើកកម្ពស់សុវត្ថិភាព និងប្រសិទ្ធភាពប្រព័ន្ធទូទាត់សងប្រាក់ ត្រួតពិនិត្យហានិភ័យ និងលើកកម្ពស់ការប្រកួតប្រជែងនៅក្នុងទីផ្សារសេវាកម្មទូទាត់ដែលមានសង្គតិភាពជាមួយនឹងស្ថេរភាពជាទូទៅនៃប្រព័ន្ធហិរញ្ញវត្ថុ ។

### មាត្រា ២២៧.-

ធនាគារជាតិនៃកម្ពុជាអាច :

-បង្កើតនិងរក្សាព័ត៌មានសម្រាប់ប្រព័ន្ធហិរញ្ញវត្ថុ នៅព្រះរាជាណាចក្រកម្ពុជា

-ដំណើរការ ត្រួតពិនិត្យ តាមដានការអនុវត្ត និងដាក់បញ្ញត្តិកម្មប្រព័ន្ធទូទាត់សងប្រាក់ជាតិ សម្រាប់ប្រតិបត្តិការទូទាត់សងប្រាក់ និងការដកសាច់ប្រាក់រួមទាំងប្រព័ន្ធផាត់ទាត់ និង ទូទាត់សម្រាប់ការសងប្រាក់ជារូបិយវត្ថុក្នុងស្រុក និងជារូបិយប័ណ្ណនៅព្រះរាជាណាចក្រកម្ពុជា

-រក្សាបញ្ជីសម្រាប់មូលប័ត្រដែលបានចេញផ្សាយ បង្កើតមជ្ឈមណ្ឌល

ដាក់ផ្ញើមូលប័ត្រ រក្សាគណនីសម្រាប់មូលប័ត្រដែលបានដាក់ផ្ញើ ព្រមទាំងដំណើរការ ត្រួតពិនិត្យ និងដាក់បញ្ញត្តិកម្មប្រព័ន្ធជាត់ទាត់ និងទូទាត់សម្រាប់មូលប័ត្រ

-លើកកម្ពស់ រៀបចំ និងចូលរួមនៅក្នុងប្រព័ន្ធទូទាត់សងប្រាក់ ជាត់ទាត់ និងទូទាត់ជារូបិយវត្ថុក្នុងស្រុក និងជារូបិយប័ណ្ណ

-ជួយដល់បណ្តាធនាគារក្នុងការរៀបចំ និង ប្រើប្រាស់ឧបករណ៍សម្រាប់ការផ្ញើ ដំណើរការ និងការទទួលបញ្ជាទូទាត់សម្រាប់អតិថិជនរបស់ធនាគារទាំងនោះ ក៏ដូចជាសម្រាប់ការជាត់ទាត់ និងទូទាត់នៃការសងប្រាក់អន្តរធនាគារ រួមទាំងការសងប្រាក់ដោយមូលប្បទានប័ត្រ និងឧបករណ៍ទូទាត់ដទៃទៀតជារូបិយវត្ថុក្នុងស្រុក និងជារូបិយប័ណ្ណ

-ដាក់បញ្ញត្តិកម្ម ត្រួតពិនិត្យ និងតាមដានការអនុវត្ត ក៏ដូចជាកំណត់ល័ក្ខខ័ណ្ឌ និងកាតព្វកិច្ចនានាសម្រាប់ការផ្តល់អាជ្ញាប័ណ្ណ ឬ ការចុះបញ្ជី ប្រតិបត្តិករនៃប្រព័ន្ធទូទាត់សងប្រាក់ និងសេវារូបិយវត្ថុរួមទាំងសម្រាប់ការផ្ទេរប្រាក់ ការដកសាច់ប្រាក់ ការដកប្រាក់ដោយមូលប្បទានប័ត្រ ការរក្សាសុវត្ថិភាពរូបិយវត្ថុ ការប្តូរប្រាក់ និងការចេញផ្សាយប័ណ្ណទូទាត់សងប្រាក់ និង ឧបករណ៍ទូទាត់សងប្រាក់ផងដែរ និង

-បង្កើតនីតិវិធី និងដាក់ចេញបទបញ្ជាពាក់ព័ន្ធនឹងបញ្ហាទាំងនោះ និងការអនុវត្តគោលនយោបាយប្រព័ន្ធទូទាត់សងប្រាក់របស់ខ្លួន នៅក្រោមមាត្រា ២២៦ នៃច្បាប់នេះ ។

បទបញ្ជាដែលបានដាក់ចេញដោយអនុលោមតាមមាត្រានេះ អាចផ្តល់សុពលភាពដល់កិច្ចព្រមព្រៀងជាត់ទាត់អន្តរធនាគារជាទ្វេ និង ពហុភាគី ព្រមទាំងវិធានទូទាត់អន្តរធនាគារ និងអាចកំណត់ជាពិសេសថាកិច្ចព្រមព្រៀង ឬវិធានទាំងនេះ អាចជំនួសឱ្យច្បាប់ផ្សេងទៀតដែលមានខ្លឹមសារមិនស្របគ្នាដែរ ទោះជាទាក់ទង ឬ មិនទាក់ទងដល់បណ្តឹងអំពីអសាធនភាព ។ បទបញ្ជាទាំងនោះក៏អាចផ្តល់កិច្ចការពារទុកជាមុន ឬ ការកាត់បន្ថយហានិភ័យដែលផ្សារភ្ជាប់ជាមួយការខកខាន ពុំបានបញ្ចប់ការទូទាត់រាល់កាតព្វកិច្ច ដែលជាលទ្ធផលនៃការជាត់ទាត់អន្តរធនាគារជាពហុភាគីផងដែរ ។

ដោយពុំមានប៉ះពាល់ដល់ខ្លឹមសារទូទៅនៃមាត្រានេះ សំរាប់ប្រតិបត្តិករនៃប្រព័ន្ធទូទាត់សងប្រាក់សេវារូបិយវត្ថុ និងរាល់ប្រព័ន្ធជាត់ទាត់និងទូទាត់នៅក្រោមមាត្រានេះ

ធនាគារជាតិនៃកម្ពុជាត្រូវមានអំណាចគ្រប់គ្រាន់ក្នុងការគ្រប់គ្រងប្រតិបត្តិការទាំងនោះ ដូចមានចែងនៅក្នុងកថាខណ្ឌទី ១១ មាត្រាទី ៧ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ។

មាត្រា ២២៨.-

ធនាគារត្រូវមានលទ្ធភាពផ្ញើ ទទួល និងដំណើរការបញ្ជាទូទាត់ និង បញ្ជារបស់អតិថិជនដែលពាក់ព័ន្ធ រួមទាំងការដកសាច់ប្រាក់ និងម្យ៉ាងទៀតអាចចូលរួមនៅក្នុងប្រតិបត្តិការទូទាត់សងប្រាក់ផងដែរ ។ ធនាគារអាចធ្វើកិច្ចការនេះ តាមរយៈអ្នកដំណើរការតតិយភាគីមួយ ឬ ច្រើន ដូចដែលបានព្រមព្រៀងរវាងធនាគារ និងអ្នកដំណើរការតតិយភាគី និងជាកម្មវត្ថុនៃកាតព្វកិច្ច ល័ក្ខខ័ណ្ឌ និងការរឹតត្បិត ដែលអាចមានចែងនៅក្នុងបទបញ្ជាចេញដោយធនាគារជាតិនៃកម្ពុជា ។

មាត្រា ២២៩.-

លើកលែងតែមានការអនុញ្ញាតដោយឡែកនៅក្នុងមាត្រាណាមួយ បទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ មិនអាចប្រែប្រួល ឬ បដិសេធដោយកិច្ចព្រមព្រៀងជាទ្វេ ឬ ពហុភាគីឡើយ លើកលែងតែកិច្ចព្រមព្រៀងនោះអាច :

១-បង្កើនសិទ្ធិរបស់អតិថិជន ដរាបណាការបង្កើននោះ មិនប៉ះពាល់ដល់សិទ្ធិរបស់បុគ្គលដទៃ

២-ផ្ដល់ឱ្យមានស្ដង់ដារសមស្រប ដែលបញ្ជាក់នូវការប្រុងប្រយ័ត្នជាធម្មតារបស់ភាគីនីមួយៗ ក៏ដូចជាវិធីសាស្ត្រសមស្រប សម្រាប់ផ្ដល់ការណែនាំ និងបទបញ្ជាណាមួយនៅក្រោមច្បាប់នេះ ព្រមទាំងកិច្ចព្រមព្រៀង

៣-ធ្វើឱ្យប្រែប្រួលសិទ្ធិ និងកាតព្វកិច្ចរវាងនិងក្នុងចំណោមធនាគារដរាបណាការប្រែប្រួលនោះ មិនប៉ះពាល់ដល់សិទ្ធិរបស់បុគ្គលណាមួយ ដែលពុំមែនជាភាគីនៃកិច្ចព្រមព្រៀង រួមទាំងអតិថិជនមិនមែនធនាគារផងដែរ ។

## ជំពូកទី ៦
## ទោសប្បញ្ញត្តិ

**មាត្រា ២៣០.–**

ធនាគារជាតិនៃកម្ពុជា មានសិទ្ធិផ្តន្ទាទោសខាងវិន័យ ដែលតម្រូវ និង អនុវត្ត ចំពោះបុគ្គលទាំងឡាយក្នុងការមិនទូទាត់សងបំណុលរបស់ខ្លួន ពាក់ព័ន្ធជាមួយឧបករណ៍អាចជួញដូរបាននិងបញ្ជាទូទាត់ ។

ការប្រព្រឹត្តល្មើសនឹងបទបញ្ជា ដែលមានចែងក្នុងកថាខណ្ឌខាងលើនៃមាត្រានេះ ត្រូវទទួលទណ្ឌកម្មដូចខាងក្រោម :

-ការព្រមាន

-ការស្តីបន្ទោស

-ការហាមឃាត់ឬការដាក់កំហិត ក្នុងការចេញផ្សាយឧបករណ៍អាចជួញដូរបានណាមួយ ឬ គ្រប់ប្រភេទ ឬ ក្នុងការផ្តល់សិទ្ធិធ្វើការផ្ទេរឥណពន្ធសម្រាប់រយៈពេលមិនលើសពីដប់ពីរ (១២) ខែ

-ការបង់ប្រាក់ពិន័យ ពីប្រាំភាគរយ (៥%) ទៅមួយរយភាគរយ (១០០%) នៃតម្លៃចារឹករបស់ឧបករណ៍ ឬ បញ្ជាទូទាត់ដែលមិនបានទូទាត់សងប្រាក់ ឬ ឧបករណ៍ ឬ សិទ្ធិអំណាចចេញផ្សាយ ដោយរំលោភលើការហាមឃាត់ឬការដាក់កំហិត ។

នៅពេលដែលពុំមានចំនួនប្រាក់គ្រប់គ្រាន់ ដើម្បីទូទាត់មូលប្បទានប័ត្រដែលមានសុពលភាព ធនាគារ បហារិតដែលមិនទូទាត់មូលប្បទានប័ត្រនេះ ត្រូវកត់ត្រាហេតុការណ៍មិនទូទាត់និងរាយការណ៍ក្នុងរយៈពេលពីរ (០២) ថ្ងៃ ស្តីពីការមិនទូទាត់សងប្រាក់ទៅធនាគារជាតិនៃកម្ពុជា ។ បហារិកនៃមូលប្បទានប័ត្រមិនត្រូវបានអនុញ្ញាតឱ្យចេញផ្សាយមូលប្បទានប័ត្រ ឬ មិនត្រូវបានផ្តល់សិទ្ធិធ្វើការផ្ទេរឥណពន្ធក្នុងរយៈពេលដប់ពីរ (១២) ខែ ។ ចំនួនប្រាក់គ្រប់គ្រាន់ក្នុងគណនីរួមមានមូលនិធិជាក់ស្តែងដែលបង្កើតបានជាសមតុល្យវិជ្ជមាននៅក្នុងគណនី ឬ ត្រូវបានផ្តល់ដោយឥណទានវិបារូបនី ដែលបហារិកបានទទួលពីធនាគារបហារិត ។

ធនាគារជាតិនៃកម្ពុជា ត្រូវដំណើរការចុះបញ្ជីកត់ត្រារាល់គណនីធនាគារ ដែល

តាមរយៈនោះមូលប្បទានប័ត្រត្រូវបានចេញផ្សាយ និងការផ្ទេរឥណពន្ធត្រូវបានធ្វើក៏ដូចជាការរាយការណ៍អំពីហេតុការណ៍ទាំងអស់ ហើយចេញនូវការព្រមាន ការស្តីបន្ទោស ការហាមឃាត់ និង ការដាក់កំហិតក្រោមមាត្រានេះ ។ នៅពេលចេញការព្រមាន ការស្តីបន្ទោស ការហាមឃាត់ ឬ ការដាក់កំហិត ធនាគារជាតិនៃកម្ពុជាត្រូវជូនដំណឹងដល់ធនាគារនីមួយៗ ដែលនៅក្នុងនោះ បុគ្គលដែលទទួលទណ្ឌកម្មទាំងនោះមានគណនី និងត្រូវផ្តល់ព័ត៌មានទាំងនេះដល់ធនាគារ បើមានការស្នើសុំ ។

ធនាគារ ដោយដឹងពីការហាមឃាត់ ឬ ការដាក់កំហិត ដែលបានដាក់ចេញក្រោមកថាខណ្ឌទី ៣ នៃមាត្រានេះ ត្រូវតម្រូវឱ្យបុគ្គលដែលទទួលរងការហាមឃាត់ ឬ ការដាក់កំហិត ប្រគល់ត្រឡប់មកវិញជាបន្ទាន់ នូវមូលប្បទានប័ត្រមិនទាន់សរសេរ និងមិនទាន់ប្រើប្រាស់ ព្រមទាំងការអនុញ្ញាតឱ្យធ្វើបេឡានិច័យតាមការផ្ទេរឥណពន្ធដែលធនាគារបានប្រគល់ឱ្យខ្លួន ។ ធនាគារ ដោយដឹងពីការហាមឃាត់ ឬ ការដាក់កំហិត ត្រូវតែទទួលខុសត្រូវចំពោះអ្នកកាន់មូលប្បទានប័ត្រ និងអ្នកផ្តើមប្រតិបត្តិការនៃការផ្ទេរឥណពន្ធ ដែលត្រូវបានចេញផ្សាយ ឬ ត្រូវបានអនុញ្ញាត ដោយបុគ្គលដែលទទួលរងការហាមឃាត់ ឬ ការដាក់កំហិត តាមចំនួនប្រាក់ទាំងអស់នៃមូលប្បទាន-ប័ត្រ ឬ នៃការផ្ទេរឥណពន្ធ កាលបើមូលប្បទានប័ត្រមិនទាន់សរសេរ ឬ ការអនុញ្ញាតឱ្យធ្វើបេឡានិច័យ តាមការផ្ទេរឥណពន្ធត្រូវបានប្រគល់ឱ្យទៅបុគ្គលដែលទទួលរងការហាមឃាត់ ឬ ការដាក់កំហិត ទៅមុនពេលដែលធនាគារបានដឹងអំពីការហាមឃាត់ ឬ ការដាក់កំហិតនោះ បានចូលជាធរមាន ។

ការហាមឃាត់ឬការដាក់កំហិត ក្នុងការចេញផ្សាយមូលប្បទានប័ត្រ ឬ ក្នុងការផ្តល់សិទ្ធិធ្វើការផ្ទេរឥណពន្ធ ត្រូវបានដកចេញវិញ នៅពេលណាដែលធនាគារជាតិនៃកម្ពុជាបានទទួលដំណឹងថា ការទូទាត់ត្រូវបានធ្វើឡើងតាមសំណូមពរអ្នកកាន់ ។ ការទូទាត់នោះត្រូវរួមបញ្ចូលសោហុយចំណាយរបស់ធនាគារ ដែលត្រូវទូទាត់ឱ្យទៅធនាគារបហារិត ការប្រាក់ និង ការខូចខាត តាមកម្រិតអប្បបរមាប្រាំភាគរយ (៥%) នៃចំនួនប្រាក់ដើម ដែលត្រូវទូទាត់ឱ្យអ្នកកាន់ និងប្រាក់ពិន័យចំនួនមួយលាន (១.០០០.០០០)រៀល ដែលត្រូវទូទាត់ឱ្យធនាគារជាតិនៃកម្ពុជា ។ ធនាគារជាតិនៃកម្ពុជា ត្រូវចេញបទបញ្ញាស្តីពីការធ្វើឱ្យពេញលេញនូវភារកិច្ចនេះ ។

123/127

មាត្រា ២៣១.-

បុគ្គលណាដែលប្រព្រឹត្តល្មើស :

-បទប្បញ្ញត្តិណាមួយនៃច្បាប់នេះ

-បទបញ្ជា សេចក្តីណែនាំ ឬ វិធានណាមួយដែលចេញដោយ ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនិងបញ្ហាណាមួយដែលមានចែងនៅក្នុងបទបញ្ជា សេចក្តីណែនាំ ឬ វិធានទាំងនោះ

-ដោយមិនព្រមផ្តល់ព័ត៌មានតាមការស្នើសុំដោយស្របច្បាប់ ដែលអនុញ្ញាតដោយច្បាប់នេះ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំ (០៥) លានរៀល ដល់ដប់ (១០) លានរៀល ឬ ត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីពីរ (២) ឆ្នាំ ទៅប្រាំ (៥) ឆ្នាំ ឬ ទទួលទោសទាំងពីរ ។

បុគ្គលណាដែល :

-ប្រព្រឹត្តល្មើសនឹងការហាមឃាត់ ឬ ការដាក់កំហិត ដែលបានដាក់ចេញនៅក្រោមមាត្រា ២៣០ នៃច្បាប់នេះ

-ផ្តល់សិទ្ធិអំណាចឱ្យធ្វើការផ្ទេរប្រាក់ចេញពីគណនីរបស់ខ្លួន ដោយមានបំណងឱ្យបញ្ជាទូទាត់នោះ មិនត្រូវបានទូទាត់សង ឬ

-កែបន្លំ ក្លែងក្លាយឧបករណ៍អាចជួញដូរបាន ការអនុញ្ញាតធ្វើបេឡានិច័យដោយការផ្ទេរឥណពន្ធឬបញ្ជាទូទាត់ និងកាន់ឬប្រើប្រាស់ដោយដឹងថាឧបករណ៍អាចជួញដូរបាន ការអនុញ្ញាតឬបញ្ជាទូទាត់ទាំងនោះ ជាឧបករណ៍កែបន្លំឬក្លែងក្លាយ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីប្រាំ (០៥)លាន ដល់ហាសិប (៥០)លានរៀល និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីពីរ (២)ឆ្នាំ ទៅប្រាំ (៥)ឆ្នាំ ។

បុគ្គលណាដែល :

-មានចេតនាធ្វើឱ្យខូចប្រយោជន៍អ្នកដទៃ ដោយការដកហូត ឬ ការដកប្រាក់ពីគណនីសម្រាប់ទូទាត់មូលប្បទានប័ត្រ

-ដាប់បំណុលលើឧបករណ៍អាចជួញដូរបាន ដោយមានចេតនាមិនទូទាត់សងឧបករណ៍នោះនៅពេលដល់ឥណប្រតិទាន

-មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន នៅពេលដល់ឥណប្រតិទាន ដោយមានបំណង និងដោយមានចេតនាធ្វើឱ្យខូចប្រយោជន៍អ្នកដទៃ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីពីរ (០២)លាន ដល់ប្រាំមួយ (០៦)លានរៀល និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីមួយ (១) ឆ្នាំ ទៅបី (៣)ឆ្នាំ ដោយមិនទាន់គិតដល់កាតព្វកិច្ចទូទាត់សងចំនួនប្រាក់ នៃឧបករណ៍អាចជួញដូរបាននោះទៅអ្នកកាន់ ។

គ្មានការប្តឹងណាមួយអាចត្រូវធ្វើប្រឆាំងនឹងធនាគារជាតិនៃកម្ពុជា មន្ត្រី បុគ្គលិក ឬ ថ្នាក់ដឹកនាំណាមួយរបស់ធនាគារជាតិនៃកម្ពុជា ឬ បុគ្គលណាមួយដែលធ្វើសកម្មភាពក្រោមការដឹកនាំរបស់ធនាគារជាតិនៃកម្ពុជាឡើយ ចំពោះការងារណាមួយដែលបានធ្វើ ឬ ខកខានមិនបានធ្វើដោយសុចរិត នៅក្នុងការប្រតិបត្តិអំណាច ឬ កាតព្វកិច្ចណាមួយដែលបំរុងដាក់ឱ្យ ឬ ត្រូវបានដាក់ឱ្យអនុវត្តនៅក្រោមច្បាប់នេះ ។

មាត្រា ២៣២.-

ក្នុងជំពូកនេះ ឧបករណ៍អាចជួញដូរបានដូចជា មូលប្បទានប័ត្រ រូបិយាណត្តិ និងប័ណ្ណសងតាមបញ្ជា មានរួមទាំងឧបករណ៍ទាំងឡាយណា ដែលត្រូវបានប្រើប្រាស់ ឬ ត្រូវបានចាត់ទុកថាមានមុខងារដូចគ្នា ។

សម្រាប់ការរំលោភដោយនីតិបុគ្គល ការផ្តន្ទាទោសណាមួយក្នុងជំពូកនេះ អាចត្រូវអនុវត្តចំពោះនាយកណាម្នាក់ និងមន្ត្រីតាមឋានានុក្រមនៃនីតិបុគ្គលនោះ ។

កាលបើការរំលោភត្រូវបានធ្វើឡើងដោយភ្នាក់ងារណាម្នាក់ ការផ្តន្ទាទោសក្រោមជំពូកនេះអាចតម្រូវទៅលើ ឬ អនុវត្តចំពោះប្រធាន ភ្នាក់ងារ ឬ ទាំងពីរព្រមគ្នា ។

ទោសក្រោមជំពូកនេះ អាចធ្វើឡើងត្រួតថែមលើគ្នា និងមិនទាន់គិតដល់ទោសក្រោមច្បាប់ផ្សេងទៀតឡើយ ។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

មាត្រា ២៣៣.-

ធនាគារជាតិនៃកម្ពុជា ត្រូវដាក់ចេញនូវបទប្បញ្ញត្តិ វិធាន បទបញ្ជា និងសេចក្តីណែនាំ ក៏ដូចជានីតិវិធីប្រតិបត្តិការសម្រាប់ការអនុវត្តច្បាប់នេះ ជាពិសេសចំពោះ :

..៧៤៥

-រចនាសម្ព័ន្ធជាឯកសណ្ឋានសម្រាប់ការសម្គាល់និងការធ្វើចំណាត់ថ្នាក់គណនី

-គំរូនៃបញ្ជាទូទាត់

-ស្តង់ដារសម្រាប់បញ្ជូនបញ្ជាទូទាត់

-ទម្រង់នៃមូលប្បទានប័ត្រ រូបិយាណត្តិ និងប័ណ្ណសងតាមបញ្ជាក៏ដូចជាទម្រង់នៃឯកសារផ្សេងទៀត ដែលត្រូវចេញផ្សាយក្រោមច្បាប់នេះ ឬ មួយដោយភាគី ឬ មន្ត្រីមានសមត្ថកិច្ច ដូចជាសេចក្តីជូនដំណឹង ឬវិវាទ និងនីតិវិធីដែលពាក់ព័ន្ធ

-ភារកិច្ច នីតិវិធី និងការអនុវត្តរបស់ធនាគារក្នុងការទទួលបញ្ជាទូទាត់ និងបញ្ជាផ្សេងទៀតរបស់អតិថិជន និងដំណើរការប្រតិបត្តិការទូទាត់សងប្រាក់

-កិច្ចព្រមព្រៀងគណនីរបស់ធនាគារ និងព័ត៌មានដែលធនាគារត្រូវផ្តល់ឱ្យអតិថិជន

-ព័ត៌មានស្ថិតិដែលចាំបាច់សម្រាប់ការអនុវត្តនយោបាយរូបិយវត្ថុឱ្យបានសមស្រប និងមានប្រសិទ្ធភាពដែលធនាគារត្រូវផ្តល់ឱ្យធនាគារជាតិនៃកម្ពុជា និង

-ប្រការផ្សេងទៀតដែលមានចែងនៅក្នុងបទប្បញ្ញត្តិដោយឡែកនៃច្បាប់នេះ ។

បទបញ្ជានេះអាចត្រូវបានធ្វើសម្រាប់ការពារអតិថិជន ភាពសុចរិត និង ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ និងការប្រើប្រាស់ឧបករណ៍អាចជួញដូរបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដើម្បីគោលបំណងនេះ បទបញ្ជាអាចរឹតត្បិត ដាក់កំហិត ឬ ហាមឃាត់ការប្រើប្រាស់មូលប្បទានប័ត្រ ឬ បញ្ជាទូទាត់ផ្សេងទៀត ចំពោះប្រភេទគណនី និងបុគ្គលដែលត្រូវបានកំណត់ ឬ ដាក់ល័ក្ខខ័ណ្ឌសម្រាប់ការប្រើប្រាស់នេះ ។ បទបញ្ជាដែលចេញក្រោមច្បាប់នេះ ក៏អាចដាក់កំហិតការទទួលខុសត្រូវរបស់ឯកត្តជន ឬ ដាក់កំហិតនិងដាក់ល័ក្ខខ័ណ្ឌដំបូងសម្រាប់ការទទួលខុសត្រូវនោះ នៅក្នុងទំនាក់ទំនងជាមួយឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ពី ឬ ទៅគណ-

ꩻ

14/128

នីដែលប្រើប្រាស់ជាបឋម ដើម្បីមូលហេតុបុគ្គល ឬ គ្រួសារ និងមិនមែនសម្រាប់គោលដៅអាជីវកម្ម ។

បទបញ្ជាដែលចេញដោយធនាគារជាតិនៃកម្ពុជាក្រោមច្បាប់នេះ អាចកំណត់ស្តង់ដារដែលប្រើសម្រាប់វាស់វែងការអនុវត្តកាតព្វកិច្ចនៅក្រោមច្បាប់នេះ និងកែប្រែក្នុងអំឡុងពេល ឬ កាលកំណត់ចុងក្រោយណាមួយសម្រាប់ការធ្វើ ឬ មិនធ្វើសកម្មភាពដែលកំណត់ឡើងដោយច្បាប់នេះ ចំពោះប្រភេទទាំងអស់ ឬ ប្រភេទដោយឡែកនៃភាគីអ្នកចូលរួមឧបករណ៍អាចជូញដូរបាន ឬ ប្រតិបត្តិការទូទាត់សងប្រាក់ ។

បទបញ្ជាដែលចេញដោយធនាគារជាតិនៃកម្ពុជាក្រោមច្បាប់នេះ ជាចំណងនីត្យានុកូលលើគ្រប់ភាគីទាំងអស់ដែលដំណើរការបញ្ជាទូទាត់ និងបដិសេធចោលកិច្ចព្រមព្រៀង ដែលគ្មានសង្គតិភាពរួមទាំងវិធានជាត់ទាត់អន្តរធនាគារនៅតាមកម្រិតមិនមានសង្គតិភាពនោះ ។

បទប្បញ្ញត្តិ វិធាន បទបញ្ជា និងសេចក្តីណែនាំ ដែលចេញដោយធនាគារជាតិនៃកម្ពុជាក្រោមច្បាប់នេះ អាចគ្រប់គ្រងលើនីតិវិធី និងផ្តល់សំរាប់កំរិតកំណត់ពេលវេលា សិទ្ធិ និងដំណោះស្រាយ ក្នុងករណីដែលមានហេតុការណ៍បន្ទាន់ផ្សេងៗដូចជាកុំព្យូទ័រខូច ឬ ប្រព័ន្ធមិនដំណើរការ ដែលនាំឱ្យរាំងស្ទះដល់ប្រតិបត្តិការទូទាត់សងប្រាក់ ឬ ការអនុវត្តន៍បញ្ជាទូទាត់ ។ បទប្បញ្ញត្តិ វិធាន បទបញ្ជា និងសេចក្តីណែនាំទាំងនោះអាចព្យួរទុកនូវរាល់កាតព្វកិច្ច និងកំរិតកំណត់ពេលវេលាសំរាប់រយៈពេលនៃហេតុការណ៍បន្ទាន់នោះ ។

បទបញ្ជា និងសេចក្តីប្រកាសទាំងអស់ សម្រាប់ការអនុវត្តទូទៅ ដែលចេញដោយធនាគារជាតិនៃកម្ពុជា ត្រូវផ្សព្វផ្សាយនៅក្នុងរាជកិច្ច ។ បទបញ្ជា និងសេចក្តីប្រកាសនោះនឹងចូលជាធរមាននៅថ្ងៃផ្សព្វផ្សាយ ឬ នៅថ្ងៃក្រោយមកទៀត តាមការកំណត់ជាក់លាក់ ។

មាត្រា ២៣៤.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។ ក្នុងករណីមានទំនាស់រវាងច្បាប់នេះ និងច្បាប់ដទៃទៀត ក្រៅពីករណីដែលមានចែងជាពិសេសនៅក្នុងច្បាប់នេះ បទប្បញ្ញត្តិនៃច្បាប់នេះត្រូវមានអានុភាព ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០០៥

នស/រកម.១០០៥.០២៧ ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

ហត្ថលេខា

ជា ចាន់តូ

លេខ ៤២៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ តាន់

៥/១២.-